សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ កក្កដា ឆ្នាំ ២០១៨

# លីអាហូណា




មរតកនៃភាពស្មោះត្រង់សម្រាប់ជំនាន់ក្រោយៗទៀត ទំព័រ ៤៤

គោលដៅរបស់យើង ៖ ចែកចាយដំណឹងល្អជាមួយមនុស្ស ១០០ នាក់ ទំព័រ ១៨

មានឥទ្ធិពលខ្លាំងជាងការកក្រើកដី ភ្លើង ឬខ្យល់ ទំព័រ ២០

អ្នកត្រួសត្រាយ ៖ តើអ្វីទៅដែលជំរុញពួកគេឲ្យឆ្ពោះទៅមុខ ? ទំព័រ ២៤




*ដកស្រង់មកពី « សេចក្ដីជំនឿដើម្បីបន្តឆ្ពោះទៅមុខ » ទំព័រ ២៤ ។*

# លីអាហូណា ខែ កក្កដា ឆ្នាំ ២០១៨



៦


## អត្ថបទពិសេសៗ

**១២** ***ពួកបរិសុទ្ធ*** **៖ រឿងអំពីសាសនាចក្រ — ជំពូក ៥ ៖ បាត់អស់ហើយ**
*បន្ទាប់ពីចាប់ផ្ដើមបកប្រែផ្ទាំងចំណារជាមួយនឹងជំនួយរបស់ ម៉ាទិន ហារីស នោះ យ៉ូសែប ជួបនឹងផលវិបាក នៅពេលលោកបានអនុញ្ញាតឲ្យសំណៅសរសេរដៃនោះបាត់ចេញពីដៃលោក ។*

**១៨ របៀបដែលយើងបានជោគជ័យក្នុងការចែកចាយដំណឹងល្អ**
ដោយ ណេវីរ ឈីខុនហ្គូវ៉
*នៅពេលយើងស្មោះត្រង់ក្នុងការដាក់គោលដៅនាំមនុស្សដទៃឲ្យមកកាន់ព្រះគ្រីស្ទ នោះយើងនឹងត្រូវបានប្រទានពរជាមួយនឹងអព្ភូតហេតុ ។*

**២០ ចូរយើងកុំបរាជ័យក្នុងការទទួលអារម្មណ៍**
ដោយអែលឌើរ ហ៊ីរហេ អេហ្វ ស្បែបាលូស
*នៅក្នុងពិភពលោកដែលមានសំឡេងជាប់ជានិច្ចនេះ យើងត្រូវតែស្ដាប់រកសំឡេងតូចរហៀងៗ ដើម្បីដឹងអំពីព្រះទ័យរបស់ព្រះវរបិតា ។*

**២៤ សេចក្ដីជំនឿដើម្បីបន្តឆ្ពោះទៅមុខ**
ដោយអែលឌើរ រ៉ូណាល អេ រ៉ាសបាន
*ជីដូនជីតាដែលជាអ្នកត្រួសត្រាយរបស់យើងបានស៊ូទ្រាំនឹងការលំបាកយ៉ាងខ្លាំង នៅពេលពួកគេបានព្យាយាមប្រមូលផ្ដុំគ្នានៅក្នុងទីក្រុងស៊ីយ៉ូន ។*

**៣០ ការរក្សាសេចក្ដីជំនឿទោះនៅដាច់ឆ្ងាយពីគេក្ដី**
ដោយ រ៉ាយអិន ដុប៉័លយូ សលហ្គីវើរ
*ទោះបីជាគ្មានអគារសាសនាចក្រ ឬសូម្បីតែវួដមួយក្ដី ក៏ពួកបរិសុទ្ធទាំងនេះបានខិតខំយ៉ាងខ្លាំងដើម្បីស្ថាបនាសាសនាចក្រនៅក្នុងប្រទេសកំណើតរបស់ពួកគេដែរ ។*

**៣៦ ព្រះគម្ពីរមរមនផ្លាស់ប្ដូរជីវិតមនុស្សជាច្រើន**
*អ្នកប្រែចិត្តជឿចែកចាយរបៀបដែលព្រះគម្ពីរមរមនបានជួយពួកគេឲ្យទទួលយកដំណឹងល្អ ។*

## ផ្នែកនានា

**៤ ការបង្ហាញអំពីសេចក្ដីជំនឿ: រិចទ័រ បាប៊ីនយ៉ាហ្គ្រា**

**៦ គោលការណ៍នៃការងារបម្រើ: ឈោងទៅជួយដោយសេចក្ដីអាណិតអាសូរ**

**១០ នៅលើវេទិកា: ការស្គាល់ថាអ្នកជា នរណា — ហើយថាយើងជាមនុស្សប្រភេទណាតាំងពីដើមមក**
ដោយ ស៊ីស្ទើរ ស្បើរី ឌូ

**៤០ សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

**៨០ លុះត្រាជួបទៀត: ព្រះគម្ពីរមរមននាំមកនូវភាពរីកចម្រើនយ៉ាងមហិមា**
ដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន




**នៅលើក្របមុខ**
រចនារូបភាពដោយ ដេវីឌ ហ្គ្រីន

## យុវមជ្ឈិមវ័យ





**៤៤ ការធ្វើដំណើររបស់អ្នកត្រួសត្រាយសម័យទំនើបបីនាក់**
ដោយ សារ៉ា យីណាន
*ដូចជាពួកអ្នកត្រួសត្រាយជំនាន់ដើមដែរ ការចូលធ្វើជាសមាជិកសាសនាចក្រសព្វថ្ងៃនេះ តម្រូវឲ្យមានភាពក្លាហាន និងការលះបង់ ។*

**៤៨ មានអារម្មណ៍ថាដាច់ទំនាក់ទំនងឬ ? សូមសាកល្បងបង្អង់បន្តិចសិន**
ដោយ ឆាឡុត ឡាកាបាល
*ខ្ញុំបានដឹងថា ល្បឿនដ៏លឿនរបស់ខ្ញុំបានបង្វែរផ្លូវនៃការរស់នៅរបស់ខ្ញុំឲ្យនៅឆ្ងាយពីព្រះ ។*


## យុវវ័យ


**៥០ ការដោះស្រាយជាមួយសំណួរពិបាកៗ ៖ គោលការណ៍ ៣ យ៉ាងដែលអាចជួយបាន**
*ការសួរសំណួរគឺជារបៀបដ៏អស្ចារ្យមួយដើម្បីបង្ហាញពីភាពរឹងមាំនៃទីបន្ទាល់របស់អ្នក និងការបែរទៅរកព្រះអម្ចាស់ទូលសូមចម្លើយនឹងធ្វើឲ្យព្រះវិញ្ញាណជួយអ្នក ។*

**៥៤ នៅពេលដែលការបម្រើមានការលំបាក**
ដោយ លីតា ជី វ៉ាំឌែល
*ការបម្រើជីតារបស់ខ្ញុំពុំមែនជារឿងរីករាយឡើយ — លុះត្រាណាខ្ញុំបានផ្លាស់ប្ដូរឥរិយាបថរបស់ខ្ញុំ ។*

**៥៦ យោបល់គន្លឹះ: ៧ ចំណុចសម្រាប់ការឡើងនិយាយ**
ដោយ សារ៉ា ហានសុន
*ការនិយាយនៅក្នុងព្រះវិហារអាចជាការមួយគួរឲ្យខ្លាច ! ប៉ុន្តែអ្នកអាចប្រើប្រាស់យោបល់គន្លឹះទាំងនេះដើម្បីរៀបចំ និងចែកចាយការនិយាយមួយដ៏គួរឲ្យចាប់អារម្មណ៍ ។*

**៥៨ ការរៀបចំខ្លួនសម្រាប់ជីវិត: តើយើងធ្វើអ្វីខ្លះនៅក្នុងព្រះវិហារបរិសុទ្ធ ?**

**៦០ អារម្មណ៍កើតទុក្ខនៅថ្ងៃឈប់សម្រាក**
ដោយ អាលីសា នៀលសិន
*ខ្ញុំបានរៀនអំពីរបៀបដែលខ្ញុំអាចចាប់ផ្ដើមទន្ទឹងរង់ចាំថ្ងៃឈប់សម្រាកជំនួសឲ្យការធុញទ្រាន់ថ្ងៃឈប់សម្រាក ។*

**៦២ ប័ណ្ណប្រកាស: ដ្យាក្រាម**

**៦៣ ពាក្យចុងក្រោយ: អ្នកអាចមានភាពសក្ដិសមសម្រាប់ព្រះវិហារបរិសុទ្ធ**
ដោយអែលឌើរ ឃ្វីនធិន អិល យុក


## កុមារ





**៦៤ ដំណើររបស់អ៊ីសាប៊ែល**
ដោយ ជេស៊ីកា ឡាសិន
*ការធ្វើដំណើរនេះអាចនឹងយូរ ប៉ុន្តែគ្រួសាររបស់អ៊ីសាប៊ែលបានដឹងថា ព្រះវិហារបរិសុទ្ធសក្ដិសមនឹងដំណើរនោះហើយ ។*

**៦៦ លោកតាលោកយាយដ៏ល្អ**
ដោយ ជេណា កូហ្វ៊ង
*អែនជ្រូមានការព្រួយបារម្ភអំពីថ្នាក់រៀនរបស់គាត់នៅទិវានាំឪពុកម្ដាយមកកាន់សាលារៀន ។*

**៦៨ ទីបំផុតក្លាយជាក្រុមគ្រួសារដ៏និរន្តរ៍**
ដោយ ជេន ម៉ាកប្រាយដ៍
*ម៉ៃចូលចិត្តអារម្មណ៍កក់ក្ដៅដែលគាត់មាននៅក្នុងផ្ទះរបស់សូយដែលជាមិត្តភក្ដិរបស់គាត់ ។*

**៧០ បញ្ចាំងពន្លឺរបស់អ្នកចេញទៅ: ជាមិត្តភក្ដិ និងជាអ្នកផ្សព្វផ្សាយសាសនា**

**៧២ ពួកសាវកថ្លែងទីបន្ទាល់អំពីព្រះគ្រីស្ទ**
ដោយអែលឌើរ ហ្គែរី អ៊ី ស្ទីវិនសុន

**៧៣ ក្លឹបអានព្រះគម្ពីរមរមន: ហេលេមិន ៥:១២**

**៧៤ ទំព័ររបស់យើង**

**៧៥ ប័ណ្ណវីរៈបុរសមកពីព្រះគម្ពីរសញ្ញាចាស់**

**៧៦ ដំណើររឿងព្រះគម្ពីរ ៖ ហាណា និង សាំយូអែល**
ដោយ គីម វិប រៀដ

**៧៩ ទំព័រផាត់ពណ៌: ខ្ញុំអាចចែកចាយជាមួយមនុស្សដទៃ**




***ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ តើលោកតារបស់អ្នកមានមុខរបរអ្វី ?***



**ខែ កក្កដា ឆ្នាំ ២០១៨ វ៉ុល 17 លេខ 4**
**លីអាហូណា 14798 258**
ទស្សនាវដ្ដីជាអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃ ចុងក្រោយ

**គណៈប្រធានទីមួយ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, ហិនរី ប៊ី. អាវរិង

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** អិម. រ័សុល បាឡឺដ, ជែហ្វ្រី អ័រ ហូឡិន, ឌៀថើរ អេស្វ. អុជដូហ្វ, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល យុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវើនសុន, ឌេល ជី រេនឡាន់, ហ្គើរិត ដបុលយូ ហ្គង និង អ៊ូលីសេស សូរ៉េស

**និពន្ធនាយក ៖** ហ៊ូហ្គ អ៊ី ម៉ាទីណេ
**ជំនួយការនិពន្ធនាយក ៖** រែនដល យេ បិនណ្ណិត, ខារ៉ូ អេហ្វ ម៉ាកខន់ឃី
**អ្នកប្រឹក្សា ៖** ប្រែន ខេ អាស្ដុន, ប៊ូនី អេច ខ័រឌុន, ឡឺហ្គ្រង់ ឬ ខឺធីស ជុញ៉រ, អេដវ៉ួដ ដាប់, ស្ហារ៉ុន អិល អើបែង, ដូណាល អិល ហាលស្ត្រម, ដូហ្គ្លាស ឌី ហូលមែស, អ៊ីរិក ដុបយូរ កូពីស្គេ

**នាយកគ្រប់គ្រង ៖** រីឆាដ អាយ ហ៊ីតុន
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ ឡយប៊ិហ្គ
**អ្នកចាត់ការពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណាន់

**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រដាម ស៊ី អូស្ហុន
**ជំនួយការ ការគ្រប់គ្រងផ្នែកកែសម្រួល ៖** រ៉ាយអិន ខារ
**ជំនួយការបោះពុម្ព ៖** ហ្វ្រាន់ស៊ីស្កា អុលសុន
**និពន្ធ និងកែសម្រួលដោយ ៖** ម៉ារីសា ឌែននី, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវើត, ម៉ាធ្យូ ឌី ហ្វ្លីតុន, ឡារី ហ្វលើរ, ហ្គារែត អេច ហ្គាហ្វ, ឡារ៉ែន ផតទើរ ហ្គាន, ចុន រ៉ាយអែន ជែនសិន, ឆាលឡុត ឡាកាបាល់, មែយល អរ ម៉ូរីស, អ៊ីរិក ប៊ី ម៉ដុក សាលី ចនសុន អូដេយ៉ឹក, យ៉ូស្វេ ដេ ភីគី, ចាន ភីនបូរ៉ាហ្វ, រីឆាត អិម រ៉មនី, មីនឌី សេលូ, ឆាខែល វ៉ួដឡេ ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កុត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ថែដ អ័រ ភីធើរសុន
**រចនាប្លង់ដោយ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, ស៊ី ឃីមបឹល បុត, ថូម៉ាស ឆាល, ដេវីឌ ហ្វ្រីន, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្វ្រីន, ស្កុត អិម ម៉ូយ, អេមីលី ឈីកូ រេម៉ុងតុន, ម៉ាក ដបុលយូ រ៉ូប៊ីសុន, ប្រាត ធៀរ, យេ នីកូល វែកឃិនហូស

**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលែត នែបេឃើ អាននី
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** អ៊ីរ៉ា ហ្គែន អាឌៀ, ខេទី ដានខាន, ថូម៉ាស ជី ក្រូនីន, ប្រែអិន ដបុលយូ ជីជី, ដីន្នី ដេ និលសុន, រីក វីឆាតសុន
**មុនការបោះពុម្ព ៖** យ៉ូស្វេ ដែននីស, អាំមុន ហារីស

**នាយកផ្នែកបោះពុម្ព ៖** ស្ទេវិន ធី លេវីស
**នាយកចែកចាយ ៖** ត្រយ អ័រ ប៉ាកឃើរ

សូមផ្ញើអត្ថបទ និង សំណួរនានា តាមអ៊ិនធើរណែតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមៀ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ុអាណូ, ចិន, ចិន ( សម្រាយ ), ក្រូអាត, ឆែក, ដាណឺម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អ៊ីស្លង់, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាត់វៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី, នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ នឹង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។

© 2018 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

ព័ត៌មានអំពីកម្មសិទ្ធិបញ្ញា ៖ លុះត្រាមានការបញ្ជាក់ បុគ្គលម្នាក់ៗអាចថតចម្លងឯកសារចេញពីលីអាហូណានេះសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬ ពុំមែនដើម្បីធ្វើអាជីវកម្ម ( រួមទាំងការហៅបម្រើក្នុងសាសនាចក្រ ) ។ សិទ្ធិនេះអាចត្រូវបានលុបចោលវិញគ្រប់ពេល ។ រូបភាពពុំអាចថតចម្លងបានឡើយ ប្រសិនបើឃើញមានការដាក់បម្រាមបង្ហាញនៅក្នុងជួរបន្ទាត់នៃការដកស្រង់នៃរូបភាពនោះ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិគួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., FL 13, Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
July 2018 Vol. 17 No. 4. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $10.00 per year; Canada, $12.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store .lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# មានច្រើនទៀតនៅលើអ៊ិនធើរណែត



សូមអាន និងផ្ញើអត្ថបទផ្ទាល់របស់អ្នកតាមគេហទំព័រ **liahona.lds.org**

សូមស្វែងរកសារលិខិតបំផុសគំនិត និង អាចចែកចាយបាន ( ជាភាសាអង់គ្លេស ព័រទុយហ្គាយ និង អេស្ប៉ាញ ) នៅ គេហទំព័រ **facebook.com/liahona**





សូមផ្ញើមតិកែលម្អទៅកាន់ **liahona@ldschurch.org**

សូមជាវតាមគេហទំព័រ **store.lds.org** ឬទៅមជ្ឈមណ្ឌលចែកចាយ សួរថ្នាក់ដឹកនាំ វួដ ឬទូរសព្ទ ១-៨០០-៥៣៧-៥៩៧១ ( សហរដ្ឋ និងប្រទេសកាណាដា )



រូបតំណាងមកពី GETTY IMAGES

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយតំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*

*ការចែកចាយ, ៧៩*
*ការបម្រើ, ៦, ៥៤*
*ការប្រែចិត្ត, ៦៣*
*ការប្រែចិត្តជឿ, ១៨, ៣៦, ៤២, ៤៤*
*ការសិក្សាព្រះគម្ពីរ, ៤៨, ៥០*
*ការអធិស្ឋាន, ២០, ៤៨, ៥០, ៧៤*
*កិច្ចការផ្សព្វផ្សាយសាសនា, ១៨, ៧០*
*ក្រុមគ្រួសារ, ៦២, ៦៤, ៦៦, ៦៨*
*គំរូ, ៤០, ៤១, ៧០*
*ថ្ងៃឈប់សម្រាក, ៥៦, ៦០*
*ទុក្ខវេទនា, ២៤, ៤៣*
*ទំនុកចិត្ត, ១០*
*ប្រវត្តិសាសនាចក្រ, ១២*
*ពលិកម្ម, ៤៤, ៦៤*
*ពិធីបុណ្យជ្រមុជទឹក, ៧៤*
*ព្រះគម្ពីរមរមន, ១២, ៣៦, ៧៣, ៨០*
*ព្រះយេស៊ូវគ្រីស្ទ, ៦០, ៧២*
*ព្រះវរបិតាសួគ៌, ២០, ៤៨*
*ព្រះវិញ្ញាណបរិសុទ្ធ, ២០, ៦៨*
*ព្រះវិហារបរិសុទ្ធ, ៥៨, ៦២, ៦៣, ៦៤, ៧៤*
*ភក្ដីភាព, ៣០, ៧៥*
*មិត្តភាព, ៦៨, ៧០, ៧៥*
*យ៉ូសែប ស្ម៊ីធ, ១២*
*សុភមង្គល, ៤*
*សេចក្ដីពិត, ៥០*
*សេចក្ដីសប្បុរស, ៦*
*សេចក្ដីជំនឿ, ៣០, ៤០, ៤៣*
*អ្នកត្រួសត្រាយ, ២៤, ៣០, ៤៤*







*វិចទ័រកើតមុនកំណើតបីខែ ។ ជាលទ្ធផល គាត់មានពិការភាពមួយចំនួន ហើយពុំអាចដើរបានរហូតដល់គាត់អាយុបានប្រាំពីរឆ្នាំ ។ ទោះបីជាគាត់ជួបឧបសគ្គក្ដី ក៏វិចទ័របានជ្រើសរើសធ្វើជាមនុស្សរីករាយដែរ ។ គាត់បានរកឃើញអំណរនៅក្នុងការជួយ និងការបង្ហាញសេចក្ដីស្រឡាញ់ដល់អ្នកដទៃ ។*

**ឡេសលី នីលសុន ជាងថតរូប**

# វិចទ័រ បាប៊ីនយ៉ាហ្គ្រា

*ទីក្រុង ខាឃីវ ប្រទេស អ៊ុយក្រែន*

ខ្ញុំពិតជាមានបញ្ហា គឺដូចជាមនុស្សគ្រប់គ្នាផ្សេងទៀតមានផងដែរ ។ វាមិនធំជាង ឬតូចជាងនោះទេ ហើយទោះបីជាយើងពុំអាចដោះស្រាយវាបាន ១០០ ភាគរយក្ដី ក៏ខ្ញុំដឹងថា យើងអាចទប់ទល់នឹងបញ្ហារបស់យើងបាន ហើយយើងអាចបន្តឆ្ពោះទៅមុខយ៉ាងពិតប្រាកដ ។

ដោយសារសាសនាចក្រ ខ្ញុំដឹងថា យើងអាចរីករាយបាន មិនថាមានរឿងអ្វីកើតឡើងឡើយ ព្រោះផែនការរបស់ព្រះគឺជាផែនការនៃសុភមង្គល ។ ខ្ញុំជឿថា សុភមង្គលគឺជាអ្វីមួយដែលស្ថិតនៅក្នុងខ្លួនរបស់យើង ពុំមែននៅក្រៅខ្លួនយើងឡើយ ។

សុភមង្គលកើតមកពីការមានសេចក្ដីជំនឿ ការពឹងផ្អែកលើព្រះ និងការរស់នៅតាមដំណឹងល្អ ។ ការណ៍នេះជួយយើងឲ្យមានឥរិយាបថត្រឹមត្រូវ ហើយប្រើប្រាស់អ្វីដែលយើងមានដើម្បីធ្វើឲ្យខ្លួនយើងកាន់តែល្អប្រសើរឡើង ។

## ស្វែងរកបន្ថែមទៀត

សូមមើលបន្ថែមទៀតអំពីដំណើរនៃសេចក្ដីជំនឿរបស់ វិចទ័រ នៅគេហទំព័រ **liahona.lds.org** ។

សូមអាន « ផែនការនៃសេចក្ដីសង្គ្រោះ » នៅគេហទំព័រ lds.org/topics ដើម្បីស្វែងយល់អំពីរបៀបដែលផែនការនៃសេចក្ដីសង្គ្រោះជួយយើងឲ្យរកឃើញសុភមង្គល ។

# គោលការណ៍នៃការងារបម្រើ

# ឈោងទៅជួយដោយសេចក្ដីអាណិតអាសូរ

*នៅពេលយើងធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះស្ដីពីសេចក្ដីអាណិតអាសូរ នោះ អ្នកនឹងរកឃើញថា អ្នកអាចធ្វើឲ្យមានការផ្លាស់ប្ដូរនៅក្នុងជីវិតរបស់មនុស្សដទៃ ។*



សេចក្ដីអាណិតអាសូរគឺការដឹងអំពីទុក្ខព្រួយរបស់មនុស្សដទៃ ជាមួយនឹងបំណងប្រាថ្នាដើម្បីសម្រាល ឬបន្ធូរទុក្ខព្រួយនោះ ។ សេចក្ដីសញ្ញាដើម្បីធ្វើតាមព្រះអង្គសង្គ្រោះគឺជាសេចក្ដីសញ្ញានៃសេចក្ដីអាណិតអាសូរដើម្បី « ទទួលបន្ទុកគ្នាទៅវិញទៅមក » ( ម៉ូសាយ ១៨:៨ ) ។ ការចាត់តាំងឲ្យមើលថែមនុស្សដទៃគឺជាឱកាសមួយដើម្បីបម្រើដូចជាព្រះអម្ចាស់បានបម្រើ ៖ ជាមួយនឹង « ចិត្តអាណិត ដែលមានសេចក្ដីសង្ឃឹមផង ( យូដាស ១:២២ ) ។ ព្រះអម្ចាស់បានត្រាស់បង្គាប់ថា « សម្ដែងសេចក្ដីសប្បុរស និងសេចក្ដីអាណិតមេត្តាដល់គ្នាទៅវិញទៅមកចុះ » ( សាការី ៧:៩ ) ។

**សេចក្ដីអាណិតអាសូររបស់ព្រះអង្គសង្គ្រោះ**

សេចក្ដីអាណិតអាសូរគឺជាកម្លាំងជំរុញនៅក្នុងការងារបម្រើរបស់ព្រះអង្គសង្គ្រោះ ( សូមមើល របាចំហៀង ៖ « ព្រះអង្គសង្គ្រោះដ៏មានសេចក្ដីអាណិតអាសូរ » ) ។ សេចក្ដីអាណិតអាសូរចំពោះបងប្អូនរបស់ទ្រង់ បានបណ្ដាលឲ្យទ្រង់ឈោងទៅជួយដល់អស់អ្នកដែលនៅជុំវិញទ្រង់ក្នុងឱកាសរាប់មិនអស់ ។ ដោយបានញែកដឹងអំពីតម្រូវការ និងបំណងប្រាថ្នារបស់មនុស្ស នោះទ្រង់អាចប្រទានពរដល់ពួកគេ ហើយបង្រៀនពួកគេក្នុងរបៀបនានាដែលសំខាន់បំផុតចំពោះពួកគេ ។ បំណងប្រាថ្នារបស់ព្រះអង្គសង្គ្រោះដើម្បីលើកស្ទួយយើងចេញពីសេចក្ដីទុក្ខព្រួយបាននាំទៅរកទង្វើដ៏ធំបំផុតនៃសេចក្ដីអាណិតអាសូរ ៖ ដង្វាយធួនរបស់ទ្រង់សម្រាប់អំពើបាប និងការរងទុក្ខនៃមនុស្សជាតិ ។

សមត្ថភាពរបស់ទ្រង់ក្នុងការឆ្លើយតបចំពោះតម្រូវការរបស់មនុស្សគឺជាអ្វីមួយដែលយើងព្យាយាមធ្វើពេលយើងបម្រើ ។ នៅពេលយើងរស់នៅដោយសុចរិត និងស្ដាប់តាមការបំផុសគំនិតពីព្រះវិញ្ញាណ នោះយើងនឹងត្រូវបានបំផុសគំនិតដើម្បីឈោងទៅជួយក្នុងរបៀបដ៏មានអត្ថន័យ ។

**សេចក្ដីសញ្ញារបស់យើងស្ដីពីសេចក្ដីអាណិតអាសូរ**

ព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យបុត្រាបុត្រីរបស់ទ្រង់មានចិត្តអាណិតអាសូរ ( សូមមើល កូរិនថូសទី ១ ១២:២៥–២៧ ) ។ ដើម្បីក្លាយជាសិស្សដ៏ពិត នោះយើងត្រូវរកឃើញ និងបង្ហាញសេចក្ដីអាណិតអាសូរដល់មនុស្សដទៃ ជាពិសេសដល់អ្នកដែលខ្វះខាត ( គ. និង ស. ៥២:៤០ ) ។



សេចក្ដីជំនឿរបស់អ្នកបានធ្វើឲ្យ
អ្នកជាសះស្បើយ ដោយ ជេ ក់ក៏

គោលការណ៍នៃការងារបម្រើមានគោលបំណងដើម្បីជួយយើងឲ្យមើលថែគ្នាទៅវិញទៅមក — ពុំមែនត្រូវបានចែកចាយដូចជាសារលិខិតនោះទេ ។ នៅពេលយើងស្គាល់អស់អ្នកដែលយើងបម្រើ នោះព្រះវិញ្ញាណបរិសុទ្ធនឹងបំផុសគំនិតយើងឲ្យដឹងអំពីសារលិខិតអ្វីខ្លះដែលពួកគេអាចត្រូវការបន្ថែមពីលើការមើលថែ និងសេចក្ដីមេត្តាករុណារបស់យើង ។

ការលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ តាមរយៈសេចក្ដីសញ្ញាបុណ្យជ្រមុជទឹករបស់យើង នោះយើងធ្វើជាសាក្សីថា យើងមានឆន្ទៈដើម្បីអនុវត្តសេចក្ដីអាណិតអាសូរ ។ ប្រធាន ហិនរី បី អាវរីង ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយបានបង្រៀនថា អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធជួយយើងឲ្យធ្វើកិច្ចការនោះ ៖ « បងប្អូនគឺជាសមាជិកនៃសេចក្ដីសញ្ញារបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។ . . .

នោះជាហេតុដែលបងប្អូនមានអារម្មណ៍ចង់ជួយមនុស្សម្នាក់ ដែលពុះពារឆ្ពោះទៅមុខក្នុងភាពសោកសៅ និងក្តីលំបាកនោះ ។ បងប្អូនសន្យាថា នឹងជួយព្រះអម្ចាស់ធ្វើឲ្យបន្ទុកពួកគេបានស្រាល និងត្រូវបានលួងលោមចិត្ត ។ ពេលបងប្អូនទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ បងប្អូនត្រូវបានប្រទានឲ្យនូវអំណាចដើម្បីជួយសម្រាលបន្ទុកទាំងនោះ » ។[1]

ឧទាហរណ៍ បងស្រីម្នាក់នៅក្នុងប្រទេសរុស្ស៊ីមានស្ថានភាពលំបាកក្នុងគ្រួសារដែលរារាំងគាត់មិនឲ្យចូលរួមព្រះវិហារអស់រយៈពេលជាងមួយឆ្នាំ ។ បងស្រីម្នាក់ទៀតនៅក្នុងសាខាបានឈោងទៅជួយដោយសេចក្ដីអាណិតអាសូរជារៀងរាល់សប្តាហ៍តាមរយៈការទូរសព្ទទៅកាន់គាត់ ហើយប្រាប់គាត់អំពីការឡើងនិយាយ មេរៀន ការហៅបម្រើបេសកកម្ម កំណើតរបស់ទារក និងព័ត៌មានដទៃទៀតអំពីសាខា ។ នៅពេលស្ថានភាពគ្រួសាររបស់បងស្រីនោះបានដោះស្រាយ គាត់បានទទួលអារម្មណ៍ថា គាត់ហាក់ដូចជានៅតែជាផ្នែកមួយនៃសាខានោះ ដោយសារការទូរសព្ទប្រាប់ជារៀងរាល់សប្ដាហ៍ពីមិត្តភក្តិរបស់គាត់ ។ ■

កំណត់ចំណាំ

១. ហិនរី បី អាវរីង « The Comforter » *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១៨ ។



# ព្រះអង្គសង្គ្រោះដែលប្រកបដោយសេចក្ដីអាណិតអាសូរ

សូមគិតពីការសិក្សាខគម្ពីរមួយចំនួននេះដើម្បីឃើញអំពីរបៀបដែលសេចក្ដីអាណិតអាសូររបស់ព្រះយេស៊ូវគ្រីស្ទបំផុសព្រះទ័យទ្រង់ឲ្យព្យាបាល ប្រទានពរ និងបង្រៀនដល់អស់អ្នកដែលនៅជុំវិញទ្រង់អំឡុងពេលការងារបម្រើរបស់ទ្រង់ ៖ ម៉ាថាយ ៩:៣៥–៣៨; ១៤:១៤; ១៨:២៧, ៣៣; ២០:៣០–៣៤; ម៉ាកុស ១:៤០–៤២; ៥:១៩; ៦:៣០–៤២; ៩:២២; លូកា ៧:១៣; ១០:៣៣; ១៥:២០ ។

*ចូរទៅ ហើយធ្វើដូច្នោះផងដែរ ៖ សាសន៍សាម៉ារីចិត្តល្អ ដោយ ចច កុកកូ*

# យោបល់បួនយ៉ាងសម្រាប់ការអភិវឌ្ឍសេចក្ដីអាណិតអាសូរ

ដោយសារជារឿយៗ សេចក្ដីអាណិតអាសូរបានកើនឡើង បន្ទាប់ពីយើងដកបទពិសោធន៍ការសាកល្បងដោយខ្លួនយើងផ្ទាល់ នោះមានអ្វីៗមួយចំនួនដែលយើងអាចធ្វើនាពេលបច្ចុប្បន្ននេះដើម្បីអភិវឌ្ឍសេចក្ដីអាណិតអាសូរ ។ សូមពិចារណាពីរបៀបដែលអ្នកអាចអនុវត្តតាមគោលការណ៍ទាំងបួននេះ ។

## សេចក្ដីអាណិតអាសូរ

## ១. អធិស្ឋាន

**អធិស្ឋានទូលសូមសេចក្ដីអាណិតអាសូរ ។** នៅពេលអ្នកអំពាវនាវដល់ព្រះវរបិតាសួគ៌ នោះទ្រង់នឹងបើកដួងចិត្តរបស់អ្នក ហើយ « អ្នកនឹងទទួលអារម្មណ៍ខ្វាយខ្វល់ដោយស្មោះសរសម្រាប់សុខុមាលភាពអស់កល្បជានិច្ចនិងសុភមង្គលរបស់មនុស្សដទៃទៀត » ( *ប្រកាសដំណឹងល្អរបស់យើង ៖ មគ្គុទេសក៍ចំពោះការបម្រើជាអ្នកផ្សព្វផ្សាយសាសនា* [ ឆ្នាំ ២០០៤ ] ទំព័រ ១១៨ សូមមើលផងដែរ មរ៉ូណៃ ៧:៤៨ ) ។

## ២. អនុវត្ត

**អនុវត្តសេចក្ដីអាណិតអាសូរ ។** អ្នកអាចបង្ហាញសេចក្ដីអាណិតអាសូរតាមរយៈការស្ដាប់ និងការយល់ចិត្ត ។ សូមដាក់ខ្លួនរបស់អ្នកទៅក្នុងស្ថានភាពរបស់ពួកគេ ហើយពិចារណាអំពីរបៀបដែលពួកគេអាចទទួលអារម្មណ៍ ។ ប្រសិនបើស្ថានភាព និងពេលវេលាសមរម្យ នោះអ្នកអាចផ្ដល់ជំនួយដែលសម្រាលការឈឺចាប់ការរងទុក្ខ ឬការបាក់ទឹកចិត្ត ។

## ៣. ការបំផុសគំនិត

**ធ្វើតាមការបំផុសគំនិត ។** ព្រះអម្ចាស់អាចបើកសម្ដែងដល់យើងនូវរបៀបនានាដើម្បីបង្ហាញសេចក្ដីអាណិតអាសូរដែលយើងពុំអាចកត់សម្គាល់ដោយខ្លួនយើងផ្ទាល់ ។ នៅពេលអ្នកទទួលអារម្មណ៍ពីការប្រាប់មកពីព្រះវិញ្ញាណដើម្បីជួយមនុស្សដទៃ នោះសូមកុំស្ទាក់ស្ទើរក្នុងការធ្វើតាមការបំផុសគំនិតនោះ ។

## ៤. មិត្តភាព

**សូមធ្វើជាមិត្តផ្ទាល់នឹងការបំផុសគំនិត ។** ការបង្ហាញសេចក្ដីអាណិតអាសូរអាចក្លាយជារឿងសាមញ្ញដូចទៅនឹងការបង្ហាញចំណាប់អារម្មណ៍ស្មោះសរក្នុងជីវិតរបស់មនុស្ស ។ រៀនដើម្បីស្ដាប់ឲ្យបានល្អ ( សូមមើល « គោលការណ៍នៃការងារបម្រើ ៖ រឿងប្រាំយ៉ាងដែលអ្នកស្ដាប់ដ៏ល្អធ្វើ » *លីអាហូណា* ខែ មិថុនា ឆ្នាំ ២០១៨ ទំព័រ ៦–៩ ) ។ សេចក្ដីស្រឡាញ់របស់អ្នកចំពោះពួកគេនឹងកើតឡើង ហើយវានឹងកាន់តែស្រួលដើម្បីទទួលស្គាល់របៀបនានាក្នុងការបង្ហាញសេចក្ដីស្រឡាញ់នោះ ។

# ការស្គាល់ថាអ្នកជានរណា — ហើយថាយើងជាមនុស្សប្រភេទណាតាំងពីដើមមក

**ដោយ ស៊ីស្ទើរ ស្បេរី ឌូ**

ការចេញផ្សាយជាបន្តបន្ទាប់នេះដកស្រង់ផ្នែកសំខាន់ៗអំពីជីវិតស្ត្រីដ៏ស្មោះត្រង់ និងសារលិខិតរបស់ពួកគាត់ ដកស្រង់ចេញពីសៀវភៅ *At the Pulpit: 185 Years of Discourses by Latter-day Saint Women* ( ឆ្នាំ ២០១៧ ) ។

ថ្មីៗនេះ ក្មួយស្រីអាយុ ១៦ ឆ្នាំរបស់ខ្ញុំឈ្មោះ មេហ្គេន និងមិត្តភក្តិពីរនាក់ទៀត របស់នាងបានមកសម្រាកនៅផ្ទះរបស់ខ្ញុំ ។ នៅពេលយើងនិយាយគ្នានាល្ងាចនោះ មិត្តម្នាក់របស់គាត់បានសួរខ្ញុំថា តើការធំឡើងនៅក្នុងកសិដ្ឋាននៅជំនាន់មុនៗនោះមានសភាពបែបណាដែរ ។ . . . ខ្ញុំបានប្រាប់ មេហ្គេន និងមិត្តភក្តិរបស់នាងថា នៅ « ជំនាន់មុន » ខ្ញុំមានការអៀនខ្មាសជ្រុលពេក ហើយពិតជាគ្មានទំនុកចិត្តលើខ្លួនឯងសោះ ។

មេហ្គេនបានសួរថា « តើអ្នកមីងអាចយកឈ្នះលើអារម្មណ៍បែបនោះដោយរបៀបណា ? » ខ្ញុំស្ទើរតែឆ្លើយចម្លើយដែលនៅចុងៗមាត់ខ្ញុំទៅហើយ ស្រាប់តែខ្ញុំបានឈប់ ដោយទទួលអារម្មណ៍ថា យុវនារីដ៏អស្ចារ្យទាំងនេះនឹងកាន់តែយល់បានច្រើនជាង ប្រសិនបើខ្ញុំពន្យល់បន្ថែមទៀត ។ ដូច្នេះខ្ញុំបានពន្យល់ពួកគេពីហេតុផលខាងវិញ្ញាណវិញ ៖ ខ្ញុំគ្មានអារម្មណ៍ទាំងនោះឡើយ រហូតដល់ខ្ញុំបានចាប់ផ្ដើមយល់អំពីរបៀបដែលព្រះអម្ចាស់មានព្រះទ័យចំពោះខ្ញុំ ថាអារម្មណ៍របស់ខ្ញុំអំពីខ្លួនខ្ញុំ និងជីវិតរបស់ខ្ញុំបានចាប់ផ្ដើមផ្លាស់ប្ដូរបន្តិចម្ដងៗ ។ ក្រោយមកសំណួររបស់ពួកគេបានកើតឡើងភ្លាមថា ៖ តើខ្ញុំ *ដឹងថា* ព្រះអម្ចាស់មានព្រះទ័យបែបណាយ៉ាងដូចម្ដេច ? ហើយតើពួកគេអាចដឹងអំពីព្រះទ័យរបស់ទ្រង់ចំពោះពួកគេដោយរបៀបណា ?

អស់រយៈជាច្រើនម៉ោង ដោយមានព្រះគម្ពីរនៅក្នុងដៃ យើងបាននិយាយគ្នាអំពីរបៀបដើម្បីស្ដាប់ឮសំឡេងនៃព្រះវិញ្ញាណ អំពីព្រះទ័យដ៏អន្ទះសាររបស់ព្រះអម្ចាស់ក្នុងការបើកសម្ដែងចំណេះដឹងដែលបានទុកយ៉ាងសុវត្ថិភាពនៅក្នុងវិញ្ញាណរបស់យើងទាក់ទងនឹងរឿងថាខ្លួនយើងជានរណា និងអ្វីជាបេសកកម្មរបស់យើង ព្រមទាំងអំពីរបៀបដែលជីវិតនឹងមានការខុសប្លែកបែបណានៅពេលយើងដឹងរឿងនោះ ។

. . . គ្មានជោគជ័យ និងសុភមង្គលរបស់យើងណានៅលើលោកនេះសំខាន់ជាងការរៀនស្ដាប់តាមសំឡេងនៃព្រះវិញ្ញាណឡើយ ។ ព្រះវិញ្ញាណគឺជាអង្គដែលបើកបង្ហាញពីអត្តសញ្ញាណរបស់យើង — គឺមិនគ្រាន់តែថាយើងជានរណានោះទេ — ប៉ុន្តែថែមទាំងដឹងថាយើងជាមនុស្សប្រភេទណាតាំងពីដើមដំបូងមកទៀតផង ។ ហើយថានៅពេលយើងដឹងពីរឿងនេះ នោះជីវិតរបស់យើងនឹងដឹងពីគោលបំណង



**អំពីស៊ីស្ទើរ ឌូ**

ស្បេរី លីន ឌូ កើតនៅ អូលីសស៍ កានសាស ស.រ.អា. ក្នុងឆ្នាំ ១៩៥៣ ។ គាត់គឺជាកូនច្បងនៃបងប្អូនប្រាំនាក់ ហើយនៅគ្រានោះគាត់បានរៀនចប់ថ្នាក់ទីប្រាំ គាត់បើកត្រាក់ទ័រនៅកសិដ្ឋានស្រែរបស់គ្រួសារ ។ នៅថ្ងៃអាទិត្យជីដូនរបស់គាត់ ម៉ោឌី ឌូ នឹងទៅយកគាត់ពីព្រលឹមដើម្បីទៅព្រះវិហារ ដែលធ្វើពិធីនៅក្នុងសាលជួលមួយ ។ ពួកគេនឹងបោសសម្អាតកន្ទុយបារី និងសំបកកំប៉ុងស្រាបៀរដើម្បីរៀបចំបន្ទប់នោះសម្រាប់ព្រះវិហារ ។ ការចូលរួមនៅក្នុងសាខាតូចមួយមានន័យថា គាត់ត្រូវឡើងនិយាយ និងបង្រៀនច្រើនណាស់ ។ គាត់បានក្លាយជាអ្នកលេងព្យាណូនៅសាខាកាលគាត់ជាយុវនារី ហើយបានបម្រើនៅក្នុងគណៈប្រធានថ្នាក់អង្គការបឋមសិក្សាកាលគាត់អាយុ ១៦ ឆ្នាំ ។

បន្ទាប់ពីរៀនបានបរិញ្ញាប័ត្រប្រវត្តិសាស្ត្រនៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ក្នុងឆ្នាំ ១៩៧៨ គាត់បានធ្វើការមួយជាអ្នកនិពន្ធជាមួយ Bookcraft ។ គាត់បានចូលរួមជាមួយ Deseret Book នៅក្នុងឆ្នាំ ១៩៨៨ ហើយក្លាយជាអនុប្រធានប្រតិបត្តិនៅក្នុងឆ្នាំ ២០០០ ។

គាត់មានអាយុ ៣៥ ឆ្នាំ កាលគាត់បានចូលរួមក្នុងគណៈកម្មការសមាគមសង្គ្រោះទូទៅ អំឡុងពេលនៃគណៈប្រធាន បាបារ៉ា ដុប័លយូ វីនឌើរ ។ គាត់មានអាយុត្រឹមតែ ៤៣ ឆ្នាំប៉ុណ្ណោះ នៅពេលគាត់ក្លាយជាទីប្រឹក្សាទីពីររបស់ ម៉ារី អ៊ីឡែន ដុប័លយូ ស្មូត ក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅក្នុងឆ្នាំ ១៩៩៧ ។

ស៊ីស្ទើរ ឌូ បានក្រើនរំឭកដល់ស្ត្រីឲ្យយល់អំពីតម្លៃរបស់ពួកគេអំឡុងពេលថ្លែងបញ្ចេញយោបល់របស់គាត់នៅសន្និសីទស្ត្រីប៊ី.វាយ.យូ.ឆ្នាំ ២០០១ ការដកស្រង់នៅទីនេះ ( វណ្ណយុត្តិត្រូវបានធ្វើតាមបទដ្ឋាន ) ។

ដ៏អស្ចារ្យ ដែលនឹងផ្លាស់ប្ដូរយើងទាំងស្រុង ។

. . . វិញ្ញាណរបស់យើងចង់ឲ្យយើងចងចាំពីសេចក្ដីពិតថាយើងជានរណា ដោយសាររបៀបដែលយើងមើលមកខ្លួនយើង ដឹងអំពីអត្តសញ្ញាណរបស់យើងវានឹងជះឥទ្ធិពលលើអ្វីគ្រប់យ៉ាងដែលយើងធ្វើ ។ . . . វាជះឥទ្ធិពលលើរបៀបដែលយើងរស់នៅ ។ ដូច្នេះនាថ្ងៃនេះ ខ្ញុំសូមអញ្ជើញអ្នកឲ្យពិចារណានៅក្នុងរបៀបមួយថ្មី — គឺមិនគ្រាន់តែថាអ្នកជានរណានោះទេ — ថែមទាំងដឹងថាអ្នកជាមនុស្សប្រភេទណាតាំងពីដើមដំបូងមកផងដែរ ។

. . . តើអ្នកអាចស្រមៃឃើញថា ព្រះដែលស្គាល់យើងយ៉ាងឥតខ្ចោះបានបម្រុងទុកឲ្យយើងកើតមកក្នុងពេលនេះ នៅពេលដែលស្ថានភាពប្រែកាន់តែតានតឹង ហើយការប្រឆាំងកាន់តែមានខ្លាំងឡើងជាងពេលណាៗទាំងអស់ដែរឬទេ ? តើនៅពេលណាដែលទ្រង់ត្រូវការស្ត្រីដែលនឹងជួយចិញ្ចឹម ហើយដឹកនាំជំនាន់ជម្រើសមួយនៅក្នុងបរិយាកាសគ្រោះថ្នាក់ខាងវិញ្ញាណនោះ ? តើអ្នកអាចស្រមៃឃើញថា ទ្រង់បានជ្រើសរើសយើងដោយសារទ្រង់បានដឹងថា យើងនឹងគ្មានក្ដីភ័យខ្លាចដើម្បីសាងសង់ទីក្រុងស៊ីយ៉ូនឬទេ ?

. . . មានត្រកូលខ្ពស់ និងអស្ចារ្យ ។ មានភាពក្លាហាន និងការប្ដេជ្ញាចិត្ត ។ ស្មោះត្រង់ ហើយគ្មានការភ័យខ្លាច ។ នោះគឺជាអ្នក — ហើយនោះគឺជារូបអ្នកតាំងពីដើមដំបូងមក ។ ការយល់ដឹងអំពីសេចក្ដីពិតនោះអាចផ្លាស់ប្ដូរជីវិតរបស់អ្នក ដោយសារចំណេះដឹងនេះនាំមកនូវទំនុកចិត្តដែលពុំអាចធ្វើតាមរបៀបផ្សេងណាទៀតឡើយ ។

. . . នៅពេលអ្នកយល់ថា *អ្នក* ត្រូវបានជ្រើសរើសហើយបម្រុងទុកសម្រាប់ពេលឥឡូវនេះ ហើយនៅពេលអ្នករស់នៅស្របតាមបេសកកម្មនោះ នោះអ្នកនឹងកាន់តែសប្បាយរីករាយជាងមុន ។

. . . ព្រះជាព្រះវរបិតារបស់យើង ហើយបុត្រាបង្កើតតែមួយរបស់ទ្រង់គឺជាព្រះគ្រីស្ទ ។ សូមឲ្យយើងរីករាយក្នុងការអនុវត្តគាំទ្រដោយក្លាហានចំពោះព្រះអង្គសង្គ្រោះសារជាថ្មីម្ដងទៀត ហើយបម្រើដោយក្លាហាន និងរឹងប៉ឹងនៅក្នុងចម្ការទំពាំងបាយជូររបស់ទ្រង់ ។ យើងសូមឲ្យយើងកុំខ្លាចក្នុងការស្ថាបនាទីក្រុងស៊ីយ៉ូននៃព្រះរបស់យើងឡើយ — ដោយសារយើងដឹងថា យើងជានរណា ហើយយើងជាមនុស្សប្រភេទណាតាំងពីដើមដំបូងមក ។ ■



រូបថតពី GETTY IMAGES





ជំពូក ៥

# បាត់អស់ហើយ

*នេះគឺជាជំពូកទី ៥ នៃនិទានកថាទាំងបួនភាគថ្មីអំពីប្រវត្តិសាសនាចក្រដែលមានចំណងជើងថា ពួកបរិសុទ្ធ ៖ រឿងអំពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៅថ្ងៃចុងក្រោយ ។ សៀវភៅនេះនឹងបោះពុម្ពជា ១៤ ភាសា នៅក្នុងវគ្គប្រវត្តិសាសនាចក្រនៃកម្មវិធីបណ្ណាល័យដំណឹងល្អ និងនៅលើអ៊ិនធើរណែតនៅគេហទំព័រ saints.lds.org ។ ជំពូកបន្ទាប់មួយចំនួនទៀតនឹងត្រូវចេញផ្សាយក្នុងច្បាប់ផ្សាយក្រោយៗរហូតដល់ភាគ ១ ត្រូវចេញផ្សាយនៅចុងឆ្នាំនេះ ។ ជំពូកទាំងនោះនឹងមានជា ៤៧ ភាសានៅក្នុងកម្មវិធីបណ្ណាល័យដំណឹងល្អ និងនៅលើអ៊ិនធើរណែតនៅគេហទំព័រ saints.lds.org ។*

បន្ទាប់ពីយ៉ូសែប បានយកផ្ទាំងចំណារមកដល់ផ្ទះ ពួកអ្នកស្វែងរកកំណប់បានព្យាយាមលួចវាពីលោកអស់ជាច្រើនសប្ដាហ៍ ។ ដើម្បីទុកផ្ទាំងចំណារឲ្យមានសុវត្ថិភាព លោកត្រូវប្ដូរកន្លែងលាក់ផ្ទាំងចំណារពីកន្លែងមួយទៅកន្លែងមួយ ដោយលាក់ផ្ទាំងចំណារតាំងពីក្រោមចង្ក្រាន ក្រោមឥដ្ឋក្នុងហាងឪពុកលោក និងក្រោមគំនរគ្រាប់ធុញ្ញជាតិជាដើម ។ គាត់មិនដែលបោះបង់ការថែរក្សាវាឡើយ ។

ពួកអ្នកជិតខាងដែលចង់ឃើញបានឈប់នៅផ្ទះលោក ហើយបានសូមអង្វរលោកឲ្យបង្ហាញកំណត់ត្រាដល់ពួកគេ ។ យ៉ូសែប តែងតែបដិសេធ ទោះបីជានៅពេលខ្លះមានមនុស្សមួយចំនួនចង់ឲ្យលុយលោកក្ដី ។ លោកបានតាំងចិត្តថានឹងរក្សាផ្ទាំងចំណារ ដោយទុកចិត្តលើសេចក្ដីសន្យារបស់ព្រះអម្ចាស់ថា ប្រសិនបើលោកធ្វើអស់ពីលទ្ធភាពលោក នោះផ្ទាំងចំណារនឹងមានសុវត្ថិភាព ។[1]

ជាញឹកញាប់ ការរំខាននេះធ្វើឲ្យលោកអាក់ខានមិនបានពិនិត្យមើលផ្ទាំងចំណារ និងរៀនបន្ថែមទៀតអំពីត្បូងយូរីម និងធូមីម ។ លោកដឹងថា ប្រដាប់បកប្រែនេះគឺសម្រាប់ជួយលោកឲ្យធ្វើការបកប្រែផ្ទាំងចំណារ ប៉ុន្តែលោកមិនធ្លាប់ប្រើត្បូងមើលឆុតដើម្បីអានភាសាពីបុរាណពីមុនមកនោះទេ ។ លោកមានចិត្តអន្ទះសាដើម្បីចាប់ផ្ដើមការងារ ប៉ុន្តែវាមិនងាយស្រួលឲ្យលោកធ្វើវានោះទេ ។[2]

នៅពេលយ៉ូសែប បានសិក្សាផ្ទាំងចំណារ មានម្ចាស់ដីដ៏គួរឲ្យគោរពម្នាក់នៅភូមិប៉ាល់ម៉ៃរ៉ាដែលមានឈ្មោះថា ម៉ាទិន ហារីស បានមានចំណាប់អារម្មណ៍លើការងាររបស់លោក ។ ម៉ាទិន មានអាយុស្របាលនឹងឪពុករបស់យ៉ូសែប ហើយនៅពេលខ្លះបានជួលឲ្យយ៉ូសែប ជួយការងារគាត់នៅឯកសិដ្ឋានគាត់ ។ ម៉ាទិន បានឮអំពីផ្ទាំងចំណារមាស ប៉ុន្តែបានឮតិចតួចអំពីវារហូតដល់ម្ដាយរបស់យ៉ូសែប បានអញ្ជើញគាត់មកលេងនឹងយ៉ូសែប ។[3]

យ៉ូសែប បានចេញទៅធ្វើការ នៅពេលម៉ាទិន បានឈប់ចូលមកលេង ដូច្នេះគាត់បានសាកសួរទៅអិមម៉ា និងសមាជិកដទៃទៀតនៅក្នុងគ្រួសារអំពីផ្ទាំងចំណារ ។ នៅពេលយ៉ូសែប បានមកដល់ផ្ទះ ម៉ាទិន បានចាប់ដៃលោក ហើយបានសួរសំណួរលម្អិតថែមទៀត ។ យ៉ូសែប បានប្រាប់គាត់អំពីផ្ទាំងចំណារមាស និងសេចក្ដីណែនាំរបស់ទេវតាមរ៉ូណៃឲ្យបកប្រែ និងបោះពុម្ពសេចក្ដីចែងនៅក្នុងផ្ទាំងចំណារនេះ ។

ម៉ាទិន បាននិយាយថា « ប្រសិនបើវាជាកិច្ចការរបស់អារក្ស នោះខ្ញុំមិនចាប់អារម្មណ៍អំពីរឿងនេះទេ » ។ ប៉ុន្តែប្រសិនបើវាជាកិច្ចការរបស់ព្រះអម្ចាស់ នោះគាត់មានចិត្តចង់ជួយដល់យ៉ូសែប ប្រកាសដំណឹងល្អនេះដល់ពិភពលោក ។

យ៉ូសែប បានអនុញ្ញាតឲ្យ ម៉ាទិន លើកផ្ទាំងចំណារនៅក្នុងប្រអប់ចាក់សោ ។ ម៉ាទិន អាចដឹងថា វាមានរបស់ធ្ងន់នៅក្នុងនោះ ប៉ុន្តែមិនជឿថាវាជាផ្ទាំងចំណារមាសឡើយ ។ គាត់បានប្រាប់យ៉ូសែប ថា « ក្មួយកុំបន្ទោសពូថា ពូមិនជឿពាក្យរបស់ក្មួយឡើយ » ។

នៅពេលម៉ាទិន ត្រឡប់ទៅផ្ទះវិញនៅពាក់កណ្ដាលយប់ គាត់បានចូលបន្ទប់ដេកគាត់យ៉ាងស្ងាត់ៗ ហើយបានអធិស្ឋាន ដោយសន្យានឹងព្រះថា នឹងផ្ដល់អ្វីៗទាំងអស់ដែលគាត់មាន ប្រសិនបើគាត់អាចដឹងថា យ៉ូសែប កំពុងធ្វើកិច្ចការរបស់ព្រះ ។

នៅពេលដែលម៉ាទិន បានអធិស្ឋាន នោះគាត់ទទួលបានអារម្មណ៍ពីសំឡេងដ៏តូចរហៀង មានបន្ទូលមកកាន់ព្រលឹងរបស់គាត់ ។ ពេលនោះទើបគាត់បានដឹងថាផ្ទាំងចំណារនោះគឺមកពីព្រះ — ហើយគាត់បានដឹងថា គាត់ត្រូវតែជួយដល់យ៉ូសែបដើម្បីចែកចាយសារដំណឹងនៅក្នុងផ្ទាំងចំណារនេះ ។[4]

នៅចុងឆ្នាំ ១៨២៧ អិមម៉ា បានដឹងថាខ្លួនមានផ្ទៃពោះ ហើយក៏សរសេរសំបុត្រទៅជម្រាបឪពុកម្ដាយនាង ។ នាង និងយ៉ូសែប បានរៀបការជិតមួយឆ្នាំទៅហើយ តែឪពុកម្ដាយរបស់នាងនៅតែមិនសប្បាយចិត្តនឹងពួកគាត់ ។ ប៉ុន្តែគ្រួសារលោក

មហន្តរាយដ៏ធ្ងន់ធ្ងរលើ ១១៦ ទំព័រដែលបានបកប្រែ ដោយ ក្រាំ ប៊ូរ៉ៃអេរ

ហេល បានយល់ព្រមឲ្យគូស្វាមីភរិយាក្មេងខ្ចីនេះត្រឡប់ទៅកាន់ ភូមិហាម៉ូនី វិញដើម្បី អិមម៉ា អាចសម្រាលកូននៅជិតក្រុមគ្រួសាររបស់ខ្លួន ។

ទោះបីជាការត្រឡប់ទៅភូមិហាម៉ូនីវិញនឹងធ្វើឲ្យលោកឃ្លាតឆ្ងាយពីឪពុកម្ដាយ និងបងប្អូនលោកផ្ទាល់ក្តី ក៏យ៉ូសែប នៅតែមានចិត្តអន្ទះសាចង់ទៅដែរ ។ ក្រុមមនុស្សនៅរដ្ឋញូវយ៉កនៅតែព្យាយាមលួចផ្ទាំងចំណារ ហើយការប្ដូរលំនៅទៅកន្លែងថ្មីអាចធ្វើឲ្យមានសុវត្ថិភាព និងឯកជនភាពដែលលោកត្រូវការដើម្បីធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។ តែជាអកុសល លោកជំពាក់បំណុលគេ ហើយគ្មានប្រាក់ដើម្បីធ្វើដំណើរឡើយ ។[៥]

ដោយមានចិត្តចង់ដោះស្រាយបញ្ហាហិរញ្ញវត្ថុរបស់លោក យ៉ូសែប បានឡើងទៅក្រុងដើម្បីសងបំណុលរបស់លោកមួយចំនួន ។ ខណៈកំពុងឈរនៅក្នុងហាងបង់ប្រាក់ស្រាប់តែ ម៉ាទិន ហារិស បានឈរនៅក្បែរលោក ។ គាត់បាននិយាយថា « លោកស៊្មីធ នេះលុយហាសិបដុល្លារ ។ ខ្ញុំឲ្យលោកដើម្បីធ្វើកិច្ចការរបស់ព្រះអម្ចាស់ » ។

យ៉ូសែប មានការភ័យខ្លាចនឹងយកលុយនេះ ហើយបានសន្យាថានឹងសងវិញ ប៉ុន្តែ ម៉ាទិន ប្រាប់ថា កុំឲ្យព្រួយបារម្ភអំពីរឿងនេះ ។ លុយនោះគឺជាអំណោយ ហើយគាត់បានហៅមនុស្សគ្រប់គ្នានៅក្នុងបន្ទប់នោះឲ្យធ្វើជាសាក្សីថា គាត់ឲ្យលុយនេះដោយសុទ្ធចិត្ត ។[៦]

បន្ទាប់ពីនោះភ្លាម យ៉ូសែប បានសងបំណុលរបស់លោក ហើយបានលើកឥវ៉ាន់ដាក់ក្នុងរទេះ ។ រួចលោក ហើយនិង អិមម៉ា បានចេញដំណើរទៅភូមិហាម៉ូនីដោយលាក់ផ្ទាំងចំណារនៅក្នុងពាងសណ្ដែក ។[៧]

> *ដោយមើលទៅកាន់តួអក្សរ សាស្ត្រាចារ្យ អែនថុន បានឃើញអក្សរមួយចំនួនដែលស្រដៀងអក្សរពួកអេស៊ីព្ទ ហើយបានប្រាប់ម៉ាទិន ហារីស ថា ការបកប្រែនោះគឺត្រឹមត្រូវ ។*

ប្រហែលជាមួយសប្ដាហ៍ក្រោយមក ប្ដីប្រពន្ធមួយគូនេះបានមកដល់គេហដ្ឋានដ៏ធំរបស់គ្រួសារ ហេល ។[៨] មិនយូរប៉ុន្មាន ឪពុករបស់អិមម៉ា បានសុំមើលផ្ទាំងចំណារមាស ប៉ុន្តែ យ៉ូសែប បានថា លោកអាចបង្ហាញតែប្រអប់ដែលលោកបានដាក់វានៅក្នុងនោះប៉ុណ្ណោះ ។ ដោយធុញទ្រាន់ពេក អ៊ីសាក បានលើកប្រអប់សោនោះឡើង ហើយបានដឹងទម្ងន់របស់ប្រអប់នេះ ប៉ុន្តែគាត់នៅតែមានការសង្ស័យ ។ គាត់បាននិយាយថា យ៉ូសែប មិនអាចទុកវានៅក្នុងផ្ទះបានទេ លុះត្រាតែយ៉ូសែប បង្ហាញដល់គាត់នូវអ្វីដែលមាននៅខាងក្នុងនោះ ។[៩]

កាលមានវត្តមានរបស់ឪពុកអិមម៉ានៅជិតនោះ វាមិនធ្វើឲ្យការបកប្រែងាយស្រួលទេ ប៉ុន្តែ យ៉ូសែប នៅតែព្យាយាមអស់ពីលទ្ធភាពរបស់លោក ។ ដោយមានជំនួយពីអិមម៉ា លោកបានចម្លងតួអក្សរចម្លែកៗជាច្រើនចេញពីផ្ទាំងចំណារដាក់លើក្រដាស ។[១០] ជាច្រើនសប្ដាហ៍បន្ទាប់មក លោកបានព្យាយាមបកប្រែវាដោយប្រើត្បូង យូរីម និងធូមីម ។ ដំណើរការបកប្រែនេះតម្រូវឲ្យលោកធ្វើច្រើនជាងការគ្រាន់តែមើលតាមប្រដាប់បកប្រែនោះ ។ លោកត្រូវតែមានចិត្តរាបសា ហើយអនុវត្តសេចក្ដីជំនឿនៅពេលលោកសិក្សាតួអក្សរនោះ ។[១១]

ពីរបីខែក្រោយមក ម៉ាទិន បានមកដល់ភូមិហាម៉ូនី ។ គាត់បាននិយាយថា គាត់មានអារម្មណ៍ថា ព្រះអម្ចាស់បានហៅគាត់ឲ្យធ្វើដំណើរទៅដល់ទីក្រុងញូវយ៉ក ដើម្បីប្រឹក្សានឹងអ្នកជំនាញអំពីភាសាបុរាណ ។ គាត់បានសង្ឃឹមថា ពួកគេអាចបកប្រែតួអក្សរនោះ ។[១២]

យ៉ូសែប បានចម្លងតួអក្សរជាច្រើនពីផ្ទាំងចំណារ បានសរសេរការបកប្រែរបស់លោក ហើយបានប្រគល់ក្រដាសនោះឲ្យទៅម៉ាទិន ។ បន្ទាប់មកលោក និងអិមម៉ា បានមើលមិត្តរបស់ពួកគាត់ធ្វើដំណើរឆ្ពោះទៅកាន់ទិសខាងកើតដើម្បីប្រឹក្សាជាមួយអ្នកប្រាជ្ញល្បីៗ ។[១៣]

នៅពេលម៉ាទិន បានមកដល់ទីក្រុងញូវយ៉ក គាត់បានទៅជួបនឹងលោក ឆាលស៍ អាន់តុន ជាសាស្ត្រាចារ្យផ្នែកភាសាឡាតាំង និងភាសាក្រិក នៅឯមហាវិទ្យាល័យកូឡុំបៀ ។ សាស្ត្រាចារ្យ អាន់តុន មានវ័យក្មេង — ដែលមានអាយុក្មេងជាង ម៉ាទិន ប្រហែលជាដប់ប្រាំឆ្នាំ — ហើយលោកមានកេរ្តិ៍ឈ្មោះល្បីផ្នែកបោះពុម្ពផ្សាយសព្វវចនាធិប្បាយដ៏មានប្រជាប្រិយភាពមួយស្ដីពីវប្បធម៌ក្រិក និងរ៉ូម ។ លោកក៏បានចាប់ផ្ដើមប្រមូលសាច់រឿងអំពីជនជាតិអាមេរិកាំងឥណ្ឌាដើមផងដែរ ។[១៤]

លោកអាន់តុន គឺជាអ្នកប្រាជ្ញដែលតឹងតែងមួយរូបមិនចូលចិត្តការរំខានឡើយ ប៉ុន្តែលោកបានស្វាគមន៍ម៉ាទិន ហើយបានសិក្សាអក្សរដែលយ៉ូសែប បានបកប្រែ ។[១៥] ទោះជាសាស្ត្រាចារ្យរូបនេះមិនចេះអក្សរអេស៊ីព្ទក្តី ក៏គាត់បានអានការស្រាវជ្រាវមួយចំនួនអំពីភាសានេះ ហើយបានដឹងថាវាមានលក្ខណៈយ៉ាងណា ។ កាលកំពុងមើលអត្ថបទនេះ លោកបានឃើញភាពស្រដៀងគ្នាមួយចំនួននឹងអត្ថន័យជាភាសាអេស៊ីព្ទ ហើយបានប្រាប់ម៉ាទិនថា ការបកប្រែនេះគឺត្រឹមត្រូវ ។

ម៉ាទិន បានបង្ហាញលោកនូវការបកប្រែជាច្រើនទៀត ហើយលោក អាន់តុន បានពិនិត្យមើលវា ។ លោកបានមានប្រសាសន៍ថា តួអក្សរនេះមានបញ្ចូលគ្នានូវភាសាពីបុរាណជាច្រើន ហើយក៏បានផ្ដល់វិញ្ញាបនបត្រដល់ម៉ាទិន បញ្ជាក់ថាការបកប្រែគឺត្រឹមត្រូវ ។ លោកក៏បានផ្ដាំឲ្យម៉ាទិន បង្ហាញការបកប្រែនេះទៅកាន់អ្នកប្រាជ្ញមួយរូបទៀតដែលមានឈ្មោះថា សាំយូអែល មិចឆែល ដែលធ្លាប់បង្រៀននៅកូឡុំបៀដែរ ។[១៦]

លោកអាន់តុន បានមានប្រសាសន៍ថា « គាត់ចេះដឹងច្រើនណាស់ពីភាសាបុរាណទាំងនេះ ហើយខ្ញុំជឿថា គាត់នឹងជួយលោកបានច្រើន » ។[១៧]

ម៉ាទិន បានដាក់វិញ្ញាបនបត្រចូលក្នុងហោប៉ៅរបស់គាត់ ប៉ុន្តែនៅពេលគាត់ហៀបនឹងចាកចេញទៅ នោះលោកអាន់តុន បានស្រែកហៅគាត់ឲ្យត្រឡប់មកវិញ ។ លោកចង់ដឹងអំពីរបៀបដែលយ៉ូសែប ទទួលបានផ្ទាំងចំណារនេះ ។

ម៉ាទិន បានមានប្រសាសន៍ថា « ទេវតារបស់ព្រះ បានបើកសម្ដែងដល់យ៉ូសែប » ។ គាត់បានថ្លែងទីបន្ទាល់ថា ការបកប្រែពីផ្ទាំងចំណារនេះនឹងផ្លាស់ប្ដូរពិភពលោក ហើយសង្គ្រោះពិភពលោកនេះពីការវិនាសបង់ ។ ហើយឥឡូវនេះ កាលដែលគាត់មានការបញ្ជាក់ពីភាពត្រឹមត្រូវរួចហើយ គាត់មានបំណងចង់លក់កសិដ្ឋានរបស់គាត់ ដើម្បីជួយឧបត្ថម្ភជាលុយដើម្បីឲ្យការបកប្រែនេះអាចបោះពុម្ពបាន ។

លោកអាន់តុន បានមានប្រសាសន៍ថា « ខ្ញុំសូមមើលវិញ្ញាបនបត្របន្តិចមក » ។

ម៉ាទិន បានលូកយកវាចេញពីហោប៉ៅរួចក៏ប្រគល់ជូនលោក ។ លោកអាន់តុន បានហែកវាជាចំណែកៗ ហើយនិយាយថា វាគ្មានទេវតាឯណាទេ ។ បើយ៉ូសែប ចង់បកប្រែផ្ទាំងចំណារ លោកគួរតែយកវាមកកូឡុំបៀ ហើយទុកឲ្យពួកអ្នកប្រាជ្ញជាអ្នកបកប្រែវា ។

ម៉ាទិន បានពន្យល់ថា ផ្នែកនៃផ្ទាំងចំណារទាំងនោះត្រូវបានផ្សារភ្ជាប់ ហើយថា យ៉ូសែប ពុំត្រូវបានអនុញ្ញាតឲ្យបង្ហាញវាដល់នរណាម្នាក់ឡើយ ។

អាន់តុន បាននិយាយថា « ខ្ញុំពុំអាចអានសៀវភៅមួយដែលបានផ្សារភ្ជាប់ឡើយ » ។ លោកបានព្រមានម៉ាទិនថា យ៉ូសែប ប្រហែលជាកំពុងកុហកគាត់ហើយ ។ លោកបាននិយាយថា « ចូរប្រុងប្រយ័ត្នចំពោះពួកមនុស្សបោកប្រាស់ » ។[១៨]

ម៉ាទិន បានចេញពីសាស្ត្រាចារ្យ អាន់តុន ហើយបានទៅជួបនឹងលោក សាំយូអែល មិចឆែល ។ សាំយូអែល បានទទួលម៉ាទិនយ៉ាងរាក់ទាក់ បានស្ដាប់អំពីដំណើររឿងរបស់គាត់ ហើយបានមើលតួអក្សរទាំងឡាយ និងការបកប្រែ ។ លោកពុំយល់អំពីវាទេ ប៉ុន្តែលោកបាននិយាយថា វាបានរំឭកលោកអំពីតួអក្សររបស់អេស៊ីព្ទពីបុរាណ ហើយគឺជាការសរសេរនៃជាតិសាសន៍មួយដែលបានសាបសូន្យទៅហើយ ។[១៩]

មិនយូរប៉ុន្មានក្រោយមក ម៉ាទិន បានចាកចេញពីទីក្រុងនោះ ហើយត្រឡប់ទៅភូមិហាម៉ូនីវិញ ដោយជឿជាក់យ៉ាងខ្លាំងថា យ៉ូសែប មានផ្ទាំងចំណារពីបុរាណ និងមានអំណាចដើម្បីបកប្រែវា ។ គាត់បានប្រាប់យ៉ូសែបអំពីការសម្ភាសរបស់គាត់ជាមួយនឹងពួកសាស្ត្រាចារ្យ ហើយបានផ្ដល់ហេតុផលថា ប្រសិនបើមនុស្សដែលមានអប់រំខ្ពស់មួយចំនួននៅប្រទេសអាមេរិកពុំអាចបកប្រែសៀវភៅនេះបានទេ នោះយ៉ូសែបត្រូវធ្វើកិច្ចការនេះ ។

យ៉ូសែប បាននិយាយដោយការរំជួលចិត្តយ៉ាងខ្លាំងចំពោះកិច្ចការនេះថា « ខ្ញុំពុំអាចធ្វើកិច្ចការនេះបានទេ ដោយសារខ្ញុំរៀនពុំបានជ្រៅជ្រះឡើយ » ។ ប៉ុន្តែលោកបានដឹងថា ព្រះអម្ចាស់បានរៀបចំប្រដាប់បកប្រែ ដើម្បីលោកអាចបកប្រែផ្ទាំងចំណារនេះបាន ។[២០]

ម៉ាទិន យល់ស្រប ។ គាត់បានរៀបផែនការត្រឡប់ទៅភូមិបាល់ម៉ៃរ៉ា ដើម្បីរៀបចំជំនួញរបស់គាត់ឲ្យរៀបរយ ហើយត្រឡប់មកវិញភ្លាមតាមដែលអាចធ្វើបាន ដើម្បីធ្វើជាអ្នកសរសេរឲ្យយ៉ូសែប ។[២១]




សំណៅតួអក្សរមកពីផ្ទាំងព្រះគម្ពីរមរមន ។

នៅខែ មេសា ឆ្នាំ ១៨២៨ អិមម៉ា និងយ៉ូសែប កំពុងរស់នៅក្នុងផ្ទះមួយនៅតាមបណ្ដោយទន្លេសុសគ្វីហាណា ក្បែរនឹងផ្ទះរបស់ឪពុកម្ដាយនាង ។[២២] ឥឡូវនេះ កាលកូនក្នុងផ្ទៃអិមម៉ាជិតគ្រប់ខែ ជារឿយៗនាងបានធ្វើជាអ្នកសរសេរឲ្យយ៉ូសែប បន្ទាប់ពីលោកចាប់ផ្ដើមបកប្រែកំណត់ត្រានោះ ។ ថ្ងៃមួយ កាលលោកបានបកប្រែ រំពេចនោះយ៉ូសែប បានមានទឹកមុខស្លេកស្លាំង ។ លោកបានសួរថា « អិមម៉ា តើទីក្រុងយេរូសាឡិម មានរបងព័ទ្ធជុំវិញដែរឬទេអូន ? »

នាងបានឆ្លើយដោយនឹកគិតអំពីព្រះគម្ពីរប៊ីបថា « ចាស មាន » ។

យ៉ូសែប បាននិយាយដោយមានអារម្មណ៍ធូរស្រាលថា « ឱ! បងខំតែបារម្ភថាក្រែងបងច្រឡំ » ។[២៣]

អិមម៉ា មានការស្ញប់ស្ញែងថា ទោះស្វាមីខ្លួនមិនសូវចេះដឹងអំពីប្រវត្តិសាស្ត្រ និងព្រះគម្ពីរក្ដី ក៏វាមិនអាចរារាំងការបកប្រែនេះបានឡើយ ។ យ៉ូសែប ស្ទឹធ ស្ទើរតែមិនអាចសរសេរអក្សរឲ្យបានត្រឹមត្រូវផង ។ ប៉ុន្តែនាងអង្គុយសរសេរក្បែរយ៉ូសែបអស់រាប់ម៉ោង កាលលោកបានអានផ្ទាំងចំណារដោយគ្មានជំនួយពីសៀវភៅណា ឬសំណៅឯកសារដើមណានោះ ។ នាងដឹងយ៉ាងច្បាស់ថា មានតែព្រះទេដែលបំផុសលោកឲ្យបកប្រែដូចដែលលោកបានធ្វើនេះ ។[២៤]

ម៉ាទិន បានត្រឡប់មកពីភូមិបាល់ម៉ៃរ៉ាវិញទាន់ពេល ហើយធ្វើជាអ្នកសរសេរដើម្បីឲ្យអិមម៉ា បានសម្រាកពីមុនសម្រាលកូន ។[២៥] ប៉ុន្តែវាមិនបានកើតឡើងដោយងាយស្រួលទេ ។ លោកស្រីលូស៊ី ជាភរិយារបស់លោកម៉ាទិន បានសុំគាត់មកភូមិហាម៉ូនីជាមួយដែរ ហើយពួកគាត់ទាំងពីរនាក់មានបុគ្គលិកលក្ខណៈចចេះ ។[២៦] លោកស្រីលូស៊ី មានការសង្ស័យអំពីបំណងប្រាថ្នារបស់ម៉ាទិន ក្នុងការជួយផ្នែកហិរញ្ញវត្ថុដល់យ៉ូសែប ហើយមានការខឹងសម្បារដែលគាត់ចេញទៅក្រុង ញូវយ៉ក ដោយមិនឲ្យនាងទៅជាមួយ ។ នៅពេលគាត់ប្រាប់ដល់នាងថា គាត់ត្រូវទៅភូមិហាម៉ូនីដើម្បីជួយដល់ការបកប្រែ នោះនាងបានរៀបចំខ្លួនទៅដែរ ដោយបានតាំងចិត្តថាទៅមើលផ្ទាំងចំណារ ។

ត្រចៀករបស់លោកស្រីលូស៊ីស្ដាប់មិនសូវឮទេ ហើយនៅពេលនាងស្ដាប់គេនិយាយគ្នាមិនបាន ពេលខ្លះនាងគិតថា គេកំពុងរិះគន់ពីនាង ។ នាងក៏មិនសូវយល់ពីឯកជនភាពផងដែរ ។ បន្ទាប់ពីយ៉ូសែប បានបដិសេធមិនបង្ហាញផ្ទាំងចំណារ នោះនាងចាប់ផ្ដើមរុករកនៅក្នុងផ្ទះ ដោយរូសក្ដារលេងអុក ទូចាន និងហិបធំមួយរបស់គ្រួសារយ៉ូសែប ។ យ៉ូសែប គ្មានជម្រើសក៏លាក់ផ្ទាំងចំណារនៅក្នុងព្រៃ ។[២៧]

មិនយូរប៉ុន្មានលូស៊ីក៏ចេញពីផ្ទះ ទៅស្នាក់នៅជាមួយអ្នកជិតខាង ។ អិមម៉ា បានរៀបចំក្ដារអុក និងទូចានឡើងវិញ ប៉ុន្តែឥឡូវនេះ លូស៊ី បានប្រាប់អ្នកជិតខាងថា យ៉ូសែបមានបំណងចង់បានលុយរបស់ម៉ាទិន ។ បន្ទាប់ពីបង្កបញ្ហាអស់ជាច្រើនសប្ដាហ៍មក លូស៊ី បានត្រឡប់ទៅផ្ទះនៅភូមិបាល់ម៉ៃរ៉ាវិញ ។

ដោយមានភាពស្ងប់ស្ងាត់វិញ យ៉ូសែប និងម៉ាទិន បានបកប្រែបានលឿន ។ យ៉ូសែប បានរីកចម្រើនក្នុងតួនាទីដែលព្រះបានប្រទានឲ្យក្នុងនាមជាអ្នកមើលឆុត និងអ្នកទទួលវិវរណៈម្នាក់ ។ តាមរយៈការមើលប្រដាប់បកប្រែ ឬត្បូងមើលឆុត លោកអាចបកប្រែបាន ទោះបីជាផ្ទាំងចំណារនៅពីមុខលោក ឬរុំនៅក្នុងក្រណាត់នីទ្បុងរបស់អិមម៉ាដាក់នៅលើតុក្ដី ។[២៨]

នៅពេញខែ មេសា ខែ ឧសភា និងដើមខែ មិថុនា អិមម៉ា បានស្ដាប់សំឡេងនៃការហៅឲ្យសរសេរការបកប្រែមកពីកំណត់ត្រារបស់យ៉ូសែប ។[២៩] លោកបានមានប្រសាសន៍មួយៗ តែច្បាស់ ដោយផ្អាកម្ដងម្កាលដើម្បីរង់ចាំម៉ាទិន និយាយថា « សរសេររួចហើយ » បន្ទាប់ពី យ៉ូសែប បានហៅឲ្យសរសេរ ។[៣០] អិមម៉ា ក៏បានផ្លាស់វេនធ្វើជាអ្នកសរសេរ ហើយបានស្ងើចសរសើរយ៉ាងខ្លាំងថា រាល់ពេលក្រោយការខាន និងការសម្រាក យ៉ូសែប តែងតែដឹងថាត្រូវចាប់ផ្ដើមត្រង់ណា ដោយពុំចាំបាច់មានការប្រាប់ឡើយ ។[៣១]

មិនយូរប៉ុន្មាន ពេលវេលាដែលអិមម៉ា ត្រូវសម្រាលកូនក៏មកដល់ ។ អត្ថបទបកប្រែសំណៅដើមបានកើនឡើងក្រាស់ ហើយម៉ាទិន បានលង់ជឿថា

ប្រសិនបើគាត់អាចឲ្យភរិយាគាត់អានការបកប្រែនេះ នោះនាងនឹងបានឃើញ ពីតម្លៃនៃការបកប្រែនេះ និងឈប់បង្អាក់ការងាររបស់ពួកគាត់ទៀត ។[៣២] គាត់ក៏សង្ឃឹមដែរថា លូស៊ីនឹងរីករាយកាលដែលគាត់បានចំណាយពេលវេលា និងលុយដើម្បីជួយនាំនូវព្រះបន្ទូលរបស់ព្រះចេញមកនោះ ។

នៅថ្ងៃមួយ ម៉ាទិន បានសុំការអនុញ្ញាតពីយ៉ូសែបដើម្បីយកសំណៅដើមនេះទៅកាន់ភូមិបាល់ម៉ៃរាពីរបីសប្ដាហ៍ ។[៣៣] ដោយនៅចាំពីឥរិយាបថដែល លូស៊ី ហារិស បានធ្វើពេលដែលនាងបានមកលេងផ្ទះលោក នោះយ៉ូសែបប្រយ័ត្ននឹងការសុំនេះ ។ ប៉ុន្តែលោកចង់ឲ្យម៉ាទិនសប្បាយចិត្ត ព្រោះម៉ាទិនជាអ្នកដែលបានជឿដល់លោក ខណៈពេលដែលមានមនុស្សជាច្រើនមានការសង្ស័យលើពាក្យសម្ដីរបស់លោកនោះ ។[៣៤]

ដោយមិនប្រាកដថាត្រូវធ្វើដូចម្ដេច នោះយ៉ូសែប បានអធិស្ឋានសូមការណែនាំ ហើយព្រះអម្ចាស់បានមានបន្ទូលប្រាប់លោកថា កុំឲ្យម៉ាទិនយកឯកសារនេះទៅនោះឡើយ ។[៣៥] ប៉ុន្តែ ម៉ាទិនមានទំនុកចិត្តយ៉ាងខ្លាំងថា បើបានបង្ហាញដល់ភរិយារបស់គាត់ នោះរឿងអ្វីៗទាំងអស់នឹងផ្លាស់ប្ដូរ ហើយគាត់បានសុំអង្វរដល់យ៉ូសែបឲ្យទូលសួរព្រះម្ដងទៀត ។ យ៉ូសែប ក៏បានទូលសួរដល់ព្រះ ប៉ុន្តែចម្លើយនៅតែដដែល ។ ប៉ុន្តែម៉ាទិន បានទទូចសុំឲ្យគាត់ទៅទូលសួរព្រះជាលើកទីបី ហើយលើកនេះព្រះបានអនុញ្ញាតឲ្យពួកគាត់ធ្វើតាមពាក្យអង្វរ ។

យ៉ូសែប បានប្រាប់ម៉ាទិន ថាគាត់អាចយកឯកសារដែលបានបកប្រែួចនេះទៅតែក្នុងរយៈពេលពីរសប្ដាហ៍ទេ ប្រសិនបើគាត់សន្យាថា នឹងរក្សាវា ហើយចាក់សោទុក ហើយបង្ហាញវាតែទៅសមាជិកគ្រួសារមួយចំនួនប៉ុណ្ណោះ ។ ម៉ាទិនបានសន្យា ហើយក៏បានត្រឡប់ទៅភូមិបាល់ម៉ៃរាវិញ ដោយមានឯកសារបកប្រែនៅក្នុងដៃ ។[៣៦]



*ផ្ទះរបស់យ៉ូសែប និងអិមម៉ា ស្ម៊ីធនៅក្នុងទីក្រុងហាម៉ូនី រដ្ឋផេនស៊ីលវេញ៉ា ។*

បន្ទាប់ពីម៉ាទិនបានចាកចេញទៅ នោះមរ៉ូណៃ បានបង្ហាញព្រះកាយដល់យ៉ូសែប ហើយបានយកប្រដាប់បកប្រែពីលោក ។[៣៧]

ក្រោយម៉ាទិនចាកចេញទៅបានមួយថ្ងៃ អិមម៉ាឈឺពោះសម្រាលកូន ហើយកើតបានកូនប្រុស ។ ទារកនោះមានសភាពឈឺទន់ខ្សោយ ហើយក៏មិនមានជីវិតបានយូរឡើយ ។ បទពិសោធន៍ដ៏អាក្រក់នេះបានធ្វើឲ្យអិមម៉ា ចុះទន់ខ្សោយខាងរូបកាយ ហើយខូចសតិអារម្មណ៍ ហើយនៅពេលមួយនោះនាងស្ទើរនឹងស្លាប់ដែរ ។ យ៉ូសែបមើលថែនាងយ៉ាងខ្ជាប់ខ្ជួន មិនដែលទុកឲ្យនាងនៅតែម្នាក់ឯងយូរឡើយ ។[៣៨]

ពីរសប្ដាហ៍ក្រោយមក សុខភាពរបស់អិមម៉ាបានធូរស្រាល ហើយនាងបានគិតអំពីម៉ាទិន និងអត្ថបទបកប្រែនោះ ។ នាងបានប្រាប់យ៉ូសែប ថា « អូនមិនស្រណុកក្នុងចិត្តសោះ វាធ្វើឲ្យអូនមិនអាចសម្រាកបានឡើយ បើមិនបានដឹងថាលោកហារិស កំពុងធ្វើអ្វីជាមួយនឹងអត្ថបទដែលបានបកប្រែនោះ » ។

នាងបានជម្រុញយ៉ូសែបឲ្យទៅរកម៉ាទិន ប៉ុន្តែយ៉ូសែបមិនចង់ទៅចោលនាងឡើយ ។ នាងបាននិយាយថា « សូមប្រាប់ម្ដាយអូនឲ្យមកនៅជាមួយអូនមក ពេលដែលបងមិននៅ » ។[៣៩]

យ៉ូសែបបានជិះរទេះទៅទិសខាងជើង ។ កាលកំពុងធ្វើដំណើរនោះ លោកទទួលអាហារ និងសម្រាកបានតិចតួចណាស់ ដោយព្រួយបារម្ភថា នឹងធ្វើឲ្យព្រះអម្ចាស់ខកព្រះទ័យ ដោយការមិនស្ដាប់តាម នៅពេលទ្រង់មានបន្ទូលប្រាប់ថាកុំឲ្យម៉ាទិនយកអត្ថបទដែលបានបកប្រែនោះទៅ ។[៤០]

គាត់មកដល់ផ្ទះឪពុកម្ដាយនៅមេនឆែសស្ទើរនៅពេលព្រះអាទិត្យរះ ។ គ្រួសារស្ម៊ីធ កំពុងរៀបចំអាហារពេលព្រឹក ហើយបានអញ្ជើញម៉ាទិន ឲ្យចូលរួមជាមួយ ។ នៅម៉ោងប្រាំបីព្រឹក អាហារក៏រួចរាល់ដាក់នៅលើតុ ប៉ុន្តែមិនឃើញម៉ាទិនមកនោះទេ ។ យ៉ូសែប និងក្រុមគ្រួសារបានចាប់ផ្ដើមព្រួយបារម្ភកាលពួកគាត់រង់ចាំ ម៉ាទិននោះ ។

នៅទីបំផុត ក្រោយពីចាំអស់រយៈពេលបួនម៉ោងមក ម៉ាទិនបានបង្ហាញខ្លួនពីចម្ងាយ ដោយដើរយឺតៗសំដៅចូលមកក្នុងផ្ទះ ទាំងឈ្ងោកមុខចុះ ។[៤១] នៅពេលមកដល់ច្រកទ្វារ គាត់បានឈប់អង្គុយលើរបង ហើយទាញមួកមកបាំងមុខ ។ បន្ទាប់មក គាត់ក៏ដើរចូលក្នុងផ្ទះអង្គុយចុះបរិភោគដោយស្ងប់ស្ងាត់ ។

ក្រុមគ្រួសារទាំងមូលមើលទៅ ម៉ាទិន កាលគាត់ លើកស្លាបព្រាបម្រុងនឹងបរិភោគ រួចក៏ឈប់វិញ ។ គាត់បានស្រែកយំយកដៃផ្ទប់ក្បាលហើយនិយាយថា « ខ្ញុំបានបាត់ព្រលឹងអស់ហើយ ! » ។ « ខ្ញុំបានបាត់ព្រលឹងអស់ហើយ ! »

យ៉ូសែប ក៏ក្រោកឡើង ។ « ម៉ាទីន លោកបានធ្វើឲ្យបាត់អត្ថបទដែលបានបកប្រែនោះឬ ? »

ម៉ាទិន បាននិយាយថា « បាទ » ។ « វាបានបាត់ហើយ ហើយខ្ញុំពុំដឹងថាវានៅឯណាទេ » ។

យ៉ូសែប បាន ស្រែកយំ ដោយក្ដាប់ដៃយ៉ាងណែនថា « ឱ ព្រះអើយ ព្រះអើយ » ។ « បាត់អស់ហើយ ! »

លោកក៏ដើរចុះឡើង ។ លោកពុំដឹងថាត្រូវធ្វើយ៉ាងម៉េចទេ ។ លោកបានប្រាប់ម៉ាទិនថា « ត្រឡប់ទៅវិញ » ។ « ទៅរកមើលម្ដងទៀត » ។

ម៉ាទិន បានយំ « វាគ្មានប្រយោជន៍ទេ ។ ខ្ញុំបានរកមើលគ្រប់កន្លែងក្នុងផ្ទះខ្ញុំហើយ ។ ខ្ញុំថែមទាំងកម្ទេចគ្រែមួយចោល និងខ្នើយអស់ជាច្រើន ហើយខ្ញុំដឹងថាវាមិននៅទីនោះទេ » ។

« តើខ្ញុំត្រូវត្រឡប់ទៅជួបភរិយាខ្ញុំជាមួយនឹងរឿងដូច្នេះឬ ? » យ៉ូសែបបារម្ភថារឿងនេះនឹងសម្លាប់នាង ។ « ហើយតើខ្ញុំមានមុខឯណាទៅជួបនឹងព្រះអម្ចាស់នោះ ? »

ម្ដាយលោកព្យាយាមលួងលោមលោក ។ គាត់បានមានប្រសាសន៍ថា ប្រហែលជាព្រះអម្ចាស់នឹងអភ័យទោសឲ្យលោក ប្រសិនបើលោកប្រែចិត្តដោយរាបសានោះ ។ ប៉ុន្តែយ៉ូសែបកំពុងស្រែកទ្រហោយំយ៉ាងខ្លាំង ខឹងនឹងខ្លួនឯងដែលមិនបានគោរពតាមព្រះអម្ចាស់តាំងពីដំបូង ។ ពេញមួយថ្ងៃនោះ លោកមិនអាចបរិភោគអ្វីបានឡើយ ។ លោកបានស្នាក់នៅមួយយប់ លុះ ព្រឹកស្អែកឡើងក៏ត្រឡប់ទៅភូមិហាម៉ូនីវិញ ។[៤២]

កាលដែលលោកស្រីលូស៊ីមើលលោកចាកចេញទៅ ដួងចិត្តគាត់សោកសៅយ៉ាងខ្លាំង ។ វាហាក់ដូចជាអ្វីៗដែលគ្រួសារគាត់សង្ឃឹមនោះ — អ្វីៗដែលនាំសេចក្ដីរីករាយដល់ពួកគាត់អស់ជាច្រើនឆ្នាំមកនេះ — ត្រូវបានបាត់បង់តែក្នុងមួយពព្រិចភ្នែក ។[៤៣] ■

បញ្ជីទាំងស្រុងនៃសៀវភៅនេះមានជាភាសាអង់គ្លេសនៅគេហទំព័រ saints.lds.org ។

ពាក្យ ប្រធានបទ នៅក្នុងកំណត់ចំណាំបង្ហាញពីព័ត៌មានបន្ថែមនៅលើអ៊ិនធើរណែតនៅគេហទំព័រ saints.lds.org ។

**កំណត់ចំណាំ**

១. Joseph Smith — History ១:៥៩; Joseph Smith History ឆ្នាំ ១៨៣៦–៥៦ ភាគ A-១ ទំព័រ ៨នៅក្នុង *JSP,* H១:២៣៦–៣៨ ( សេចក្ដីព្រាង ២ ); Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៦ [ ១ ]–[ ២ ]; Knight, Reminiscences, ទំព័រ ៣ ។

២. Knight, Reminiscences, ទំព័រ ៣–៤; Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៦ [ ១ ]–[ ៣ ]; Joseph Smith History, ប្រហែលក្នុងរដូវក្ដៅ ឆ្នាំ ១៨៣២ ទំព័រ ១នៅក្នុង *JSP,* H១:១១ ។

៣. « Mormonism — No. II » *Tiffany's Monthly,* ខែ សីហា ឆ្នាំ ១៨៥៩ ទំព័រ ១៦៧–៦៨; Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៦ [ ៣ ]–[ ៤ ]; Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៨នៅក្នុង *JSP,* H១:២៣៨ ( សេចក្ដីពង្រាង ២ ) ។ **ប្រធានបទ ៖** Witnesses of the Book of Mormon

៤. « Mormonism — No. II » Tiffany's Monthly, ខែ សីហា ឆ្នាំ ១៨៥៩ ទំព័រ ១៦៨–៧០ ។

៥. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៨–៩នៅក្នុង *JSP,* H១:២៣៨ ( សេចក្ដីព្រាង ២ ); Knight, Reminiscences, ទំព័រ ៣; « Mormonism — No. II » Tiffany's Monthly ខែ សីហា ឆ្នាំ ១៨៥៩ ទំព័រ ១៧០ ។

៦. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៦ [ ៦ ]; Lucy Mack Smith, History ឆ្នាំ ១៨៤៥ ទំព័រ ១២១ ។

៧. « Mormonism — No. II » Tiffany's Monthly, ខែ សីហា ឆ្នាំ ១៨៥៩ ទំព័រ ១៧០ ។

៨. « Mormonism — No. II » Tiffany's Monthly ខែ សីហា ឆ្នាំ ១៨៥៩ ទំព័រ ១៧០; Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៩នៅក្នុង *JSP,* H១:២៤០ ( សេចក្ដីពង្រាង ២ ) ។

៩. Isaac Hale, Affidavit ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៨៣៤ នៅក្នុង « Mormonism » Susquehanna Register, and Northern Pennsylvanian *ថ្ងៃទី ១* ខែ ឧសភា ឆ្នាំ ១៨៣៤ [ ទំព័រ ១ ] ។

១០. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៩នៅក្នុង *JSP,* H១:២៤០ ( សេចក្ដីពង្រាង ២ ); Knight, Reminiscences, ទំព័រ ៣ ។

១១. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៦ [ ៣ ]; Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៩នៅក្នុង *JSP,* H១:២៤០ ( សេចក្ដីព្រាង ២ ); « Letter from Elder W. H. Kelley » *Saints' Herald,* ថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៨៨២ ទំព័រ ៦៨, សូមមើលផងដែរ គោលលទ្ធិ និងសេចក្ដីសញ្ញា ៩:៧–៨ ( Revelation ខែ មេសា ឆ្នាំ ១៨២៩–Dមាននៅលើគេហទំព័រ josephsmithpapers.org ) ។

១២. Joseph Smith History, circa Summer ឆ្នាំ ១៨៣២ ទំព័រ ៥នៅក្នុង *JSP,* H១:១៥; Knight, Reminiscences, ទំព័រ ៣។ **ទំព័រ ៖** Book of Mormon Translation.

១៣. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ វ៉ុល A-១ ទំព័រ ៩ នៅក្នុង *JSP,* H១:២៣៨–៤០ ( សេចក្ដីព្រាង ២ ), Joseph Smith History, ប្រហែលក្នុងរដូវក្ដៅ ឆ្នាំ ១៨៣២ ទំព័រ ៥ នៅក្នុង *JSP,* H១:១៥ ។

១៤. ម៉ាកឃេ « Git Them Translated » ទំព័រ ៩៨–១០០ ។

១៥. Bennett, « Read This I Pray Thee » ទំព័រ ១៩២ ។

១៦. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៩នៅក្នុង *JSP,* H១:២៤០ ( សេចក្ដីព្រាង ២ ); Bennett, Journal ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៨៣១ នៅក្នុង Arrington « James Gordon Bennett's 1831 Report on 'The Mormonites » ទំព័រ ៣៥៥ ។

១៧. [ James Gordon Bennett ] « Mormon Religion — Clerical Ambition — Western New York — the Mormonites Gone to Ohio » *Morning Courier and New-York Enquirer,* ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ១៨៣១ [ ទំព័រ ២ ]។

១៨. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៩នៅក្នុង *JSP,* H១:២៤០–៤២ ( សេចក្ដីពង្រាង ២ ); Jennings « Charles Anthon » ទំព័រ ១៧១–៨៧; Bennett « Read This I Pray Thee » ទំព័រ ១៧៨–២១៦ ។

១៩. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៩នៅក្នុង *JSP,* H១:២៤៤ ( សេចក្ដីពង្រាង ២ ); Bennett, Journal ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៨៣១ នៅក្នុង Arrington « James Gordon Bennett's ១៨៣១ Report on ‹ The Mormonites › » ទំព័រ ៣៥៥; Knight, Reminiscences, ទំព័រ ៤។ **ប្រធានបទ ៖** Martin Harris's Consultations with Scholars.

២០. Joseph Smith History, circa Summer ១៨៣២ ទំព័រ ៥នៅក្នុង *JSP*, H១:១៥; អេសាយ ២៩:១១–១២; នីហ្វៃទី ២ ២៧:១៥–១៩។

២១. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៦ [ទំព័រ ៨]; Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៩នៅក្នុង *JSP,* H១:២៤៤; Joseph Smith III « Last Testimony of Sister Emma » Saints' Herald, ថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៨៧៩ ទំព័រ ២៨៩–៩០ ។

២២. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៩នៅក្នុង *JSP,* H១:២៤៤ ( សេចក្ដីព្រាង ២ ); Isaac Hale, Affidavit ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៨៣៤ នៅក្នុង « Mormonism » *Susquehanna Register, and Northern Pennsylvanian,* ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ១៨៣៤ [ ទំព័រ ១ ] ; Agreement with Isaac Hale ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨២៩នៅក្នុង *JSP,* D១:២៨–៣៤ ។

២៣. Briggs « A Visit to Nauvoo in 1856 » ទំព័រ ៤៥៤; សូមមើលផងដែរ Edmund C. Briggs to Joseph Smith ថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ១៨៨៤ Saints' Herald ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៨៨៤ ទំព័រ ៣៩៦ ។

២៤. Joseph Smith III « Last Testimony of Sister Emma," *Saints' Herald* ថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៨៧៩ ទំព័រ ២៨៩–៩០; Briggs « A Visit to Nauvoo in 1856 » ទំព័រ ៤៥៤ ។

២៥. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៩នៅក្នុង *JSP,* H១:២៤៤ ( សេចក្ដីព្រាង ២ ); Isaac Hale, Affidavit ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៨៤៣ នៅក្នុង « Mormonism » Susquehanna Register, and Northern Pennsylvanian *ថ្ងៃទី ១* ខែ ឧសភា ឆ្នាំ ១៨៣៤ [ ទំព័រ ១ ] ។

២៦. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៦ [ ទំព័រ ៨ ] ។

២៧. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៦ ទំព័រ [ ៣ ]–[ ៥] , [ ៨ ]–[ ៩ ] ។

២៨. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៦, ទំព័រ [ ៩ ]–[ ១០ ] ; Joseph Smith III « Last Testimony of Sister Emma » Saints' Herald ថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៨៧៩ ទំព័រ ២៨៩–៩០ ។

២៩. នៅក្នុងការសំណេះសំណាលមួយ អិមម៉ា ស្ម៊ីធ បាននិយាយថា នាងបានធ្វើការនៅក្នុងបន្ទប់ជាមួយគ្នានឹងយ៉ូសែប និងអូលីវើរ ខៅឌើរី ខណៈពួកគាត់កំពុងបំពេញការងារបកប្រែនៅក្នុងឆ្នាំ ១៨២៩ ហើយគាត់ក៏មានវត្តមានដូចគ្នានៅក្នុងការបកប្រែរបស់យ៉ូសែប និងម៉ាទិននៅក្នុងឆ្នាំ ១៨២៩ ផងដែរ ។ ( Joseph Smith III « Last Testimony of Sister Emma » Saints' Herald ថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៨៧៩ ទំព័រ ២៩០ ) ។

៣០. William Pilkington, Affidavit, Cache County, UT, ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៩៣៤នៅក្នុង William Pilkington, Autobiography and Statements, Church History Library; « One of the Three Witnesses » Deseret News, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៨៨១ ទំព័រ ១០ ។

៣១. Briggs « A Visit to Nauvoo in 1856 » ៤៥៦; Joseph Smith III « Last Testimony of Sister Emma » *Saints' Herald* ថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៨៧៩ ទំព័រ ២៨៩–៩០ ។

៣២. សូមមើល Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៦ [ ទំព័រ ១០ ]; Joseph Smith History ឆ្នាំ ១៨៣៦–៥៦ ភាគ A-១ ទំព័រ ៩នៅក្នុង *JSP,* H១:២៤៤; Joseph Smith History, ប្រហែលរដូវក្ដៅ ឆ្នាំ ១៨៣២ ទំព័រ ៥នៅក្នុង *JSP,* H១:១៥; Knight, Reminiscences, ទំព័រ ៥; and Historical Introduction to Preface to the Book of Mormon, ប្រហែលនៅខែ សីហា ឆ្នាំ ១៨២៩នៅក្នុង *JSP,* D១:៩២–៩៣ ។

៣៣. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៩នៅក្នុង *JSP,* H១:២៤៤ ( សេចក្ដីព្រាង ២ ); Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៦ [ទំព័រ ១០]។

៣៤. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៦ ទំព័រ [១០ ]–[ ១ ] ; សៀវភៅ ៧, [ ទំព័រ ១ ] ។.

៣៥. Joseph Smith History, ប្រហែលក្នុងរដូវក្ដៅ ឆ្នាំ ១៨៣២ ទំព័រ ៥នៅក្នុង *JSP,* H១:១៥ ។

៣៦. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៩–១០នៅក្នុង *JSP,* H១:២៤៤–៤៦ ( សេចក្ដីព្រាង ២ ); Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៧ [ ទំព័រ ១ ] ; Knight, Reminiscences, ទំព័រ ៥។

៣៧. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៩–១០នៅក្នុង *JSP,* H១:២៤៤–៤៦ ( សេចក្ដីព្រាង ២ ) ។

៣៨. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៧ ទំព័រ [ ១ ]–[ ២ ] ។ **ប្រធានបទ ៖** Joseph and Emma Hale Smith Family

៣៩. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៧ ទំព័រ [ ១ ]–[ ២ ] ។

៤០. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៧ ទំព័រ [ ២ ]–[ ៤ ] ។

៤១. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៧ ទំព័រ [ ៥ ] ។

៤២. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៧ ទំព័រ [ ៥ ]–[ ៧ ] ។ **ប្រធានបទ ៖** Lost Manuscript of the Book of Mormon

៤៣. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៧ ទំព័រ [ ៧ ] ។ **ប្រធានបទ ៖** Lucy Mack Smith.

# របៀបដែលយើងបានជោគជ័យ
# ក្នុងការចែកចាយដំណឹងល្អ

*ក្នុងនាមជាអ្នកប្រែចិត្តជឿថ្មី ភរិយារបស់ខ្ញុំ និងខ្ញុំពុំបានដឹងច្រើនអំពីរបៀបធ្វើជាអ្នកផ្សព្វផ្សាយសាសនាឡើយ ។ ប៉ុន្តែយើងដាក់គោលដៅដើម្បីចែកចាយជាមួយមនុស្ស ១០០ នាក់ ។*

**ដោយ ណេវើរ ឈីខុនហ្គូវ៉ូ**
អ្នកប្រឹក្សាខាងពង្សប្រវត្តិ ប្រទេស ស៊ីមបាវ៉េ

ភរិយារបស់ខ្ញុំ អេវើរចយ ហើយនិងខ្ញុំមកពីទីក្រុងតូចមួយនៃ ម៉ូតែរ នៅព្រំដែនភាគខាងកើតរបស់ប្រទេសស៊ីមបាវ៉េ ។ មិនយូរប៉ុន្មានបន្ទាប់ពីយើងបានទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់រួច នោះយើងមានចិត្តរំភើបក្នុងការធ្វើកិច្ចការផ្សព្វផ្សាយសាសនា ។ យើងបានអានថា « ស្រែសសំព្រុះល្មមច្រូតហើយ » ( គ. និង ស. ៣៣:៧ ) ហើយទោះបីជាយើងពុំដឹងច្រើនអំពីរបៀបធ្វើជាអ្នកផ្សព្វផ្សាយសាសនាក្តី ក៏យើងបានសម្រេចចិត្តថា យើងត្រូវតែ « លូកកណ្ដៀវ [ របស់យើង ] ហើយច្រូតដោយអស់ពីពលំ អស់ពីគំនិត និងអស់ពីកម្លាំង [ របស់យើង ] » ដែរ ។


*ណេវើរ និង អេវើរចយ ឈីខុនហ្គូវ៉ូ*

យើងគឺជាសមាជិកនៃសាខា ដែងហ្គាម្វ៉ារ៉ាដែលទើបនឹងបង្កើតថ្មី មានទីតាំងនៅក្នុងទីក្រុងមួយនៃ ម៉ូតែរ ។ នៅគ្រានោះកាលឆ្នាំ ១៩៩១ សាខាមានសមាជិក ២៥ នាក់ ។ មិនយូរប៉ុន្មានក្រោយមក យើងត្រូវបានហៅឲ្យធ្វើជាអ្នកផ្សព្វផ្សាយសាសនាប្រចាំសាខា ។ យើងបានរៀនយ៉ាងច្រើនពីអ្នកផ្សព្វផ្សាយសាសនាស្វាមីភរិយារៀមច្បងដែលបម្រើនៅក្នុងតំបន់របស់យើង ។ យោបល់មួយដែលពួកគាត់បានផ្តល់ឲ្យនោះគឺថា យើងត្រូវដាក់គោលដៅ ។

យើងចង់ចែកចាយដំណឹងល្អជាមួយមនុស្សគ្រប់រូប ដូច្នេះយើងបានដាក់គោលដៅចែកចាយវាជាមួយនឹងមនុស្ស ១០០ នាក់ អំឡុងឆ្នាំដំបូងដែលយើងគឺជាអ្នកផ្សព្វផ្សាយសាសនាក្នុងសាខានោះ ។ យើងប្រហែលជាខ្វះបទពិសោធន៍ ប៉ុន្តែវាហាក់ដូចជាពិតប្រាកដចំពោះយើង ។ យើងបានទុកចិត្តថា ព្រះអម្ចាស់នឹងជួយយើង ។

តាមរយៈការច្រៀងទំនុកតម្កើងនៅក្នុងការប្រជុំនៅព្រះវិហារ យើងបានឃើញថា យើងមានទេពកោលស្យផ្នែកតន្ត្រីដែលយើងពុំបានដឹងពីមុនមក ។ យើងបានសម្រេចចិត្តប្រើប្រាស់ទេពកោសល្យរបស់យើង ដូច្នេះយើងបានចាប់ផ្តើមច្រៀងឲ្យមនុស្សស្តាប់ — និងច្រៀងជាមួយ — មនុស្សដែលបានបង្ហាញចំណាប់អារម្មណ៍នៅក្នុងដំណឹងល្អ នៅពេលយើងបានជួបបង្រៀនពួកគេ ។ ព្រះវិញ្ញាណបានគង់នៅជាមួយយើងពេលយើងច្រៀងចម្រៀងដ៏ពិសិដ្ឋ ហើយទ្រង់បានរំជួលដួងចិត្តនៃអស់អ្នកដែលយើងកំពុងបង្រៀន ។ សារលិខិតនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញក៏បានធ្វើឲ្យពួកគេរំជួលចិត្តផងដែរ ។ យើងបានលើកទឹកចិត្តមនុស្សគ្រប់គ្នាឲ្យចូលរួមក្រុមចម្រៀងនៃសាខារបស់យើង ហើយមនុស្សជាច្រើនបានចូលរួម ទាំងពួកបរិសុទ្ធថ្ងៃចុងក្រោយ ឬមិនមែនក្តី ។ នៅពេលមនុស្សកាន់តែច្រើនបានរៀនអំពីដំណឹងល្អ នោះមនុស្សជាច្រើនបានចូលទៅក្នុងទឹកនៃពិធីបុណ្យជ្រមុជទឹកផងដែរ ។

នៅពេលយើងបន្តកិច្ចខិតខំផ្សព្វផ្សាយសាសនារបស់យើង នោះយើងបានបន្តតមអាហារ និងអធិស្ឋានសម្រាប់ក្រុមគ្រួសារដែលបានចូលសាសនាចក្រ ។ យើងមានអារម្មណ៍ថា មនុស្សដទៃនៅក្នុងសហគមន៍កំពុងមើលគំរូដ៏សុចរិតនៃក្រុមគ្រួសារទាំងនេះ ។ យើងបានទទួលការអញ្ជើញកាន់តែច្រើនឲ្យបង្រៀនក្រុមគ្រួសារ ហើយការបង្រៀនរបស់យើងពោរពេញដោយអ្នកដែលនឹងត្រៀមធ្វើជាសមាជិក ។

ជាលទ្ធផលនៃការរៀនសូត្រ និងការរស់នៅតាមដំណឹងល្អ គូស្វាមីភរិយាដែលបានជ្រមុជទឹកថ្មោងថ្មីនោះបានប្រែកាន់តែស្និទ្ធស្នាល ហើយកាន់តែមានក្តីស្រឡាញ់ ។ ពួកឪពុកម្តាយអាចទម្លាក់ចោលនូវប្រពៃណីនានា ដែលពុំស្របទៅនឹងវប្បធម៌របស់ដំណឹងល្អ ។ ពួកគេបានឈប់ប្រើប្រាស់គ្រឿងស្រវឹង និងថ្នាំជក់ ។ ពួកគេបានបង្រៀនកូនៗខ្លួននូវគោលការណ៍ដ៏ត្រឹមត្រូវទាំងឡាយ ។ មនុស្ស



ជាច្រើនដែលធ្លាប់បានផ្តោតយ៉ាងលើសលុបទៅលើរឿងខាងលោកិយកាលពីមុន ឥឡូវនេះអាចទទួលយកការហៅនៅក្នុងសាសនាចក្រ ។ ពួកគេបានក្លាយជាពរជ័យសម្រាប់សាខា *និង* សហគមន៍របស់ពួកគេ ។ ព្រះហស្តរបស់ព្រះអម្ចាស់បាននាំមកនូវការផ្លាស់ប្តូរដ៏ខ្លាំងដល់ជីវិតរបស់ពួកគេ ។

ទោះបីជាការបៀតបៀនដ៏ធំបានកើតឡើងនៅ ម៉ូផែរនៅគ្រានោះក្តី ក៏វាពុំបានបញ្ឈប់ការរីកចម្រើនរបស់សាសនាចក្រឡើយ ។ វាទំនងថា នៅពេលការប្រឆាំងបានកើនឡើង នោះចំនួនមនុស្សដែលចង់រៀនអំពីសាសនាចក្រក៏កើនឡើងផងដែរ ។ ឧទាហរណ៍ នៅពេលមនុស្សពីកងទ័ពជាតិបានមកដោយបន្លំខ្លួន ដើម្បីស៊ើបអង្កេតពីសាសនាចក្រក្នុងការធ្វើខុសឆ្គង នោះព្រះវិញ្ញាណបានធ្វើឲ្យពួកគេរំជួលចិត្ត ។ ក្រោយមកមនុស្សជាច្រើនបានជ្រមុជទឹក និងត្រូវបានតែងតាំងឲ្យទទួលបានបព្វជិតភាព ។

ជាមួយនឹងជំនួយរបស់ព្រះអម្ចាស់ យើងបានចែកចាយដំណឹងល្អជាមួយមនុស្សកាន់តែច្រើនលើសពីគោលដៅដំបូងរបស់យើងទៅទៀត ។ ដោយសារយើងមានឆន្ទៈស្វែងរកមធ្យោបាយនានាដែលយើងអាចឈោងទៅដល់មនុស្សដទៃ នោះយើងអាចឃើញការផ្លាស់ប្តូរដ៏ធំនៅក្នុងជីវិតមនុស្សជាច្រើននៅក្នុងសហគមន៍យើងទាំងមូល ។ ■

*កំណត់ចំណាំរបស់អ្នកបោះពុម្ពផ្សាយ ៖ ការរីកចម្រើនដ៏លឿននៃសាខា ដេងហ្គាមវ៉ូរ៉ា មិនយូរប៉ុន្មានក្រោយមកបាននាំទៅរកការសាងសង់សាលាជំនុំមួយ ។ កិច្ចខិតខំរបស់អ្នកផ្សព្វផ្សាយសាសនាបានរីកសុះសាយទៅតំបន់បន្ថែមទៀត ហើយនៅក្នុងឆ្នាំ ១៩៩៥ ម៉ូផែរត្រូវបានរៀបចំទៅជាមណ្ឌលមួយដែលមានសាខាចំនួនប្រាំបី ។*

រចនារូបភាពដោយ អូរីអុល វីដាល



# ចូរយើងកុំបរាជ័យក្នុងការទទួលអារម្មណ៍



**ដោយអែលឌើរ**
**ហ៊ីរហេ អេហ្វ ស្បៃបាលូស**
ក្នុងពួកចិតសិបនាក់

*មានកម្លាំងមួយដែលមានថាមពលខ្លាំងជាងការរញ្ជួយដី ខ្យល់ព្យុះកំណាច ឬភ្លើងឆេះដ៏សន្ធោរសន្ធៅទៅទៀត ។ ប៉ុន្តែវាគឺជាសំឡេងដ៏តូចរហៀង ហើយយើងត្រូវយកចិត្តទុកដាក់ ប្រសិនបើយើងចង់ឲ្យទ្រង់ដឹកនាំយើង ។*

នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១០ នៅម៉ោង ៣:៣៤ ព្រឹក ការរញ្ជួយដីមួយដែលមានកម្លាំង ៨.៨ រិចទ័រ ក្នុងរង្វាស់ទំហំមាត្រដ្ឋានដែលបានធ្វើឲ្យប្រទេសឈីលីញ័ររញ្ជួយយ៉ាងខ្លាំងបណ្ដាលឲ្យមានការស្លន់ស្លោរ ភ័យខ្លាច និងខ្វល់ខ្វាយនៅក្នុងចំណោមមនុស្សរាប់លាននាក់ ។

ពីរបីថ្ងៃក្រោយមក ខ្ញុំត្រូវបានចាត់ឲ្យទៅធ្វើជាអធិបតីលើសន្និសីទស្តេកមួយនៅតំបន់ដែលជិតនឹងកន្លែងដែលមានការរញ្ជួយដីដ៏ខ្លាំងនោះ ។ ខ្ញុំបានសង្ស័យប្រសិនបើការរញ្ជួយដី និងការរញ្ជួយបន្ទាប់មកទៀតនោះនឹងប៉ះពាល់ដល់វត្តមានចូលរួមនៅសន្និសីទនោះ ។ ខ្ញុំមានការភ្ញាក់ផ្អើលណាស់ នៅពេលវត្តមានចូលរួមនៅវគ្គនីមួយនៃសន្និសីទមានច្រើនជាងសន្និសីទមុនៗ ។

តាមមើលទៅ ការរញ្ជួយដីបានរំឭកសមាជិកស្តេក យ៉ាងហោចណាស់ជាបណ្ដោះអាសន្នអំពីសារៈសំខាន់នៃការខិតទៅជិតព្រះ ការញែកថ្ងៃឈប់សម្រាកឲ្យបានបរិសុទ្ធ និងការចូលរួមការប្រជុំនានា ។ ជាច្រើនសប្ដាហ៍ក្រោយមក ខ្ញុំបានទូរសព្ទទៅប្រធានស្តេក ។ ខ្ញុំបានសួរប្រសិនបើវត្តមានចូលរួមនៅការប្រជុំនៅព្រះវិហារនៅតែមានកម្រិតខ្ពស់ ។ គាត់បានតបថា ដូចជាចំនួន និងទំហំមាត្រដ្ឋានបន្ទាប់ពីការរញ្ជួយដីបានធ្លាក់ចុះ នោះចំនួនវត្តមានចូលរួមនៅព្រះវិហារក៏ចុះផងដែរ ។

ឥរិយាបថស្រដៀងគ្នានេះកើតឡើងដូចទៅនឹងព្រឹត្តិការណ៍ដ៏សោកសៅដែលបានបំផ្លាញ មជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោកនៅទីក្រុង នូវ យ៉ោក ស.រ.អា. ក្នុងខែ កញ្ញា ឆ្នាំ ២០០១ ដែរ ។ មនុស្សរាប់ពាន់នាក់បានបែរទៅរកព្រះវិហាររបស់ពួកគេដើម្បីស្វែងរកភាពសុខសាន្តនៃគំនិត និងការលួងលោមដែលពួកគេត្រូវការយ៉ាងខ្លាំង ។ ប៉ុន្តែនៅពេលពេលវេលាកន្លងផុតទៅ ការស្វែងរកនោះបានមានតិចទៅៗ ហើយអ្វីៗបានត្រឡប់ទៅរកភាពប្រក្រតីវិញ ។ មិនថាវាកើតដោយសារធម្មជាតិ ឬដោយសារមនុស្សធ្វើនោះទេ វាពុំមែនមកពីការរញ្ជួយដី ព្យុះ ឬគ្រោះធម្មជាតិ និងសោកនាដកម្មនោះទេដែលវាបង្កើននូវសេចក្ដីជំនឿ ទីបន្ទាល់ និងការប្រែចិត្តជឿដ៏យូរអង្វែងនោះ ។

**អេលីយ៉ា និងសំឡេងតូចរហៀង**

នៅក្នុងជំនាន់របស់ព្យាការីអេលីយ៉ា អ័ហាប់គឺជាស្តេចសាសន៍អ៊ីស្រាអែល ។ អ័ហាប់បានរៀបអភិសេកជាមួយយេសិបិល ដែលជាម្ចាស់ក្សត្រីហ្វូនីសៀនមួយអង្គ ។ ព្រះនាងបានណែនាំពួកសាសន៍អ៊ីស្រាអែលនូវរបៀបនានារបស់សាសន៍ហ្វូនីសៀន រួមទាំងការថ្វាយបង្គំរូបសំណាកផងដែរ ។ បន្ទាប់ពីអេលីយ៉ាបានអញ្ជើញ និងយកឈ្នះលើពួកសង្ឃនៃព្រះបាល ដែលមានច្រើនសន្ធឹកនៅក្នុងចៅក្រមរបស់ស្តេចអ័ហាប់ នោះយេសិបិលបានគំរាមកំហែងយកជីវិតរបស់ព្យាការី ហើយលោកបានរត់គេចខ្លួនចូលទៅក្នុងទីរហោស្ថាន ។ ( សូមមើល ពង្សាវតារក្សត្រ ទី ១ ១៨:៤, ១៣, ១៩, ២១–៤០; ១៩:១–៤ ) ។

បន្ទាប់ពីទទួលបានអាហារពីទេវតាមួយអង្គនៅក្នុងទីរហោស្ថានមក អេលីយ៉ាបានដើរអស់រយៈពេល ៤០ យប់ ៤០ ថ្ងៃ ទៅកាន់ភ្នំហោរែប ( សូមមើល ពង្សាវតារក្សត្រ ទី ១ ១៩:៥–៨ ) ។ នៅក្នុងទីរហោស្ថាន ព្រះអង្គម្ចាស់បានមានបន្ទូលមកកាន់អេលីយ៉ា ។ លោកត្រូវបានប្រាប់ឲ្យចេញពីរូងភ្នំជាកន្លែងដែលលោកបានសម្រាកនៅទីនោះអស់មួយយប់ ។ នៅពេលលោកឈរលើភ្នំនៅចំពោះព្រះភក្ត្ររបស់ព្រះអម្ចាស់ « មានខ្យល់ព្យុះគំហុកជាខ្លាំង » បោកបក់មក ដែលមានកម្លាំងធ្វើឲ្យបែកថ្ម និងភ្នំខ្ទេចខ្ទី « តែព្រះអម្ចាស់មិនមែនគង់នៅក្នុងខ្យល់នោះទេ » ។ បន្ទាប់មកមានរញ្ជួយដីមួយ « តែព្រះអម្ចាស់មិនមែនគង់នៅក្នុងការកក្រើកដីនោះទេ » ។ បន្ទាប់មកមានភ្លើងឆេះ « តែព្រះអម្ចាស់មិនមែនគង់នៅក្នុងភ្លើងឆេះនោះទេ »



( ពង្សាវតារក្សត្រ ទី ១ ១៩:១១–១២ ) ។ ថ្វីបើមានខ្យល់បក់គំហុក ផែនដីរញ្ជួយញាប់ញ័រ និងភ្លើងឆេះសន្ធោសន្ធៅក្តី ក៏វាពុំមែនជាការបង្ហាញអំពីសំឡេងរបស់ព្រះអម្ចាស់ថ្លែងទៅកាន់ព្យាការីឡើយ ។

បន្ទាប់ពីកម្លាំងទាំងនេះដែលបង្ហាញអំពីថាមពលនៃធម្មជាតិមក « សំឡេងតូចរហៀងៗ » បានឮឡើងដល់អេលីយ៉ា ហើយលោកបានស្តាប់ឮសំឡេងនោះ ( សូមមើល ពង្សាវតារក្សត្រ ទី ១ ១៩:១២–១៣ ) ។ សំឡេងដ៏ស្រទន់របស់ព្រះអម្ចាស់បានប្រាប់លោកអំពីអ្នកដែលត្រូវលាបប្រេងតាំងធ្វើជាស្តេចបន្ទាប់របស់ស្រុកស៊ីរី ជាអ្នកដែលត្រូវធ្វើជាស្តេចបន្ទាប់របស់ពួកសាសន៍អ៊ីស្រាអែល ហើយថាគាត់ត្រូវលាបប្រេងតាំងអេលីសេឲ្យធ្វើជាព្យាការីដែលនឹងស្នងតំណែងពីលោក ។

## ការស្វែងរកសំឡេង

សំឡេងដូចគ្នាដែលកើតឡើងចំពោះអេលីយ៉ានោះ — សំឡេងដែលប្រាប់គាត់អំពីអ្វីដែលត្រូវធ្វើក្នុងគ្រាលំបាកនៅក្នុងជីវិត និងការបម្រើរបស់លោក — គឺនៅតែកើតមានដល់បុត្រាបុត្រីគ្រប់រូបរបស់ព្រះ ដែលចង់ធ្វើតាមព្រះទ័យរបស់ព្រះវរបិតាដោយស្មោះសរ ។ ប៉ុន្តែនៅកណ្តាលនៃសំឡេងទ្រហឹងអឺងកង សំឡេងនៃពិភពលោកដែលអញ្ជើញយើងឲ្យធ្វើដំណើរនៅលើផ្លូវងងឹត និងច្របូកច្របល់នេះ ជាកន្លែងដែលយើងអាចរកឃើញសំឡេងតូចរហៀងៗ ដែលនឹងប្រាប់យើងនូវអ្វីដែលត្រូវធ្វើ អ្វីដែលត្រូវនិយាយ និងអ្វីដែលព្រះសព្វព្រះទ័យឲ្យយើងប្រែក្លាយ ?

នីហ្វៃបានទូន្មានយើងឲ្យ « ទទួលទាននូវព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ ដ្បិតមើលចុះ ព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ នឹងប្រាប់ដល់អ្នកនូវគ្រប់អ្វីទាំងអស់ដែលអ្នកត្រូវធ្វើ » ( នីហ្វៃទី ២ ៣២:៣ ) ។

តើយើងអាចរកឃើញព្រះបន្ទូលនៃព្រះគ្រីស្ទនៅឯណា ដើម្បីយើងអាចទទួលទានព្រះបន្ទូលទាំងនោះ ? យើងអាចអានព្រះគម្ពីរ ជាពិសេសព្រះគម្ពីរមរមន ដែលបានសរសេរឡើង និងរក្សាទុកនៅភាពបរិសុទ្ធរបស់វាសម្រាប់ពួកយើង ដែលជាប្រជាជននៃជំនាន់នេះ ។ យើងក៏ត្រូវស្តាប់តាមប្រសាសន៍របស់ពួកព្យាការីសម័យទំនើប ដែលប្រាប់យើងអំពីព្រះទ័យរបស់ព្រះវរបិតាដ៏អស់កល្បជានិច្ច និងព្រះអង្គសង្គ្រោះរបស់យើងគឺព្រះយេស៊ូវគ្រីស្ទសម្រាប់សព្វថ្ងៃនេះផងដែរ ។

ប្រសាសន៍របស់ព្យាការីនៅរស់ដឹកនាំយើង នៅពេលយើងជួបប្រទះនឹងឧបសគ្គថ្មីៗ និងស្មុគស្មាញទាំងឡាយ ។ ឧទាហរណ៍ នៅប៉ុន្មានឆ្នាំថ្មីៗកន្លងមកនេះ ខណៈដែលការរីករាលដាលនៃការយល់ច្រឡំអំពីពិភពលោក និងទស្សនៈរបស់ពិភពលោកដែលបានព្យាយាមផ្លាស់ប្តូរគោលគំនិតនៃអាពាហ៍ពិពាហ៍ និងក្រុមគ្រួសារជាអចិន្ត្រៃយ៍ នោះប្រសាសន៍របស់ពួកព្យាការីបានគូសបញ្ជាក់យ៉ាងម៉ឺងម៉ាត់ អង់អាច និងពេញដោយក្តីស្រឡាញ់ទៅលើលក្ខណៈពិសិដ្ឋនៃក្រុមគ្រួសារ ដោយប្រកាសថា « អាពាហ៍ពិពាហ៍រវាងបុរស និង ស្ត្រីគឺត្រូវបានតែងតាំងឡើងដោយព្រះ ហើយថាគ្រួសារជាផ្នែកដ៏សំខាន់មួយនៅក្នុងផែនការរបស់ព្រះដ៏បង្កបង្កើតសម្រាប់គោលដៅដ៏នៅអស់កល្បជានិច្ចនៃកូនចៅរបស់ទ្រង់ » ។[១]

ពួកព្យាការី និងពួកសាវកបច្ចុប្បន្ននេះក៏បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការគោរពថ្ងៃឈប់សម្រាកទាំងនៅផ្ទះ និងនៅព្រះវិហារ និងការសម្រេចឲ្យបាននូវសេចក្តីសង្គ្រោះដល់ជីដូនជីតារបស់យើងតាមរយៈកិច្ចការពង្សប្រវត្តិ និងព្រះវិហារបរិសុទ្ធផងដែរ ។ នៅក្នុងគ្រប់សន្និសីទទូទៅ ពួកលោកផ្តល់ការដឹកនាំខាងវិញ្ញាណបន្ថែមទៀតដល់សមាជិកសាសនាចក្រ ។

## ព្រះវិញ្ញាណបរិសុទ្ធនឹងដឹកនាំអ្នក

នីហ្វៃបានបង្រៀនទៀតថា « បើសិនជាអ្នករាល់គ្នា នឹងចូលទៅតាមផ្លូវនោះ ហើយទទួលព្រះវិញ្ញាណបរិសុទ្ធ នោះព្រះវិញ្ញាណបរិសុទ្ធនឹងបង្ហាញដល់អ្នក នូវគ្រប់អ្វីទាំងអស់ដែលអ្នកត្រូវធ្វើ » ( នីហ្វៃទី ២ ៣២:៥ ) ។ ដូច្នេះការពង្រឹងដល់សារៈសំខាន់នៃការស្វែងរកព្រះបន្ទូលនៃព្រះគ្រីស្ទ ឥឡូវនេះនីហ្វៃណែនាំយើងអំពីទំនាក់ទំនងផ្ទាល់ដោយផ្ទាល់ខ្លួន ដែលយើងត្រូវតែមានជាមួយព្រះវិញ្ញាណ ដែលជាសមាជិកទីបីនៃក្រុមព្រះ ។

នីហ្វៃបានដឹងយ៉ាងច្បាស់អំពីអ្វីដែលលោកបានថ្លែង ។ ប្រមាណជា ៣០ ឬ ៤០ ឆ្នាំមុននោះ កាលគ្រួសាររបស់លោកកំពុងនៅទីរហោស្ថាន ហើយលោកកំពុង



សង់សំពៅដែលនឹងនាំពួកគេទៅកាន់ដែនដីសន្យា នោះនីហ្វៃបានស្ដីបន្ទោសបងៗរបស់លោកចំពោះការចោទសួរនានា ទោះបីជាបន្ទាប់ពីបានឮសំឡេងនៃទេវតាក្ដី ។

នីហ្វៃបានថ្លែងទៅកាន់ពួកគេថា « បងរាល់គ្នារហ័សធ្វើអំពើទុច្ចរិតណាស់ ប៉ុន្តែកម្រនឹកចាំដល់ព្រះអម្ចាស់ជាព្រះរបស់បង ។ បងរាល់គ្នាបានឃើញទេវតា ហើយទេវតានោះបាននិយាយជាមួយនឹងបងរាល់គ្នា មែនហើយ បងរាល់គ្នាបានឮសំឡេងរបស់ព្រះអង្គជាញឹកញយ ហើយទ្រង់មានព្រះបន្ទូលជាមួយនឹងបងរាល់គ្នាដោយសំឡេងតូចរហៀងៗ ប៉ុន្តែបងរាល់គ្នាមានចិត្តរក់រិញ ទើបមិនអាចចាប់អារម្មណ៍ពីព្រះបន្ទូលរបស់ព្រះអង្គឡើយ ហេតុដូច្នោះហើយ បានជាទ្រង់មានព្រះបន្ទូលជាមួយនឹងបង ដូចជាសូរផ្គរលាន់ ដែលធ្វើឲ្យផែនដីញ័រ ហាក់បីដូចជាចង់ប្រេះចេញពីគ្នា » ( នីហ្វៃទី ១ ១៧:៤៥ ) ។

## ចូរយើងកុំឈប់ក្នុងការទទួលអារម្មណ៍

ជាទូទៅទំនាក់ទំនងរបស់ព្រះជាមួយបុត្រាបុត្រីរបស់ទ្រង់កើតឡើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលភាគច្រើនព្រះវិញ្ញាណបរិសុទ្ធទាក់ទងយើងតាមសំឡេងដែលចូលមកក្នុងគំនិត និងចិត្តរបស់យើង « សំឡេងតូចរហៀងៗដែលខ្សឹប ហើយទំលុះគ្រប់ទាំងអស់ » ( គ. និង ស. ៨៥:៦ ) ។ ចូរយើងស្ដាប់សំឡេងដ៏ស្រទន់នោះ ហើយកុំរង់ចាំរហូតដល់នរណាម្នាក់ទៀតត្រូវនិយាយមកកាន់យើងដោយសំឡេងផ្គរលាន់ឡើយ ! ចូរចាំថា អេលីយ៉ាបានដឹងថា សំឡេងរបស់ព្រះអម្ចាស់ពុំគង់នៅក្នុងខ្យល់ ការកក្រើកដី ឬនៅក្នុងភ្លើងឡើយ ។ ព្រះអម្ចាស់មានបន្ទូលមកកាន់លោកតាមរយៈព្រះវិញ្ញាណបរិសុទ្ធជាសំឡេងតូចរហៀងៗ ។

ប្រធាន ប៊យ ខេ ផាកកឺ ( ១៩២៤–២០១៥ ) ប្រធានកូរ៉ុមពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា « សំឡេងនៃព្រះវិញ្ញាណកើតឡើងជា *អារម្មណ៍* ជាជាងជាសំឡេង ។ អ្នកនឹងរៀន ដូចជាខ្ញុំបានរៀនដែរ ដើម្បី ‹ ស្ដាប់ › សំឡេងនោះ នោះគឺជា *អារម្មណ៍* ជាជាង *ការស្ដាប់ឮ* ។ . . .

. . . វាជាសំឡេងខាងវិញ្ញាណដែលមកក្នុងដួងចិត្តជាគំនិត ឬជាអារម្មណ៍ដែលដាក់ក្នុងដួងចិត្តរបស់អ្នក » ។[2]

យើង *ទទួលអារម្មណ៍* នូវពាក្យនានាមកពីព្រះវិញ្ញាណបរិសុទ្ធនៅក្នុងគំនិត និងចិត្តរបស់យើង ជាជាងពាក្យទាំងនោះ *ដែលយើងស្ដាប់ឮ* ដោយត្រចៀករបស់យើង ។ ចូរយើងកុំបរាជ័យក្នុងការទទួលអារម្មណ៍នៃការបំផុសគំនិតទាំងនោះឡើយ ! ចូរយើងបើកគំនិត និងដួងចិត្តរបស់យើងទទួលប្រសាសន៍របស់ពួកព្យាការី ។ ចូរយើងអនុញ្ញាតឲ្យព្រះវិញ្ញាណបរិសុទ្ធបន្តបង្រៀនយើងតាមរយៈសំឡេងតូចរហៀងៗ ។ ការបង្រៀនរបស់ពួកសិស្សទ្រង់អំពីព្រះវិញ្ញាណបរិសុទ្ធ ដែលនឹងត្រូវបញ្ជូនមកកាន់ពួកគេ បន្ទាប់ពីទ្រង់បានយាងចេញទៅ នោះព្រះអង្គសង្គ្រោះបានប្រាប់ពួកគេថា « តែព្រះដ៏ជាជំនួយគឺជាព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះវរបិតានឹងចាត់មកដោយនូវឈ្មោះខ្ញុំ ទ្រង់នឹងបង្រៀនអ្នករាល់គ្នាពីគ្រប់សេចក្ដីទាំងអស់ ក៏នឹងរំឭកពីគ្រប់ទាំងសេចក្ដី ដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាដែរ » ( យ៉ូហាន ១៤:២៦ ) ។

សមាជិកស្មោះត្រង់គ្រប់រូបនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយមានសិទ្ធ និងពរជ័យនៃការទទួលបានការដឹកនាំ ការបំផុសគំនិត និងវិវរណៈផ្ទាល់ខ្លួនមកពីស្ថានសួគ៌តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។

ប្រធាន ថូម៉ាស អេស ម៉នសុន ( ១៩២៧–២០១៨ ) បានមានប្រសាសន៍ថា ៖ « ចូរទទួលឥទ្ធិពលមកពីសំឡេងតូចរហៀងៗ ។ ចូរចងចាំថា មនុស្សម្នាក់ដែលមានសិទ្ធិអំណាចបានដាក់ដៃលើក្បាលអ្នកនៅពេលបញ្ជាក់អ្នក ហើយថ្លែងថា ‹ ចូរទទួលព្រះវិញ្ញាណបរិសុទ្ធចុះ › ។ ចូរបើកដួងចិត្តរបស់អ្នក សូម្បីតែព្រលឹងរបស់អ្នកស្ដាប់សំឡេងដ៏ពិសេសនោះ ដែលថ្លែងទីបន្ទាល់អំពីសេចក្ដីពិត ។ ដូចដែលព្យាការីអេសាយ បានសន្យា ‹ ត្រចៀកនឹងឮពាក្យ . . . គឺផ្លូវនេះទេ ចូរដើរតាមនេះវិញ › [ អេសាយ ៣០:២១ ] » ។[3] ■

**កំណត់ចំណាំ**

១. « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Liahona* ខែ ឧសភា ឆ្នាំ ២០១៧ ទំព័រ ១៤៥ ។
២. ប៊យដ៍ ឃេ ផាកកឺ « Counsel to Youth » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ១៧–១៨ ។
៣. ថូម៉ាស អេស ម៉នសុន « ជឿ, គោរពប្រតិបត្តិ, និងកាន់ខ្ជាប់ » *Liahona* ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ១២៩ ។

# សេចក្ដីជំនឿ
## ដើម្បីបន្ដឆ្ពោះទៅមុខ

*ដោយមានការគាំទ្រជាមួយនឹងទីបន្ទាល់អំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ នោះសមាជិកនៃក្រុមរទេះ
រឹល្លី  បានបន្តធ្វើដំណើរឆ្ពោះទៅមុខតទល់នឹងការលំបាក និងការស្រេកឃ្លាន ។*





**ដោយអែលឌើរ រ៉ូណល អេ រ៉ាសបាន**

ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

ដំណើររឿងដែលខ្ញុំចង់ចែកចាយបានចាប់ផ្តើមឡើងនៅក្នុងទីជនបទដែលមានទេសភាពពណ៌បៃតងនៃប្រទេសអង់គ្លេស ជាកន្លែងដែល ចន បែនណែត ហាឃីន បានកើតនៅហ្គូឆេស្ទើរ ក្នុងឆ្នាំ ១៨២៥ ។ គាត់បានជ្រមុជទឹកក្លាយជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ នៅឆ្នាំ ១៨៤៩ ហើយបានចាកចេញទៅកាន់ទ្វីបអាមេរិកនៅក្នុងឆ្នាំដដែលនោះ ជាមួយក្រុមពួកបរិសុទ្ធថ្ងៃចុងក្រោយដោយជិះកប៉ាល់ *ហ៊ិនរីវ៉េ* ។ គាត់បានមកដល់រដ្ឋ យូថាហ៍ នៅក្នុងខែ សីហា ឆ្នាំ ១៨៥២ ហើយជាអ្នកត្រួសត្រាយដែលជាជាងដែកនៅក្នុងជំនាន់ដើមនៃការតាំងទីលំនៅនៅរដ្ឋយូថាហ៍ ។

អនាគតភរិយារបស់គាត់ឈ្មោះ សារ៉ា អេលីស្សាប៊ែត មូលតុន ក៏មកពីតំបន់ជនបទនៃប្រទេសអង់គ្លេសផងដែរ ។ អឺឆេសស្ទើរគឺជាភូមិតូចមួយនៅក្បែរ រីវើរ នីនី ដែលមានចម្ងាយប្រហែលជា ១០៥ គីឡូម៉ែត្រនៅភាគខាងជើងប្រទេសអង់គ្លេស ហើយមានចម្ងាយប្រហាក់ប្រហែលទៅនឹងទីក្រុង ប៊ើមីងហាំ ភាគខាងកើត ។ សារ៉ា អេលីស្សាប៊ែត កើតនៅទីនោះក្នុងឆ្នាំ ១៨៣៧ ជាកូនរបស់ ថូម៉ាស់ មូលតុន -និង អេស្ទើរ ម៉ាស្ស ។ ម្តាយរបស់សារ៉ា អេលីស្សាប៊ែត បានស្លាប់កាលគាត់អាយុពីរឆ្នាំ ហើយក្នុងឆ្នាំ ១៨៤០ ឪពុករបស់គាត់បានរៀបការនឹង សារ៉ា ដែនតុន ។

នៅក្នុងខែ មិថុនា ឆ្នាំ ១៨៣៧ អែលឌើរ ហ៊ីប៊ើរ ស៊ី ឃិមបឹល ( ១៨០១–១៨៦៨ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ និងសមាជិកដទៃទៀតនៃសាសនាចក្របាននៅក្នុងប្រទេសអង់គ្លេសធ្វើកិច្ចការផ្សព្វផ្សាយសាសនា ។ ក្នុងចំណោមអ្នកប្រែចិត្តជឿជាច្រើនដែលត្រូវបានបង្រៀនដោយពួកអ្នកផ្សព្វផ្សាយសាសនាទាំងនេះ មានក្រុមគ្រួសារមួយដែលបានឲ្យសៀវភៅ *A Voice of Warning* ដោយអែលឌើរ ប៉ាលី ភី ប្រាត្ត ( ១៨០៧–១៨៥៧ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ដោយបានអានសៀវភៅនោះ ថូម៉ាស់ និងសារ៉ាបានប្រែចិត្តជឿ ហើយបានជ្រមុជទឹកនៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៨៤១ ។ កាលនោះ គ្រួសាររបស់ពួកគេមានតែកូនពីរនាក់ប៉ុណ្ណោះ — សារ៉ា អេលីស្សាប៊ែត អាយុបួនឆ្នាំ និងម៉ារី អាន អាយុប្រាំពីរខែ ។

វិញ្ញាណនៃការប្រមូលផ្តុំគ្នាគឺមានទំហំធំធេងនៅក្នុងដួងចិត្តនៃអ្នកប្រែចិត្តជឿនៅក្នុងទ្វីបអឺរ៉ុប ។ បំណងប្រាថ្នាដ៏ធំបំផុតរបស់ពួកគេគឺធ្វើអន្តោប្រវេសន៍ទៅទ្វីបអាមេរិក ជាកន្លែងដែលពួកគេអាចនៅជាមួយពួកបរិសុទ្ធក្នុងចំនួនដ៏ច្រើន ។ ដូចជាមនុស្សដទៃទៀងផងដែរ គ្រួសារមូលតុនគ្មានប្រាក់គ្រប់គ្រាន់ដើម្បីបំពេញបំណងប្រាថ្នានេះទេ ។ ប៉ុន្តែការប្តេជ្ញាចិត្តរបស់ពួកគេនោះមានទំហំធំធេងណាស់ ហើយពួកគេបានចាប់ផ្តើមសន្សំប្រាក់នៅក្នុងក្រឡផ្លែឈើមួយ ។

**មូលនិធិអន្តោប្រវេសន៍ដែលមានជាបន្តបន្ទាប់**

នៅក្នុងឆ្នាំ ១៨៤៩ ប្រធាន ព្រិកហាំ យ៉ង់ ( ១៨០១–១៨៧៧ ) បានបង្កើតមូលនិធិអន្តោប្រវេសន៍ដែលមានជាបន្តបន្ទាប់ ដើម្បីជួយសមាជិកសាសនាចក្រទទួលបានមធ្យោបាយធ្វើដំណើរទៅទ្វីបអាមេរិក ។ មនុស្សដំបូងដែលត្រូវធ្វើដំណើរជាមួយនឹងជំនួយនៃមូលនិធិនេះបានធ្វើដំណើរដោយក្រុមរទេះជាមួយគ្នា ប៉ុន្តែមធ្យោបាយធ្វើដំណើរនេះមានសភាពយឺត និងថ្លៃ ។ ទោះបីជាមានជំនួយមកពីមូលនិធិអន្តោប្រវេសន៍ដែលមានជាបន្តបន្ទាប់ក្តី ក៏មានមនុស្ស

*ឆ្វេងដៃ ៖ ទីក្រុង ហ្គូឆេស្ទើរ ប្រទេសអង់គ្លេសបច្ចុប្បន្ន ទីជនបទ*

ថតរូបដោយ EDDIECLOUD/STOCK.ADOBE.COM



*វិមានជាតិ ស្កត់ ប្លឹ នៅភាគខាងលិច រដ្ឋនេប្រាស្កា ស. រ. អា.*

បន្តិចបន្តួចប៉ុណ្ណោះដែលអាចមានប្រាក់គ្រប់គ្រាន់ដើម្បីធ្វើដំណើរ ។ ថ្នាក់ដឹកនាំសាសនាចក្របានធ្វើការសើបអង្កេតអំពីការប្រើរទេះអូស ហើយបានដឹងថា រទេះអូសអាចធ្វើដំណើរលឿនជាង ហើយចំណាយប្រាក់ទាបជាង ។

នៅគ្រានោះគ្រួសារមូលតុនមានកូនចំនួនប្រាំពីរនាក់ ប៉ុន្តែជាមួយនឹងប្រាក់សន្សំក្នុងក្រឡផ្លែឈើរបស់ពួកគេ និងជំនួយមកពីមូលនិធិអន្តោប្រវេសន៍ដែលមានជាបន្តបន្ទាប់ រួមទាំងមធ្យោបាយធ្វើដំណើរដែលថោកជាងមុន នោះក្តីសុបិនរបស់ពួកគេក្នុងការធ្វើអន្តោប្រវេសន៍កើតចេញជារូបរាងឡើង ។ សម្រាប់ក្រុមគ្រួសារមួយដែលមានគ្នាប្រាំបួននាក់ វាតម្រូវឲ្យមានការដាក់ផែនការយ៉ាងប្រុងប្រយ័ត្នដើម្បីរៀបចំធ្វើដំណើរ ។ ដើម្បីសន្សំប្រាក់ឲ្យច្រើនថែមទាំងដើម្បីទិញអ្វីដែលពួកគេចាំបាច់ត្រូវទិញ នោះពួកគេបានរស់នៅដោយបរិភោគតែម្សៅស្រូវបាលីប៉ុណ្ណោះស្ទើរជិតមួយឆ្នាំ ។

នៅពេលការចេញដំណើររបស់ពួកគេមកដល់ ថូម៉ាស់ ស្ទាក់ស្ទើរមិនចង់ធ្វើដំណើរ ដោយសារភរិយារបស់គាត់កំពុងពពោះ ។ ប៉ុន្តែ សារ៉ា ដេនតុន មូលតុន គឺជាស្ត្រីម្នាក់ដែលមានសេចក្តីជំនឿ ហើយពុំបានរុញរាឡើយ ។ ពីមុនពួកគេចាកចេញពីប្រទេសអង់គ្លេស អ្នកផ្សព្វផ្សាយសាសនាម្នាក់បានផ្តល់ការប្រសិទ្ធពរឲ្យសារ៉ា ដែលគាត់បានសន្យានឹងនាងថា ប្រសិនបើនាងនឹងទៅរដ្ឋយូថាហ៍ នោះនាងនឹងធ្វើដំណើរដោយសុវត្ថិភាព ដោយគ្មានបាត់បង់សមាជិកណាម្នាក់នៃគ្រួសាររបស់នាងឡើយ — ជាការសន្យាមួយនៅក្នុងការប្រសិទ្ធពរនោះ ដែលមិនយូរឡើយនឹងមានសមាជិក ១០ នាក់នៅក្នុងគ្រួសារនេះ !

បន្ទាប់ពីក្រុមគ្រួសារនោះបានចេញដំណើរដោយជិះកប៉ាល់បានបីថ្ងៃ ដោយជិះកប៉ាល់ពី លីវើរភូល ប្រទេសអង់គ្លេសនៅក្នុងឆ្នាំ ១៨៥៦ នោះកប៉ាល់ *ស្បនតុន* បានស្វាគមន៍ទារកថ្មីម្នាក់ ។ កប៉ាល់ *ស្បនតុន* ត្រូវបានជួលឲ្យដឹកពួកបរិសុទ្ធចំនួន ៧៦៤ នាក់ ដែលមានជនជាតិដាណាម៉ាក់, ស៊ុយអែត និងអង់គ្លេស ។ ពួកគេនៅក្រោមការដឹកនាំរបស់អ្នកផ្សព្វផ្សាយសាសនាម្នាក់ឈ្មោះ ជេមស៍ ហ្រ្គេ វីល្លី ។

ប្រាំមួយសប្តាហ៍ក្រោយមកកប៉ាល់ *ស្បនតុន* បានធ្វើដំណើរចូលទៅកំពង់ផែ នូវយ៉ោក ។ បន្ទាប់មក ក្រុមគ្រួសារមូលតុនបានជិះរថភ្លើង ដើម្បីធ្វើដំណើរដ៏វែងទៅភាគខាងលិច ។ ពួកគេបានទៅដល់ទីក្រុងអៃអូវ៉ា រដ្ឋអៃអូវ៉ា ក្នុងខែ មិថុនា ឆ្នាំ ១៨៥៦ ជាចំណុចចាប់ផ្តើមនៃក្រុមរទេះអូស ។ ក្នុងរយៈពេលតែបីថ្ងៃប៉ុណ្ណោះពីមុនពួកគេទៅដល់ក្រុមរទេះអូសរបស់លោកមេបញ្ជាការ អែតវឺត ប័ងឃើរ បានធ្វើដំណើរចេញពីទីក្រុងអៃអូវ៉ា ដោយយកក្រុមរទេះអូសជាច្រើនដែលអាចយកទៅបាន ។

**ការលំបាករបស់ក្រុមរទេះអូស**

ពីរសប្តាហ៍ក្រោយមក ក្រុមរទេះវីល្លីត្រូវបានពួកបរិសុទ្ធមួយក្រុមទៀតចូលរួមជាមួយ ក្រោមការដឹកនាំរបស់ អែតវឺត ម៉ាទីន ។ ឥឡូវនេះ ភ្នាក់ងាររបស់សាសនានៅទីក្រុងអៃអូវ៉ា ដែលបានធ្វើការយ៉ាងខ្លាំងក្នុងការផ្គត់ផ្គង់ និងបញ្ជូនក្រុមរទេះអូសទាំងបីក្រុមដំបូង មានការលំបាកយ៉ាងខ្លាំងក្នុងការផ្គត់ផ្គង់ដល់ក្រុមដ៏ធំដែលទើបតែមកដល់យឺតដោយពុំបានរំពឹងទុកនេះ ។ ពួកគេត្រូវធ្វើរទេះអូសចំនួន ២៥០ រទេះពីមុនពួកបរិសុទ្ធទាំងនេះអាចបន្តដំណើររបស់ពួកគេ ។

បុរសគ្រប់គ្នាដែលមានសុខភាពល្អ និងរឹងមាំ ត្រូវដាក់ឲ្យធ្វើរទេះ ខណៈដែលពួកស្ត្រីធ្វើតង់ជាច្រើនសម្រាប់ការធ្វើដំណើរ ។ អ្នកធ្វើរទេះជាច្រើននាក់ដែលគ្មានជំនាញពុំបានអនុវត្តតាមគំរូប្លង់ឡើយ ប៉ុន្តែបានធ្វើរទេះដែលមានទំហំ និងកម្លាំងផ្សេងៗ ដែលបង្កឲ្យមានការលំបាកនៅពេលក្រោយមកទៀត ។ ជាចាំបាច់រទេះដែលត្រូវការមួយចំនួនតម្រូវឲ្យធ្វើចេញពីឈើដែលទើបតែកាប់ថ្មី ដែលពុំទាន់ចាស់ ហើយជួនកាលប្រើស្បែក និងកំប៉ុងដើម្បីធ្វើជាកង់រទេះ ។ រទេះនីមួយៗផ្ទុកអាហារ ព្រមទាំងទ្រព្យសម្បត្តិទាំងអស់របស់ពួកបរិសុទ្ធជាច្រើន ។

ជារឿយៗ រទេះនីមួយៗត្រូវផ្ទុកតវ៉ាន់ពី ១៨០ ទៅ ២៣០ គីឡូក្រាម ដែលមានដូចជាម្សៅអង្ករ សម្ភារដេក ប្រដាប់ប្រដាចម្អិនអាហារ និងសម្លៀកបំពាក់ ។ បុគ្គលម្នាក់ៗអនុញ្ញាតឲ្យដាក់វ៉ាលីផ្ទាល់ខ្លួនតែ ៨ គីឡូក្រាមតែប៉ុណ្ណោះ ។

ថូម៉ាស មូលតុន និងក្រុមគ្រួសាររបស់លោកដែលមានគ្នា ១០ នាក់ត្រូវបានចាត់ឲ្យទៅក្រុមរទេះទីបួន គាត់នៅក្រោមការដឹកនាំរបស់មេបញ្ជាការវីល្លីម្តងទៀត ។ ក្រុមនេះមានពួកបរិសុទ្ធជាង ៤០០ នាក់ ដែលជាទូទៅមានមនុស្សចាស់ច្រើនជាង ។ របាយការណ៍ដែលបានធ្វើឡើងនៅក្នុងខែ កញ្ញានាឆ្នាំនោះបានរៀបរាប់ថាមាន « មនុស្ស ៤០៤ នាក់, រទេះសេះ ៦ គ្រឿង, រទេះអូស ៨៧ គ្រឿង, គោ ៦ នឹម, គោ ៣២ ក្បាល និងសេះ ៥ ក្បាល » ។[១]

គ្រួសារមូលតុនត្រូវបានផ្តល់ឲ្យតែតង់មួយ និងរទេះទទេមួយប៉ុណ្ណោះ ។



ថូម៉ាស់ និងភរិយារបស់គាត់ទាញរទេះដែលមានដំបូល ។ ទារកដែលទើបកើត ឆាលឡេស និងបងស្រី លីស៊ី ( សូហ្វីយ៉ា អេលីស្សាប៉ែត ) ជិះនៅលើរទេះនេះ ។ ឡូធី ( ឆាឡុត ) អាចជិះបាននៅពេលរទេះអូសចុះទួលប៉ុណ្ណោះ ។ ជេមស៍ ហើយបើ ដែលមានអាយុប្រាំបីឆ្នាំ ដើរពីក្រោយជាមួយខ្សែចងជាប់នឹងចង្កេះរបស់គាត់ដើម្បី កុំឲ្យគាត់វង្វេង ។ រទេះធុនមួយផ្សេងទៀតទាញដោយបងស្រីច្បងពីរនាក់ — សារ៉ា អេលីស្សាប៉ែត ( ១៩ ឆ្នាំ ) និង ម៉ារី អាន ( ១៥ ឆ្នាំ ) — និងដោយប្អូនប្រុស វីល្លាម ( ១២ ឆ្នាំ ) ព្រមទាំង យ៉ូសែប ( ១០ ឆ្នាំ ) ។

នៅក្នុងឆ្នាំ ១៨៥៦ គ្រួសារមូលតុនលើកដៃលាទីក្រុងអៃអូវ៉ា ហើយបានចាប់ផ្ដើម ការធ្វើដំណើររបស់ពួកគេដែលមានចម្ងាយ ២០៩០ គីឡូម៉ែត្រទៅភាគខាងលិច ។ បន្ទាប់ពីធ្វើដំណើរបាន ២៦ ថ្ងៃ ពួកគេបានទៅដល់ វិនធើរ ខ្វរធើរ ( ហ្លូរិន ) រដ្ឋ នេប្រាស្កា ។ ជាទម្លាប់ ពួកគេបានចំណាយពេលជាច្រើនថ្ងៃនៅទីនោះ ជួសជុលរទេះ និងរកគ្រឿងផ្គត់ផ្គង់បន្ថែមទៀត ដោយសារគ្មានទីក្រុងធំៗពីវិនធើរ ខ្វរធើរ ទៅទីក្រុង សលត៍ លេក ឡើយ ។

វារាងយឺតពេលនៅក្នុងរដូវនោះ ពីមុនក្រុមរទេះវីល្លីរៀបចំខ្លួនចេញដំណើរពី វិនធើរ ខ្វរធើរ ដែលក្រុមប្រឹក្សាមួយត្រូវបានបង្កើតឡើងដើម្បីសម្រេចចិត្តថា តើពួកគេគួរតែ ធ្វើដំណើរទៅ ឬរង់ចាំរហូតដល់និទាឃរដូវ ។ មនុស្សមួយចំនួនដែលបានធ្វើដំណើរ ជ្រុលទៅមុនហើយនោះបានព្រមានពួកគេពីគ្រោះថ្នាក់នៃការធ្វើដំណើររាងយឺត នៅក្នុងរដូវនោះ ។ ប៉ុន្តែមេបញ្ជាការវីល្លី និងសមាជិកក្រុមមួយចំនួនមានអារម្មណ៍ថា ពួកគេគួរតែបន្តដំណើរទៅមុខ ដោយសារពួកគេគ្មានទីអាស្រ័យនៅក្នុងរដូវរងារនៅ ទីក្រុងហ្លូរិនឡើយ ។

**ស្បៀងបានរលោះបន្តិចម្ដងៗ**

ដោយគ្មានស្បៀងអាហារគ្រប់គ្រាន់ នោះសមាជិកក្រុមរទេះអូសវីល្លីបានចាប់ផ្ដើម ដំណើររបស់ពួកគេម្ដងទៀតនៅថ្ងៃទី ១៨ ខែ សីហា ដោយគិតថា ពួកគេអាចបំពេញ គ្រឿងបរិក្ខាររបស់ពួកគេឡើងវិញនៅ ហ្វត ឡារ៉ាមី ( នៅភាគខាងជើងនៃ ឡារ៉ាមី សព្វថ្ងៃនេះក្នុងរដ្ឋវ៉ាយអូមីង ) ។ ដោយសារតែការព្រមានដែលពួកគេបានទទួល នោះ ពួកគេបានដាក់ម្សៅស្រូវសាលីទម្ងន់ ៤៥ គីឡូក្រាមបន្ថែមទៀតទៅលើរទេះ អូសនីមួយៗរបស់ពួកគេ ហើយមានទំនុកចិត្តថា ពួកគេនឹងជួបក្រុមរទេះស្បៀង ដែលបញ្ជូនមកពីទីក្រុង សលត៍ លេក ។ ប៉ុន្តែដោយគិតថាគ្មានពួកជនអន្តោប្រវេសន៍ បានធ្វើដំណើរមកទៀត នោះអ្នកបើកបររទេះស្បៀងបានធ្វើដំណើរត្រឡប់ទៅទីក្រុង សលត៍ លេក វិញ នៅចុងខែកញ្ញានោះ ពីមុនក្រុមរទេះវីល្លីបានទៅដល់ពួកគេ ។

នៅហ្លូរិន គ្រួសារមូលតុនបានគិតថា អាចជាគំនិតល្អដើម្បីទុកស្បៀងមួយប្រអប់ នោះចោល ដោយសារតវ៉ាន់ដែលពួកគេបានអូសសម្រាប់គ្រួសារមួយដែលមានគ្នា ១០ នាក់នោះគឺវាធ្ងន់ខ្លាំងណាស់ ។ កាលនោះ ពួកគេបានទុកកាបូបមួយចោលនៅ កំពង់ផែលីវើរភូល សម្លៀកបំពាក់មួយកាបូបនៅពេលជិះលើកប៉ាល់ សម្លៀកបំពាក់ មួយហិបនៅទីក្រុង នូវ យ៉ោក និងស្បៀងមួយហិបដែលមានសុទ្ធតែរបស់របរផ្ទាល់ ខ្លួនរបស់ពួកគេនៅទីក្រុងអៃអូវ៉ា ។ ទោះបីនៅតាមផ្លូវក្ដី ពួកគេរកមើលវិធីដើម្បី សម្រាលបន្ទុករបស់ពួកគេ ។

វាមានការលំបាកដល់អស់អ្នកដែលរីករាយនឹងភាពស្រណុកសុខស្រួលនៃ ជីវិតសម័យទំនើបនេះ ដើម្បីស្រមៃអំពីការរងទុក្ខប្រចាំថ្ងៃរបស់គ្រួសារមូលតុន និងពួកបុរស និងស្ត្រីដ៏អស្ចារ្យផ្សេងទៀតនៃក្រុមរទេះអូសទាំងនោះ ។ តើយើង អាចស្រមៃឃើញអំពីពងបែកនៅនឹងដៃ និងជើង ឈឺសាច់ដុំ ដីហុយ និងខ្សាច់ រលាក ដោយកម្ដៅព្រះអាទិត្យ រុយ និងមូស ការរត់ប្រសេចប្រសាចរបស់ហ្វូងក្របី និង ការប្រឈមមុខនឹងពួកអាមេរិកកាំងដើមដែរឬទេ ? តើយើងអាចស្រមៃឃើញ ពីការដើរឆ្លងទន្លេ និងការលំបាកនៃការដើររអិលលើដី និងលើថ្ម នៅពេលពួកគេ ព្យាយាមអូសរទេះកាត់ទឹកដែលហូរលឿន និងជ្រៅនោះដែរឬទេ ? តើយើងអាចយល់ អំពីភាពទន់ខ្សោយដែលកើតមកពីកង្វះសារធាតុចិញ្ចឹមដែរឬទេ ?

អំឡុងពេលធ្វើដំណើររបស់ពួកគេ កូនៗរបស់គ្រួសារមូលតុនបានទៅវាលស្រែ ជាមួយម្ដាយរបស់ពួកគេដើម្បីប្រមូលស្រូវសាឡីបន្តិចបន្តួច យកមកបន្ថែមជា អាហារដែលស្បៀងរបស់ពួកគេបានអស់យ៉ាងលឿន ។ មានគ្រាមួយនោះ គ្រួសារ នេះមានតែនំប៉ុងស្រូវបាលីតែបន្តិច និងផ្លែប៉ោមមួយសម្រាប់បរិភោគមួយថ្ងៃ ដើម្បីចែកជាមួយសមាជិកបីនាក់ ។

ពីមុនថ្ងៃអស្ដង្គតនាថ្ងៃទី ១២ ខែ កញ្ញា ក្រុមអ្នកផ្សព្វផ្សាយសាសនាមកពី បេសកកម្មចក្រភពអង់គ្លេសបានមកដល់ជំរំនោះ ។ ពួកគេត្រូវបានដឹកនាំដោយ

រូបថតពីការ GETTY IMAGES



*ស្វីតវ៉តធើរ រីវើរ នៅក្បែរចេកម៉ាទីន រដ្ឋវ៉ាយអូមីង ស. រ. អា.*

អែលឌើរ ហ្វ្រែគ្លីន ឌី រីឆាត ( ១៨២១–១៨៩៩ ) ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ និងជីតាលួតរបស់ភរិយាខ្ញុំ ។ នៅពេលអែលឌើរ រីឆាត និងអ្នកដទៃទៀតបានឃើញការលំបាករបស់ក្រុមរទេះអូសនោះ ពួកគេបានសន្យាថា នឹងប្រញាប់ទៅជ្រលងភ្នំសលត៍ លេក ហើយបញ្ជូនមកវិញនូវជំនួយកាន់តែឆាប់តាមដែលអាចធ្វើបាន ។

នៅថ្ងៃទី ៣០ ខែ កញ្ញា ក្រុមរទេះអូសវីល្លី បានទៅដល់ ហ្វត ឡារ៉ាមី រដ្ឋ វ៉ាយអូមីង ដែលមានចម្ងាយ ៦៤៥ គីឡូម៉ែត្រនៃភាគខាងកើតពីទីក្រុង សលត៍ លេក ។

នៅដើមខែតុលា រដូវរងារបានចាប់ផ្ដើមចូលមក ហើយការលំបាកបានកើនឡើង នៅពេលក្រុមនេះបានព្យាយាមពុះពារទៅមុខ ។ ស្បៀងអាហារនៅសល់បន្តិចបន្តួច ដែលធ្វើឲ្យមេបញ្ជាការ វីល្លី បានបង្ខំចិត្តកាត់បន្ថយចំណែកម្សៅអង្ករឲ្យនៅត្រឹមតែ ៤២៥ ក្រាមសម្រាប់បុរស, ៣៦៨ ក្រាមសម្រាប់ស្ត្រី, ២៥៥ ក្រាមសម្រាប់កុមារ និង ១៤២ ក្រាមសម្រាប់ទារកប៉ុណ្ណោះ ។ មិនយូរប៉ុន្មានក្រោយមក ពួកគេបានជួបនឹងខ្យល់ដ៏ខ្លាំង និងព្រិលធ្លាក់ដ៏ក្រាស់ ។ នៅព្រឹកថ្ងៃទី ២០ ខែ តុលា ព្រិលបានធ្លាក់កម្ពស់ ១០ សង់ទីម៉ែត្រ ហើយតង់ និងដំបូលរទេះបានហែកដោយសារទម្ងន់របស់វា ។ សមាជិកប្រាំនាក់នៃក្រុមនោះ និងសត្វអូសរទេះមួយចំនួនរបស់ពួកគេបានស្លាប់ដោយសារតែភាពត្រជាក់ និងការស្រេកឃ្លានអាហារនៅយប់ពីមុនមានខ្យល់ព្យុះ ហើយសមាជិកប្រាំនាក់បន្ថែមទៀតបានស្លាប់នៅបីថ្ងៃបន្ទាប់មក ។ ដោយត្រូវទុកអាហារដល់ស្ត្រី កុមារ និងអ្នកមានជំងឺជាមុនសិន នោះពួកបុរសដែលមាំមួនត្រូវបង្ខំចិត្តធ្វើដំណើរទៅមុខដោយគ្មានអ្វីបរិភោគឡើយ ។

## ក្រុមសង្គ្រោះបានចាប់ផ្ដើមធ្វើដំណើរ

នៅចម្ងាយ ៣ គីឡូម៉ែត្រនៅខាងក្រោមភ្នំ រ៉កគី រីច នៅលើតាមដងទន្លេ ស្វីតវ៉តធើរ រីវើរ ក្រុមនោះបានបោះជំរំ ហើយរង់ចាំដោយការស្រេកឃ្លាន រងារ និងរងទុក្ខរង់ចាំឲ្យព្យុះកន្លងហួសទៅ ។

នៅពេលក្រុមរបស់ ហ្វ្រែនគ្លីន ឌី រីឆាត បានទៅដល់ទីក្រុង សលត៍ លេក ពួកគេបានប្រញាប់រាយការណ៍ប្រាប់ប្រធាន យ៉ង់ អំពីស្ថានភាពដ៏គ្រោះថ្នាក់របស់ពួកអ្នកធ្វើអន្តោប្រវេសន៍ទាំងនោះ ។ ពួកបរិសុទ្ធនៅក្នុងជ្រលងភ្នំនោះពុំបានរំពឹងទុកថា នឹងមានអ្នកធ្វើអន្តោប្រវេសន៍ទៀតឡើយរហូតដល់ឆ្នាំបន្ទាប់ទៀត ហើយដំណឹងអំពីស្ថានភាពដ៏គ្រោះថ្នាក់នេះបានរីករាលដាលយ៉ាងលឿន ។

ពីរថ្ងៃក្រោយមក នៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៨៥៦ សន្និសីទទូទៅត្រូវបានធ្វើឡើងនៅក្នុងរោងឧបោសថចាស់ ។ នៅលើវេទិកា ប្រធាន យ៉ង់ បានអំពាវនាវសុំពួកបុរស ស្បៀង និងបរិក្ខារផ្សេងៗឲ្យចាកចេញទៅដោយជិះសេះ ឬរទេះសេះនៅថ្ងៃបន្ទាប់ដើម្បីផ្ដល់ជាជំនួយ ។[២]

ចន បែនណែត ហាយិន បាននៅក្នុងរោងឧបោសថចាស់នៅថ្ងៃនោះផងដែរ ហើយបានឆ្លើយតបសម្រាប់ជំនួយនោះ ។ គាត់គឺជាបុរសម្នាក់ក្នុងចំណោមបុគ្គលរាប់រយនាក់នៅក្នុងក្រុមសង្គ្រោះ ដែលបានចេញដំណើរពីទីក្រុង សលត៍ លេក ។ ទីបំផុតនៅល្ងាចថ្ងៃទី ២១ ខែ តុលា ក្រុមរទេះសេះជួយសង្គ្រោះបានទៅដល់ជំរំវីល្លី ។ ពួកគេត្រូវបានស្វាគមន៍ដោយអំណរ និងអំណរគុណពីអ្នកដែលនៅរស់ពីអាកាសធាតុត្រជាក់ និងការស្រេកឃ្លាននោះ ។ នេះគឺជាការជួបលើកដំបូងរបស់ ចន បែនណែត ហាយិន និង សារ៉ា អេលីស្សាប៊ែត មូលតុន ដែលក្លាយជាជីដូនជីតាតួតរបស់ខ្ញុំ ។

នៅថ្ងៃទី ២២ ខែ តុលា អ្នកជួយសង្គ្រោះមួយចំនួនបានបន្តជួយក្រុមរទេះអូសផ្សេងទៀត ខណៈដែល វិល្លាម អេច ឃីមបល ជាមួយនឹងរទេះដែលនៅសល់ បានចាប់ផ្ដើមធ្វើដំណើរត្រឡប់ទៅទីក្រុង សលត៍ លេក វិញ ដោយមើលខុសត្រូវលើក្រុមរទេះវីល្លី ។

អស់អ្នកដែលទន់ខ្សោយពុំអាចអូសរទេះរបស់ពួកគេបានដាក់ទ្រព្យសម្បត្តិរបស់ពួកគេលើរទេះសេះ ហើយដើរនៅក្បែររទេះនោះ ។ អស់អ្នកដែលពុំអាចដើររួចបានជិះលើរទេះសេះ ។ នៅពេលពួកគេបានទៅដល់ រ៉កគី រីច មានព្យុះព្រិលដ៏ខ្លាំងមួយទៀតបានបោកបក់មកលើពួកគេ ។ នៅពេលពួកគេកំពុងមានការលំបាកឡើងទៅចង្កេះភ្នំ នោះពួកគេត្រូវរុំខ្លួនពួកគេនឹងភួយ និងភួយរាញ់សំឡីដើម្បីការពារពួកគេកុំឲ្យរងារហូតដល់ស្លាប់ ។ មានមនុស្សប្រហែលជា ៤០ នាក់នៅក្នុងក្រុមនោះបានស្លាប់រួចទៅហើយ ។[៣]

អាកាសធាតុត្រជាក់យ៉ាងខ្លាំងដែលធ្វើឲ្យពួកបរិសុទ្ធជាច្រើននាក់បានរងទុក្ខនឹងការរលាកនឹងធាតុត្រជាក់នៅដៃ ជើង និងមុខរបស់ពួកគេ អំឡុងពេលដើរឆ្លងកាត់កំពូលភ្នំនោះ ។ ស្ត្រីម្នាក់បានខ្វាក់ភ្នែកដោយសារតែអាកាសធាតុត្រជាក់នោះ ។



យើងអាចស្រមៃឃើញគ្រួសារមូលតុន ជាមួយនឹងកូនទាំងប្រាំបីនាក់របស់ពួកគេ ទាញ និងអូសរទេះពីររបស់ពួកគេ ខណៈដែលពួកគេពុះពារឆ្លងកាត់ព្រិលដ៏ក្រាស់នោះ ។ រទេះមួយអូសដោយ ថូម៉ាស់ និងភរិយារបស់គាត់ ជាមួយនឹងកូនៗដ៏មានតម្លៃរបស់ពួកគេគឺ — ឡូតធី, លីស៊្សី និងទារក ឆាលទ្បេស — ជាមួយនឹង ជេមស៍ ហៃបើរ តូចដែលដើរគ្រេចជើង និងត្រូវបានទាញដោយខ្សែដែលចងនៅចង្កេះរបស់គាត់ ។ រទេះមួយទៀតទាញ និងអូសដោយ សារ៉ា អេលីស្សាប៊ែត និងកូនទាំងបីនាក់ផ្សេងទៀត ។ ស្ត្រីវ័យចំណាស់ចិត្តល្អម្នាក់ ដោយឃើញ ជេមស៍ ហៃបើរ ដែលមានការលំបាកបានចាប់ដៃរបស់គាត់ នៅពេលគាត់ដើរតាមពីក្រោយរទេះ ។ ទង្វើដ៏សប្បុរសនេះបានសង្គ្រោះដៃខាងស្តាំគាត់ ប៉ុន្តែដៃខាងឆ្វេងឥតគ្របដណ្ដប់របស់គាត់បានប៉ះនឹងអាកាសធាតុក្រោមសូន្យអង់ស្សាសេដ៏ត្រជាក់នោះ ។ នៅពេលពួកគេបានទៅដល់ទីក្រុង សលត៍ លេក ម្រាមដៃបីបួនរបស់គាត់នៅខាងដៃឆ្វេងនោះត្រូវបានកាត់ចោល ។

នៅមុនរសៀលថ្ងៃទី ៩ ខែ វិច្ឆិកា ក្រុមរទេះមនុស្សធម៌សង្គ្រោះអ្នករងទុក្ខនោះបានឈប់នៅពីមុខអគារការិយាល័យដង្វាយមួយភាគក្នុងដប់ ជាកន្លែងនៃអគាររំឭកចាំយ៉ូសែប ស៊្មីធ នៅក្នុងទីក្រុង សលត៍ លេក សព្វថ្ងៃនេះ ។ មនុស្សជាច្រើនបានទៅដល់ទីនោះដោយមានជើង និងដៃដែលកកត្រជាក់ ។ មនុស្សហុកសិបប្រាំបួននាក់បានស្លាប់នៅក្នុងការធ្វើដំណើរនោះ ។ ប៉ុន្តែការសន្យាទៅកាន់គ្រួសារមូលតុននៅក្នុងការប្រសិទ្ធពរនៅក្នុងប្រទេសអង់គ្លេសត្រូវបានបំពេញ ។ ថូម៉ាស់ និងសារ៉ា ដេនតុន មូលតុន ពុំបានបាត់បង់កូនមួយណាឡើយ ។

## ពីការសង្គ្រោះទៅរកសេចក្ដីស្នេហា

ក្រុមនេះត្រូវបានទទួលស្វាគមន៍ដោយពលរដ្ឋ សតល៍ លេក រាប់រយនាក់ដែលរង់ចាំដោយអន្ទះសារនៃការមកដល់របស់ពួកគេ ហើយបានត្រៀមរួចជាស្រេចដើម្បីជួយមើលថែពួកគេ ។ ការដឹងគុណ និងអំណរគុណចំពោះវីរៈបុរសម្នាក់ដែលបានជួយសង្គ្រោះគ្រួសាររបស់មូលតុនពីក្រញ៉ាំនៃសេចក្ដីស្លាប់បានធ្លាក់ក្នុងអន្លង់ស្នេហ៍ និងស្រឡាញ់ សារ៉ា អេលីស្សាប៊ែត ។

នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ១៨៥៦ នៅក្នុងចំណោមនៃក្ដីប្រាថ្នាដ៏រីករាយរបស់មនុស្សជាទីស្រឡាញ់ នោះ សារ៉ា អេលីស្សាប៊ែត បានរៀបការនឹង ចន បែនណែត ហាឃីន ដែលជាអ្នកជួយសង្គ្រោះគាត់ ។ ពួកគេបានផ្សារភ្ជាប់សម្រាប់ពេលនេះ និងអស់កល្បជានិច្ច នៅខែកក្កដាបន្ទាប់នៅក្នុងដំណាក់នៃអំណោយទានពិសិដ្ឋ ។ ពួកគេបានសាងសង់ផ្ទះនៅទីក្រុង សលត៍ លេក ហើយមានពរជាមួយនឹងកូនប្រុសបីនាក់ និងកូនស្រីប្រាំពីរនាក់ ។ កូនម្នាក់នៃកូនស្រីទាំងនោះឈ្មោះ អេសធើរ អ៊ីមីលី បានរៀបអាពាហ៍ពិពាហ៍នឹងជីតារបស់ខ្ញុំឈ្មោះ ឆាឡេស រ៉ាសបាន នៅក្នុង ១៨៩១ ។

នៅថ្ងៃទី ២៤ ខែ កក្កដា យើងប្រារព្ធទិវាអ្នកត្រួសត្រាយ ហើយយើងថ្លែងអំណរគុណដល់អ្នកត្រួសត្រាយជាច្រើននាក់ដែលបានផ្ដល់អ្វីៗគ្រប់យ៉ាង ដើម្បីស្ថាបនាជ្រលង សតល៍ លេក និងសហគមន៍ជាច្រើនផ្សេងទៀតនៅក្នុងសហរដ្ឋអាមេរិកភាគខាងលិច ។ យើងក៏សូមថ្លែងអំណរគុណដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយដែលជាអ្នកត្រួសត្រាយនៅទូទាំងពិភពលោកដែលបានបង្កើតផ្លូវ — និងកំពុងបង្កើតផ្លូវ — គឺផ្លូវនៃដំណឹងល្អដើម្បីឲ្យអ្នកដទៃដើរតាមផងដែរ ។

តើអ្វីទៅដែលធ្វើឲ្យពួកគេបន្តឆ្ពោះទៅមុខនោះ ? តើអ្វីទៅដែលជំរុញពួកគេឲ្យឆ្ពោះទៅមុខនោះ ? ចម្លើយនោះគឺទីបន្ទាល់របស់ពួកគេអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។ ក្នុងនាមជាចៅតួតនៃអ្នកត្រួសត្រាយម្នាក់ ខ្ញុំសូមបន្ថែមសាក្សី និងទីបន្ទាល់របស់ខ្ញុំថា ការលំបាករបស់ពួកគេពុំឥតប្រយោជន៍ឡើយ ។ អ្វីដែលពួកគេបានទទួលអារម្មណ៍ នោះខ្ញុំក៏បានទទួលអារម្មណ៍ផងដែរ ។ អ្វីដែលពួកគេបានដឹង នោះខ្ញុំក៏ដឹង ហើយថ្លែងទីបន្ទាល់អំពីវាផងដែរ ។ ■

*ដកស្រង់ចេញពីសារលិខិតដែលបានថ្លែងឡើងនៅរោងឧបោសថទីក្រុង សលត៍ លេក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៧ នៅក្នុងទិវាពួកអ្នកត្រួសត្រាយ ដែលធ្វើការប្រជុំពិសេសនាពេលព្រឹកព្រលឹម ។*

**កំណត់ចំណាំ**

១. របាយការណ៍ដោយ អេហ្វ ឌី រីឆាត និង ដានីញ៉ែល ស្ពេនសើរ « Smith, Marilyn Austin, *Faithful Stewards—the Life of James Gray Willie and Elizabeth Ann Pettit,* 95–120 » history.lds.org ។

២. សូមមើល ព្រិកហាំ យ៉ង់ « Remarks » Deseret News ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៨៥៦ សូមមើលផងដែរ LeRoy R. Hafen and Ann W. Hafen *Handcarts to Zion* ( ឆ្នាំ ១៩៨១ ) ទំព័រ ១២០–១២១ ។

៣. មនុស្ស ១៩ នាក់នៃក្រុមនេះបានស្លាប់ពីមុនក្រុមនេះបានទៅដល់ ហ្វត ឡារ៉ាមី រួមទាំង ៧ នាក់ទៀតបានស្លាប់នៅលើឆ្នេរមហាសមុទ្រ និង ៤ នាក់ទៀតបានស្លាប់នៅទីក្រុងអៃអូវ៉ា ។ ១៩ នាក់បានស្លាប់នៅ ហ្វត ឡារ៉ាមី និងពេលចាប់ផ្ដើមរដូវរងារ ភាគច្រើនគឺនៅជាច្រើនថ្ងៃមុនក្រុមសង្គ្រោះបានទៅដល់ ។

## ការរក្សា

# សេចក្ដីជំនឿ ទោះ នៅដាច់ឆ្ងាយពីគេក្ដី

**ដោយ រ៉ាយអិន ដុប័លយូ សលហ្គីវើរ**
ការិយាល័យប្រវត្តិសាស្ត្ររបស់សាសនាចក្រ

*នៅពេលដែលសង្គ្រាម ជំងឺ ឬកាលៈទេសៈផ្សេងទៀត បានបន្សល់ទុកឲ្យសមាជិកសាសនាចក្រទាំងនេះនៅឯកោនៅក្នុងប្រទេសរបស់ពួកគេ នេះគឺជារបៀបដែលពួកគេបន្តនៅស្មោះត្រង់ ។*

ពួកបរិសុទ្ធថ្ងៃចុងក្រោយភាគច្រើនថ្វាយបង្គំនៅក្នុងវួដ និងសាខា ជាកន្លែងដែលពួកគេអាច « ជួបជុំគ្នាជាញឹកញាប់ ដើម្បីតមអាហារ ហើយអធិស្ឋាន ហើយពិគ្រោះគ្នាទៅវិញទៅមក អំពីសុខុមាលភាពដល់ព្រលឹងពួកគេ » ( ម៉ូរ៉ូណៃ ៦:៥ ) ។ ប៉ុន្តែម៉ូរ៉ូណៃជាព្យាការីដែលបានសរសេរពាក្យទាំងនេះ បានធ្វើកិច្ចការមួយចំនួនចុងក្រោយបំផុតរបស់លោក នៅពេលលោកនៅតែម្នាក់ឯង ដោយបន្តធ្វើជាសិស្សម្នាក់ បន្ទាប់ពីការបំផ្លិចបំផ្លាញនៃប្រជាជនលោកមក ។

ពេញប្រវត្តិសាសនាចក្រ ពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើននាក់បានរក្សាសេចក្ដីជំនឿរបស់ពួកគេតែឯង នៅពេលកាលៈទេសៈបានទុកឲ្យពួកគេនៅដាច់ឆ្ងាយពីគេ ។ មនុស្សមួយចំនួនដូចជាម៉ូរ៉ូណៃ បានរស់នៅក្នុងជីវិតរបស់ពួកគេក្នុងនាមជាសាក្សី និងគំរូសម្រាប់មនុស្សជំនាន់ក្រោយៗទៀត ។ មនុស្សដទៃទៀតបានរស់នៅដើម្បីឃើញនូវថ្ងៃមួយដែលពួកគេអាចចែកចាយសេចក្ដីជំនឿរបស់ពួកគេសារជាថ្មីម្ដងទៀត ។

### ការអធិស្ឋានអស់ជាច្រើនឆ្នាំសម្រាប់ថ្ងៃនេះ

ហ្វ្រានទីស្កា ប្រូឌីឡូវ៉ា មានការលំបាកក្នុងការទស្សនទាយអំពីតួនាទីដែលគាត់នឹងមាននៅក្នុងប្រវត្តិសាសនាចក្រ កាលអ្នកផ្សព្វផ្សាយសាសនាម្នាក់បានគោះទ្វារផ្ទះរបស់គាត់នៅទីក្រុងវៀនណា ក្នុងឆ្នាំ ១៩១៣ ។ មួយឆ្នាំក្រោយពីការប្រែចិត្ត

ចេនាប្រភាព ដោយ ខេន ស្ពែនស៊ើរ

ជឿរបស់គាត់មក សង្គ្រាមលោកលើកទី I បានលេបយក អាណាចក្រអូទ្រី — ហុងគ្រី ធ្វើឲ្យពួកអ្នកផ្សព្វផ្សាយសាសនាត្រូវត្រឡប់ទៅផ្ទះ ហើយសមាជិកបុរសជាច្រើននាក់ត្រូវបានហៅឲ្យចូលបម្រើទាហាន ដោយទុកឲ្យ ហ្វ្រានទីស្កា និង បងប្អូនស្រីពីរបីនាក់ផ្សេងទៀតបំពេញនូវសេចក្ដីត្រូវការដោយខ្លួនពួកគេផ្ទាល់ ។

វាគឺជាពេលដែល ហ្វ្រានទីស្កា ទាក់ទងជាមួយសមាជិកសាសនាចក្រច្រើនជាងគេបំផុតអស់រយៈពេលជាច្រើនឆ្នាំ ។ បន្ទាប់ពីសង្គ្រាម ស្វាមីរបស់ ហ្វ្រានទីស្កា ឈ្មោះ ហ្វ្រានទីសេក ត្រូវបានជាប់ការសន្យាបម្រើមុខងារនៅក្នុងជួររដ្ឋាភិបាលថ្មីនៃប្រទេសឆេកូស្លូវ៉ាគី ។ បន្ទាប់ពីពួកគេបានប្ដូរទៅរស់នៅប្រាក នោះហ្វ្រានទីស្កា គឺជាសមាជិកសាសនាចក្រតែម្នាក់ឯងគត់នៅក្នុងប្រទេសនោះ ។ ពីរបីខែក្រោយមក ហ្វ្រានទីសេក បានស្លាប់ ដោយទុកឲ្យហ្វ្រានទីស្កានៅជាមួយកូនស្រីតូចពីរនាក់គឺ — ហ្វ្រានសេស និងជេន — ទំនុកបម្រុងដល់ពួកគេ ។

ហ្វ្រានទីស្កាបានបង្រៀនដំណឹងល្អដល់កូនស្រីរបស់គាត់ដោយខ្លួនគាត់ផ្ទាល់ ។ ហ្វ្រានសេសនិយាយថា « ខ្ញុំត្រូវបានចិញ្ចឹមឲ្យធំឡើងនៅក្នុងសាសនាចក្រ ។ សាសនាចក្រគឺជាផ្ទះរបស់យើង ! »[1] ហ្វ្រានទីស្កាក៏បានសរសេរសំបុត្រទៅថ្នាក់ដឹកនាំសាសនាចក្រនៅក្នុងប្រទេសអូទ្រីស



*ហ្វ្រានទីស្កា ប្រូឌីឡូវ៉ាបានចូលជាសមាជិកសាសនាចក្រនៅទីក្រុងវៀនណាក្នុងឆ្នាំ ១៩១៣— មួយឆ្នាំមុនសង្គ្រាមលោកលើកទី I ចាប់ផ្ដើម— ហើយគ្មានទំនាក់ទំនងជាមួយសមាជិកដទៃទៀតនៃសាសនាចក្ររហូតដល់ឆ្នាំ ១៩២៩ ។*

រូបថតរបស់ហ្វ្រានទីស្កា វេសេឡា ប្រូឌីឡូវ៉ា ទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការពីបណ្ណាល័យធនធានសោតទស្សន៍



*ហ្វ្រានទីស្កាមានវត្តមាននៅពេលដែលអែលឌើរ ចន អេ វិតសូ ( ទាំងពីរនាក់ឈរនៅជួរកណ្ដាល ) បានឧទ្ទិសឆ្លងប្រទេសឆេកកូស្លូវ៉ាគីសម្រាប់ការប្រកាសដំណឹងល្អនៅក្នុងឆ្នាំ ១៩២៩ ។*



ដោយសូមចាត់ឲ្យអ្នកផ្សព្វផ្សាយសាសនាឲ្យមកប្រទេសឆេកូស្លូវ៉ាគី ។ ថ្នាក់ដឹកនាំសាសនាចក្រមានការស្ទាក់ស្ទើរ ដោយសារអ្នកផ្សព្វផ្សាយសាសនាចុងក្រោយគេនៅទីក្រុងប្រាក កាលពីប្រមាណ ៤០ ឆ្នាំមុនត្រូវបានចាប់ដាក់គុកដោយសារតែប្រកាសដំណឹងល្អ ហើយក្រោយមកត្រូវបាននិរទេសចេញពីទីក្រុងនោះ ។ ទោះបីជាមានរដ្ឋាភិបាលថ្មីក្តី ក៏ថ្នាក់ដឹកនាំសាសនាចក្រមានការភ័យខ្លាចថា មានការផ្លាស់ប្តូរតែបន្តិចបន្តួចប៉ុណ្ណោះ ។

ដោយពុំបានគិតអំពីកង្វល់នោះ ហ្វ្រានទីស្កាបានបន្តសរសេរសំបុត្រ ហើយអធិស្ឋានទូលសូមឲ្យមានបេសកកម្មមួយត្រូវបានបង្កើតឡើង ។ ក្នុងឆ្នាំ ១៩២៨ បន្ទាប់ពីហ្វ្រានទីស្កាបានធ្វើជាសមាជិកតែម្នាក់ឯងអស់រយៈពេលមួយទសវត្សរ៍មក ថូម៉ាស បឺសឺហ្គើរ អាយុ ៨៣ ឆ្នាំ — អ្នកផ្សព្វផ្សាយសាសនាដដែលដែលបានប្រកាសដំណឹងល្អនៅទីក្រុងប្រាក កាលពីប៉ុន្មានឆ្នាំមុននោះ — បានត្រឡប់មកវិញ ។ វាទំនងថា ភាពនៅដាច់តែឯងរបស់គ្រួសារនេះត្រូវបានឈានដល់ទីបញ្ចប់ហើយ ។ ប៉ុន្តែ មិនយូរប៉ុន្មានក្រោយមក សុខភាពទ្រុឌទ្រោមរបស់អែលឌើរ បឺសឺហ្គើរ បានបង្ខំឲ្យគាត់ចាកចេញពីប្រទេសនោះ ។

ហ្វ្រានទីស្កាមានការខកចិត្ត ប៉ុន្តែគាត់បានសម្រេចចិត្តបន្តសរសេរសំបុត្រទៅកាន់សមាជិក និងថ្នាក់ដឹកនាំសាសនាចក្រនៅក្រៅប្រទេស ។ ស្មារតីលះបង់របស់គាត់ត្រូវបានទទួលរង្វាន់ ៖ នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩២៩ អែលឌើរ ចន អេ វិតសូ ( ១៨៧២–១៩៥២ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានទៅដល់ទីក្រុងប្រាក ជាមួយនឹងអ្នកផ្សព្វផ្សាយសាសនាមួយក្រុម ។ នៅល្ងាចនោះ ហ្វ្រានទីស្កា និងក្រុមនោះបានឡើងទៅកូនភ្នំក្បែរប្រាសាទខាស្ថិចដាក់ន្លែងដែលអែលឌើរ វិតសូ បានឧទ្ទិសឆ្លងប្រទេសឆេកូស្លូវ៉ាគីសម្រាប់ការប្រកាសដំណឹងល្អ ហើយបានបង្កើតបេសកកម្មមួយជាផ្លូវការ ។ ក្រោយមកហ្វ្រានទីស្កា បានសរសេរថា « មានមនុស្សបន្តិចបន្តួចប៉ុណ្ណោះដែលអាចយល់នូវអំណរដែលយើងបានមាន ។ យើង [ បាន ] អធិស្ឋានអស់ជាច្រើនឆ្នាំសម្រាប់ថ្ងៃនេះ » ។[២]

អស់រយៈពេលប្រហែលជាប្រាំមួយខែ សាខាមួយបានជួបប្រជុំគ្នានៅក្នុងផ្ទះរបស់ហ្វ្រានទីស្កា ។ ទីបំផុតហ្វ្រានទីស្កាបានជួយកូនស្រីរបស់គាត់ក្នុងការបកប្រែព្រះគម្ពីរមរមនទៅជាភាសាឆេក ហើយបានចាក់គ្រឹះសម្រាប់សាសនាចក្រដែលឥឡូវនេះត្រូវបានហៅថា សាធារណរដ្ឋឆេក ។

ដូចជាហ្វ្រានទីស្កាដែល ពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើននាក់មានការកាន់ខ្ជាប់ទោះជានៅដាច់ឆ្ងាយតែឯងក្តី ។ បុរស និងស្ត្រីដូចតទៅនេះគឺនៅក្នុងចំណោមមនុស្សដំបូងគេដែលចែកចាយដំណឹងល្អ ហើយចាក់គ្រឹះនៃសាសនាចក្រនៅក្នុងប្រទេសកំណើតរបស់ពួកគេ ដែលឲ្យមនុស្សដទៃទៀតចែកចាយនៅពេលក្រោយទៀតក្នុងការស្វាគមន៍ដល់ពួកបរិសុទ្ធ ។



*បន្ទាប់ស្វាមីរបស់គាត់បានស្លាប់ទៅ ហ្វ្រានទីស្កា បានចិញ្ចឹមកូនស្រីរបស់គាត់ទាំងពីរនាក់តែម្នាក់ឯង ។*

*ដូចជាហ្វ្រានទីស្កាដែល ពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើននាក់មានការកាន់ខ្ជាប់ ទោះជានៅដាច់ឆ្ងាយតែឯងក្ដី ។ ពួកបុរស និងស្ត្រីទាំងនេះបានចិញ្ចឹមបីបាច់ភ្លើងនៃសេចក្ដីជំនឿរបស់ពួកគេ បានចែកចាយដំណឹងល្អ ហើយបានស្ថាបនាសាសនាចក្រនៅក្នុងប្រទេសកំណើតរបស់ពួកគេ ។*

**អំណោយទានដ៏ខ្ជាប់ខ្ជួននៃសេចក្ដីជំនឿពិត**

នៅពេលបេសកកម្មប្រទេសជប៉ុនបានបិទនៅក្នុងឆ្នាំ ១៩២៤ សមាជិកជាច្រើនមានអារម្មណ៍ថាបាត់បង់ និងត្រូវគេបោះបង់ចោល ។ ភាពជាថ្នាក់ដឹកនាំសម្រាប់សមាជិកដែលមានប្រមាណជា ១៦០ នាក់នៅក្នុងប្រទេសជប៉ុនត្រូវធ្លាក់ទៅលើ ហ្វូជីយ៉ា ណារ៉ា ជាអែលឌើរដែលជាអធិបតីនៅក្នុងប្រទេស ដែលបម្រើការងារនៅតាមរថភ្លើងដែលបានធ្វើឲ្យគាត់អាចសួរសុខទុក្ខដល់សមាជិកដែលបែកខ្ញែកទាំងនោះ ។ នៅពេលដែលគាត់ពុំអាចទៅសួរសុខទុក្ខបាន ហ្វូជីយ៉ាបានបន្តទាក់ទងតាមរយៈទស្សនាវដ្ដីបោះពុម្ពដែលមានចំណងជើងថា *Shuro* ( *ស្លឹកភ្លោត* ) នៅក្នុងនោះលោកបានចែកចាយសារលិខិតដំណឹងល្អ ហើយបានលើកទឹកចិត្តពួកបរិសុទ្ធដែលនៅសល់ទាំងប៉ុន្មាននៅក្នុងអំឡុងប៉ុន្មានឆ្នាំដ៏លំបាកបន្ទាប់មកទៀតនោះ ។

បន្ទាប់ពីកន្លែងការងាររបស់ហ្វូជីយ៉ាបានប្ដូរគាត់ទៅម៉ាន់ជូរី ហើយអ្នកជំនួសគាត់ក្នុងនាមជាអែលឌើរជាអធិបតីបានស្លាប់ភ្លាមៗក្នុងឆ្នាំ ១៩៣៧ នោះទំនាក់ទំនងជាមួយសមាជិកនៅក្នុងប្រទេសជប៉ុនត្រូវបានបាត់បង់ភ្លាម ។ ហ្វូជីយ៉ាបាននិយាយថា « ទោះបីជាយើងគ្មានការឆ្លើយឆ្លងជាមួយអ្នកនៅទីក្រុង សលត៍ លេក ក្ដី . . . ក៏យើងមានការជឿជាក់ថា សាសនាចក្រនឹងបានបើកវិញម្ដងទៀត [ នៅទីនេះ ] » ។[៣]

*ក្នុងនាមជាអែលឌើរជាអធិបតី ហ្វូជីយ៉ា ណារ៉ា ( ស្លៀកសម្លៀកបំពាក់ពណ៌ក្រម៉ៅ ) បានទទួលការខុសត្រូវក្នុងការបន្តទាក់ទងជាមួយសមាជិកបន្ទាប់ពីបេសកកម្មប្រទេសជប៉ុនត្រូវបានបិទនៅក្នុងឆ្នាំ ១៩២៤ ។*



អំឡុងពេលសង្គ្រាមលោកលើកទី II ហ្វូជីយ៉ាបានត្រឡប់ទៅទីក្រុងតូក្យូវិញ ជាកន្លែងដែលគាត់បានប្រកាសដំណឹងល្អដល់អ្នកជិតខាងរបស់គាត់ ហើយបានរៀបចំការប្រជុំថ្នាក់សាលាថ្ងៃអាទិត្យប្រចាំសប្ដាហ៍ ។ បន្ទាប់ពីសង្គ្រាមចប់ ហ្វូជីយ៉ាបានរកឃើញកំណត់ចំណាំមួយដែលបានសរសេរដោយ អែតវីត អិល គ្លីសុល — ជាពួកបរិសុទ្ធថ្ងៃចុងក្រោយម្នាក់ដែលបម្រើនៅក្នុងកងទ័ពអាមេរិកកាំង — អញ្ជើញឲ្យសមាជិកសាសនាចក្រនៅក្នុងប្រទេសនោះទាក់ទងគាត់ ។ ភ្លាមនោះហ្វូជីយ៉ាបានទៅជួបអែតវីតនៅក្នុងបន្ទប់របស់គាត់នៅសណ្ឋាគារ ។ នៅពេលអែតវីតបានចូលរួមការប្រជុំរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅក្នុងទីក្រុងតូក្យូ គាត់មានការអស្ចារ្យក្នុងចិត្តដែលឃើញមានមនុស្សជិត ១០០ នាក់បានចូលរួមប្រជុំ ។

ក្រោយមក ហ្វូជីយ៉ាបាននិយាយថា « ឆ្លងកាត់នូវអ្វីៗទាំងអស់មក អំណោយទានដ៏មហិមា និងអំណោយទានដ៏ខ្ជាប់ខ្ជួនកើតមានដើម្បីដឹង ហើយឱបក្រសោបយកសេចក្ដីជំនឿដ៏ពិត — នោះគឺមានន័យថា ស្គាល់ព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធ » ។[៤]

**ការស្ថាបនាសាសនាចក្រនៅរដ្ឋហាវ៉ៃ**

ចូណាថាន់ អេច ណាភេឡា គឺជាចៅក្រមដែលទទួលការគោរពដ៏ប្រពៃនៅលើកោះម៉ោអ៊ី ពីមុនគាត់ និងភរិយាគាត់ កាតើ ឃីធី បានជ្រមុជទឹកក្នុងឆ្នាំ ១៨៥១ ។ បន្ទាប់ពី ចូណាថាន់ ត្រូវបានបង្ខំឲ្យលាលែងពីតំណែងជាចៅក្រមដោយសារតែការចូលជាសមាជិកសាសនាចក្រ នោះលោកបានលះបង់ថាមពលរបស់លោកក្នុងការស្ថាបនាសាសនាចក្រនៅក្នុងចំណោមពួកអ្នកដែលនិយាយភាសាហាវ៉ៃ ។ ចូណាថាន់បានបង្រៀនភាសាដល់ចច យូ្យ ខានុន ដែលជាអ្នកផ្សព្វផ្សាយសាសនា បានជួយបកប្រែព្រះគម្ពីរមរមន ហើយបង្កើតកម្មវិធីដំបូងសម្រាប់បំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនាជាភាសាបរទេសនានា ។

ជាលទ្ធផល មានពួកសាសន៍ហាវ៉ៃសញ្ជាតិដើមជាង ៣០០០ នាក់បានចូលជាសមាជិកសាសនាចក្រនៅក្នុងអំឡុងពេលបីឆ្នាំ ។ ចូណាថាន់ បានសរសេរថា « វាមានភាពច្បាស់លាស់ណាស់ចំពោះយើងថា នេះគឺជាសាសនាចក្ររបស់ព្រះ ។ មានមនុស្សជាច្រើននៅលើកោះទាំងនេះដែលបានទទួលសេចក្ដីជំនឿដ៏រឹងមាំ តាមរយៈព្រះគុណនៃព្រះតាមរយៈព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ ដែលយើងអាចទទួលព្រះវិញ្ញាណបរិសុទ្ធ » ។[៥]




*ស្ដាំដៃ ៖ អ្នកប្រែចិត្តជឿមុនដំបូងគេនៅក្នុងរដ្ឋហាវ៉ៃ ចូណាថាន់ ណាភេឡា បានជួយបកប្រែព្រះគម្ពីរមរមនទៅជាភាសាហាវ៉ៃ ។ ខាងក្រោម ៖ វីលហែម ហ្វ្រេដ្រីច ( រូបទីពីរមកពីខាងឆ្វេងដៃ ) និង អ៊ីមីល ហូប ( នៅកណ្ដាល ជួរខាងក្រោយ ) បានចូលរួមពិធីបុណ្យជ្រមុជទឹកដំបូងគេនៅប្រទេសអាហ្សង់ទីន ។*

នៅក្នុងឆ្នាំ ១៨៧២ ឃីធី ណាភេឡា បានកើតឃ្លង់ ហើយត្រូវបានតម្រូវឲ្យប្ដូរទៅនៅជាមួយក្រុមអ្នកកើតជំងឺឃ្លង់នៅ ម៉ូឡូកាយ ជាជាងបន្តនៅជាមួយពួកបរិសុទ្ធនោះចូណាថាន់បានសូមអង្វរឲ្យក្រុមនោះទទួលយកគាត់ទៅនៅជាមួយផងដែរ ។ គាត់បានសរសេរសំបុត្រទៅកាន់គណៈកម្មការសុខាភិបាលថា « អំឡុងពេលដ៏ខ្លីដែលនៅសល់នេះ ខ្ញុំចង់រស់នៅជាមួយភរិយារបស់ខ្ញុំ » ។[៦] ការអង្វរករនោះត្រូវបានផ្ដល់ឲ្យ ហើយចូណាថាន់បានក្លាយជាប្រធានសាខានៅម៉ូឡូកាយ ។ ចូណាថាន់បានធ្វើការយ៉ាងជិតស្និទ្ធជាមួយសង្ឃកាតូលិកក្នុងមូលដ្ឋាននោះ គឺលោកឪពុក ដាមៀន ដើម្បីបម្រើដល់អស់អ្នកដែលរងទុក្ខដោយសារជំងឺនោះ ។ ទីបំផុត ចូណាថាន់បានស្លាប់ដោយសារជំងឺឃ្លង់ដែលគាត់បានឆ្លងពីក្រុមនោះ ។



**« ខ្ញុំរីករាយក្នុងការធ្វើជាគ្រឿងឧបករណ៍មួយនៅក្នុងព្រះហស្តនៃព្រះ » ។**

មានតែក្រុមគ្រួសារ ហ្វ្រេដ្រីច និង ហូប ប៉ុណ្ណោះដែលជាពួកបរិសុទ្ធថ្ងៃចុងក្រោយនៅប្រទេសអាហ្សង់ទីន កាលពួកគេបានប្ដូរទីលំនៅពីប្រទេសអាល្លឺម៉ង់ទៅទីនោះនៅដើមទសវត្សរ៍ទី ២០ ។ វីលហែម ហ្វ្រេដ្រីច និងអ៊ីមីល ហូប បានព្យាយាមចែកចាយដំណឹងល្អនៅក្នុងប្រទេសថ្មីរបស់ពួកគេ ដោយចែកកូនសៀវភៅ ហើយអញ្ជើញមនុស្សដទៃទៀតឲ្យចូលរួមការប្រជុំរបស់ពួកគេ ។ វីហែលបានសរសេរថា « ខ្ញុំមានទំនុកចិត្តទាំងស្រុងលើព្រះវរបិតាសួគ៌របស់ខ្ញុំថា ទ្រង់នឹងបញ្ជូនមិត្តភក្ដិដ៏ស្មោះសរ ដែលនឹងទទួលយកដំណឹងល្អ ដ្បិតខ្ញុំរីករាយនៅក្នុងការធ្វើជាគ្រឿងឧបករណ៍នៅក្នុងព្រះហស្តនៃព្រះ » ។[៧]

ប៉ុន្តែមានឧបសគ្គចម្បងនានាបានកើតឡើង ។ ក្រុមគ្រួសារទាំងនេះបានរស់នៅឆ្ងាយពីគ្នា ហើយត្រូវធ្វើដំណើរអស់រយៈពេលពីរម៉ោងដើម្បីជួបគ្នា ។ ដោយសារអ៊ីមីលគឺជាឌីកុន ហើយវីលហែមគឺជាគ្រូនៅក្នុងបព្វជិតភាពអើរ៉ុន នោះពួកគេពុំអាចចាត់ចែងពិធីបរិសុទ្ធដូចជាពិធីសាក្រាម៉ង់ឬផ្ដល់ការប្រសិទ្ធពរបព្វជិតភាពបានឡើយ ។

ក្នុងឆ្នាំ ១៩២៤ ហីលដេហ្គាត ហូប បានបង្កើតកូនស្រីម្នាក់ ដែលកូនស្រីនោះបានស្លាប់នៅរយៈពេលពីរខែក្រោយមក ។ នៅពេលគាត់កាន់ទុក្ខហីលដេហ្គាត បានសួរអំពីរបៀបដែលឈ្មោះរបស់កូនស្រីនោះអាចត្រូវបានដាក់បញ្ចូលទៅក្នុងកំណត់ត្រានៃសាសនាចក្រ ។ ជាលទ្ធផល វីលហែម បាន



*ការតស៊ូរបស់ពួកគេនៅក្នុងការចាក់គ្រឹះនៃសាសនាចក្របានធ្វើឲ្យមនុស្សដទៃទៀតចែកចាយនៅពេលក្រោយទៀតក្នុងការស្វាគមន៍ដល់ពួកបរិសុទ្ធ ។*

ចាប់ផ្ដើមឆ្លើយឆ្លងជាមួយថ្នាក់ដឹកនាំសាសនាចក្រនៅទីក្រុងសលត៍ លេក ។

មួយឆ្នាំកន្លះក្រោយមក អែលឌើរ មែលវិន ជេ បាឡឺដ ( ១៨៧៣–១៩៣៩ ) ក្នុងកូរ៉ុមនៃពួកសាវក ដប់ពីរនាក់ បានបញ្ជូនអ្នកផ្សព្វផ្សាយសាសនាពីរនាក់ទៅជួបក្រុមអ្នកប្រែចិត្តជឿដែលកំពុងរីកចម្រើនឡើងនោះនៅទីក្រុងប៊ុយណូ ហៃរ្ស ។ នៅពេលពួកគេបានទៅដល់ទីនោះនៅក្នុងខែ ធ្នូ ឆ្នាំ ១៩២៥ អែលឌើរ បាឡឺដ បានជ្រមុជទឹកអ្នកប្រែចិត្តជឿជាច្រើននាក់ ហើយបានរៀបចំបង្កើតសាខាមួយឡើង ។ នៅថ្ងៃបុណ្យគ្រីស្ទម៉ាស់ អែលឌើរ បាឡឺដបានឧទ្ទិសទ្វីបអាមេរិកខាងត្បូងសម្រាប់កិច្ចការផ្សព្វផ្សាយសាសនា ហើយបានរៀបចំបេសកកម្មដំបូងឡើងនៅលើទ្វីបនេះ ។

**ការនាំយកដំណឹងល្អត្រឡប់មកកាន់វាស្រ្តរបស់ទ្រង់វិញ**

ហ្វីលីព និង អានីលី អាសាត បានស្គាល់បនាជីវិតមួយដ៏ស្ដុកស្ដម្ភ កាលអ្នកផ្សព្វផ្សាយសាសនាបានគោះទ្វារផ្ទះរបស់ពួកគេនៅ ទីក្រុងខូន ប្រទេស អាល្លឺម៉ង់ ក្នុងឆ្នាំ ១៩៨០ ។ ពួកគាត់បានឱបក្រសោបយកដំណឹងល្អភ្លាម ហើយទទួលអារម្មណ៍នូវ « ពរជ័យដ៏លើសលុប » ។ មិនយូរប៉ុន្មានក្រោយមក ហ្វីលីពបានទទួលអារម្មណ៍យ៉ាងខ្លាំងនូវបំណងប្រាថ្នាដើម្បីត្រឡប់ទៅកាន់ប្រទេសកំណើតរបស់គាត់នៅកូតឌីវ័រ ដើម្បីចែកចាយដំណឹងល្អដែលស្ដារឡើងវិញ ។ ហ្វីលីពបានចាំថា « ដូច្នេះនៅក្នុងឆ្នាំ ១៩៨៦ បន្ទាប់ពីការអធិស្ឋាន និងតមអាហារអស់ជាច្រើនដងជាមួយភរិយារបស់ខ្ញុំ នោះខ្ញុំបានសម្រេចចិត្តត្រឡប់ទៅកូតឌីវ័រវិញ ដើម្បីផ្ដល់នូវអ្វីដែលខ្ញុំបានទទួល ដើម្បីធ្វើឲ្យក្រុមគ្រួសារ និងប្រជាជនជាច្រើនរបស់ខ្ញុំមានភាពប្រសើរឡើង » ។[8]

ពីមុនចាកចេញពីប្រទេសអាល្លឺម៉ង់ ហ្វីលីពបានប្រឹក្សាជាមួយថ្នាក់ដឹកនាំសាសនាចក្រ ។ ទោះបីជាគ្មានអង្គភាពសាសនាចក្រនៅកូតឌីវ័រក្ដី ក៏មានសមាជិកមួយចំនួននៅទីនោះបានចូលជាសមាជិកសាសនាចក្រ ខណៈដែលពួកគេបាននៅក្នុងប្រទេសដទៃទៀត ។ គ្រួសារអាសាតបានទទួលនូវបញ្ជីឈ្មោះរបស់សមាជិកនៅក្រៅប្រទេសទាំងនោះ ហើយនៅឆ្នាំបន្ទាប់មកគាត់បានឧស្សាហ៍សរសេរសំបុត្រទៅកាន់ពួកគេម្នាក់ៗ ។ ដោយសន្សឹមៗ គ្រួសារអាសាតបានបង្កាត់ភ្លើងនៃសេចក្ដីជំនឿនៅក្នុងមនុស្សដទៃ ហើយត្រូវបានផ្ដល់ការអនុញ្ញាតឲ្យចាប់ផ្ដើមធ្វើការប្រជុំនៅថ្ងៃអាទិត្យនៅក្នុងផ្ទះរបស់ពួកគេ ។ មានវួដ និងសាខាជាច្រើនបានកើតឡើងបន្ដមកទៀត ហើយនៅក្នុងឆ្នាំ ១៩៩៧ ស្ដេកដំបូងគេនៅក្នុងប្រទេសកូតឌីវ័រត្រូវបានបង្កើតឡើង ។ ■

**សម្រាប់ព័ត៌មានបន្ថែមស្ដីពីរឿងទាំងនេះ និងពួកបរិសុទ្ធស្មោះត្រង់ជាច្រើននាក់ទៀតនៅជុំវិញពិភពលោក សូមមើលប្រវត្តិប្រទេសនៅក្នុងវគ្គប្រវត្តិសាស្រ្តសាសនាចក្រនៃកម្មវិធីបណ្ណាល័យដំណឹងល្អ ឬនៅគេហទំព័រ history.lds.org ។**



*នៅពេលហ្វីលីព និង អានីលី អាសាត ( ខាងឆ្វេង ) បានជួប លូសៀន និង អាហ្គាធី អាហ្វ្រូអេ នៅក្នុងប្រទេសកូតឌីវ័រ គូស្វាមីភរិយាទាំងពីរនេះបានរីករាយដែលដឹងថា ពួកគេពុំនៅឯកោនៅក្នុងសាសនាចក្រនៅទីនោះឡើយ ។*


កំណត់ចំណាំ

១. Frances McOmber នៅក្នុង Ruth McOmber Pratt « Frantiska Vesela Brodilova » ឯកសារសរសេរដោយដៃដែលពុំបានបោះពុម្ព ( ឆ្នាំ ២០០៩ ) ទំព័រ ១៨ ។

២. Františka Brodilová នៅក្នុង Pratt « Frantiska Vesela Brodilova » ទំព័រ ២៥ ។

៣. Fujiya Nara នៅក្នុង Lee Benson « Japanese Member Survives Adversity » *Church News* ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៩ ទំព័រ ៧ ។

៤. Fujiya Nara នៅក្នុង Benson « Japanese Member Survives Adversity » ទំព័រ ៧ ។

៥. Jonathan Napela នៅក្នុង « Foreign Correspondence: Sandwich Islands — Minutes of Conference, Makawao, April 1st, 1852 » *Deseret News* ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៨៥២ ទំព័រ ៤ ។

៦. Jonathan Napela នៅក្នុង Fred E. Woods « A Most Influential Mormon Islander: Jonathan Hawaii Napela » The Hawaiian Journal of History វ៉ុលទី ៤២ ( ឆ្នាំ ២០០៨ ) ទំព័រ ១៤៨ ។

៧. សំបុត្រឆ្លើយឆ្លង Wilhelm Friedrichs ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ១៩២៤ Argentine Mission បណ្ណាល័យប្រវត្តិសាស្រ្តសាសនាចក្រ ។

៨. Robert L. Mercer « Pioneers in Ivory Coast » *Liahona* ខែ មីនា ឆ្នាំ ១៩៩៩ ទំព័រ ១៩ ។



រូបថតដោយ កូឌី បែល

# ព្រះគម្ពីរមរមន

# ផ្លាស់ប្ដូរជីវិតមនុស្សជាច្រើន

*អ្នកប្រែចិត្តជឿទាំងនេះបានអភិវឌ្ឍសេចក្ដីជំនឿតាមរយៈការអានព្រះគម្ពីរមរមន ។*

ព្រះគម្ពីរមរមនគឺពិតជាអំណោយមួយ ដែលមានបំណងនាំឲ្យយើងដែលជាបុត្រាបុត្រីរបស់ព្រះទៅកាន់ចំណេះដឹងអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដ៏ពិត ។ អ៊ិនរីហ្គ សើប៉ា ប៊ូស្តាម៉ែនតេ សមាជិកមកពីទីក្រុង លីម៉ា ប្រទេស ប៉េរូ គិតថា ព្រះគម្ពីរមរមនគឺជាសំបុត្រមួយមកពីឪពុកម្ដាយដ៏មានសេចក្ដីស្រឡាញ់ ៖ « ព្រះវរបិតាសួគ៌យើងបានសរសេរ ‹ សំបុត្រ › តាមរយៈព្យាការី ប្រទានព្រះដំបូន្មាន ការលួងលោម និងការណែនាំសម្រាប់សេចក្ដីល្អដល់យើង និងប្រទានពរដល់យើងគ្រប់ពេលវេលាទាំងអស់ ។ ទ្រង់មានប្រាជ្ញាឈ្លាសវៃនៅក្នុងផែនការរបស់ទ្រង់ ដែលទ្រង់ជ្រាបដឹងអំពីរបៀបដើម្បីប្រទានដល់យើងនូវសំបុត្រនៃសេចក្ដីស្រឡាញ់ទាំងនោះត្រូវនឹងពេលយើងត្រៀមដួងចិត្តយើងជាស្រេចដើម្បីយល់ពីពរជ័យ និងដំណឹងល្អរបស់ទ្រង់ » ។

នេះគឺជាទីបន្ទាល់មួយចំនួនមកពីអ្នកប្រែចិត្តជឿជាច្រើននាក់នៅជុំវិញពិភពលោកស្ដីពីព្រះគម្ពីរមរមន ដែលមានសារៈសំខាន់យ៉ាងពិសេសចំពោះពួកគេ នៅពេលពួកគេកំពុងរៀនអំពីសាសនាចក្រ ។

**សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ**

ខ្ញុំបានឃើញព្រះគម្ពីរមរមនមួយក្បាលនៅក្នុងផ្ទះរបស់ក្មួយស្រីខ្ញុំនៅទីក្រុងអ៊ីបាដាន ប្រទេសនីហ្សេរីយ៉ា ។ ដោយសារខ្ញុំជាអ្នកចង់ចេះចង់ដឹងក្នុងការអាន នោះខ្ញុំចង់ដឹងចង់យល់ពីមូលហេតុដែលគម្ពីរនោះថ្លែងថា « សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ » ដូច្នោះខ្ញុំបានយកគម្ពីរនោះមកអាន ។

ចំណងជើងរង « សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ » បានបើកដួងចិត្តខ្ញុំទៅរកសក្ខានុពលរបស់ព្រះអង្គសង្គ្រោះសាកលលោកមួយ ជាជាងគ្រាន់តែជាព្រះអង្គសង្គ្រោះនៃសាសន៍អ៊ីស្រាអែល ដែលគ្រានោះគឺជាកង្វល់ដ៏ធំមួយចំពោះខ្ញុំ ។ ការយាងរបស់ទ្រង់ទៅជួបសាសន៍នីហ្វៃ និងការបង្កើតក្រឹត្យវិន័យ និងពិធីបរិសុទ្ធរបស់ទ្រង់ក្នុងចំណោមប្រជាជនទាំងនោះ ធ្វើឲ្យខ្ញុំចង់ដឹងកាន់តែខ្លាំងអំពីការបម្រើរបស់ទ្រង់ ។

ចំណងជើងរងនោះបាននាំខ្ញុំឲ្យរៀនបន្ថែមទៀតអំពីសាសនាចក្រ ។ ខ្ញុំបានចាប់ផ្ដើមទទួលអារម្មណ៍ពីព្រះវិញ្ញាណ ពេលខ្ញុំបានធ្វើតាមការដាស់តឿនដែលបានសរសេរនៅក្នុងព្រះគម្ពីរមរមន ដូចជាការអធិស្ឋានដើម្បីដឹងសេចក្ដីពិតដោយខ្លួនឯងផ្ទាល់ ( សូមមើល មរ៉ូណៃ ១០:៤ ) ។ ឥឡូវនេះ ខ្ញុំដឹងថា ព្រះអង្គសង្គ្រោះមានព្រះជន្មរស់ ហើយស្រឡាញ់យើងទាំងអស់គ្នា ។

អេសេគាល អាខៃ រជ្ជអែដាហូ ស.រ.អា.

**នីហ្វៃទី១ ៨ — ផ្លែឈើ « ជាងអ្វីៗទាំងអស់ដែលខ្ញុំធ្លាប់បានភ្លក់ពីមុន »**

នៅក្នុង នីហ្វៃទី ១ ៨:១១–១២ លីហៃបានពិពណ៌នាអំពីផ្លែនៃដើមជីវិតថា « មានរសជាតិផ្អែមបំផុតគឺផ្អែមជាងអ្វីៗដែលខ្ញុំធ្លាប់បានភ្លក់ពីមុនមក ។ . . . នោះព្រលឹងវិញ្ញាណឪពុកក៏ពោរពេញទៅដោយសេចក្ដីអំណរជាអតិបរមា » ។ នៅពេលខ្ញុំអានខគម្ពីរទាំងនេះ ខ្ញុំមានអារម្មណ៍យ៉ាងខ្លាំងថា ផ្លែឈើនេះគឺពិសេសណាស់ ហើយខ្ញុំមានបំណងចង់បានវា ។

ខ្ញុំទទួលអារម្មណ៍នៃការយល់ចិត្តយ៉ាងខ្លាំងចំពោះលីហៃ ។ ខ្ញុំបានគិតថា ចុះប្រសិនបើខ្ញុំគឺជាលីហៃ ហើយផ្លែឈើនេះនៅមាន នោះខ្ញុំនឹងទទួលអារម្មណ៍ដូចលោកដែរ ហើយខ្ញុំពិតជាចង់ឲ្យគ្រួសារខ្ញុំបរិភោគផ្លែឈើនោះផងដែរ ។ ការណ៍នេះធ្វើឲ្យខ្ញុំទទួលអារម្មណ៍ពិសេសដ៏ពិត ដោយសារឪពុកម្ដាយខ្ញុំពុំមែនជាសមាជិកសាសនាចក្រ ដូច្នេះសូម្បីតែពេលនេះហើយក្ដីពេលខ្ញុំអានខគម្ពីរទាំងនេះក្នុងពេលឥឡូវនេះ នោះខគម្ពីរទាំងនេះហាក់ដូចជាថ្លែងអំពីអ្វីដែលមាននៅក្នុងចិត្តខ្ញុំ ។

ខ្ញុំបានដឹងថា ផ្លែឈើនេះពិសេស ទោះបីពីមុនមកខ្ញុំបានដឹងថា ផ្លែឈើតំណាងឲ្យសេចក្ដីស្រឡាញ់នៃព្រះ និងដំណឹងល្អរបស់ទ្រង់ក្ដី ។ ក្រោយមកពេលខ្ញុំបានយល់អំពីអត្ថន័យរបស់ផ្លែឈើ នោះខ្ញុំបានគិតអំពីអត្ថន័យយ៉ាងច្បាស់របស់វាដែលបានពិពណ៌នានៅក្នុងខគម្ពីរ ។

ព្រះគម្ពីរកត់ត្រានូវសេចក្ដីពិតមកពីពួកព្យាការី ហើយមាននូវព្រះបន្ទូលព្រះប្រាកដមែន ។

អ៊ុន ជីន យឿម យ៉ាំងជី កូរ៉េខាងត្បូង

**យ៉ាកុប ៥:៧៤ — បំណងប្រាថ្នាដើម្បីបម្រើព្រះ**

កាលខ្ញុំកំពុងរៀនអំពីសាសនាចក្រ ខ្ញុំបានអាន យ៉ាកុប ៥:៧៤ ។ វាដក់ជាប់ក្នុងចិត្តខ្ញុំតាំងពីពេលដែលខ្ញុំបានអានវាមក ។ ខ្ញុំគឺជាសមាជិកដ៏សកម្មម្នាក់ពេញមួយជីវិតខ្ញុំ កាលពីនៅព្រះវិហារមុនរបស់ខ្ញុំ ហើយខ្ញុំបានមានចិត្តចង់បម្រើព្រះជានិច្ច ។ ខ្ញុំថែមទាំងមានសង្ឃឹមថា នៅថ្ងៃណាមួយខ្ញុំនឹងសិក្សាទស្សនវិទ្យា និងសាសនាវិទ្យាដើម្បីបម្រើទ្រង់ទៀតផង ។ ខ្ញុំក៏បានជាប់ការប្រឡងចូលរបស់ខ្ញុំដើម្បីរៀនទស្សនវិទ្យាផងដែរ ។

ប៉ុន្តែខ្ញុំនឹងមិនបំភ្លេច ពេលខ្ញុំបានអានខគម្ពីរនោះដំបូងឡើយ ។ ខ្ញុំចាំថា វាគឺជាយប់បន្ទាប់ពីខ្ញុំបានចូលរួមការប្រជុំនៅព្រះវិហារ អិល.ឌី.អេស. ជាលើកដំបូង ។ អំឡុងពេលម៉ោងសម្រាកនៃចន្លោះម៉ោងរៀន ខ្ញុំបានឃើញនៅលើក្តារខៀនបិទព័ត៌មាននូវវិវរណៈដែលប្រធាន ថូម៉ាស អេស ម៉នសុន បានទទួលទាក់ទងនឹងការបន្ថយអាយុរបស់ពួកអ្នកផ្សព្វផ្សាយសាសនា ។



ពេលខ្ញុំអាន យ៉ាកុប ៥:៧៤ នាយប់នោះ ខ្ញុំបានដឹងថា ខ្ញុំត្រូវតែបម្រើព្រះ ។ ហើយមិនដឹងជាយ៉ាងម៉េចទេ ដោយសម្លឹងមើលទៅអ្នកផ្សព្វផ្សាយសាសនា — គឺយុវជនទាំងពីរនាក់នោះដែលមានអាយុស្រាបាលនឹងខ្ញុំ — បានលះបង់ជីវិតរបស់ពួកគេថ្វាយដល់ទ្រង់ នោះខ្ញុំបានដឹងថា នេះគឺជារបៀបដែលខ្ញុំអាចធ្វើដូច្នោះផងដែរ ។ នាយប់មួយពីមុនការប្រជុំនៅព្រះវិហារ ខ្ញុំបានសម្រេចចិត្តទទួលបុណ្យជ្រមុជទឹក ។ យប់ក្រោយពីបុណ្យជ្រមុជទឹក ខ្ញុំបានសម្រេចចិត្តបម្រើបេសកកម្ម ។ ឥឡូវនេះ ខ្ញុំបានត្រឡប់មកផ្ទះវិញដោយកិត្តិយស បន្ទាប់ពីបម្រើប្រជាជនដ៏អស្ចារ្យនៅបេសកកម្ម សេប៊ូ ភាគខាងកើត ប្រទេសហ្វីលីពីន ។

ចូសេហ្វ ហ្វូឌីវេស ទីក្រុងប៉ាតាំងហ្គាស ប្រទេសហ្វីលីពីន

**គម្ពីរអេណុស — ការអភ័យទោសពីអំពើបាប**

ពេលខ្ញុំអានព្រះគម្ពីរមរមនលើកដំបូង ខ្ញុំពុំដឹងថាត្រូវចាប់ផ្ដើមអានពីត្រង់ណាទៅទេ ។ ខ្ញុំមានការលំបាកជាមួយនឹងការអភ័យទោស ជាពិសេសគឺការអភ័យទោសដល់ខ្លួនឯង និងការដឹងថា តើខ្ញុំសក្តិសមនឹងទទួលបានការអភ័យទោសដែរឬអត់ ។ មានស៊ីស្ទើដែលជាអ្នកផ្សព្វផ្សាយសាសនាម្នាក់បានប្រាប់ខ្ញុំថា ខ្ញុំនឹងទទួលចម្លើយនៅក្នុងព្រះគម្ពីរ ហើយថា ប្រសិនបើខ្ញុំពុំដឹងពីកន្លែងចាប់ផ្ដើមអានទេនោះ ខ្ញុំគួរតែអធិស្ឋានឲ្យដឹងអំពីវា និងខគម្ពីរដែលខ្ញុំត្រូវអាននៅត្រង់កន្លែងនោះផងដែរ ។ ខ្ញុំបានសម្រេចចិត្តបើកព្រះគម្ពីរនោះដោយព្រាវ ហើយអាននៅកន្លែងដែលខ្ញុំឈប់ — នៅគម្ពីរអេណុស ខទី ៤–៦ ។ ខ្ញុំបានដឹងថា ព្រះគម្ពីរមរមនពិតនៅគ្រានោះតែម្ដង បន្ទាប់ពីខ្ញុំបានអានវារួច ។

ជេនីហ្វើរ អែនទ្រេស្តី រដ្ឋកាលីហ្វូញ៉ា ស.រ.អា

**ម៉ូសាយ ២៧—ឱកាសដើម្បីផ្លាស់ប្ដូរ**

នៅពេលគ្រាដំបូងដែលខ្ញុំបានអានព្រះគម្ពីរមរមន វគ្គមួយនៃព្រះគម្ពីរមរមនដែលខ្ញុំចូលចិត្តខ្លាំងបំផុតនោះគឺនៅក្នុងម៉ូសាយ ពេលកូនប្រុសរបស់អាលម៉ា ប្រកែកពុំទទួលស្គាល់សាសនាចក្រ ហើយព្យាយាមបំផ្លាញសាសនាចក្រចោល ។ ប៉ុន្តែមានការផ្លាស់ប្ដូរមួយដ៏ធំនៅក្នុងខ្លួនលោក — លោកបានទទួលអារម្មណ៍ពីព្រះវិញ្ញាណ ហើយលោកបានផ្លាស់ប្រែទៅជាអ្នកជឿម្នាក់ ។ ខ្ញុំពិតជាចូលចិត្តដំណើររឿងនោះណាស់ ដោយសារឱកាសដើម្បីផ្លាស់ប្ដូរគួរតែត្រូវបានប្រទានឲ្យដល់មនុស្សគ្រប់រូប ។

ម៉ារៀ ហ្វ្រេសៀ ហិនរីហ្គើក ហ្គុងស្សាលែស ទីក្រុង ម៉ោលេ ប្រទេស ឈីលី ។

**ម៉ូសាយ ២៧:២៨ — ២៩សុភមង្គល និងការប្រោសលោះ**

ក្នុងនាមជាសមាជិកថ្មី ខ្ញុំមានការណ៍អស្ចារ្យក្នុងចិត្តដោយសារបទគម្ពីរ ម៉ូសាយ ២៧:២៨–២៩ ។ ខ្ញុំបាន — ហើយខ្ញុំនៅតែ — មានអំណរគុណដែល



អេសេគាល អាខែ



ចូសេហ្វ ហ្គូធីរ៉េស



ជេនីហ្វើរ អែនទ្រេស្គី



ម៉ារី ចាន់ថល ហុង



វ៉ែនុ បាស្កា ណាក់កា

ព្រះអម្ចាស់មានសេចក្តីមេត្តាករុណាដល់ខ្ញុំ ហើយប្រោសលោះខ្ញុំពីជីវិតនៃអំពើបាបនេះ ។ ពីមុនបុណ្យជ្រមុជទឹករបស់ខ្ញុំ ខ្ញុំបានគិតថា ខ្ញុំមានភាពរីករាយ ប៉ុន្តែគ្មានអ្វីអាចយកមកប្រៀបផ្ទឹមនឹងសុភមង្គល ដែលខ្ញុំបានទទួលអារម្មណ៍ នៅពេលខ្ញុំបានទទួលយកដំណឹងល្អដែលបានស្តារឡើងវិញឡើយ ។ ខ្ញុំពុំធ្លាប់បានមានទំនុកចិត្ត និងប្រាកដប្រាជាដូចនេះឡើយថា អនាគតដ៏ភ្លឺស្វាងបាននៅរង់ចាំខ្ញុំនោះ ។

បន្ទាប់ពីការទទួលយកការអញ្ជើញរបស់អាលម៉ាឲ្យ « ចូរមក ហើយទទួលបុណ្យជ្រមុជទឹកចំពោះការប្រែចិត្តចុះ ដើម្បីឲ្យអ្នករាល់គ្នាអាចបានទៅជាពួកអ្នកទទួលទាននូវផ្លែនៃដើមជីវិតដែរ » ( អាលម៉ា ៥:៦២ ) ខ្ញុំបានដកបទពិសោធន៍នៃការលួងលោមស្រដៀងគ្នានោះ និងការរំដោះដ៏សុខសាន្តដូចដែលអាលម៉ាជាកូនបានមាន កាលលោកបានសរសេរថា ៖ « ខ្ញុំបាននៅក្នុងជ្រោះជ្រៅងងឹត ប៉ុន្តែឥឡូវនេះ ខ្ញុំឃើញពន្លឺដ៏អស្ចារ្យនៃព្រះហើយ ។ ព្រលឹងខ្ញុំត្រូវបានញាំញីដោយសេចក្តីទុក្ខវេទនាដ៏អស់កល្បជានិច្ច ប៉ុន្តែឥឡូវនេះ ខ្ញុំត្រូវបានទាញចេញមកហើយ ហើយព្រលឹងខ្ញុំពុំឈឺចាប់ទៀតទេ » ( ម៉ូសាយ ២៧:២៩ ) ។ វគ្គបទគម្ពីរនេះបានជួយខ្ញុំឲ្យយល់ថា ការចាប់ផ្តើមជីវិតថ្មីរបស់ខ្ញុំ និងសុភមង្គលដែលទើបតែរកឃើញនោះត្រូវបានបង្កើតឡើងនៅលើការទទួលស្គាល់ថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះរបស់ខ្ញុំ ។ ឥឡូវនេះ ខ្ញុំមានអំណរគុណជានិរន្តរថា ព្រះអង្គសង្គ្រោះរបស់ខ្ញុំបានបង់ថ្លៃនៃភាពយុត្តិធម៌ ហើយអនុញ្ញាតឲ្យខ្ញុំទទួលអារម្មណ៍នៃសេចក្តីស្រឡាញ់ដ៏ប្រោសលោះដដែលនោះម្តងហើយម្តងទៀតគ្រប់ពេលដែលខ្ញុំបានប្រែចិត្ត ។

ម៉ារី ចាន់ថល ហុង ទីក្រុង អនតារីយ៉ូ ប្រទេសកាណាដា

### សៀវភៅពណ៌ខៀវតូចនោះ

ខ្ញុំបានធំឡើងនៅក្នុងប្រទេសឥណ្ឌា ជាកន្លែងដែលខ្ញុំបានជួបពួកអ្នកផ្សព្វផ្សាយសាសនា ហើយបានចូលរួមសាសនាចក្រ ។ នៅថ្ងៃអាទិត្យនោះវាគាប់ជួនជាថ្ងៃអាទិត្យនៃបុណ្យអ៊ីស្ទើរ ។ ដោយសារកាលវិភាគការងាររបស់ខ្ញុំ នោះខ្ញុំបានទៅព្រះវិហារយឺត ហើយបានចូលរួមថ្នាក់សាលាថ្ងៃអាទិត្យរបស់ពួកយុវវ័យ ជាកន្លែងដែលអ្នកផ្សព្វផ្សាយម្នាក់បានបង្រៀនមេរៀន ។ គាត់បានដកស្រង់ខគម្ពីរមួយចំនួនមកពីសៀវភៅពណ៌ខៀវដែលខ្ញុំពុំធ្លាប់បានឃើញពីមុនឡើយ ប៉ុន្តែវាដូចជាព្រះគម្ពីរបរិសុទ្ធ ។ នៅពេលគាត់កំពុងបង្រៀន ខ្ញុំទទួលអារម្មណ៍យ៉ាងខ្លាំងក្នុងចិត្តរបស់ខ្ញុំ ហើយបានដឹងថា ខ្ញុំក៏គួរតែមានសៀវភៅនោះផងដែរ ។

ខ្ញុំបានទៅជួបគាត់ដោយផ្ទាល់បន្ទាប់ពីចប់ថ្នាក់រៀន ហើយបានប្រាប់គាត់ថា « ខ្ញុំត្រូវការសៀវភៅនោះ » ។ ដោយសារតែសៀវភៅនោះគឺជាព្រះគម្ពីរមួយឈុតរបស់គាត់ផ្ទាល់ នោះគាត់ពុំអាចឲ្យវាមកខ្ញុំឡើយ ប៉ុន្តែគាត់បានឲ្យខ្ញុំមើលវា ហើយទទួលអារម្មណ៍ពីវា ។ ខ្ញុំបានឃើញអក្សរដែលមានពណ៌ទឹកមាសដែលមានក្បាច់ក្បូរនៅលើក្របខាងមុខសរសេរថា ៖ « ព្រះគម្ពីរមរមន » ។ ខ្ញុំបានទទួលអារម្មណ៍ដូចគ្នានោះម្តងទៀតថា ខ្ញុំត្រូវការព្រះគម្ពីរនោះសម្រាប់ខ្លួនខ្ញុំផ្ទាល់ ។ អ្នកផ្សព្វផ្សាយសាសនាបានយកអាសយដ្ឋានរបស់ខ្ញុំ ហើយបានសន្យាថានឹងយកព្រះគម្ពីរនេះមួយក្បាលឲ្យខ្ញុំ ។ ប្រាកដណាស់ មិនយូរប៉ុន្មានក្រោយមក ពួកអ្នកផ្សព្វផ្សាយសាសនាបានមកដល់ផ្ទះខ្ញុំ ហើយបានបង្ហាញខ្ញុំនូវព្រះគម្ពីរមរមនដែលជាព្រះគម្ពីរផ្ទាល់របស់ខ្ញុំ ។ បន្ទាប់មក ពួកគេបានបង្រៀនការពិភាក្សាដល់ខ្ញុំ ។

នៅឆ្នាំនោះ បុណ្យអ៊ីស្ទើរបាននាំមកនូវពរជ័យដ៏មិនគួរឲ្យជឿមកក្នុងជីវិតខ្ញុំ ៖ គឺព្រះគម្ពីរមរមន ។ សៀវភៅពណ៌ខៀវតូចនោះបាននាំមកនូវវិញ្ញាណនៃជីវិតមកកាន់ជីវិតរបស់ខ្ញុំ ហើយខ្ញុំមានអំណរគុណដែលខ្ញុំមានឯកសិទ្ធិដើម្បីរៀនពីព្រះគម្ពីរនេះ ។ ■

វ៉ែនុ បាស្កា ណាក់កា រដ្ឋកាលីហ្វ័រញ៉ា ស.រ.អា.



### សេចក្តីពិតដ៏មានឥទ្ធិពលនៅក្នុងព្រះគម្ពីរមរមន

« មានរឿងអស្ចារ្យមួយកើតឡើងពេលកូនម្នាក់របស់ព្រះស្វែងយល់ចង់ដឹងបន្ថែមទៀតអំពីទ្រង់ និងព្រះរាជបុត្រាស្ងួនភ្ជាទ្រង់ ។ គ្មានកន្លែងណាផ្សេងទៀតដែលសេចក្តីពិតទាំងនោះបានបង្រៀនកាន់តែច្បាស់ ហើយកាន់តែពេញដោយអនុភាពជាងនៅក្នុងព្រះគម្ពីរមរមនឡើយ ។ . . .

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះគម្ពីរមរមនពិតជាបន្ទូលរបស់ព្រះ ។ វាមាននូវចម្លើយសម្រាប់សំណួរពិបាកៗបំផុតក្នុងជីវិត » ។

ប្រធាន រ័សុល អិម ណិលសុន « ព្រះគម្ពីរមរមន ៖ តើជីវិតរបស់អ្នកទៅជាយ៉ាងណា បើគ្មានគម្ពីរនេះ ? » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ៦១, ៦២ ។

# មនុស្សល្អនៃទីក្រុងសេន ចច

កាលខ្ញុំអាយុប្រហែល ១២ ឆ្នាំ ខ្ញុំបានឃើញខ្សែភាពយន្តសាសនាចក្រដែលបង្ហាញអំពីប្រធាន ឡូរ៉ែនសូ ស្នូ ( ១៨១៤–១៩០១ ) អធិស្ឋានទូលសូមពរឲ្យពួកបរិសុទ្ធថ្ងៃចុងក្រោយនៅទីក្រុងសេន ចច រដ្ឋ យូថាហ៍ ស. រ. អា. ដែលកំពុងរងទុក្ខមកពីគ្រោះរាំងស្ងួតដ៏ធ្ងន់ធ្ងរ ។

ប្រធាន ស្នូបានអធិស្ឋានថា « ឱព្រះអម្ចាស់អើយ សូមប្រទានពរដល់មនុស្សល្អនៅទីក្រុងសេន ចច » ។

ឃ្លានោះ « មនុស្សល្អនៃទីក្រុងសេន ចច » បានបន្សល់ទុកនូវការបំផុសគំនិតដ៏យូរអង្វែងនៅក្នុងគំនិតមនុស្សវ័យក្មេងដូចរូបខ្ញុំ ។ ដោយសារខ្ញុំរស់នៅប្រទេសឈីលី នោះខ្ញុំបានព្យាយាមស្រមៃគិតអំពីប្រភេទនៃពួកបរិសុទ្ធដែលស្មោះត្រង់ « មនុស្សល្អនៃទីក្រុងសេន ចច » ថាជាមនុស្សដែលត្រូវមានលក្ខណៈបែបណា ។ ខ្ញុំចង់ជួបពួកគាត់ ។

ច្រើនជាង ៣០ ឆ្នាំក្រោយមក ក្នុងឆ្នាំ ២០០៥ គ្រួសាររបស់ខ្ញុំ និងខ្ញុំបានយកកូនប្រុសទីពីររបស់យើងទៅទីក្រុងប្រូវ៉ូ រដ្ឋយូថាហ៍ ដើម្បីចូលរួមនឹងបងប្រុសរបស់គាត់ដែលកំពុងរៀននៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់ ។ នៅល្ងាចបន្ទាប់ពីយើងបានទៅដល់ទីនោះ ខ្ញុំបាននិយាយថា « ខ្ញុំចង់ទៅជួបមនុស្សល្អនៃទីក្រុងសេន ចច » ។

កូនប្រុសច្បងរបស់យើងបានប្រកែកថា « អត់ទេប៉ា សេន ចន នៅឆ្ងាយណាស់ » ។

ខ្ញុំបានតបថា « កូនប៉ាគឺជាអ្នកដែលបានបង់ថ្លៃសំបុត្រយន្តហោះ ។ គឺប៉ាកំពុងបង់ថ្លៃអាហារ ។ គឺប៉ាកំពុងបង់ថ្លៃសាំង ។ ហើយប៉ាគ្រាន់តែចង់បានអ្វីមួយសម្រាប់ខ្លួនប៉ាប៉ុណ្ណោះ ។ ប៉ាចង់ជួបមនុស្សល្អនៃទីក្រុងសេន ចច ! »

កូនប្រុសរបស់ខ្ញុំបាននិយាយថា « យល់ព្រម » បន្ទាប់ពីគាត់បានដឹងថា ខ្ញុំនិយាយពិតប្រាកដមែន ។

លុះស្អែកឡើង យើងបានជិះឡានអស់ចម្ងាយ ៤១៨ គីឡូម៉ែត្រ ។ បន្ទាប់ពីទៅដល់ទីក្រុងសេន ចច ហើយ យើងបានទៅមជ្ឈមណ្ឌលអ្នកទស្សនានៅឯព្រះវិហារបរិសុទ្ធ ហើយដើរទស្សនាផ្ទះរដូវរងាររបស់ប្រធាន ព្រិកហាំ យ៉ង់ ( ១៨០១–១៨៧៧ ) ។ យើងក៏បានទៅទស្សនារោងឧបោសថផងដែរ ជាកន្លែងដែលខ្ញុំត្រូវបានអញ្ជើញឲ្យនិយាយទៅកាន់ក្រុមគ្រួសាររបស់ខ្ញុំរយៈពេលមួយនាទីពីវេទិកាដដែលដែលប្រធាន ស្នូបានថ្លែងអំពី « មនុស្សល្អនៃទីក្រុងសេន ចច » ។ យើងបានដើរជុំវិញទីក្រុងនោះបានមើល និងជួបមនុស្សម្នា ។ ពួកគេហាក់ដូចជាមនុស្សធម្មតា គឺជាពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏ស្មោះត្រង់ ។

ខ្ញុំរីករាយណាស់ដែលយើងបានទៅទីនោះ ។ ប៉ុន្តែនៅពេលយើងបានត្រឡប់មកប្រទេសឈីលី វិញ ខ្ញុំបានដឹងនូវអ្វីមួយ ៖ ខ្ញុំធ្លាប់បានឃើញ « មនុស្សល្អនៃទីក្រុងសេន ចច » ពីមុន ។

ដោយសារតែការងារ និងការហៅក្នុងសាសនាចក្ររបស់ខ្ញុំ នោះខ្ញុំបានធ្វើដំណើរទូទាំងប្រទេសឈីលី ។ នៅក្នុងទីក្រុង ខាឡាម៉ា ខ្ញុំបានឃើញពួកយុវមជ្ឈិមវ័យដែលព្យាយាមគោរពតាមព្រះបញ្ញត្តិ ។ នៅឡា សែរ៉េណា ខ្ញុំបានឃើញឪពុកម្ដាយដែលមានការលះបង់មកដល់ការប្រជុំមុនម៉ោងជាមួយកូនៗរបស់ពួកគេសម្រាប់ការប្រជុំនៅព្រះវិហារ ។ នៅទីក្រុង អែនតូហ្វាហ្គាសស្ដា ខ្ញុំបានឃើញពួកបរិសុទ្ធថ្ងៃចុងក្រោយដែលបានប្រយុទ្ធស្វែងរកសិទ្ធិរបស់ពួកគេរៀងរាល់ថ្ងៃ ។ នៅទីក្រុង វ៉ាលិនណា, កូភៀប៉ូ, ខាលឌើរ៉ា, តូខូពីឡា និងទីក្រុងផ្សេងៗទៀត ខ្ញុំបានឃើញសមាជិកដែលលុតជង្គង់អធិស្ឋាន ហើយបន្ទាប់មកបោះជំហានឆ្ពោះទៅមុខ ទោះបីជាកិច្ចការនានាពុំងាយស្រួលក្ដី ។

នៅពេលខ្ញុំឃើញពួកបរិសុទ្ធថ្ងៃចុងក្រោយដែលគោរព និងការខ្ជាប់ខ្ជួន — ទោះបីពួកគេរស់នៅទីណាក្ដី ឬឧបសគ្គអ្វីដែលពួកគេជួបប្រទះក៏ដោយ — ខ្ញុំបាននិយាយប្រាប់ខ្លួនឯងថា « ទាំងនេះគឺជាមនុស្សល្អនៃទីក្រុង សេន ចច » ។ ■

ខ្លោឌីយូ ហ្គុងស្សាណែល ទីក្រុងអានតូហ្វាហ្គាស្ដា ប្រទេស ឈីលី

នៅពេលខ្ញុំឃើញពួកបរិសុទ្ធថ្ងៃចុងក្រោយ — ទោះបីពួកគេរស់នៅទីណាក្ដី — ខ្ញុំបាននិយាយប្រាប់ខ្លួនឯងថា « ទាំងនេះគឺជាមនុស្សល្អនៃទីក្រុង សេន ចច » ។





ចេនារូបភាពដោយ អេលែន ហ្គានស៍

# « តាមពិតទៅ ខ្ញុំគឺជាសមាជិកសាសនាចក្រ »

ខ្ញុំទើបតែអង្គុយលើឡានក្រុង កាលមានបុរសម្នាក់បានដើរកាត់ច្រកផ្លូវក្នុងឡាននោះដោយផ្អៀងខ្លួនមកលើខ្ញុំ ហើយនិយាយថា « ព្រលឹងរបស់អ្នកស្រស់ស្អាតណាស់ » ។

ប្រាកដណាស់ ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង ។ គ្មាននរណាធ្លាប់សរសើរអំពីព្រលឹងខ្ញុំពីមុនឡើយ ។ ដោយពុំប្រាកដអំពីអ្វីដែលត្រូវតបទៅវិញ នោះខ្ញុំគ្រាន់តែនិយាយថា « អរគុណ » ។

បុរសនោះបានប្រាប់ខ្ញុំថា គាត់អាចប្រាប់រឿងនេះបានដោយសារគាត់ធ្វើការជាមួយក្រុមសាសនារបស់គាត់ ។ ខ្ញុំបានស្ដាប់គាត់ នៅពេលគាត់បានផ្ដល់ដំបូន្មានដល់ខ្ញុំស្ដីពីរបៀបដើម្បីរក្សាព្រលឹងរបស់ខ្ញុំឲ្យល្អស្អាត ។

នៅពេលឡានក្រុងបើកដល់ចំណតមួយ យើងទាំងពីរនាក់បានឈរនៅមាត់ច្រកទ្វារចេញ ហើយគាត់បានផ្ដល់ជាយោបល់មួយចុងក្រោយមកកាន់ខ្ញុំ ៖ « សូមប្រាកដថា អ្នកពុំស្ដាប់តាមពួកមរមនទាំងនោះទេ » ។

ពេលវេលានោះហាក់ដូចជាមិនដើរទៅមុខសោះ ។ បុរសម្នាក់នេះបានឃើញអ្វីមួយពិសេសនៅលើមុខរបស់ខ្ញុំ ប៉ុន្តែគាត់ពុំដឹងសោះឡើយថាវាកើតមក *ដោយសារ* សាសនារបស់ខ្ញុំ ។

តើខ្ញុំត្រូវឆ្លើយតបដូចម្ដេចទៅ ? និយាយតាមត្រង់ទៅ គំនិតដំបូងរបស់ខ្ញុំគឺថា ខ្ញុំមិននិយាយអ្វីទាំងអស់ ហើយធ្វើពុតដូចជាពុំឮគាត់និយាយ ។ ខ្ញុំបារម្ភថា ប្រសិនបើខ្ញុំប្រាប់គាត់ថា ខ្ញុំជាសមាជិកសាសនាចក្រ នោះគាត់ប្រហែលជាឆ្លើយតបយ៉ាងអវិជ្ជមាន ឬប្រហែលជាគម្រោះគម្រើយទៀតផង ។

ប៉ុន្តែក្រោយមកមានខគម្ពីរមួយបានផុសក្នុងគំនិតរបស់ខ្ញុំ ៖ « ដ្បិតខ្ញុំគ្មានសេចក្ដីខ្មាស ចំពោះដំណឹងល្អនៃព្រះគ្រីស្ទទេ ពីព្រោះជាព្រះចេស្ដានៃព្រះ សម្រាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ » ( រ៉ូម ១:១៦ ) ។ ខ្ញុំបានដឹងថា ខ្ញុំពុំខ្មាសចំពោះដំណឹងល្អឡើយ ហើយខ្ញុំបានដឹងថា ព្រលឹងរបស់ខ្ញុំពុំអាចបញ្ចាំងពន្លឺចេញទៅដល់អ្នកដទៃឡើយ ប្រសិនបើខ្ញុំពុំក្រោកឈរឡើងធ្វើជាសាក្សីនោះ ។ ដោយការតាំងចិត្តថ្មីរបស់ខ្ញុំ នោះខ្ញុំបានមើលទៅបុរសនោះ ហើយនិយាយថា « តាមពិតទៅ ខ្ញុំគឺជាសមាជិកសាសនាចក្រ » ។



ខ្ញុំបានដឹងថា ព្រលឹងរបស់ខ្ញុំពុំអាចបញ្ចាំងពន្លឺចេញទៅដល់អ្នកដទៃឡើយ ប្រសិនបើខ្ញុំពុំបានក្រោកឈរឡើងធ្វើជាសាក្សីនោះ ។

គំនូរដោយ ប្រេដលី ខ្លាក

បុរសនោះបានសម្លឹងមើលខ្ញុំ ហើយខ្ញុំបានសម្លឹងមើលគាត់វិញ ។ គួរឲ្យភ្ញាក់ផ្អើលណាស់ គាត់បានសើច ហើយបាននិយាយថា គាត់ពុំអាចចូលជាសមាជិកសាសនាចក្របានទេ ដោយសារគាត់ចូលចិត្តផឹកកាហ្វេខ្លាំងពេក ។ ខ្ញុំក៏បានសើចផងដែរ ហើយយើងបានបែកគ្នាទៅតាមផ្លូវរៀងៗខ្លួន ។

រហូតមកដល់សព្វថ្ងៃ ខ្ញុំសប្បាយរីករាយអំពីជម្រើសដែលខ្ញុំបានធ្វើ ។ ខ្ញុំដឹងថា វាអាចជាការពិបាកក្នុងឲ្យគេដឹងថា អ្នកជាសមាជិកសាសនាចក្រ ។ ជូនកាលវាអាចជារឿងគួរឲ្យតក់ស្លុត ! ប៉ុន្តែនៅពេលយើងឈរយ៉ាងរឹងប៉ឹងតំណាងឲ្យព្រះ នោះព្រលឹងយើងអាចបញ្ចាំងជាពន្លឺដល់ពិភពលោក ។ ■

អាប់ប៊ី ស្សុន ដេមួយថាហ៍ ស.រ.អា



ការរត់របស់ខ្ញុំនៅចំណតនោះបានបន្តជាទៀងទាត់អស់រយៈពេលបីឆ្នាំ ។

# ការជួបប្រទះនឹងសាសនាចក្រដោយចៃដន្យ

ថ្ងៃមួយ អំឡុងពេលកំពុងរកមើលកន្លែងរត់ហាត់ប្រាណ នោះខ្ញុំបានសម្រេចចិត្តសាកល្បងរត់នៅចំណតរថយន្តរបស់ព្រះវិហារនៅក្នុងភូមិរបស់ខ្ញុំ ។ ខ្ញុំចូលចិត្តវា ដោយសារវាមានពន្លឺភ្លើង និងមានចាក់បេតុង ។ ខ្ញុំរកឃើញថា ការរត់ជុំវិញអគារនោះពី ១០ ទៅ ១៥ ដងស្មើនឹងការរត់ចម្ងាយ ៤.៨ គីឡូម៉ែត្រនៃការហាត់ប្រាណរបស់ខ្ញុំ ។

ការរត់របស់ខ្ញុំនៅចំណតនោះបានបន្តជាទៀងទាត់អស់រយៈពេលបីឆ្នាំ ។ ពីពេលមួយទៅពេលមួយទៀត ខ្ញុំបានឃើញមនុស្សនៅចំណតនោះ ដោយសារជួនកាលខ្ញុំរត់នៅអំឡុងពេលការប្រជុំព្រះវិហារ និងសកម្មភាពដទៃទៀត ។

ជាច្រើនលើកច្រើនគ្រា ខ្ញុំមានការបំផុសគំនិតថា ខ្ញុំត្រូវនិយាយជាមួយនរណាម្នាក់អំពីសាសនាចក្រ ប៉ុន្តែខ្ញុំពុំដឹងថាត្រូវធ្វើដូចម្ដេចឡើយ ។ នៅតាមផ្លូវពេលខ្ញុំត្រឡប់មកពីធ្វើការវិញនាល្ងាចមួយ ខ្ញុំបានសម្រេចចិត្តឈប់ ហើយសម្លឹងរកមើល ក្រែងខ្ញុំអាចរកឃើញនរណាម្នាក់នៅទីនោះ ។ នៅពេលខ្ញុំបានដើរទៅក្នុងអគារសាសនាចក្រ ខ្ញុំបានជួបពួកអ្នកផ្សព្វផ្សាយសាសនា នៅពេលពួកគេបានបញ្ចប់ការសម្ភាសន៍ជាមួយប្រធានបេសកកម្មរបស់ពួកគេ ។ ខ្ញុំបានណែនាំខ្លួនខ្ញុំ ហើយបានអង្គុយនៅលើកៅអីត្រង់ច្រកដើរនោះ ។ នោះជាកន្លែងដែលពួកគេបានបង្រៀនខ្ញុំជាលើកដំបូងអំពីមេរៀននៃដំណឹងល្អ ។

អស់រយៈពេលពីរសប្ដាហ៍ជាងបន្ទាប់មក ខ្ញុំបានបន្តជួបនឹងពួកអ្នកផ្សព្វផ្សាយសាសនា ។ នៅពេលខ្ញុំបានចូលរួមពិធីសាក្រាម៉ង់ សមាជិកនៅវួដនោះបានបង្ហាញសេចក្ដីស្រឡាញ់ ការទទួលយក ការស្វាគមន៍ និងការលើកទឹកចិត្តដល់ខ្ញុំ ។ នៅពេលខ្ញុំបានគិតអំពីអ្វីដែលខ្ញុំកំពុងរៀន នោះខ្ញុំបានដឹងថា ការចង់ដឹងចង់យល់របស់ខ្ញុំអំពីសាសនាចក្របានអភិវឌ្ឍទៅកតម្រូវការឲ្យខ្ញុំសម្រេចចិត្តទទួលបុណ្យជ្រមុជទឹក ។ ខ្ញុំបានទទួលអារម្មណ៍ថា ខ្ញុំត្រូវបានបំផុសគំនិតដោយព្រះវិញ្ញាណឲ្យធ្វើនូវអ្វីដែលព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យខ្ញុំធ្វើ ប៉ុន្តែខ្ញុំបានបន្តពុះពារជាមួយនឹងការសម្រេចចិត្តនោះ ។ ទីបំផុតខ្ញុំបានជ្រមុជទឹកនៅខែ វិច្ឆិកា ឆ្នាំ ២០០១ នៅអាយុ ៣៦ ឆ្នាំ ។

ការសម្រេចចិត្តរបស់ខ្ញុំដើម្បីរត់នៅក្នុងចំណតរបស់ព្រះវិហារនោះហាក់ដូចជាគ្រាមួយមិនគួរឲ្យអស្ចារ្យឡើយ ។ ប៉ុន្តែវាបាននាំខ្ញុំទៅកាន់ពរជ័យដ៏មហិមារបស់ខ្ញុំ ៖ គឺសមាជិកភាពនៅក្នុងសាសនាចក្រ, ការជួបនឹងភរិយាដ៏អស្ចារ្យរបស់ខ្ញុំ គឺ ជេននីហ្វើរ ហើយបានផ្សារភ្ជាប់នឹងគាត់សម្រាប់ពេលនេះ និងអស់កល្បជានិច្ចនៅក្នុងព្រះវិហារបរិសុទ្ធសាន់ឌីអាហ្គោ កាលីហ្វញ៉ា ។

ដូច្នេះប្រសិនបើដោយចៃដន្យអ្នកបានឃើញនរណាម្នាក់ហាត់ប្រាណនៅក្នុងចំណតនៃសាលាប្រជុំរបស់អ្នក សូមណែនាំខ្លួនរបស់អ្នកឲ្យគាត់ស្គាល់ ! អ្នកពុំដឹងឡើយ — ថាមិនយូរមិនឆាប់ គាត់អាចក្លាយជាសមាជិកថ្មីនៅក្នុងវួដរបស់អ្នក ! ■

ដានីយ៉ែល អ័រ ថមសុន រដ្ឋកាលីហ្វ័រញ៉ា ស.រ.អ.

រចនារូបភាពដោយ អេលែន ហ្គានស៍

# ការទូន្មានដែលខ្ញុំពុំចង់ឮ

នៅពេលស្វាមីខ្ញុំ និងខ្ញុំបានចាប់ផ្ដើមអាជីវកម្មផ្ទាល់ខ្លួនរបស់យើង នោះនៅបីឆ្នាំដំបូងមានការលំបាកណាស់ ។ យើងពុំបានទទួលប្រាក់ចំណេញទេ ហើយយើងធ្លាក់ទៅក្នុងការជំពាក់បំណុល ។ យើងបានខិតខំធ្វើការ ប៉ុន្តែបញ្ហាដែលពុំអាចរំពឹងទុកជាមុនបានធ្វើឲ្យគ្រានោះក្លាយជាគ្រាដ៏លំបាកបំផុតនៃជីវិតរបស់យើង ។

វាកាន់តែអាក្រក់ឡើង នៅពេលម្ដាយក្មេករបស់ខ្ញុំបានចែកឋានទៅនៅថ្ងៃបន្ទាប់ពីបុណ្យគ្រីស្ទម៉ាស់ ហើយមួយសប្ដាហ៍ក្រោយមកគឺមុនយប់ថ្ងៃបុណ្យចូលឆ្នាំថ្មី នោះខ្ញុំបានធ្លាក់ខ្លួនឈឺយ៉ាងខ្លាំង ។ នាគ្រានោះយើងគ្មានប្រាក់សោះ ហើយយើងបានបាត់ឡានរបស់យើង ហើយអ្វីដែលកាន់តែអាក្រក់បំផុតនោះគឺ យើងគ្មានប្រាក់នឹងបង់ការធានារ៉ាប់រងសុខភាពរបស់យើងឡើយ ។

ទីបំផុត ខ្ញុំត្រូវបានធ្វើរោគវិនិច្ឆ័យដឹងថា មានកើតជំងឺមហារីកដ៏កាចសាហាវមួយប្រភេទ ដែលវាបានអភិវឌ្ឍអស់រយៈពេលយ៉ាងហោចណាស់ប្រាំឆ្នាំមកហើយ ។ វាមានសភាពធ្ងន់ធ្ងរ ហើយតម្រូវឲ្យវះកាត់ជាបន្ទាន់ ។ ខ្ញុំគ្មានពេលច្រើនឡើយ ហើយយើងគ្មានប្រាក់ដើម្បីចំណាយថ្លៃព្យាបាលដែលខ្ញុំត្រូវការឡើយ ។

ស្វាមីរបស់ខ្ញុំ និងខ្ញុំបានជួបជាមួយប៊ីស្សពរបស់យើង ហើយយើងបានសូមរកជំនួយ ។ យើងបានពន្យល់ថា នេះពិតជាករណីរឿងស្លាប់រស់ ។ ប៊ីស្សពបានខ្វល់ខ្វាយ ប៉ុន្តែគាត់បានប្រាប់យើងថា គាត់បានទទួលការបំផុសគំនិតឲ្យចាំបន្តិចទៀត ពីមុនផ្ដល់ជំនួយប្រសិនបើមានមធ្យោបាយមួយផ្សេងទៀតប្រហែលជាអាចបើកផ្លូវសម្រាប់យើង ។ គាត់បានអះអាងនឹងយើងថា ប្រសិនបើសេចក្ដីជំនឿរបស់យើងមានគ្រប់គ្រាន់ នោះព្រះអម្ចាស់នឹងប្រទានមធ្យោបាយមួយសម្រាប់ខ្ញុំឲ្យទទួលបានជំនួយដែលខ្ញុំត្រូវការ ។

នៅគ្រាដំបូង ការឆ្លើយតបរបស់ប៊ីស្សពបានធ្វើឲ្យខ្ញុំខឹង និងមានការថ្នាំងថ្នាក់ចិត្ត ។ ខ្ញុំមានអារម្មណ៍ថា ទាំងគាត់ និងព្រះអម្ចាស់បានបោះបង់ខ្ញុំចោល ។ ប៉ុន្តែខ្ញុំមានទីបន្ទាល់អំពីដំណឹងល្អ ហើយខ្ញុំបានជឿថា ប៊ីស្សពរបស់យើងត្រូវបានហៅពីព្រះ ។ ទោះបីជាដួងចិត្តរបស់ខ្ញុំឈឺចាប់ក្ដី ខ្ញុំបានអធិស្ឋានទូលសូមថា ព្រះវរបិតាសួគ៌នឹងជួយខ្ញុំឲ្យបន្តស្រឡាញ់ គោរព និងគាំទ្រប៊ីស្សពរបស់ខ្ញុំ ។ នៅពេលខ្ញុំបានអធិស្ឋានទូលសូមរឿងនេះ នោះខ្ញុំត្រូវបានលួងលោម ហើយទទួលអារម្មណ៍ថា ព្រះអម្ចាស់នឹងជួយខ្ញុំនៅក្នុងរបៀបផ្សេង ។

ស្វាមីខ្ញុំ និងខ្ញុំបានបន្តឆ្ពោះទៅមុខដោយសេចក្ដីជំនឿ ហើយខ្ញុំបានទទួលការធ្វើតេស្តវេជ្ជសាស្ត្រចាំបាច់នានា ព្រមទាំងដាក់កាលវិភាគសម្រាប់ការវះកាត់របស់ខ្ញុំ ទោះបីជាយើងខ្វះប្រាក់ក្ដី ។ នៅថ្ងៃមុនការវះកាត់របស់ខ្ញុំ យើងបានលក់អាជីវកម្មរបស់យើងក្នុងតម្លៃមួយដ៏ល្អ ដែលធ្វើឲ្យយើងអាចបង់ថ្លៃការចំណាយថ្លៃពេទ្យរបស់ខ្ញុំទាំងអស់ ។

ឥឡូវនេះ វាប្រែកាន់តែច្បាស់ថា ហេតុអ្វីប៊ីស្សពរបស់ខ្ញុំមានចិត្តស្ទាក់ស្ទើរក្នុងការជួយ ។ គាត់បានធ្វើតាមការបំផុសគំនិត ដើម្បីឲ្យខ្ញុំមានបទពិសោធន៍ខាងវិញ្ញាណដ៏មានតម្លៃមួយ ។ បទពិសោធន៍នោះបានបង្រៀនខ្ញុំឲ្យទុកចិត្តលើព្រះអង្គសង្គ្រោះ ទោះបីជាផ្លូវនោះហាក់ដូចជាមានឧបសគ្គ និងភ័យខ្លាចយ៉ាងណាក្ដី ។ ខ្ញុំមានអំណរគុណចំពោះការទូន្មានដែលខ្ញុំពុំចង់ឮមកពីប៊ីស្សពរបស់ខ្ញុំ ។ ឥឡូវនេះខ្ញុំដឹងថា ព្រះគឺជាព្រះនៃអព្ភូតហេតុ ហើយទ្រង់ពុំដែលបោះបង់យើងចោលឡើយ ។ ■

ឈ្មោះត្រូវបានលាក់ ទីក្រុង ព័រតូ អាលេហ្គ្រេ ប្រទេស ប្រេស៊ីល



ខ្ញុំគ្មានពេលច្រើនឡើយ ហើយយើងគ្មានប្រាក់ដើម្បីចំណាយថ្លៃព្យាបាលដែលខ្ញុំត្រូវការឡើយ ។

រូបភាពមកពី GETTY IMAGES

# ការធ្វើដំណើររបស់អ្នកត្រួសត្រាយសម័យទំនើបបីនាក់

ដោយ សារ៉ា ឃីណាន

អំឡុងពេលខ្ញុំកំពុងបម្រើបេសកកម្មរបស់ខ្ញុំនៅទីក្រុងមែលប៊ើន ប្រទេសអូស្ត្រាលី ខ្ញុំបាននៅក្នុងវួដមួយដែលបង្កើតឡើងដោយនិស្សិតអន្តរជាតិ ។ នៅពេលពួកគេរៀនអំពីពួកអ្នកត្រួសត្រាយនៅក្នុងថ្នាក់ថ្ងៃអាទិត្យ ខ្ញុំបានឆ្ងល់អំពីចំណាប់អារម្មណ៍ដ៏ខ្លាំងរបស់ពួកគេ — ពួកគេស្ទើរតែទាំងអស់គ្នាគឺជាអ្នកប្រែចិត្តជឿថ្មី ហើយគ្មាននរណាម្នាក់មានជីដូនជីតាដែលបានដើរឆ្លងកាត់វាលទំនាបនៃទ្វីបអាមេរិកខាងជើងឡើយ ។

គួរឲ្យអស្ចារ្យណាស់ និស្សិតអន្តរជាតិជាច្រើនបានចាប់អារម្មណ៍ដោយសារតែដំណើររឿងនានាដែលបានចែកចាយ ។ ពួកគេមួយចំនួនបានប្រាប់អំពីរបៀបដែលពួកគេផ្សារភ្ជាប់ទៅនឹងពួកបរិសុទ្ធជំនាន់ដើមដោយផ្ទាល់មួយ ៖ គឺដូចជាពួកអ្នកត្រួសត្រាយដែរ និស្សិតអន្តរជាតិទាំងនេះគឺជាអ្នកប្រែចិត្តជឿថ្មី ហើយបានធ្វើការលះបង់នានា ដើម្បីស្ថាបនាសាសនាចក្រនៅក្នុងតំបន់នានាដែលពួកគេរស់នៅ ។ សម្រាប់សមាជិកមួយចំនួន សាសនាចក្រមានតិចតួច ឬគ្មានសោះនៅក្នុងប្រទេសកំណើតរបស់ពួកគេ ។ ពួកគេគឺជាអ្នកត្រួសត្រាយសម័យទំនើបនេះ ដែលនឹងបង្កើតមរតកនៃសាសនាថ្មីមួយសម្រាប់ជំនាន់ក្រោយៗទៀត ។

នេះគឺជាបទពិសោធន៍បីយ៉ាងមកពីអ្នកប្រែចិត្តជឿ ដែលបានក្លាយជាពួកអ្នកត្រួសត្រាយសម័យទំនើបនេះ ។

## គោរពក្រុមគ្រួសាររបស់ខ្ញុំនៅក្នុងរបៀបថ្មីៗ

ណាមី ចាន់ ទីក្រុង តៅយ៉ុន ប្រទេស តៃវ៉ាន់

គ្រួសាររបស់ខ្ញុំ និងសាច់ញាតិជាច្រើនទៀតរបស់គ្រួសារខ្ញុំនៅក្នុងប្រទេសតៃវ៉ាន់គឺជាពុទ្ធសាសនិក ។ កាលខ្ញុំនៅតូច ខ្ញុំចាំពីការជួយរៀបចំគ្រឿងបូជាសម្រាប់ជីដូនជីតា និងព្រះជាច្រើនអង្គនៅក្នុងពិធីបុណ្យចូលឆ្នាំចិន និងថ្ងៃបុណ្យជាតិផ្សេងៗទៀត ។ វាគឺជាប្រពៃណីគ្រួសាររបស់ពួកយើង ព្រមទាំងជាពិធីមួយដើម្បីរំឭកដល់ជីដូនជីតារបស់យើង និងនាំសុខសន្តិភាពព្រមទាំងភាពចម្រុងចម្រើនដល់គ្រួសាររបស់ខ្ញុំ ។

នៅពេលសាច់ញាតិមួយចំនួនរបស់ខ្ញុំបានចូលជាសមាជិកព្រះវិហារសាសនាគ្រិស្តដែលគ្មាននិកាយណាមួយ ដំបូង វាគ្មានការបះពាល់អ្វីឡើយដល់ក្រុមគ្រួសាររបស់ខ្ញុំនាគ្រានោះឡើយ ។ ប៉ុន្តែនៅ

> **ពួកយុវមជ្ឈិមវ័យបីនាក់ចែកចាយដំណើររឿងរបស់ពួកគេអំពីការចូលជាសមាជិកសាសនាចក្រ និងការបង្កើតមរតកនៃសេចក្ដីជំនឿសម្រាប់ខ្លួនពួកគេ និងក្រុមគ្រួសាររបស់ពួកគេ ។**

អំឡុងពេលបុណ្យសែនផ្នូរ ជាពេលអ្នកថ្វាយបង្គំជីដូនជីតារបស់អ្នក ហើយដុតធូបនៅឯផ្នូររបស់ពួកគាត់នោះសាច់ញាតិដែលជាពួកគ្រិស្តសាសនិករបស់ខ្ញុំបានបដិសេធមិនព្រមចូលរួមឡើយ ។ ពួកគេបាននិយាយថា ពួកគេត្រូវបានតាំងចិត្តធ្វើតាមក្រឹត្យវិន័យដប់ប្រការជាពិសេស « កុំឲ្យមានព្រះឯណាទៀតនៅចំពោះយើងឲ្យសោះ » ( និក្ខមនំ ២០:៣ ) ។ ក្រុមគ្រួសាររបស់ខ្ញុំពុំបានពិភាក្សាអំពីជំនឿដទៃទៀតពីមុនឡើយ ប៉ុន្តែចាប់តាំងពីថ្ងៃនោះមក ជំនឿលើសាសនាគ្រិស្តតំណាង





ឲ្យការបំផ្លាញប្រពៃណីនៅក្នុងក្រសែភ្នែករបស់គ្រួសារខ្ញុំ ហើយឃើញថា វាគឺជាពន្លឺអវិជ្ជមានមួយ ។

កាលខ្ញុំចូលរៀនមហាវិទ្យាល័យ នោះខ្ញុំបានជួបអ្នកផ្សព្វផ្សាយសាសនា អិល. ឌី. អេស. នៅតាមផ្លូវ ។ ជាទូទៅ ខ្ញុំពុំចាប់អារម្មណ៍លើអ្វីដែលពួកគេនិយាយឡើយ ប៉ុន្តែបទពិសោធន៍មួយចំនួនបានត្រៀមចិត្តរបស់ខ្ញុំដើម្បីទទួលយកសារលិខិតរបស់ពួកគេ ។ អំឡុងពេលជួបជាមួយពួកគេ ខ្ញុំបានយល់ព្រមអធិស្ឋាន ហើយអានព្រះគម្ពីរមរមន ហើយខ្ញុំបានចាប់ផ្ដើមបង្កើននូវទីបន្ទាល់ផ្ទាល់ខ្លួនអំពីព្រះយេស៊ូវគ្រីស្ទនូវអ្វីដែលខ្ញុំកំពុងត្រូវបានបង្រៀន ។ ប៉ុន្តែដោយសារអារម្មណ៍របស់ឪពុកម្ដាយរបស់ខ្ញុំប្រឆាំងនឹងជំនឿគ្រិស្តសាសនា នោះខ្ញុំពុំចង់ប្រាប់ពួកគេថា ខ្ញុំចង់ទទួលបុណ្យជ្រមុជទឹកឡើយ ។ ជាច្រើនខែ បន្ទាប់ពីខ្ញុំបានជួបជាមួយនឹងអ្នកផ្សព្វផ្សាយសាសនាលើកដំបូង ទីបំផុតខ្ញុំបានប្រាប់ឪពុកម្ដាយរបស់ខ្ញុំថា ខ្ញុំចង់ទទួលបុណ្យជ្រមុជទឹក ហើយខ្ញុំចង់បម្រើបេសកកម្ម ។ ពួកគាត់បានអាក់អន់ចិត្ត ប៉ុន្តែខ្ញុំបានដឹងថា ខ្ញុំបានសម្រេចចិត្តត្រឹមត្រូវ ។

ខ្ញុំគ្មានជីដូនជីតាជាអ្នកត្រួសត្រាយឡើយ ប៉ុន្តែខ្ញុំមានអារម្មណ៍ដូចជាខ្ញុំយល់អំពីការលះបង់របស់ពួកគាត់ ។ វាមានការលំបាកក្នុងការបោះបង់ទំនៀមទម្លាប់មួយចំនួន ហើយប្រឈមមុខនឹងការជំទាស់មកពីសមាជិកគ្រួសារ ។ សូម្បីតែពេលឥឡូវនេះ ប្រាំឆ្នាំបានកន្លងផុតទៅបន្ទាប់ពីខ្ញុំបានចូលជាសមាជិកសាសនាចក្រ នៅក្នុងគ្រាដែលខ្ញុំបានបម្រើបេសកកម្ម នោះគ្រួសាររបស់ខ្ញុំពុំគាំទ្រខ្ញុំទាំងស្រុងលើការសម្រេចចិត្តរបស់ខ្ញុំឡើយ ប៉ុន្តែពួកគាត់បានទទួលយកវា ។ ការចូលរួមសាសនាចក្របានអនុញ្ញាតឲ្យខ្ញុំគោរពគ្រួសាររបស់ខ្ញុំតាមរបៀបថ្មីៗ តាមរយៈការធ្វើពង្សប្រវត្តិ និងការស្រាវជ្រាវអំពីជីដូនជីតារបស់ខ្ញុំ ។ ទីបន្ទាល់របស់ខ្ញុំអំពីព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ជួយខ្ញុំក្នុងការដោះស្រាយជម្លោះដែលខ្ញុំអាចមានជាមួយគ្រួសាររបស់ខ្ញុំ ។

# ការរកឃើញអំណរមកពីដំណឹងល្អ

ហារី ហួន រដ្ឋយូថាហ៍ ស.រ.អា

ខ្ញុំធំឡើងនៅក្នុងប្រទេសចិន ហើយបានចាត់ទុកខ្លួនខ្ញុំថាជាគ្រិស្តសាសនិក ទោះបីជាតាមពិតទៅ ខ្ញុំពុំធ្លាប់បានទៅព្រះវិហារក្ដី ។ ខ្ញុំបានចាប់អារម្មណ៍លើព្រះ និងព្រះយេស៊ូវគ្រីស្ទ ហើយខ្ញុំបានគិតអំពីគោលលទ្ធិរបស់គ្រិស្តសាសនាថាជាការលួងលោមចិត្តមួយ ។

នៅពេលខ្ញុំប្ដូរទៅរៀនមហាវិទ្យាល័យនៅសហរដ្ឋ ខ្ញុំបានចាប់ផ្ដើមចូលរួមព្រះវិហារគ្រិស្តសាសនាមួយដែលគ្មាននិកាយណាមួយឡើយ ។ ពីរបីខែក្រោយមក ខ្ញុំបានឮអំពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយមកពីមិត្តភក្តិមួយចំនួនដែលកំពុងគិតពីការចូលរៀននៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ។ ខ្ញុំបានសួរនិស្សិតមួយចំនួននៅព្រះវិហារគ្រិស្តសាសនាអំពីពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយគួរឲ្យភ្ញាក់ផ្អើលណាស់ នៅពេលពួកគេបានព្រមានខ្ញុំដោយស្មោះសរថា ឲ្យខ្ញុំនៅឲ្យឆ្ងាយពី « ពួកមរមន » ។ នៅពេលដំបូងខ្ញុំបានស្ដាប់ការទូន្មានរបស់ពួកគេ ប៉ុន្តែនៅពេលខ្ញុំបានមើលប្រព័ន្ធផ្សព្វផ្សាយសង្គមប្រហែលជាមួយសប្ដាហ៍ក្រោយមក ខ្ញុំបានឃើញសុន្ទរកថាមួយដែលថ្លែងដោយអែលឌើរ ដេព្រ៊ី អ័ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ នៅក្នុងសុន្ទរកថានោះ លោកបានថ្លែងថា សមាជិកសាសនាចក្រគួរតែមានការគោរពដល់សាសនាដទៃ ( សូមមើល « Faith, Family, and Religious Freedom » lds.org/prophets-and-apostles ) ។ នៅពេលខ្ញុំបានស្ដាប់អែលឌើរ ហូឡិន ខ្ញុំមានអារម្មណ៍ពីអ្វីដែលឥឡូវនេះខ្ញុំដឹងគឺជាព្រះវិញ្ញាណ ហើយបានសម្រេចចិត្តថា ខ្ញុំត្រូវតែរៀនបន្ថែមទៀតអំពីសាសនាចក្រនេះ ។



ទីបំផុតខ្ញុំបានទៅព្រះវិហារ ហើយក្រោយមកបានជួបជាមួយពួកអ្នកផ្សព្វផ្សាយសាសនា ។ ខ្ញុំមានការរំជួលចិត្តចំពោះការបង្រៀនរបស់ពួកគេ ជាពិសេសអំពីផែនការនៃសេចក្ដីសង្គ្រោះ ។ ឪពុកម្ដាយរបស់ខ្ញុំពុំសូវរីករាយប៉ុន្មានទេ នៅពេលខ្ញុំបានសម្រេចិត្តទទួលបុណ្យជ្រមុជទឹក ប៉ុន្តែពួកគាត់បានទទួលស្គាល់ថា ខ្ញុំមានភាពចាស់ទុំល្មមដើម្បីធ្វើការសម្រេចចិត្តផ្ទាល់ខ្លួនហើយ ។ នៅពេលលោកតាលោកយាយរបស់ខ្ញុំបានមកសួរសុខទុក្ខខ្ញុំនៅអាមេរិកពីរបីខែក្រោយមក ខ្ញុំក៏បានបង្រៀនដំណឹងល្អដល់ពួកគាត់ ។ ពួកគាត់ទាំងពីរនាក់បានសម្រេចចិត្តទទួលបុណ្យជ្រមុជទឹក ។

ដំណឹងល្អបាននាំអំណរដ៏ខ្លាំងដល់ខ្ញុំ ហើយវាបាននាំខ្ញុំទៅរកស្ត្រីម្នាក់ដែលខ្ញុំនឹងរៀបការឆាប់ៗនាពេលខាងមុខ ។ វាសក្តិសមចំពោះតម្លៃនៃការលះបង់ដែលខ្ញុំធ្លាប់បានធ្វើ ឬនឹងធ្វើ ។

# ការរៀបចំផ្លូវសម្រាប់ជំនាន់ក្រោយៗទៀត

ប្រូក គីនីគីនី រដ្ឋហាវ៉ៃ ស.រ.អា.

ខ្ញុំបានចូលជាសមាជិកសាសនាចក្រកាលខ្ញុំអាយុ ១៥ ឆ្នាំ ប៉ុន្តែខ្ញុំបានទៅព្រះវិហារ និងអភិវឌ្ឍសេចក្ដីជំនឿ និងទីបន្ទាល់របស់ខ្ញុំតាំងពីខ្ញុំនៅតូចម្ល៉េះ ។ ទោះបីខ្ញុំជាសមាជិកតែម្នាក់ឯងនៅក្នុងក្រុមគ្រួសារខ្ញុំក្ដី ក៏មិត្តភក្តិដ៏ស្មោះត្រង់របស់ខ្ញុំស្រឡាញ់ខ្ញុំ ហើយបានដឹកនាំខ្ញុំតាមរយៈគំរូរបស់ពួកគេ ។

មិនដូចជាពួកអ្នកត្រួសត្រាយជំនាន់បុរាណឡើយ ខ្ញុំពុំធ្លាប់ដើរជាមួយនឹងការអូសរទេះឆ្លងកាត់វាលទំនាប



ដ៏ត្រជាក់ឡើយ ។ ប្រាកដណាស់ ខ្ញុំពុំជួបនូវការលំបាកច្រើនឡើយនៅពេលខ្ញុំចូលជាសមាជិកសាសនាចក្រ ។ មែនហើយ ខ្ញុំបានបាត់បង់មិត្តភក្ដិមួយចំនួន ហើយខ្ញុំត្រូវចូលរួមព្រះវិហារតែម្នាក់ឯង ហើយទៅរៀនថ្នាក់សិក្ខាសាលាដោយខ្លួនឯង ។ ប៉ុន្តែនៅពេលខ្ញុំគិតអំពីឥទ្ធិពលដែលវាបានមាន ហើយបន្តមានមកលើគ្រួសាររបស់ខ្ញុំ នោះខ្ញុំដឹងថា វាគឺជាការសម្រេចចិត្តមួយដ៏ល្អបំផុតដែលខ្ញុំពុំធ្លាប់បានធ្វើពីមុនមក ។ ការសម្រេចចិត្តរបស់ខ្ញុំដើម្បីទទួលបុណ្យជ្រមុជទឹក ដើម្បីផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ និងបន្តស្មោះត្រង់ចំពោះសេចក្ដីសញ្ញាដែលខ្ញុំបានបង្កើតជាច្រវ៉ាក់នៃលក្ខខណ្ឌដែលនឹងមានឥទ្ធិពលវិជ្ជមានដល់ជីវិតនៃកូនទាំងបីដ៏ស្រស់ស្អាតរបស់ខ្ញុំ ព្រមទាំងជំនាន់ក្រោយៗទៀតជារៀងរហូត ។

ការធ្វើជាអ្នកត្រួសត្រាយគឺជាការរៀបចំផ្លូវសម្រាប់មនុស្សដទៃ ។ ខ្ញុំចូលចិត្តគិតអំពីពរជ័យមួយក្នុងចំណោមពរជ័យជាច្រើនដែលខ្ញុំបានទទួលក្នុងការធ្វើជាសមាជិកស្មោះត្រង់នៃសាសនាចក្រនោះគឺថា ខ្ញុំអាចជួយនាំមនុស្សដទៃទៀតឲ្យមកកាន់ព្រះគ្រីស្ទ ។ ព្រឹត្តិការណ៍នេះទំនងដូចជាតូចតាច — ដូចជាបុណ្យជ្រមុជទឹកនៃក្មេងស្រីអាយុ ១៥ ឆ្នាំ នៅម៉ោអ៊ី រដ្ឋ ហាវ៉ៃ ឬការអធិស្ឋានដ៏រាបសារបស់ក្មេងប្រុសអាយុ ១៤ ឆ្នាំនៅក្នុងព្រៃពិសិដ្ឋ — អាចផ្លាស់ប្ដូរជីវិតរបស់ក្រុមគ្រួសារនៅក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ។

មុខងារនៃពួកអ្នកត្រួសត្រាយសម័យទំនើបពុំគ្រាន់តែបម្រុងទុកសម្រាប់អ្នកប្រែចិត្តជឿប៉ុណ្ណោះទេ ។ នៅពេលយើងព្យាយាមបង្កើតមរតកនៃសេចក្ដីស្មោះត្រង់ដ៏យូរអង្វែងមួយសម្រាប់ជំនាន់ក្រោយៗមកទៀត នោះយើងទាំងអស់គ្នាអាចក្លាយជាអ្នកត្រួសត្រាយបាន ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*

**ការប្រកាសអំពីមរតកនៃអ្នកត្រួសត្រាយរបស់យើង**

« ខ្ញុំស្រឡាញ់ និងគោរពសេចក្ដីជំនឿ ព្រមទាំងភាពក្លាហានរបស់ពួកអ្នកត្រួសត្រាយជំនាន់ដើមរបស់សាសនាចក្រណាស់ ។ បុព្វការីជនរបស់ខ្ញុំផ្ទាល់បានរស់នៅឆ្ងាយឆ្លងមហាសមុទ្រនៅពេលនោះ ។ . . . គ្មានពួកគាត់ណាម្នាក់បានដើរឆ្លងកាត់វាលទំនាបនោះឡើយ ។ ប៉ុន្តែក្នុងនាមជាសមាជិកសាសនាចក្រម្នាក់ ខ្ញុំប្រកាសដោយកតញ្ញូតា និងដោយមោទនភាពពីកេរដំណែលអ្នកត្រួសត្រាយនេះជារបស់ខ្ញុំផ្ទាល់ ។

« ជាមួយនឹងសេចក្ដីអំណរដូចគ្នានោះ ខ្ញុំសូមប្រកាសពីកេរដំណែលនៃពួកអ្នកត្រួសត្រាយក្នុងសាសនាចក្រសម័យទំនើបនាបច្ចុប្បន្ននេះ ដែលរស់នៅក្នុងគ្រប់ជាតិសាសន៍ ហើយដែលដំណើររឿងនៃការតស៊ូ សេចក្ដីជំនឿ និងការលះបង់ផ្ទាល់ខ្លួនរបស់ពួកគេបានបន្ថែមនូវវគ្គថ្មីៗដ៏មានសិរីល្អក្នុងវគ្គបន្ទរដ៏អស្ចារ្យនៃបទភ្លេងនគរព្រះនាថ្ងៃចុងក្រោយនេះ » ។

អែលឌើរ ឌៀថើរ អេហ្វ អុជដូហ្វ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីនាក់
« **Faith of Our Father** » ***Liahona*** ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៧០ ។

# មានអារម្មណ៍ថាដាច់ទំនាក់ទំនងឬ ? សូមសាកល្បងបន្ថយល្បឿន

**ដោយ ឆាឡុត ឡាកាបាល**
ទស្សនាវដ្ដីសាសនាចក្រ

ប្រសិនបើអ្នកឈរតម្រង់ជួរនៅក្នុងជួរដ៏វែងក្បែរពីងពាង និងពស់ដែលជាសត្វដែលអ្នកខ្លាច នោះអ្នកមិនមែនជាអ្នកខ្លាចតែឯងទ្បើយ ។

មិនថាយើងកំពុងឈរតម្រង់ជួរ អង្គុយរង់ចាំដោយស្ទះចរាចរណ៍ ឬរង់ចាំឡានក្រុងនោះទេ យើងស្អប់ការរង់ចាំណាស់ ។

សំណាងល្អសម្រាប់យើង ពេលវេលារង់ចាំក្លាយជាអ្វីមួយដែលកាន់តែអាក្រក់ ៖ វាជាអ្វីមួយដែលយើងមិនចង់ជួប ប៉ុន្តែវាពុំមែនជាអ្វីដែលយើងជួបរាល់ថ្ងៃនោះទេ ។ យើងរស់នៅក្នុងសម័យមួយដែលគ្មានពេលវេលារង់ចាំទ្បើយ ។ បច្ចេកវិជ្ជាកំពុងបង្កើនល្បឿនអ្វីៗគ្រប់យ៉ាងរហូតដល់វាធ្វើឲ្យយើងមានការយកចិត្តទុកដាក់ខ្លីជាងត្រីមាសទៅទៀត ( មែនហើយ នោះគឺជាការពិត ) ។[1] នៅពេលតម្រូវការឲ្យរង់ចាំកើតឡើង នោះយើងព្យាយាមបំពេញពេលវេលារបស់យើង — ជាទូទៅគឺការបែរទៅរកឧបករណ៍ចល័ត ។

ជាទូទៅ វាគ្មានអ្វីខុសនឹងបច្ចេកវិជ្ជា ឬសមត្ថភាពទ្បើយ ប៉ុន្តែល្បឿនដ៏លឿន និងការបង្វែរចិត្តជាប្រចាំនោះអាចរារាំងយើងពីអ្វីមួយដែលកាន់តែសំខាន់ជាងនោះ ។

### ខគម្ពីរលើសពីភាពច្បាស់លាស់ទៅទៀត

មិនយូរប៉ុន្មានកន្លងមកនេះ អារម្មណ៍ខាងវិញ្ញាណរបស់ខ្ញុំបានរសាត់អណ្ដែត ។ ខ្ញុំពុំយល់ពីអារម្មណ៍នោះទ្បើយ ។ ខ្ញុំបានទៅព្រះវិហារ អធិស្ឋានច្រំដែលៗ ហើយអានព្រះគម្ពីររបស់ខ្ញុំតែបន្តិចបន្តួច ។ យូរៗម្ដង ខ្ញុំទទួលអារម្មណ៍បំផុសគំនិតខាងវិញ្ញាណ ប៉ុន្តែយូរៗទៅខ្ញុំមានអារម្មណ៍ថា ខ្ញុំដាច់ទំនាក់ទំនង ។

នៅពេលខ្ញុំបានទូលប្រាប់ព្រះវរបិតាសួគ៌អំពីរឿងនេះនៅក្នុងការអធិស្ឋានដ៏អន្ទះសាររបស់ខ្ញុំ ពាក្យទាំងនេះបានផុសទ្បើងក្នុងចិត្តរបស់ខ្ញុំ ៖ « សូមបង្អង់សិន ឲ្យបានដឹងថាយើងជាព្រះ » ( ទំនុកតម្កើង ៤៦:១០ ) ។

វាហាក់ដូចជាពាក្យ *បង្អង់សិន* ត្រូវបានគូសចំណាំគូសបន្ទាត់ពីក្រោម និងជាប្រភេទអក្សរដិត ។

ប្រហែលជាខ្ញុំបានធ្វើនូវរឿងទាំងអស់ដែលត្រឹមត្រូវ ប៉ុន្តែខ្ញុំបានធ្វើវានៅក្នុងល្បឿនដ៏លឿនមួយ ជាមួយនឹងការផ្ដោតចិត្តទុកដាក់រាក់កំភែល ។ ខ្ញុំបានចាប់ផ្ដើមលែងរស់នៅតាមដំណឹងល្អហើយ ។

គ្មានការអនុវត្តសាសនាណាអាចនាំខ្ញុំឲ្យមានទំនាក់ទំនងខាងវិញ្ញាណដ៏ជ្រាលជ្រៅទ្បើយ ប្រសិនបើការចូលរួមរបស់ខ្ញុំធ្វើទ្បើងដោយសើរៗ និងពុំយកចិត្តទុកដាក់នោះ ។ ខគម្ពីរនោះបញ្ជាក់ពីការណ៍លើសពីច្បាស់លាស់ទៅទៀត ។ ដើម្បីស្គាល់ព្រះឲ្យច្បាស់ និងទាក់ទងនឹងព្រះ ហើយទាញយកចំណេះដឹងដែលខ្ញុំកំពុងប្រាថ្នាចង់បានយ៉ាងខ្លាំង នោះខ្ញុំត្រូវបន្ថយល្បឿន ហើយនៅបង្អង់សិន ។

ការស្ដាប់តាមការបំផុសគំនិតនោះគឺពុំងាយស្រួលទ្បើយ ។ ប៉ុន្តែវានឹងធ្វើឲ្យមានការផ្លាស់ប្ដូរទាំងស្រុង ។

### ឥឡូវនេះ សូមបន្ថយល្បឿន . . .

នីហ្វៃបង្រៀនថា អស់អ្នកដែល « *ព្យាយាមរក* នឹងឃើញ ហើយការអាថ៌កំបាំងទាំងឡាយនៃព្រះនឹង *បានបើកបង្ហាញ* ដល់គេដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ » ( នីហ្វៃទី ១ ១០:១៩, ការគូសបញ្ជាក់បានបន្ថែម ) ។

**គ្មាននរណាម្នាក់និយាយថា « ខ្ញុំចូលចិត្តការរង់ចាំទ្បើយ » ។ ប៉ុន្តែប្រហែលជាពួកគេគួរតែធ្វើដូច្នោះ ។**

ចូរយើងពិនិត្យវាឲ្យបានម៉ត់ចត់ ៖ ការដឹងអំពីការអាថ៌កំបាំងរបស់ព្រះតម្រូវឲ្យយើង *ព្យាយាមរក* ។ វាគឺជាការអនុវត្តដ៏ខ្ជាប់ខ្ជួន និងមានចេតនា ហើយពុំមែនធ្វើតែម្ដងដូចការស្រាវជ្រាវតាមអ៊ិនធើរណែតទ្បើយ ។ បន្ទាប់មកទៀត អាថ៌កំបាំងពុំផុសទ្បើងភ្លាមទ្បើយ វា *បើកបង្ហាញ*ដោយសន្សឹមៗ ។ ដំណើរការនេះត្រូវការពេលវេលា ។ ហើយពេលវេលានោះវាសំខាន់ណាស់ ! វាជា *ពេល* ដែលយើងចំណាយដើម្បីពិចារណា និងស្វែងរកនូវ *ពេលវេលា* ឲ្យយើងទាក់ទងនឹងព្រះវិញ្ញាណ ជាអង្គដែលប្រទានចម្លើយដ៏មានអនុភាព ។

រចនារូបភាពដោយ ផាស្កាល ខេមភៀន

ប្រធាន ដេវីឌ អូ មិកឃេ ( ១៨៧៣–១៩៧០ ) បានប្រកាសថា ការស្ញឹងស្មាធ — « ជ្រាលជ្រៅ បន្តគិតអំពីប្រធានបទសាសនាមួយចំនួន » — គឺជា « ទ្វារដ៏ពិសិដ្ឋបំផុតមួយ . . . ដែលយើងឆ្លងកាត់ចូលទៅក្នុងវត្តមានរបស់ព្រះអម្ចាស់ » ។[២] តាមរយៈការបន្ថយល្បឿន នោះយើងអាចបើកទ្វារទៅកាន់វិវរណៈបាន ។ យើងអាចផ្លាស់ប្ដូរឧត្តមគតិដែលរីករាលដាលរបស់ពិភពលោក ហើយទាក់ទងជាមួយនឹងព្រះ ។ យើង *ត្រូវការ* ទ្វារនោះ ។ យើងត្រូវតែបន្ថយល្បឿន ។

### វាត្រូវការការខិតខំខ្នះខ្នែង

សម្រាប់ខ្ញុំ ការបន្ថយល្បឿនមានន័យថា ការលុតជង្គង់ចុះ និងការអធិស្ឋានឲ្យឮៗ ។ ការបង្ហាញគារវភាព និងសំឡេងនៃពាក្យផ្ទាល់របស់ខ្ញុំបានជួយខ្ញុំឲ្យផ្ដោតចិត្តទុកដាក់កាន់តែប្រសើរឡើង ។



ការបន្ថយល្បឿនមានន័យថា ការសិក្សាមកពីព្រះគម្ពីរជាសៀវភៅ ហើយកត់ត្រាក្នុងសៀវភៅកំណត់ហេតុ ។ វាតម្រូវឲ្យមានការខិតខំកាន់តែខ្លាំង និងត្រូវការពេលវេលាកាន់តែច្រើន ហើយការខិតខំ និងពេលវេលាដែលបានបង្កើននោះគឺជាមធ្យោបាយល្អមួយដើម្បី « ភ្ញាក់ឡើង ហើយដាស់សមត្ថភាពទាំងឡាយរបស់ខ្លួន » ដើម្បីអនុញ្ញាតឲ្យព្រះវិញ្ញាណ និងបំណងប្រាថ្នានៃសេចក្ដីពិត « ធ្វើការក្នុងខ្លួនអ្នក » ហើយថាគ្រាប់ពូជនៃទីបន្ទាល់ « ដុះឫស ដើម្បីវាអាចដុះឡើង ហើយនឹងផ្ដល់ផ្លែផ្កា » ( អាលម៉ា ៣២:២៧, ៣៧ ) ។

យើងអាចរកបានព័ត៌មានស្ទើរតែទាំងអស់ដោយគ្រាន់តែវាយពាក្យនោះចូលក្នុងកុំព្យូទ័រ ប៉ុន្តែការយល់ដឹងខាងវិញ្ញាណ និងការប្រែចិត្តជឿតម្រូវឲ្យយើងចំណាយ *ពេលវេលា* និង ខិតខំ *ព្យាយាម* ។ *របៀប*ដែលអ្នកបន្ថយល្បឿន និងបូជាការខិតខំចំពោះដំណឹងល្អពុំសំខាន់ឡើយ អ្វីដែលសំខាន់នោះគឺអ្វីដែលអ្នកធ្វើតាមដំណឹងល្អនោះ ។ នៅពេលយើងទទួលបានព័ត៌មានដោយងាយស្រួល នោះយើងក៏មិនសូវចូលរួមនៅក្នុងការរៀនសូត្រដោយផ្ទាល់ខ្លួនរបស់យើងផងដែរ ។ យើងលុបចោលឱកាសដើម្បីទាក់ទងជាមួយព្រះវិញ្ញាណ ។

យើងពិតជាអាចប្រើប្រាស់បច្ចេកវិទ្យា និងការរីកចម្រើនរបស់វាដើម្បីធ្វើឲ្យកិច្ចការប្រចាំថ្ងៃកាន់តែងាយស្រួល ហើយធ្វើឲ្យយើងប្រើប្រាស់ពេលវេលាយើងកាន់តែមានប្រសិទ្ធភាព ។ ប៉ុន្តែយើងពុំសមនឹងសម្របខ្លួនដើម្បីរស់នៅតាមការបង្វែអារម្មណ៍នោះ ហើយគិតយ៉ាងរាក់កំភែលដែលជារឿយៗវាកើតមកពីបច្ចេកវិទ្យានោះឡើយ ។ ជំនួសឲ្យការខ្លាចការត្រូវរង់ចាំ នោះយើងអាចទទួលយកវាជាឱកាសមួយដើម្បីបន្ថយល្បឿន ស្ញឹងស្មាធ ហើយបង្កើនទំនាក់ទំនងរបស់យើងជាមួយព្រះវិញ្ញាណឲ្យកាន់តែជ្រាលជ្រៅឡើង ។ ■

**កំណត់ចំណាំ**

១. សូមមើល Leon Watson « Humans Have Shorter Attention Span Than Goldfish, Thanks to Smartphones » The Telegraph ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៥ គេហទំព័រ telegraph.co.uk ។

២. *Teachings of Presidents of the Church: David O. McKay* ( ឆ្នាំ ២០១១ ) ទំព័រ ៣១, ៣២ ។

## ការដោះស្រាយជាមួយសំណួរពិបាកៗ ៖

# គោលការណ៍ ៣ យ៉ាងដែលអាចជួយបាន

*នេះគឺជារបៀបស្វែងរកចម្លើយនៅក្នុងរបៀបមួយដែលពង្រឹងសេចក្ដីជំនឿរបស់អ្នក ។*



តើអ្នកធ្លាប់មានសំណួរមួយអំពីដំណឹងល្អ ឬសាសនាចក្រដែរឬទេ ? តើអ្នកធ្លាប់បារម្ភថា តើសំណួររបស់អ្នកអាចមានន័យថា អ្នកគ្មានសេចក្ដីជំនឿគ្រប់គ្រាន់ ឬថាទីបន្ទាល់របស់អ្នកពុំខ្លាំងគ្រប់គ្រាន់ដែរឬទេ ?

សំណួរគឺជាផ្នែកមួយដ៏សាមញ្ញ និងចាំបាច់នៃដំណើររបស់អ្នកពេញមួយជីវិតរមែងស្លាប់នេះ ។ វាអាចនាំអ្នកទៅរកការយល់ដឹង និងសេចក្ដីជំនឿកាន់តែប្រសើរឡើង ។ ប៉ុន្តែ ឥរិយាបថ ការជំរុញចិត្ត និងដំណើរការស្វែងរកចម្លើយរបស់អ្នក វាជះឥទ្ធិពលដល់លទ្ធផលនោះ ។

នៅក្នុងថ្នាក់សិក្ខាសាលា អ្នកនឹងរៀនអំពីគោលការណ៍ចំណេះចំណានខាងគោលលទ្ធិទាំងបីនេះ ដែលអាចជួយដឹកនាំអ្នកទៅរកសេចក្ដីពិតអស់កល្បជានិច្ច ។

រូបភាពផ្ដិតខាងក្រោយមកពី GETTY IMAGES

## ១. ធ្វើសកម្មភាពដោយសេចក្ដីជំនឿ

នៅពេលអ្នកមានសំណួរ អ្នកអាចធ្វើសកម្មភាពដោយសេចក្ដីជំនឿ ដោយជ្រើសរើសទុកចិត្តព្រះ ហើយបែរទៅរកទ្រង់ជាមុនដើម្បីទទួលបានចម្លើយ ។ ព្រះប្រទានចម្លើយ « មួយបន្ទាត់ម្ដងៗ មួយសិក្ខាបទម្ដងៗ » ( នីហ្វៃទី ២ ២៨:៣០ ) ។ វាសំខាន់ដើម្បីពឹងផ្អែកទៅលើទីបន្ទាល់ដែលអ្នកមានរួចជាស្រេចនៅក្នុងគ្រានៃការសង្ស័យ ។

« សង្ស័យមន្ទិលអ្នកពីមុនសង្ស័យសេចក្ដីជំនឿអ្នក »[១] — អែលឌើរ ឌៀថើរ អេហ្វ អុជដូហ្វ ។

« ចូរតោងឲ្យជាប់ទៅនឹងអ្វីដែលអ្នកបានដឹងរួចហើយនោះ ហើយឈរឲ្យរឹងមាំរហូតដល់ទទួលបានចំណេះដឹងបន្ថែម »[២] — អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ។

## ២. ពិនិត្យមើលគោលគំនិត និងសំណួរទាំងឡាយដោយទស្សនវិស័យនៃដំណឹងល្អ

ប្រសិនបើអ្នកពិចារណាសំណួរនៅក្នុងបរិបទនៃផែនការនៃសេចក្ដីសង្គ្រោះ ឬការបង្រៀនរបស់ព្រះអង្គសង្គ្រោះ នោះអ្នកអាចចាប់ផ្ដើមឃើញរឿងនានាតាមរបៀបដែលព្រះទតឃើញដែរ ។ ការណ៍នេះនឹងជួយអ្នកឲ្យពិនិត្យមើលសំណួររបស់អ្នកឡើងវិញ ដោយប្រើប្រាស់បទដ្ឋានរបស់ព្រះអំពីសេចក្ដីពិតជាជាងប្រើប្រាស់បទដ្ឋានរបស់ពិភពលោក ។

« ចូរធ្វើជាយុថ្កាទៅនឹងសេចក្ដីពិតអស់កល្ប . . . នឹងផ្ដល់ភាពសុខសាន្តដល់យើង ដែលកើតឡើងមកពីសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងចំណេះដឹងដែលយើងកំពុងដើរលើផ្លូវឆ្ពោះទៅរកជីវិតអស់កល្បជានិច្ច »[៣] —ប្រធាន ដាល្លិន អេក អូក ។

« បើអ្នករកឃើញថាមានអ្វីមួយហាក់ដូចជារាំងក្ដីអំណរ និងពន្លឺនៃដំណឹងល្អក្នុងជីវិត *របស់អ្នក* ខ្ញុំសូមអញ្ជើញអ្នកឲ្យដាក់វានៅក្នុងទស្សនវិស័យនៃដំណឹងល្អ ។ សូមមើលតាមកញ្ចក់ពង្រីកនៃដំណឹងល្អ ហើយមានការប្រុងប្រយ័ត្នកុំបណ្ដោយឲ្យរឿងមិនសំខាន់ និងគ្មានប្រយោជន៍មកក្នុងជីវិតអ្នក ដើម្បីបិទបាំងទស្សនអស់កល្បជានិច្ចរបស់អ្នកអំពីផែនការនៃសុភមង្គលដ៏មហិមាឡើយ »[៤] —អែលឌើរ ហ្គែរី អ៊ី ស្ទីវ៉ែនសុន ។

## ៣. ស្វែងរកការយល់ដឹងបន្ថែមតាមរយៈប្រភពដែលត្រូវបានតាំងមកពីព្រះ

ព្រះបានប្រទានប្រភពជាច្រើនដល់អ្នកដើម្បីប្រើប្រាស់ នៅពេលអ្នកស្វែងរកសេចក្ដីពិត ។ ប្រភពទាំងនោះរួមមាន ព្រះវិញ្ញាណបរិសុទ្ធ, ព្រះគម្ពីរ, គ្រួសារ, ថ្នាក់ដឹកនាំសាសនាចក្ររបស់អ្នក ព្រមទាំងប្រភពខាងក្រៅសាសនាចក្រដែលពង្រឹងសេចក្ដីជំនឿរបស់អ្នកលើព្រះយេស៊ូវគ្រីស្ទ ។ នៅពេលស្វែងរកចម្លើយនានា សូមប្រាកដថា យើងញែកឲ្យដាច់រវាងប្រភពដែលពុំអាចទុកចិត្តបាន និងប្រភពដែលអាចទុកចិត្តបាន ដែលនឹងពង្រឹងសេចក្ដីជំនឿរបស់អ្នក ហើយយាងអញ្ជើញព្រះវិញ្ញាណបរិសុទ្ធមកកាន់ជីវិតរបស់អ្នក ។

« ប្រយោជន៍ជាច្រើន . . . កើតឡើងមកពីការខិតខំរបស់អ្នកដើម្បីពង្រីក ពន្លាត និងបង្កើនការយល់ដឹងរបស់អ្នកអំពីសេចក្ដីពិត ។

សូមប្រើប្រាស់ព្រះគម្ពីរ និងការប្រកាសនានារបស់ពួកព្យាការី ដើម្បីពង្រីកចំណេះដឹងរបស់អ្នក »[៥] — អែលឌើរ រីឆាដ ជី ស្កត ( ១៩២៨–២០១៥ ) ។

« យើងបន្តស្វែងរកសេចក្តីពិតមកពីសៀវភៅល្អៗ និងប្រភពកម្សាន្តត្រឹមត្រូវផ្សេងៗទៀត ។ ‹ ហើយបើសិនជាមានអ្វីណាមួយដែលប្រកបដោយគុណធម៌ គួរឲ្យស្រឡាញ់ ឬឈ្មោះល្អ ឬក៏គួរឲ្យសរសើរ នោះយើងខ្ញុំស្វែងរករបស់ផងទាំងនេះហើយ › [ មាត្រានៃសេចក្តីជំនឿ ១:១៣ ] »[៦] — អែលឌើរ ឌៀថើរ អែហ្វ អុជដូហ្វ ។

**សូមសាកល្បងវាដោយខ្លួនឯង !**

ឧទាហរណ៍ខាងក្រោមនេះបង្ហាញអំពីរបៀបដែលវាអាចត្រូវបានធ្វើ ។ សូមកត់ចំណាំថា ទាំងនេះពុំមែនជាចម្លើយពេញលេញទេ គឺគ្រាន់តែជាឧទាហរណ៍អំពីរបៀបដែលយុវជន ឬយុវនារីអាចសាកល្បងឆ្លើយសំណួរទាំងនោះដោយខ្លួនពួកគេ ។ អ្នកនឹងចង់បន្តការសិក្សា និងការអធិស្ឋានអំពីប្រធានបទនានាដែលអ្នកមានសំណួរ ដើម្បីស្វែងរកចម្លើយ ហើយពង្រឹងទីបន្ទាល់របស់អ្នក ។

**ហេតុអ្វីព្រះវរបិតាសួគ៌ទុកឲ្យរឿងអាក្រក់កើតមានឡើង ?**

**ធ្វើសកម្មភាពដោយសេចក្តីជំនឿ ៖** ខ្ញុំបានទទួលអារម្មណ៍នៃសេចក្តីស្រឡាញ់របស់ព្រះសម្រាប់ខ្ញុំ ហើយខ្ញុំដឹងថា ទ្រង់មានពិតមែន ទោះបីជាខ្ញុំពុំយល់ពីមូលហេតុដែលព្រះទុកឲ្យរឿងអាក្រក់កើតឡើងក្តី ។

**ពិនិត្យមើលគោលគំនិត និងសំណួរទាំងឡាយដោយទស្សនវិស័យនៃដំណឹងល្អ ៖** សិទ្ធិសេរីភាពជ្រើសរើសគឺជាផ្នែកសំខាន់មួយនៃផែនការនៃសេចក្តីសង្គ្រោះ ។ ព្រះបានបញ្ជូនយើងមកកាន់ផែនដីនេះដើម្បីដកពិសោធន៍ការសាកល្បង សម្រេចចិត្ត និងទទួលរូបកាយសាច់ឈាម ។ ប៉ុន្តែការអនុញ្ញាតឲ្យមនុស្សធ្វើការសម្រេចចិត្តមានន័យថា ជួនកាលមនុស្សនឹងធ្វើការជ្រើសរើសខុស ហើយប៉ះទង្គិចដល់ជីវិតរបស់មនុស្សដទៃទៀត ។ ហើយការសាកល្បងនោះគឺពុំមែនជាលទ្ធផលនៃការខ្វះការជ្រើសរើសត្រឹមត្រូវនោះទេ — ដូចជាគ្រោះធម្មជាតិ, ពិការភាព និងសេចក្តីស្លាប់ — អាចផ្តល់ឱកាសសម្រាប់យើងដើម្បីពង្រឹងទីបន្ទាល់របស់យើង ហើយទុកចិត្តលើព្រះ ។

**ស្វែងរកការយល់ដឹងបន្ថែមតាមរយៈប្រភពដែលត្រូវបានតាំងមកពីព្រះ ៖** តើព្រះគម្ពីរ និងពួកព្យាការីសម័យទំនើបបានថ្លែងអ្វីខ្លះអំពីមូលហេតុដែលយើងត្រូវឆ្លងកាត់រឿងលំបាកទាំងនេះ ? « សេចក្តីទំនាស់ និងសេចក្តីទុក្ខលំបាករបស់អ្នក នោះគ្រាន់តែមួយភ្លែតប៉ុណ្ណោះទេ ហើយខណៈនោះ បើសិនជាអ្នកស៊ូទ្រាំការណ៍នោះដោយហ្មត់ចត់ នោះព្រះទ្រង់នឹងតម្កើងអ្នកឡើងនៅស្ថានខ្ពស់ » ( គ. និង ស. ១២១:៧–៨ ) ។ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា « ព្រះពុំបោះបង់យើងឲ្យនៅឯកោឡើយ ពុំបោះបង់ចោលដោយពុំជួយយើងនៅក្នុងឧបសគ្គដែលយើងជួបប្រទះឡើយ » ។[៧] ខ្ញុំពុំដឹងពីហេតុផលចំពោះការសាកល្បងទាំងអស់របស់ខ្ញុំឡើយ ប៉ុន្តែខ្ញុំជឿថា ព្រះយេស៊ូវគ្រីស្ទបានធ្វើដង្វាយធួនសម្រាប់ខ្ញុំ និងមនុស្សគ្រប់គ្នា ។ ខ្ញុំអាចបែរទៅរកទ្រង់ និងព្រះវរបិតាសួគ៌ទូលសូមភាពសុខសាន្ត កម្លាំង និងការគាំទ្រអំឡុងពេលនៃការសាកល្បងរបស់ខ្ញុំ ( សូមមើល អាលម៉ា ៧:១១–១២ ) ។



### តើខ្ញុំអាចប្រាប់ថា ពេលណាដែលព្រះវិញ្ញាណមានបន្ទូលមកកាន់ខ្ញុំ ?

**ធ្វើសកម្មភាពដោយសេចក្ដីជំនឿ ៖** ទោះបីជួនកាលវាមានការពិបាកសម្រាប់ខ្ញុំដើម្បីប្រាប់ នៅពេលខ្ញុំកំពុងទទួលការបំផុសគំនិត ខ្ញុំដឹងមកពីស្ដាប់ទីបន្ទាល់របស់មនុស្សដទៃ និងអានព្រះគម្ពីរដែលព្រះវិញ្ញាណនឹងជួយខ្ញុំយល់ ប្រសិនបើខ្ញុំបន្ដព្យាយាមស្ដាប់តាមការទូន្មានរបស់ទ្រង់ ។

**ពិនិត្យមើលគោលគំនិត និងសំណួរទាំងឡាយដោយទស្សនវិស័យនៃដំណឹងល្អ ៖** ព្រះប្រទានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដល់យើង ដូច្នេះយើងអាចទទួលការបំផុសគំនិតដើម្បីធ្វើអ្វីដែលត្រឹមត្រូវ ។ ប្រសិនបើខ្ញុំកំពុងទទួលការបំផុសគំនិតដើម្បីធ្វើអ្វីមួយល្អ នោះខ្ញុំអាចដឹងថា វាគឺមកពីព្រះវិញ្ញាណ ទោះបីវាហាក់ដូចជាគំនិតផ្ទាល់របស់ខ្ញុំក្ដី ។

**ស្វែងរកការយល់ដឹងបន្ថែមតាមរយៈប្រភពដែលត្រូវបានតាំងមកពីព្រះ ៖** ព្រះគម្ពីរបង្រៀនថា « ចូរមានចិត្តរាបសា ហើយព្រះអម្ចាស់ជាព្រះរបស់អ្នកនឹងដឹកដៃអ្នក ហើយប្រទានចម្លើយដល់បទអធិស្ឋានទាំងឡាយរបស់អ្នក » ( គ. និង ស. ១១២:១០ ) ។ អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « បំណងប្រាថ្នា និងភាពសក្តិសមដ៏ស្មោះសរអញ្ជើញវិញ្ញាណនៃវិវរណៈមកកាន់ជីវិតយើង » ។[8] ប្រសិនបើខ្ញុំព្យាយាមបន្ទាបខ្លួន ហើយធ្វើឲ្យអស់ពីសមត្ថភាពរបស់ខ្ញុំឲ្យមានភាពសក្តិសមនឹងព្រះវិញ្ញាណ នោះព្រះអម្ចាស់នឹងជួយដឹកនាំខ្ញុំទៅរកចម្លើយ ។ ទ្រង់នឹងបង្រៀនខ្ញុំអំពីរបៀបដែលព្រះវិញ្ញាណមានបន្ទូលមកកាន់ខ្ញុំយ៉ាងជាក់លាក់ ។

### សេចក្ដីបញ្ចប់

សំណួរពុំមែនជាសញ្ញានៃការខ្វះសេចក្ដីជំនឿទេ ជារឿយៗសំណួរគឺជាការបង្ហាញនូវការរីកចម្រើននៃទីបន្ទាល់ ។ នៅពេលអ្នកធ្វើសកម្មភាពដោយសេចក្ដីជំនឿ ពិនិត្យមើលគោលគំនិត និងសំណួរទាំងឡាយដោយទស្សនវិស័យនៃដំណឹងល្អ និងស្វែងរកការយល់ដឹងបន្ថែមតាមរយៈប្រភពដែលត្រូវបានតាំងមកពីព្រះ នោះអ្នកអាចស្វែងរកចម្លើយដែលមានប្រយោជន៍ចំពោះសំណួររបស់អ្នក ហើយមានសេចក្ដីជំនឿកាន់តែប្រសើរឡើងលើព្រះយេស៊ូវគ្រីស្ទ ។ ■

**កំណត់ចំណាំ**

១. ឌៀថើរ អេហ្វ អុជដូហ្វ « សូមមកចូលរួមជាមួយយើង » សន្និសីទទូទៅខែ តុលា ឆ្នាំ ២០១៣ ។
២. ជែហ្វ្រី អ័រ ហូឡិន « ខ្ញុំជឿហើយ លោកម្ចាស់អើយ » សន្និសីទទូទៅខែ មេសា ឆ្នាំ ២០១៣ ។
៣. ដាល្លិន អេក អូក « As He Thinketh in His Heart » ( ការប្រជុំធម្មនិដ្ឋានប្រព័ន្ធអប់រំសាសនាចក្រសម្រាប់យុវមជ្ឈិមវ័យ ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ) គេហទំព័រ lds.org/prophets-and-apostles ។
៤. ហ្គៃរីអ៊ី ស្ទីវ៉េនសុន « សូរ្យគ្រាសខាងវិញ្ញាណ » សន្និសីទទូទៅខែ តុលា ឆ្នាំ ២០១៧ ។
៥. រីឆាដ ជី ស្កត « Acquiring Spiritual Knowledge » សន្និសីទទូទៅខែ តុលា ឆ្នាំ ១៩៩៣ ។
៦. ឌៀថើរ អេហ្វ អុជដូហ្វ « តើសេចក្ដីពិតជាអ្វី ? » ( ការប្រជុំធម្មនិដ្ឋានសម្រាប់យុវមជ្ឈិមវ័យអំពីប្រព័ន្ធអប់រំសាសនាចក្រ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៣ ) គេហទំព័រ broadcasts.lds.org ។
៧. ជែហ្វ្រី អ័រ ហូឡិន « The Ministry of Angels » សន្និសីទទូទៅខែ តុលា ឆ្នាំ ២០០៨ ។
៨. ដេវីឌ អេ បែដណា « The Spirit of Revelation » សន្និសីទទូទៅខែ មេសា ឆ្នាំ ២០១១ ។

### មើលរបៀបដែលវាដំណើរការ

សូមមើលវីដេអូនេះ « ដំណើររឿងរបស់ម៉ាឌីសុន » ដើម្បីមើលអំពីយុវនារីម្នាក់ដែលបានធ្វើតាមដំណើរការនេះក្នុងការឆ្លើយនឹងសំណួររបស់គាត់ផ្ទាល់ ។ សូមទស្សនាគេហទំព័រ **lds.org/go/71853** ។



*តើខ្ញុំអាចមើលថែមនុស្សម្នាក់ដែល មានឥរិយាបថពិបាកបែបនេះ ដោយរបៀបណាទៅ ?*

# នៅពេល ដែលការបម្រើ មានការលំបាក

**ដោយ លីតា ធី វ៉ាឌែល**

រឿងមួយដែលជាឧបសគ្គមួយដ៏ធំបំផុតដែលខ្ញុំធ្លាប់យកឈ្នះនោះគឺឥរិយាបទ « ខ្ញុំមិនខ្វល់ » ។ ប្រសិនបើខ្ញុំពុំចូលចិត្តនឹងអ្វីដែលខ្ញុំកំពុងធ្វើទេ នោះខ្ញុំមានចិត្តសោះកក្រោះ និងគ្មានចិត្តអត់ធ្មត់ជាមួយគេឯងឡើយ ។

អ្វីៗទាំងអស់បានផ្លាស់ប្ដូរនាគ្រាសម្រាកពីការសិក្សា កាលខ្ញុំត្រូវបានសុំឲ្យមើលថែជីតាអាយុ ៧៦ ឆ្នាំរបស់ខ្ញុំ ។ « ដាតឌី » ជាឈ្មោះដែលយើងហៅគាត់ គាត់មានឈឺជំងឺដាច់សសៃឈាមក្នុងខួរក្បាលដែលធ្វើឲ្យគាត់ស្លាប់មួយចំហៀងខ្លួន ។ នៅពេលគ្រួសាររបស់ខ្ញុំបានសុំឲ្យខ្ញុំមើលថែគាត់រយៈពេលពីរខែ ខ្ញុំសឹងពុំអាចស្រមៃថា តើវានឹងកើតឡើងដោយរបៀបណាផង ។

ខ្ញុំត្រូវក្រោកពីព្រលឹមដើម្បីរៀបចំអាហារពេលព្រឹកឲ្យគាត់ ងូតទឹកឲ្យគាត់ និងបញ្ចុកថ្នាំគាត់ ។ ខ្ញុំបានជួយគ្រាគាត់ឲ្យដើរហាត់ប្រាណប្រចាំថ្ងៃ ។ ចាប់តាំងពីគាត់មានការលំបាកក្នុងការកម្រើកមក ខ្ញុំនៅក្បែរគាត់គ្រប់ពេលវេលា រួមទាំងពេលគាត់ងូតទឹក និងពេលគាត់បត់ជើងតូចធំផងដែរ ។ ជាក្មេងស្រីអាយុ ១៨ ឆ្នាំរឿងនេះគឺជារឿងលំបាកបំផុត ។

ក្រៅពីអ្វីៗទាំងអស់នេះ គាត់ពិបាកនឹងនៅជាមួយណាស់ ។ គាត់ពុំមែនជាសមាជិកសាសនាចក្រទេ ហើយគាត់មានគោលការណ៍ផ្សេងពីខ្ញុំ ។ គាត់ជាមនុស្សម្នាក់ពោរពេញដោយវិប្បដិសារី — គាត់តែងតែស្រែក ពុំដែលញញឹម ហើយនិយាយជាប់ជានិច្ចថា « អញងាប់ហើយៗ ! » ។ ដោយសារតែឥរិយាបថនេះហើយ វាធ្វើឲ្យពួកយើងពិបាកនឹងបង្កើតទំនាក់ទំនងល្អជាមួយគាត់ ។

នៅគ្រាដំបូង ខ្ញុំបានធ្វើអ្វីៗទាំងអស់ដើម្បីខ្ញុំអាចចៀសវាងពីកិច្ចការរបស់ខ្ញុំ ប៉ុន្តែខ្ញុំពុំអាចធ្វើទៅបានឡើយ ។ ដូច្នេះខ្ញុំបានសម្រេចចិត្តផ្លាស់ប្ដូរឥរិយាបថរបស់ខ្ញុំ ហើយខំប្រឹងយ៉ាងអស់ពីសមត្ថភាពរបស់ខ្ញុំ ។

រូបភាពដោយ គ្រីស្ទី ប៊ែណេត

មួយសប្ដាហ៍ក្រោយពីឥរិយាបថថ្មីនេះ ការបម្រើដាតឌីបានក្លាយជាអំណរមួយសម្រាប់ខ្ញុំ ។ ការអត់ធ្មត់របស់ខ្ញុំបានកើនឡើង ហើយខ្ញុំបានយល់ពីការរងទុក្ខរបស់គាត់ ។ នៅពេលខ្ញុំបានបម្រើគាត់ ខ្ញុំបានឈប់គិតអំពីការនៅជាមួយគាត់ថាជាបន្ទុក ផ្ទុយទៅវិញខ្ញុំបានគិតថា វាជាឱកាសដើម្បីបង្កើតគ្រាដ៏សប្បាយៗជាមួយគាត់ ។

ដាតឌីបានផ្លាស់ប្ដូរផងដែរ ។ ទឹកមុខក្រញ៉ូវរបស់បុរសចំណាស់នេះបានប្រែជាញញឹម និងជាជីតាដែលសុភាព ។ គាត់ថែមទាំងប្រែជាចូលចិត្តស្ដាប់តន្ត្រីពិសេសសម្រាប់យុវវ័យទៀតផង !

នាយប់មួយ ខ្ញុំបានស្ដាប់ឮគាត់ធ្វើសំឡេងអ្វីមួយ ដូច្នេះខ្ញុំបានមើលទៅក្នុងបន្ទប់គាត់ដើម្បីចង់ដឹងថា តើគាត់កំពុងធ្វើអ្វី ។ គាត់កំពុងតែអធិស្ឋានជាលើកដំបូង ។ ខ្ញុំទទួលបានការបំផុសគំនិតរៀងរាល់ថ្ងៃដោយសារតែការផ្លាស់ប្ដូរនេះ ។

ឥឡូវនេះខ្ញុំបានត្រឡប់ទៅរៀនវិញហើយ ប៉ុន្តែខ្ញុំនៅតែទៅសួរសុខទុក្ខដាតឌីជាមួយគ្រួសាររបស់ខ្ញុំពីរដងក្នុងមួយខែ ។ យើងបានបរិភោគអាហារជាមួយគាត់ ហើយច្រៀងឲ្យគាត់ស្ដាប់ ។ សុខភាពរបស់គាត់កាន់តែដុនដាបទៅៗ ដូច្នេះជំនួយដ៏មានឥទ្ធិពលខ្លាំងបំផុតដែលខ្ញុំអាចផ្ដល់ឲ្យបាននៅពេលនេះគឺការអធិស្ឋានសម្រាប់គាត់ ។

ខ្ញុំមានអំណរគុណចំពោះឱកាសមើលថែដាតឌី ដោយសារវាបានជួយខ្ញុំឲ្យមើលឃើញពីអ្វីដែលខ្ញុំអាចមានសមត្ថភាពក្នុងការផ្ដល់ឲ្យអ្នកដទៃ ។ សេចក្ដីស្រឡាញ់គឺជាអ្វីមួយដែលមានឥទ្ធិពលបំផុត — វាបានបន្ទន់ចិត្តរបស់ខ្ញុំ និងចិត្តរបស់ដាតឌី ។ ខ្ញុំបានរៀនអំពីអត្ថន័យនៃការលះបង់ និងសេចក្ដីមេត្តាករុណា ។ ពិតប្រាកដណាស់ សេចក្ដីសប្បុរសសម្រាលបន្ទុកដល់ដួងចិត្តនៃជនគ្រប់រូប ! ■

*អ្នកនិពន្ធរស់នៅទីក្រុង សាន់ទីអាហ្គោ ប្រទេសហ្វីលីពីន ។*





**ការបម្រើក្រុមគ្រួសាររបស់អ្នក**

« សូមចាប់ផ្ដើមការបម្រើរបស់អ្នកនៅក្នុងគេហដ្ឋានអ្នកផ្ទាល់ និងក្នុងគ្រួសារអ្នកផ្ទាល់ ។ ទាំងនេះគឺជាទំនាក់ទំនងដែលអាចនៅអស់កល្បជានិច្ច ។ ទោះជា — ហើយជាពិសេសប្រហែលជា — ស្ថានភាពគ្រួសារអ្នកមិនសូវល្អឥតខ្ចោះក្ដី ក៏អ្នកអាចស្វែងរកវិធីបម្រើ លើកតម្កើង ហើយពង្រឹងគ្នាផងដែរ ។ សូមចាប់ផ្ដើមពីរូបអ្នក សូមស្រឡាញ់ពួកគេតាមលក្ខណៈរបស់គេ ហើយរៀបចំសម្រាប់គ្រួសារដែលអ្នកចង់បាននៅពេលអនាគត » ។

ស៊ីស្ទើរ បូនី អិល អូស្កាសុន ប្រធានយុវនារីទូទៅ « សេចក្ដីត្រូវការនៅចំពោះយើង » សន្និសីទទូទៅខែ តុលា ឆ្នាំ ២០១៧ ។

# យោបល់គន្លឹះ ៧ ចំណុចសម្រាប់ការឡើងនិយាយ

*តើត្រូវឡើងនិយាយនៅក្នុងការប្រជុំសាក្រាម៉ង់ឆាប់ៗនេះមែនទេ ? សូមសាកល្បងយោបល់គន្លឹះទាំងនេះ ។*

ដោយ សារ៉ា ហានសុន



ខ្ញុំមិនដឹងអំពីអ្នកឡើយ ប៉ុន្តែនៅពេលខ្ញុំត្រូវបានចាត់ឲ្យឡើងនិយាយនៅក្នុងប្រជុំសាក្រាម៉ង់ ខ្ញុំពិតជាមានអារម្មណ៍ភ័យណាស់ — ពុំមែនអំពីការសរសេរការនិយាយនោះទេ ប៉ុន្តែពិតប្រាកដណាស់វាគឺជា *ការឡើង* និយាយនោះ ។ ខ្ញុំបារម្ភជានិច្ចថា « តើមានអ្វីកើតឡើងទៅ ប្រសិនបើគេធុញទ្រាន់នឹងខ្ញុំខ្លាំងពេកនោះ ? ចុះបើខ្ញុំភ្លេចនិយាយអំពីអ្វីមួយវិញនោះ ? ចុះបើខ្ញុំនិយាយពាក្យខុសនោះ ? »

តើធ្លាប់មានអារម្មណ៍ដូច្នេះដែរឬទេ ? ( សង្ឃឹមថាខ្ញុំពុំមែនជាមនុស្សបែបនោះតែឯងទេ ) ។ ប្រសិនបើដូច្នេះមែននោះ រឿងនេះពុំមែនជារឿងខូចខាតធ្ងន់ធ្ងរអីនោះទេ ! សូមមើលយោបល់គន្លឹះទាំងប្រាំពីរ

## ការរៀបចំការនិយាយ

**១. សូមប្រើប្រាស់ព្រះគម្ពីរ និងការបង្រៀនរបស់ពួកព្យាការីសម័យទំនើប ( សូមមើល គ. និង ស. ៥២:៩ )** ។ នេះគឺជាចំណុចសំខាន់នៃការនិយាយរបស់អ្នក ។ លើសពីនោះទៀត នោះគឺជាហេតុផលចម្បងមួយដែលយើងត្រូវនៅព្រះវិហារ — គឺដើម្បីបង្រៀន និងរៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ អ្នកអាចសិក្សាប្រធានបទរបស់អ្នកដោយមានជំនួយមកពីសេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ( គេហទំព័រ scriptures.lds.org ) និងសុន្ទរកថាសន្និសីទទូទៅ ( ស្រាវជ្រាវតាមប្រធានបទនៅគេហទំព័រ gc.lds.org ) ។ សូមប្រាកដថា អ្នកយល់ពីខគម្ពីរ និងការដកស្រង់ដែលអ្នកគ្រោងនឹងប្រើប្រាស់នៅក្នុងសុន្ទរកថារបស់អ្នក ។ ប្រសិនបើអ្នកត្រូវការជំនួយ សូមសួរឪពុកម្ដាយឬថ្នាក់ដឹកនាំសាសនាចក្ររបស់អ្នក ។

**២. សូមយាងអញ្ជើញព្រះវិញ្ញាណ** ។ វាជាគំនិតល្អជានិច្ចដើម្បីអធិស្ឋាន ហើយរៀបចំជាមុនដើម្បីមានព្រះវិញ្ញាណគង់នៅជាមួយអ្នកនៅពេលអ្នកនិយាយ ។ ព្រះវិញ្ញាណពុំគ្រាន់តែប្រទាននូវការលួងលោមដល់អ្នកប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ថ្លែងទីបន្ទាល់អំពីសេចក្ដីពិតផងដែរ ( សូមមើល គ. និង ស. ៤២:១៤ ) ។ សូមយាងអញ្ជើញព្រះវិញ្ញាណមកក្នុងការប្រជុំសាក្រាម៉ង់របស់អ្នកតាមរយៈការថ្លែងទីបន្ទាល់អំពីអ្វីដែលអ្នកជឿថាជាការពិត ។

**៣. សូមគិតអំពីរឿងផ្ទាល់ខ្លួន** ។ វិធីមួយដ៏ល្អបំផុតដើម្បីមានទំនាក់ទំនងជាមួយមនុស្សដទៃគឺតាមរយៈដំណើររឿង ។ យើងចូលចិត្តស្ដាប់បទពិសោធន៍របស់មនុស្សដទៃ និងអ្វីដែលជីវិតរបស់ពួកគេបានឆ្លងកាត់ ។ ដូច្នេះសូមព្យាយាមគិតអំពីបទពិសោធន៍រីករាយ ពិសេសៗ ឬបទពិសោធន៍នៃឧបសគ្គនានាដែលអ្នកបានមានដែលទាក់ទងនឹងគោលការណ៍នៃដំណឹងល្អ ដែលអ្នកត្រូវបានចាត់ឲ្យនិយាយនោះ ។ តើអ្នកបានរៀនអ្វីខ្លះពីបទពិសោធន៍នោះ ? តើវាបានជួយអ្នកយ៉ាងដូចម្ដេច ? នេះគឺជារបៀបដ៏ល្អបំផុតដើម្បីបើកការនិយាយរបស់អ្នក ប្រសិនបើអ្នកពុំដឹងពីរបៀបចាប់ផ្ដើមនិយាយ ។

**៤. សូមហាត់និយាយម្ដងហើយម្ដងទៀតៗ !** បន្ទាប់ពីអ្នកបានសរសេរការនិយាយរបស់អ្នកហើយ អ្នកអាចហាត់សមការនិយាយនោះឲ្យឮៗដោយខ្លួនឯង ហើយបន្ទាប់មកហាត់និយាយវានៅពីមុខសមាជិកគ្រួសារ ឬមិត្តភក្តិរបស់អ្នក ។ អ្នកអាចដឹងថា តើការនិយាយរបស់អ្នកនៅក្នុងរយៈពេលកំណត់ដែលបានផ្ដល់ឲ្យដែរឬទេ ហើយថាមានផ្នែកណាខ្លះដែលអ្នកត្រូវបញ្ជាក់ឲ្យច្បាស់ ។ ប្រសិនបើមានការអនុញ្ញាតពីប៊ីស្សពរបស់អ្នក អ្នកថែមទាំងអាចសាកល្បងទៅអគារសាសនាចក្រជាមុន ដើម្បីឡើងនិយាយនៅលើវេទិកាផងដែរ !

## ការផ្ដល់ការនិយាយ



**៥. សូមចៀសវាងចាប់ផ្ដើមដោយការនិយាយថា « ខ្ញុំពុំចង់ឡើងមកទីនេះទេ »** ។ ការចាប់ផ្ដើមនិយាយបែបនេះមានជាច្រើនទម្រង់ផ្សេងគ្នា ប៉ុន្តែអ្នកស្ដាប់ភាគច្រើនស្ដាប់វាស្គាល់ភ្លាម ។ ជាទូទៅវាដូចជាការនិយាយថា « នៅពេលប៊ីស្សពទូរសព្ទមកខ្ញុំ ហើយសួរប្រសិនបើខ្ញុំអាចឡើងនិយាយបានឬទេ នោះខ្ញុំបានព្យាយាមគិតអំពីការដោះសារមួយចំនួនដើម្បីបដិសេធមិនឡើងនិយាយ » ។ សមាជិកសាសនាចក្រភាគច្រើនអាចយល់អំពីភាពពុំស្រណុកចិត្តក្នុងការឡើងនិយាយ ប៉ុន្តែជាទូទៅនៅពេលអ្នកនិយាយថា « ខ្ញុំពុំចង់ឡើងមកទីនេះ » នោះមនុស្សអាចស្ដាប់ឮថា « សូមកុំស្ដាប់ខ្ញុំនិយាយអី » ។ វាជារឿងល្អបំផុតដើម្បីចៀសវាងការនិយាយពាក្យទាំងនោះ — ចូរមានភាពសុទិដ្ឋនិយមអំពីប្រធានបទរបស់អ្នក !

**៦. សូមនិយាយឲ្យច្បាស់ៗ** ។ វាជារឿងធម្មតាដែលមនុស្សម្នាក់និយាយលឿនពេក ឬយឺតពេកដោយសារតែការភ័យ ។ ខ្ញុំអាចយល់រឿងនេះច្បាស់ណាស់ ។ ប៉ុន្តែវាសំខាន់ដើម្បីនិយាយច្បាស់ៗ នៅពេលអ្នកផ្ដល់ការនិយាយរបស់អ្នក ដូច្នេះក្រុមជំនុំអាចយល់អ្នកបាន ។ សូមខិតខំដោយការតាំងចិត្តក្នុងការបន្ថយល្បឿននិយាយ បញ្ចេញសំឡេងពាក្យរបស់អ្នក ហើយនិយាយដោយចេះលើកដាក់សំឡេងរបស់អ្នក ( មែនហើយ សូម្បីតែជាមួយមេក្រូហើយ ក៏វាអាចស្ងាត់ពេកផងដែរ ) ។ មនុស្សចង់ស្ដាប់អ្វីដែលអ្នកត្រូវនិយាយ !

**៧. សូមបន្តសម្លឹងមើលទៅមុខ** ។ ការសំឡឹងមើលកែវភ្នែកគឺជាផ្នែកសំខាន់បំផុតនៃទំនាក់ទំនងល្អ ។ វាបង្ហាញថា អ្នកផ្ដោតចិត្តទុកដាក់ដោយស្មោះសរ ហើយចាប់អារម្មណ៍ក្នុងការសន្ទនា ។ ឥឡូវនេះ អ្នកពុំត្រូវតែសំឡឹងមើលកែវភ្នែកមនុស្សគ្រប់រូបនៅក្នុងក្រុមជំនុំនៅពេលអ្នកនិយាយឡើយ ប៉ុន្តែប្រសិនបើអ្នកសម្លឹងមើលទៅខាងក្រោយ ឬខាងមុខបន្ទប់ នោះអ្នកនឹងមានចំណាប់អារម្មណ៍កាន់តែខ្លាំងឡើងក្នុងនាមជាអ្នកឡើងនិយាយ ។ សូមចៀសវាងការសំឡឹងមើលតម្រុយនៃការកត់ចំណាំរបស់អ្នក ! អ្នកស្ដាប់ចង់ឃើញស្នាមញញឹមរបស់អ្នក ពុំមែនមើលក្បាលរបស់អ្នកឡើយ ។

សូម្បីតែជាមួយនឹងយោបល់គន្លឹះទាំងប្រាំពីរចំណុចនេះក្ដី ក៏អ្នកអាចនៅតែមានកំហុស ឬកត់សម្គាល់ឃើញមានអ្នកកំពុងដេកលក់នៅជួរទីបីផងដែរ ។ ប៉ុន្តែតើការណ៍នោះមានន័យថា អ្នកគឺជាអ្នកនិយាយមិនល្អ ឬ ? ប្រាកដណាស់ វាពុំមែនដូច្នោះទេ !

នៅពេលអ្នកធ្វើអ្វីមួយដែលពិបាកនឹងធ្វើ នោះជារឿងធម្មតាដែលអ្នកមានអារម្មណ៍ភ័យ ឬមានកំហុសតិចតួច ។ ប៉ុន្តែដរាបណាអ្នកព្យាយាមឲ្យអស់ពីសមត្ថភាពរបស់អ្នក ហើយយាងអញ្ជើញព្រះវិញ្ញាណ ទោះបីជាអ្នកនិយាយត្រដិត ឬភ្លេចនិយាយអ្វីមួយក្ដីនោះវាមិនជាបញ្ហាអ្វីឡើយ ។ អ្នកកំពុងធ្វើកិច្ចការរបស់ព្រះ ហើយជួយបុត្រាបុត្រីរបស់ទ្រង់ឲ្យរៀនកាន់តែច្រើនទៀតអំពីដំណឹងល្អ !

ប្រសិនបើអ្នកបង្រៀន និងថ្លែងទីបន្ទាល់អំពីអ្វីដែលអ្នកជឿ នោះអ្វីៗគ្រប់យ៉ាងនឹងប្រែទៅជាល្អប្រសើរឡើង ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*

នេះ ដើម្បីធ្វើឲ្យការប៉ិនប្រសប់ក្នុងការនិយាយ និងការឡើងនិយាយដែលគួរឲ្យចាប់អារម្មណ៍មានសភាពកាន់តែប្រសើរឡើង ។

រចនារូបភាព ដោយ អ៊ែដាម ហោវើង



# តើយើងធ្វើអ្វីនៅក្នុងព្រះវិហារបរិសុទ្ធ ?

ព្រះវិហារបរិសុទ្ធគឺជាកន្លែងពិសិដ្ឋដែលអ្នកអាចខិតកាន់តែជិតព្រះវរបិតាសួគ៌របស់យើង និងព្រះយេស៊ូវគ្រីស្ទ ។ នៅក្នុងព្រះវិហារបរិសុទ្ធ យើងត្រូវបានបង្រៀនអំពីសារៈសំខាន់នៃសេចក្តីពិត ចូលរួមក្នុងពិធីបរិសុទ្ធបព្វជិតភាព ( ពិធីពិសិដ្ឋនានា ) និងចុះសេចក្តីសញ្ញា ( ការសន្យាពិសិដ្ឋ ) ជាមួយព្រះ ដែលរៀបចំយើងឲ្យត្រឡប់ទៅកាន់វត្តមានរបស់ទ្រង់វិញ ។

យើងអាចទទួលពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធសម្រាប់ខ្លួនរបស់យើង ព្រមទាំងជីដូនជីតារបស់យើងផងដែរ ។ ឧទាហរណ៍ ពួកយុវវ័យអាចចូលរួមនៅក្នុងបុណ្យជ្រមុជទឹកជំនួសឲ្យជីដូនជីតារបស់អ្នក និងមនុស្សដទៃទៀត ដែលគ្មានឱកាសទទួលបុណ្យជ្រមុជទឹកដោយសិទ្ធិអំណាចត្រឹមត្រូវកាលពីពួកគេនៅរស់ ។ សម្រាប់យុវមជ្ឈិមវ័យ ពិធីបរិសុទ្ធផ្សេងទៀតនៃព្រះវិហារបរិសុទ្ធរួមទាំងពិធីអំណោយទានពិសិដ្ឋ និងការផ្សារភ្ជាប់ ( ដូចជាអាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ ) ។

**ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់សម្រាប់ជីដូនជីតារបស់យើង**

ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់មានភាពចាំបាច់ចំពោះសេចក្តីសង្គ្រោះរបស់មនុស្សគ្រប់រូបដែលមានការទទួលខុសត្រូវ ដែលបានរស់នៅលើផែនដីនេះ ( សូមមើល យ៉ូហាន ៣:៥ ) ។ ប៉ុន្តែមនុស្សជាច្រើនបានស្លាប់ដោយគ្មានឱកាសនៃការស្តាប់ឮដំណឹងល្អ ឬទទួលពិធីបរិសុទ្ធទាំងនេះឡើយ ។ តាមរយៈព្រះគុណ និងសេចក្តីករុណានៃព្រះយេស៊ូវគ្រីស្ទ របៀបមួយត្រូវបានរៀបចំសម្រាប់មនុស្សគ្រប់រូបឲ្យទទួលពរជ័យទាំងនេះ ។ នៅក្នុងព្រះវិហារបរិសុទ្ធ សមាជិកសាសនាចក្រដែលសក្តិសមអាចធ្វើពិធីបុណ្យជ្រមុជទឹកជំនួសអ្នកដែលបានស្លាប់ ។ នៅក្នុងពិភពវិញ្ញាណ ដំណឹងល្អត្រូវបានប្រកាស ( សូមមើល គ. និង ស. ១៣៨ ) ហើយអស់អ្នកដែលស្តាប់ឮដំណឹងល្អអាចជ្រើសរើសទទួលយកវា រួចមកពិធីបរិសុទ្ធដែលបានធ្វើជំនួសពួកគេ ។



**ព្រះវិហារបរិសុទ្ធ ៖ និមិត្តសញ្ញានៃសេចក្ដីជំនឿរបស់យើង**

« ព្រះវិហារបរិសុទ្ធនីមួយៗគឺជានិមិត្តសញ្ញានៃសេចក្ដីជំនឿរបស់យើងចំពោះព្រះ និង ជាភស្ដុតាងមួយពីសេចក្ដីជំនឿរបស់យើងនៅក្នុងជីវិតបន្ទាប់ពីសេចក្ដីស្លាប់ ។ ព្រះវិហារបរិសុទ្ធជាគោលបំណងនៃរាល់សកម្មភាព រាល់មេរៀន រាល់ជំហានដែលរីកចម្រើននៅក្នុងសាសនាចក្រ ។ រាល់ការខិតខំទាំងអស់របស់យើងនៅក្នុងការប្រកាសដំណឹងល្អ ការធ្វើឲ្យពួកបរិសុទ្ធបានល្អឥតខ្ចោះ និង ការប្រោសលោះមនុស្សស្លាប់ ដឹកនាំទៅរកព្រះវិហារបរិសុទ្ធ ។

ប្រធាន រ័សុល អិម ណិលសុន « Prepare for the Blessings of the Temple » *Liahona* ខែ តុលា ឆ្នាំ ២០១០ ទំព័រ ៤១ ។

## តើអ្នករៀបចំខ្លួនដោយរបៀបណា ?

តើការរក្សាសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់អ្នកជួយអ្នកឲ្យរៀបចំខ្លួន ដើម្បីទទួលពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធដោយរបៀបណា ?

.....................................................

.....................................................

.....................................................

តើអ្នកចាំបាច់ត្រូវធ្វើអ្វីខ្លះទៀត ដើម្បីអ្នកអាចត្រៀមខ្លួនទទួលពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ ?

.....................................................

.....................................................

.....................................................

តើប័ណ្ណចូលព្រះវិហារបរិសុទ្ធរបស់អ្នកមានសុពលភាពដែរឬទេ ? ប្រសិនបើអ្នកគ្មានប័ណ្ណចូលព្រះវិហារបរិសុទ្ធទេ អ្នកអាចណាត់ជួបប៊ីស្សព ឬ ប្រធានសាខារបស់អ្នក ។

.....................................................



*ដើម្បីរៀនបន្ថែមទៀតអំពីការទៅព្រះវិហារបរិសុទ្ធនៅលើកដំបូង សូមទស្សនា « នៅខាងក្នុងព្រះវិហារបរិសុទ្ធ » នៅគេហទំព័រ* **lds.org/temples** ។

## អំណោយទានពិសិដ្ឋ

ពាក្យ *អំណោយទានពិសិដ្ឋ* មានន័យថា « អំណោយ » ។ អំណោយទានពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធគឺជាអំណោយមកពីព្រះដែលទ្រង់ប្រទានពរជ័យពិសេសមកលើអ្នក រួមមាន « ព្រះចេស្ដាពីស្ថានលើ » ( គ. និង ស. ៩៥:៨ ) ។

នៅពេលអ្នកចូលជាសមាជិកសាសនាចក្រ អ្នកបានទទួលពិធីបរិសុទ្ធចំនួនពីរ — ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ។ អំណោយទានពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធក៏ត្រូវបានទទួលជាពីរផ្នែកផងដែរ ។ ទីមួយ អ្នកទទួលពិធីបរិសុទ្ធនៃពិធីលាងជម្រះ ជាកន្លែងដែលអ្នកត្រូវបាន « លាងជម្រះ » ឲ្យស្អាតដោយនិមិត្តសញ្ញា និងដោយសមរម្យ ហើយទទួលពរជ័យពិសេសទាក់ទងនឹងមរតក និងសក្ដានុពលដ៏អស់កល្បជានិច្ចនៃភាពជាព្រះរបស់អ្នក ។ នៅក្នុងផ្នែកទីពីរ អ្នកទទួលពិធីអំណោយទានពិសិដ្ឋដែលសល់ទាំងប៉ុន្មានរបស់អ្នក នៅពេលអ្នករៀនបន្ថែមទៀតអំពីផែនការនៃសេចក្ដីសង្គ្រោះ រួមមានការបង្កបង្កើត គោលបំណងរបស់យើងនៅលើផែនដី និងបេសកកម្ម ព្រមទាំងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។

អំឡុងពេលអំណោយទានពិសិដ្ឋ យើងធ្វើការសន្យាដ៏ឱឡារិកដើម្បីគោរពព្រះ ធ្វើតាមព្រះយេស៊ូវគ្រីស្ទ មានភាពស្អាតស្អំខាងផ្លូវភេទ ហើយជួយស្ថាបនានគរព្រះ ។ ប្រសិនបើយើងរក្សាសេចក្ដីសញ្ញារបស់យើង នោះយើងមាននូវការសន្យានៃការទទួលបាននូវពរជ័យអស់កល្បជានិច្ចរបស់ព្រះ ។

## ពិធីផ្សារភ្ជាប់

ក្រុមគ្រួសារគឺជាផ្នែកដ៏សំខាន់មួយនៃផែនការរបស់ព្រះសម្រាប់សុភមង្គលរបស់យើង ។ ក្រុមគ្រួសាររួមរស់ជាមួយគ្នាជារៀងរហូតគឺជាពរជ័យដ៏ធំមហិមាដែលមាននៅក្នុងព្រះវិហារបរិសុទ្ធតាមរយៈសិទ្ធិអំណាចបព្វជិតភាពនៃពិធីផ្សារភ្ជាប់ — ជាសិទ្ធិអំណាចដូចគ្នាដែលព្រះយេស៊ូវបានប្រាប់ពួកសាវករបស់ទ្រង់ ( សូមមើល ម៉ាថាយ ១៦:១៩ ) ។ ពិធីផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធអាចជួយឲ្យស្វាមី និងភរិយា ព្រមទាំងកូនៗ និងឪពុកម្ដាយអាចនៅជាមួយគ្នាជារៀងរហូត តាមរយៈសេចក្ដីស្មោះត្រង់របស់ពួកគេចំពោះសេចក្ដីសញ្ញារបស់ពួកគេ ។ ■

# អារម្មណ៍កើតទុក្ខ នៅថ្ងៃឈប់

*ខ្ញុំបានដឹងថា ខ្ញុំគួរតែចូលចិត្តថ្ងៃឈប់សម្រាក ប៉ុន្តែខ្ញុំពុំដឹងអំពីរបៀបចូលចិត្តនោះឡើយ ។*

**ដោយ អាលីសា នៀលសិន**

ខគម្ពីរចែងថា ថ្ងៃឈប់សម្រាកគឺជាថ្ងៃបរិសុទ្ធ ជាថ្ងៃអំណរ និងជាទីរីករាយជាថ្ងៃសម្រាក ជាថ្មីដើម្បីសាទរ ។[1] ប៉ុន្តែពីរបីឆ្នាំកន្លងទៅនេះ អំឡុងពេលចុងក្រោយនៃវ័យជំទង់របស់ខ្ញុំ ខ្ញុំបានឃើញថាថ្ងៃអាទិត្យគឺជាថ្ងៃដ៏សោកសៅ ។ ខ្ញុំមានអារម្មណ៍តានតឹងក្នុងចិត្តជាជាងមានអារម្មណ៍សុខសាន្ត ។ កើតទុក្ខជាជាងមានអំណរ ។ មានកំហុសជាជាងមានសេចក្តីសង្ឃឹម ។ ខ្ញុំមានអារម្មណ៍កើតទុក្ខយ៉ាងខ្លាំងនៅថ្ងៃឈប់សម្រាក ។

នៅរៀងរាល់ព្រឹកថ្ងៃអាទិត្យ បន្ទាប់ពីការលាក់ខ្លួនក្នុងភួយដោយអៀនខ្មាសអស់ជាច្រើនម៉ោងមក ខ្ញុំបានដឹងថាវាជាថ្ងៃអាទិត្យហើយរៀបចំខ្លួនស្លៀកពាក់ទៅព្រះវិហារ ។ នៅព្រះវិហារខ្ញុំបានរំឭកពីអ្វីៗកាលពីសប្តាហ៍មុន ។ អំឡុងពេលសាក្រាម៉ង់ ខ្ញុំនឹងរាប់នូវបរាជ័យនានារបស់ខ្ញុំពុំចប់ឡើយពីមុនអ្នកនិយាយទីមួយឡើងនិយាយ ។ ម៉ោងដែលនៅសល់ទាំងប៉ុន្មាននៅព្រះវិហារក្លាយជាសមរភូមិនៃការទប់ទឹកភ្នែកនៅពេលទោសកំហុសកាន់តែមានច្រើនឡើងជាមួយនឹងវិប្បដិសារីថ្មីនៃអារម្មណ៍ដែលមិនរីករាយសោះនៅព្រះវិហារ ។

នៅពេលរសៀលក៏ដូចគ្នាផងដែរ ។ ខ្ញុំនឹងមានអារម្មណ៍ថា មានទោសដោយសារតែការជ្រើសរើសពីអតីតកាល មានភាពតានតឹងក្នុងចិត្តអំពីជម្រើសនាពេលអនាគត ហើយកើតទុក្ខអំពីកាលៈទេសៈនាពេលបច្ចុប្បន្ន ។ បើគ្មានសកម្មភាពមកពីសាលា និងសកម្មភាពនៃកាលវិភាគបន្ថែមជួយបង្វែរអារម្មណ៍ខ្ញុំទេ នោះខ្ញុំនឹងចំណាយពេលរបស់ខ្ញុំរស់នៅក្នុងគំនិតអវិជ្ជមាន ។

បន្ទាប់ពីស្តាប់ អាន ហើយអានម្តងទៀតនូវសុន្ទរកថាសន្និសីទទូទៅខែ តុលា ឆ្នាំ ២០១៥ របស់ប្រធាន រ័សុល អិម ណិលសុន អំពីរបៀបដែលថ្ងៃឈប់សម្រាកគឺជាទីរីករាយចិត្ត នោះខ្ញុំបានអធិស្ឋានទូលសូមភាពសុខសាន្ត និងសេចក្តីស្រឡាញ់សម្រាប់ថ្ងៃឈប់សម្រាក ជាជាងកើតទុក្ខដូចខ្ញុំកំពុងតែទទួលអារម្មណ៍នេះ ។[2] ហើយចម្លើយមួយបានកើតមានឡើង ។

រូបថតដោយ ដាវីឌ ស្មីធ



# សម្រាក

ផ្ដោតទៅលើព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ

ខ្ញុំបានទទួលអារម្មណ៍ឲ្យប្ដូរការផ្ដោតចិត្តទុកដាក់របស់ខ្ញុំពីទុក្ខសោករបស់ខ្ញុំទៅជាការផ្ដោតលើទំនាក់ទំនងរបស់ខ្ញុំជាមួយព្រះវរបិតាសួគ៌ និងព្រះអង្គសង្គ្រោះ ។ ជាជាងពិចារណាអំពីបរាជ័យរបស់ខ្ញុំ ខ្ញុំបានចំណាយពេលពិចារណាអំពីទំនាក់ទំនងរបស់ពួកទ្រង់នៅក្នុងជីវិតរបស់ខ្ញុំ ។

នៅពេលគំនិតអវិជ្ជមានកើតឡើង ខ្ញុំបាននិយាយប្រាប់ខ្លួនខ្ញុំម្ដងហើយម្ដងទៀតថា អ្វីដែលខ្ញុំបានដឹង និងជឿអំពីព្រះ និងព្រះយេស៊ូវគ្រីស្ទគឺថា ៖ ខ្ញុំជាកូនរបស់ព្រះ ។ ទ្រង់ស្រឡាញ់ខ្ញុំ ។ ព្រះយេស៊ូវគ្រីស្ទគឺជាបងប្រុសរបស់ខ្ញុំ ហើយទ្រង់បានធ្វើដង្វាយធួនសម្រាប់ខ្ញុំ ។ ពួកទ្រង់សព្វព្រះទ័យឲ្យខ្ញុំរីករាយ ហើយត្រឡប់ទៅកាន់ពួកទ្រង់វិញ ។ ថ្ងៃឈប់សម្រាកគឺជាអំណោយមកពីព្រះ ។

ខ្ញុំបានចាប់ផ្ដើមអនុវត្តសេចក្ដីជំនឿនៅក្នុងទីបន្ទាល់នេះ ។

## ទទួលសាក្រាម៉ង់ដោយសកម្ម

ការផ្លាស់ប្ដូរការផ្ដោតចិត្តទុកដាក់របស់ខ្ញុំក៏បាននាំខ្ញុំឲ្យពិចារណាជាថ្មីម្ដងទៀតអំពីរបៀបដែលខ្ញុំទទួលសាក្រាម៉ង់ផងដែរ ។ អស់រយៈពេលជាយូរមកហើយ ដែលខ្ញុំបានចាត់ទុកថា សាក្រាម៉ង់គឺជាពេលវេលាដែលខ្ញុំដាក់ទោសខ្លួនឯង ។ ប៉ុន្តែនោះពុំមែនជាគោលបំណងនៃពិធីសាក្រាម៉ង់ឡើយ ។ ពិធីសាក្រាម៉ង់គឺជាពិធីបរិសុទ្ធពិសិដ្ឋ ដើម្បីរំឭកសេចក្ដីសញ្ញារបស់យើង ។ វាជាឱកាសដើម្បីប្រែជាស្អាតវិញម្ដងទៀត តាមរយៈអំណាចដ៏ធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ ការផ្ដោតលើពិធីបរិសុទ្ធ និងសេចក្ដីសញ្ញាជាមួយនឹងសេចក្ដីជំនឿ និងដួងចិត្តដែលប្រែចិត្ត នោះខ្ញុំបានដឹងថា ពិធីសាក្រាម៉ង់បានផ្ដល់ភាពសុខសាន្ត នៅពេលខ្ញុំបានទទួលអំណោយទាននៃការអភ័យទោស នៅពេលខ្ញុំបានរក្សាសេចក្ដីសញ្ញារបស់ខ្ញុំ ហើយបានទទួលព្រះវិញ្ញាណរបស់ព្រះអម្ចាស់ ( សូមមើល គ. និង ស. ២០:៧៧, ៧៩ ) ។

ការគិតអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទអំឡុងពេលពិធីសាក្រាម៉ង់នាំមកនូវអំណោយមួយទៀតក្នុងគំនិតរបស់ខ្ញុំ ។ ខ្ញុំពុំគ្រាន់តែអាចទទួលបានការអភ័យទោសប៉ុណ្ណោះទេ ប៉ុន្តែខ្ញុំថែមទាំងបានទទួលការព្យាបាលផងដែរ ដោយសារព្រះអង្គសង្គ្រោះបានលើកដាក់លើព្រះអង្គទ្រង់នូវការឈឺចាប់ និងជំងឺរបស់ខ្ញុំ ( សូមមើល អាលម៉ា ៧:១១–១២ ) ។ តាមរយៈដង្វាយធួនរបស់ទ្រង់ និងពិធីសាក្រាម៉ង់នោះខ្ញុំអាចរកឃើញភាពសុខសាន្ត និងកម្លាំងនៅថ្ងៃឈប់សម្រាក — ឬនៅថ្ងៃដទៃផ្សេងទៀត — ជាជាងមានភាពតានតឹងចិត្ត និងកើតទុក្ខ ។

ហើយខ្ញុំបានរកឃើញភាពសុខសាន្តនោះ ។ ព្រះអង្គសង្គ្រោះគង់នៅទីនោះសម្រាប់ខ្ញុំនៅថ្ងៃអាទិត្យ និងគ្រប់ពេលជានិច្ច !

## អនុវត្តសេចក្ដីជំនឿដែលអត់ធ្មត់

នេះពុំមែនជាការជួសជុលដែលលឿនឡើយ ។ វាជាការពុះពារមួយ ហើយវាត្រូវការពេលវេលា ។ « តែបើយើងសង្ឃឹមនឹងបានអ្វី ដែលមើលមិនឃើញវិញ នោះយើងនឹងរង់ចាំនៅដោយអំណត់ (រ៉ូម ៨:២៥) ។ ខ្ញុំបានបន្តខិតខំផ្ដោតចិត្តទុកដាក់ និងអធិស្ឋានដើម្បីទទួលអារម្មណ៍នៃក្ដីស្រឡាញ់សម្រាប់ថ្ងៃឈប់សម្រាក ។

នៅពេលចេះតែកន្លងទៅ ខ្ញុំបានរកឃើញភាពសុខសាន្ត និងក្ដីរីករាយនៅថ្ងៃបរិសុទ្ធនោះ ប៉ុន្តែខ្ញុំពុំអាចឈប់នៅទីនោះឡើយ បើមិនអញ្ចឹងទេខ្ញុំនឹងត្រូវធ្លាក់ទៅក្នុងភាពសោកសៅនៅថ្ងៃឈប់សម្រាកម្ដងទៀតហើយ ។ រៀងរាល់សប្ដាហ៍តម្រូវឲ្យមានភាពរីករាយផ្ដោតទៅលើព្រះអង្គសង្គ្រោះ និងគោលបំណងនៃថ្ងៃឈប់សម្រាក ប៉ុន្តែខ្ញុំដឹងថា ការសន្យានៃភាពសុខសាន្ត និងអំណរគឺជាការពិត ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*



**កំណត់ចំណាំ**

១. សូមមើល និក្ខមនំ ២០:១១; និក្ខមនំ ៣១:១៥; លេវីវិន័យ ២៣:៣២; អេសាយ ៥៨:១៣; គោលលទ្ធិ និងសេចក្ដីសញ្ញា ៥៩:១៣ ។

២. សូមមើល រ័សុល អិម ណិលសុន « ថ្ងៃឈប់សម្រាកជាថ្ងៃមួយដ៏សប្បាយ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១២៩–១៣២ ។




ដ្យាក្រាមនេះតំណាងឲ្យការប្រកួតបាល់ទាត់ពានរង្វាន់ពិភពលោកឆ្នាំ ២០១៤ ហើយពុំមែនជាការទាយអំពីការប្រកួតនាពេលអនាគតណាមួយឡើយ

រូបថតខាងក្រោម បាល់ទាត់ និងទង់ជាតិដោយ៖ Getty Images

# អ្នកអាចសក្ដិសមចំពោះព្រះវិហារបរិសុទ្ធ

ដោយអែលឌើរ ឃ្វិនធិន អិល ឃុក
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

វាជាបំណងប្រាថ្នាដ៏ធំរបស់យើងថា សមាជិកសាសនាចក្រនឹងរស់នៅដោយសក្ដិសមតាមប័ណ្ណចូលព្រះវិហារបរិសុទ្ធ ។ សូមកុំយល់ថាព្រះវិហារបរិសុទ្ធគឺជាគោលដៅមួយដែលនៅដាច់ឆ្ងាយ និងមិនអាចសម្រេចបានឡើយ ។ សូមពិភាក្សាជាមួយប៊ីស្សពរបស់អ្នក សមាជិកភាគច្រើនអាចសម្រេចបានតាមកិច្ចតម្រូវសុចរិតទាំងអស់នៅក្នុងរយៈពេលមួយដ៏ខ្លី ប្រសិនបើពួកគេប្ដេជ្ញាចិត្តឲ្យមានគុណសម្បត្តិ និងប្រែចិត្តទាំងស្រុងពីអំពើរំលងនានា ។ ការណ៍នេះរួមមានការមានឆន្ទៈអភ័យទោសដល់ខ្លួនឯង ហើយពុំផ្ដោតលើភាពឥតគ្រប់លក្ខណ៍ ឬអំពើបាបរបស់ខ្លួនថាជាគុណវិបត្តិរាំងយើងពីការចូលរួមក្នុងព្រះវិហារបរិសុទ្ធដ៏ពិសិដ្ឋនោះឡើយ ។

ដង្វាយធួនរបស់ព្រះអង្គសង្គ្រោះបានធ្វើឡើងសម្រាប់កូនចៅទាំងអស់របស់ព្រះ ។ ពលិកម្មដ៏ប្រោសលោះរបស់ទ្រង់បំពេញនូវតម្រូវការនៃសេចក្ដីយុត្តិធម៌សម្រាប់អស់អ្នកដែលប្រែចិត្តពិតប្រាកដ ។ ព្រះគម្ពីរពិពណ៌នាការណ៍នេះក្នុងរបៀបមួយដ៏អស្ចារ្យបំផុត ៖

« ទោះបើអំពើបាបរបស់អ្នករាល់គ្នាខ្មៅកខ្វក់យ៉ាងណាក្តីក៏វាប្រែសដូចសំឡីវិញដែរ » ( អេសាយ ១:១៨ ) ។

ហើយយើងជាព្រះអម្ចាស់មិនចាំពី [ អំពើបាបទាំងនោះ ] ទៀតទេ » ( យេរេមា ៣១:៣៤ ) ។

យើងសូមបញ្ជាក់ដល់បងប្អូនថា ការរស់នៅតាមគោលការណ៍សុចរិតនឹងនាំមកនូវសុភមង្គល ការបំពេញការសន្យា និងភាពសុខសាន្តដល់បងប្អូន និង គ្រួសារបងប្អូន ។ សមាជិកទាំងចាស់ទាំងក្មេងធ្វើការបញ្ជាក់នូវភាពសក្ដិសមរបស់ខ្លួនឯង នៅពេលពួកគេឆ្លើយសំណួរសម្ភាសប័ណ្ណចូលព្រះវិហារបរិសុទ្ធ ។ កិច្ចតម្រូវចាំបាច់នេះគឺ ដើម្បីបង្កើនទីបន្ទាល់របស់យើងអំពីព្រះជាព្រះវរបិតា ព្រះរាជបុត្រាទ្រង់គឺព្រះយេស៊ូវគ្រីស្ទ និងការស្ដារឡើងវិញនៃដំណឹងល្អរបស់ទ្រង់ និងបទពិសោធន៍នៃការបម្រើរបស់ព្រះវិញ្ញាណបរិសុទ្ធ ។

ចូរដឹងថា ពួកយើងមានបំណងចិត្តខ្លាំងប៉ុណ្ណា ដើម្បីឲ្យបុគ្គលម្នាក់ៗអាចធ្វើការផ្លាស់ប្ដូរដ៏ចាំបាច់ ដើម្បីមានគុណសម្បត្តិសម្រាប់ព្រះវិហារបរិសុទ្ធ ។ សូមគិតដោយស្មោះពីចិត្តថា តើបងប្អូនកំពុងឈានដល់ចំណុចណាហើយ សូមស្វែងរកការណែនាំពីព្រះវិញ្ញាណ ហើយពិភាក្សាជាមួយប៊ីស្សពរបស់បងប្អូនអំពីការរៀបចំខ្លួនទៅព្រះវិហារបរិសុទ្ធ ។ ប្រធានថូម៉ាស អេស ម៉នសុន ( ១៩២៧–២០១៨ ) បានមានប្រសាសន៍ថា « គ្មានគោលដៅណាមួយរបស់អ្នកសំខាន់ជាងការខិតខំឲ្យមានភាពសក្ដិសម ដើម្បីទៅព្រះវិហារបរិសុទ្ធឡើយ » ។[1]

ខ្ញុំសូមអធិស្ឋានថា យើងម្នាក់ៗនឹងគោរពព្រះអង្គសង្គ្រោះ ហើយធ្វើការផ្លាស់ប្ដូរចាំបាច់នានាដើម្បីឃើញថា បងប្អូននៅក្នុងព្រះវិហារបរិសុទ្ធដ៏ពិសិដ្ឋរបស់ទ្រង់ ។ នៅពេលធ្វើដូច្នោះ យើងអាចសម្រេចបាននូវគោលបំណងដ៏បរិសុទ្ធរបស់ទ្រង់ ហើយរៀបចំខ្លួន និង គ្រួសាររបស់យើងសម្រាប់ពរជ័យទាំងអស់ដែលព្រះអម្ចាស់ និងសាសនាចក្ររបស់ទ្រង់អាចផ្ដល់ឲ្យនៅក្នុងជីវិតនេះ និងភាពអស់កល្បជានិច្ច ។ ■

*ដកស្រង់ចេញពីសុន្ទរកថាសន្និសីទទូទៅខែ មេសា ឆ្នាំ ២០១៦ ។*

កំណត់ចំណាំ

១. ថូម៉ាស អេស ម៉នសុន « The Holy Temple — a Beacon to the World » សន្និសីទទូទៅ ខែ មេសា ឆ្នាំ ២០១១ ។





*កើតនៅ* **ឡូហ្គិន រដ្ឋ យូថាហ៍**
*នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ១៩៤០ ។*

*ពីឆ្នាំ ១៩៦០ ដល់ ១៩៦២*
*លោកបានបម្រើនៅក្នុង*
**បេសកកម្មចក្រភព**
**អង់គ្លេស** *ហើយអែលឌែល*
*ជែហ្វ្រី អ័រ ហូឡិន គឺជាដៃគូម្នាក់*
*របស់លោក ។*



*បានគាំទ្រជាសមាជិកក្នុង*
**កូរ៉ុមនៃពួកសាវកដប់ពីរនាក់**
*នៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០៧*





*បានលេងទាំងកីឡា*
**បាល់ឱប**
*និងកីឡា*
**វាយកូនបាល់**
*ក្នុងការប្រកួតយកពានរង្វាន់រដ្ឋនៅក្នុងវិទ្យាល័យ ។*

*បានរៀបអាពាហ៍ពិពាហ៍*
*ជាមួយនឹង ម៉ារី*
*ហ្គាតឌី នៅក្នុង*
**ព្រះវិហារបរិសុទ្ធ**
**លូហ្គែន យូថាហ៍**
*នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៦២*



*មាន* **កូន ៣ នាក់** *និង*
**ចៅ ១១ នាក់**



រូបភាពមកពី GETTY IMAGES និងដោយ អែរឌ្រូ រ៉ូប៊ើត

# ដំណើររបស់អ៊ីសាប៊ែល



**ដោយ ជេសីកា ឡួសិន**
ផ្អែកទៅលើដំណើររឿងពិត

*ប្រទេស ប្រេស៊ីល ឆ្នាំ ១៩៩២*

អ៊ីសាប៊ែលបានសម្លឹងមើលទៅមេឃពណ៌ខៀវងងឹត ។ ពុំមានឃើញពពកឡើយ ។ នាងបានលិឍបបូរមាត់ស្ងួតរបស់នាង ។

ឪពុកម្ដាយរបស់នាងកំពុងនិយាយគ្នាយ៉ាងស្ងៀមស្ងាត់ជាមួយប្រធានសាន់ឌីអាហ្គោ ដែលជាប្រធានស្ដេក ។ សំឡេងម៉ាស៊ីនទូករោទ៍លាន់ខ្លាំងដែលធ្វើឲ្យនាងពុំអាចស្ដាប់ពួកគាត់បាន ។ ប៉ុន្តែនាងបានដឹងថា ពួកគាត់កំពុងនិយាយរឿងអ្វី ។ គ្មានទឹកផឹកទៀតទេ ។

អ៊ីសាប៊ែលបានព្យាយាមផ្ដោតចិត្តទុកដាក់ទៅលើហេតុផលសម្រាប់ដំណើររបស់ពួកគេ ។ ពួកគេនឹងទៅព្រះវិហារបរិសុទ្ធដើម្បីផ្សារភ្ជាប់ជាក្រុមគ្រួសារ ! នាងបានចាំពីការនិយាយរបស់ឪពុកម្ដាយនាងអំពីព្រះវិហារបរិសុទ្ធដ៏ស្រស់ស្អាតនៅទីក្រុងសៅ ប៉ូឡូ តាំងពីនាងនៅក្មេងម្ល៉េះ ។ ការទៅទីនោះហាក់ដូចជារឿងនិទានមួយអញ្ចឹង ។ លើសពីនោះទៀត គ្រួសាររបស់អ៊ីសាប៊ែលបានរស់នៅទីក្រុងម៉ាណូស នៅជ្រៅនៅក្នុងព្រៃល្បាតអាម៉ាស្សូន ហើយព្រះវិហារបរិសុទ្ធមានចម្ងាយជាង ៣២១៩ គីឡូម៉ែត្រ ។

បន្ទាប់មកប្រធាន សាន់ឌីអាហ្គោ បានគ្រោងការធ្វើដំណើររយៈពេលប្រាំមួយថ្ងៃដើម្បីទៅដល់ទីនោះ ។ មានសមាជិកជាង ១០០ នាក់បានសម្រេចចិត្តទៅ ។ *ម៉ាម៉ែ* បានប្រាប់នាងថា « វាជាពលិកម្មមួយ ។ ប៉ុន្តែពលិកម្មនាំមកនូវពរជ័យ » ។

នៅពេលគ្រាដំបូងការធ្វើដំណើរនោះគួរឲ្យរំភើបណាស់ ។ ពួកគេបានដេកនៅក្នុងអង្រឹងនៅលើដំបូលទូក ច្រៀងទំនុកតម្កើង និងអានព្រះគម្ពីរ ។

ប៉ុន្តែក្រោយមក ទឹកផឹកបានអស់ ហើយទឹកទន្លេពុំអាចផឹកបានឡើយ ដោយសារវាកខ្វក់ខ្លាំងពេក ។

អ៊ីសាប៊ែលមានអារម្មណ៍ថា *ម៉ាម៉ែ* ស្ទាបដៃរបស់នាង ។ នាងបាននិយាយថា « ប្រធានសាន់ទីអាហ្គោ កំពុងប្រមូលយើងទាំងអស់គ្នាឲ្យជួបជុំគ្នា ។ យើងនឹងអធិស្ឋានទូលសូមឲ្យភ្លៀង » ។

អ៊ីសាប៊ែលបានចូលរួមជាមួយក្រុម ហើយការអធិស្ឋានបានចាប់ផ្ដើម ។ បន្ទាប់ពីការអធិស្ឋានបានបញ្ចប់ទៅ នាងមានអារម្មណ៍ថា ខ្យល់ត្រជាក់បានបក់ប៉ះករបស់នាង ។ នាងបានរត់ទៅកៀនទូក ហើយខំដកដង្ហើម ។ ពពកព្យុះពណ៌ប្រផេះកំពុងរំកិលមកកាន់ពួកគេ ។ មិនយូរប៉ុន្មានក្រោយមក ភ្លៀងបានចាប់ផ្ដើមធ្លាក់ ! នាងបានហាមាត់ដើម្បីត្រងតំណក់ទឹកភ្លៀង ។

*ម៉ាម៉ែ* បានស្រែកថា « លឿនឡើងៗ ! យកធុង, យកខ្ទះ — អ្វីក៏បានដែរ ! »

អ៊ីសាប៊ែលបានចាប់យកខ្ទះមួយ ហើយកាន់វា ។ នាងចង់ត្រងទឹកទាំងអស់តាមដែលនាងអាចធ្វើបាន ។ មនុស្សគ្រប់គ្នាធ្វើការរួមគ្នា ទាំងសើចសប្បាយ និងមានក្ដីសាទរ ។ មិនយូរប៉ុន្មានក្រោយមក ពួកគេបានទទឹកខ្លួនជោគ ! ព្យុះនោះមានរយៈពេល ១៥ នាទី ។ វាយូរល្មមសម្រាប់ឲ្យពួកគេត្រងទឹកទាំងអស់ដែលពួកគេត្រូវការ ។ វាជាអព្ភូតហេតុមួយ ។

មិនយូរប៉ុន្មានក្រោយមក ទូកបានទៅដល់កំពង់ ។ ប៉ុន្តែពួកគេនៅតែត្រូវធ្វើដំណើរចម្ងាយ ២៤១៤ គីឡូម៉ែត្រទៀត ។ មនុស្សគ្រប់គ្នាបានជិះឡានក្រុងសម្រាប់ការធ្វើដំណើរដែលនៅសល់នោះ ។ អស់រយៈពេលជាច្រើនថ្ងៃឡានក្រុង

*ការធ្វើដំណើរនេះអាចនឹងយូរ ហើយគ្រោះថ្នាក់ ប៉ុន្តែការទៅព្រះវិហារបរិសុទ្ធវាសក្តិសមនឹងដំណើរនោះហើយ ។*



**ពរជ័យដែលពុំអាចកាត់ថ្លៃបាន**

« ពរជ័យនៃព្រះវិហារបរិសុទ្ធគឺពុំអាចកាត់ថ្លៃបានឡើយ » ។

ប្រធាន ថូម៉ាស អេស ម៉នសុន ( ១៩២៧–២០១៨ ) « ពរជ័យទាំងឡាយនៃព្រះវិហារបរិសុទ្ធ » ***Liahona*** ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ៩៣ ។



បរនៅលើផ្លូវដែលរលាក់ ។ មានម្តងនោះវាបានរលាក់យ៉ាងខ្លាំងដែលធ្វើឲ្យកញ្ចក់ខាងមុខឡានក្រុងនោះបានខូច ! ជួនកាលពួកគេជិះកាត់ទីក្រុងដែលក្តៅ ហើយមានមនុស្សអ៊ូរអរ ។ ប៉ុន្តែយ៉ាងហោចណាស់ ផ្លូវនៅទីនោះពុំសូវរលាក់ប៉ុន្មានទេ !

មនុស្សគ្រប់គ្នាមានអំណរគុណជានិច្ច នៅពេលពួកគេឈប់នៅតាមភូមិ ឬទីក្រុងណាមួយដើម្បីបរិភោគអាហារ ។ ពួកគេបានបរិភោគអាហារនៅសាលាជំនុំ ឬជាមួយសមាជិកសាសនាចក្រនៅតាមផ្ទះនោះ ។ នាយប់ដំបូង ពួកគេបានទៅដល់ទីនោះរាងយប់ជ្រៅ ដែលធ្វើឲ្យអ៊ីសាប៉ែលខ្លាចថាគ្មាននរណាម្នាក់នឹងរង់ចាំពួកគេ ។ *ម៉ាម៉ែ* បាននិយាយដោយញញឹមទាំងអស់កម្លាំងថា « កុំបារម្ភអី ។ មើលន៎ ! »

ប្រធានសាខា និងសមាជិកសាសនាចក្របានឈរតម្រង់ជួរនៅផ្លូវម្ខាងទៀត ។ ពួកគេបានកាន់បដាដែលមានសរសេរអក្សរថា « ពលិកម្មនាំមកនូវពរជ័យ » ។ អ៊ីសាប៉ែលបានញញឹម ។ *ម៉ាម៉ែ* មានប្រសាសន៍ត្រូវ !

បន្ទាប់ពីជិះឡានក្រុងលើផ្លូវរលាក់អស់រយៈពេលបីថ្ងៃមក នៅទីបំផុតពួកគេបានទៅដល់ទីក្រុង សៅ ប៉ូឡូ ។ អ៊ីសាប៉ែលបានឈរនៅលើកៅអីអង្គុយរបស់នាងដើម្បីមើលឃើញទេសភាពកាន់តែច្បាស់ នៅពេលឡានក្រុងបើកជុំវិញផ្លូវកោង ។ រំពេចនោះ មនុស្សគ្រប់គ្នានៅលើឡានក្រុងបានផ្ទុះនូវក្តីរីករាយឡើង ។ « *O templo ! O templo !* » ពួកគេអាចឃើញកំពូលខ្ពស់ស្រួចៗស្តើងរបស់ព្រះវិហារបរិសុទ្ធលេចខ្ពស់ត្រដែតលើសចុងជួរដើមត្នោត ។ ពន្លឺព្រះអាទិត្យបានចាំងទៅលើរូបទេវតាមរ៉ូណៃពណ៌មាសនោះ ។

មនុស្សគ្រប់គ្នាអស់កម្លាំងជាខ្លាំង ប៉ុន្តែគ្មាននរណាម្នាក់ចង់សម្រាកឡើយ ។ ពួកគេចង់ទទួលបានការផ្សារភ្ជាប់ៗភ្លាមតែម្តង ។ នៅពេលដល់វេនដែលគ្រួសាររបស់នាងត្រូវផ្សារភ្ជាប់ អ៊ីសាប៉ែលបានស្លៀកសម្លៀកបំពាក់ពណ៌សយ៉ាងយកចិត្តទុកដាក់ ។ ពេលនាងដើរចូលទៅក្នុងបន្ទប់ផ្សារភ្ជាប់ នាងបានឃើញឪពុករបស់នាងញញឹមពព្រាយ ។ ទឹកភ្នែកនៃអំណរបានហូរមកលើមុខរបស់ *ម៉ាម៉ែ* ។ អ៊ីសាប៉ែលបានគិតថា « ដំណើររបស់ពួកគេយូរ ហើយថែមទាំងមានគ្រោះថ្នាក់ទៀត ។ ប៉ុន្តែពលិកម្មនោះសក្តិសមនឹងការធ្វើដំណើរនោះ » ។ នាងបានញញឹម នៅពេលនាងបានអង្គុយនៅកន្លែងនាងដើម្បីផ្សារភ្ជាប់ជាមួយគ្រួសាររបស់នាងជារៀងរហូត ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា ។*



នៅក្នុងឆ្នាំ ២០១២ ព្រះវិហារបរិសុទ្ធមួយត្រូវបានសាងសង់ឡើងនៅទីក្រុងម៉ាណូសប្រទេសប្រេស៊ីល ជាកន្លែងដែលអ៊ីសាប៉ែលបានធំឡើង ។ ក្រោយមក អ៊ីសាប៉ែល និងក្មេងដទៃទៀតបានធំឡើងជាមួយគ្រួសារផ្ទាល់របស់ពួកគេ ។ ពួកគេជាច្រើននាក់បានមកទស្សនាព្រះវិហារថ្មីដ៏ស្រស់ស្អាតនេះ ហើយចាំអំពីដំណើរផ្ទាល់របស់ពួកគេ ។

# លោកតា លោកយាយដ៏ល្អ

ដោយ ដេណា កូហ្វ៊ង

ផ្អែកទៅលើដំណើររឿងពិត

« *ខ្ញុំមានក្រុមគ្រួសារលើផែន ។ គេផ្ដល់ក្ដីសុខដល់ខ្ញុំ* » (សៀវភៅចម្រៀងកុមារ *លេខ ៩៨* ) ។

ណាណាបានហៅ « អែនជ្រូ ! ឡានក្រុងមកដល់ទីនេះហើយ ! »

អែនជ្រូបានរត់ចេញពីទ្វារ ។ គាត់បានលើកដៃលាណាណា ប៉ាប៉ា និងប្អូនស្រីរបស់គាត់អែមមី ។ អែមមីនៅតូចពេកមិនអាចទៅរៀនបាននៅឡើយ ដូច្នេះនាងនៅផ្ទះជាមួយណាណា និងប៉ាប៉ា ។

អែនជ្រូចូលចិត្តសាលារៀន ។ គាត់ចូលចិត្តលេងជាមួយមិត្តភក្តិរបស់គាត់ពេលចេញលេង ។ គាត់ចូលចិត្តអ្នកគ្រូរបស់គាត់ឈ្មោះអ្នកគ្រូ ឃឹមបល ។

បន្ទាប់ពីម៉ោងចេញលេងពេលព្រឹក អ្នកគ្រូ ឃឹមបល បាននិយាយថា « សប្ដាហ៍ក្រោយយើងនឹងមានទិវានាំឪពុកម្ដាយមកកាន់សាលារៀន ។ នៅពេលឪពុកម្ដាយរបស់កូនៗមក សូមប្រាកដថា ពួកគាត់យកអ្វីមួយមកពីមុខរបររបស់ពួកគាត់មកបង្ហាញពួកយើង ។ យើងរីករាយដើម្បីស្ដាប់ពួកគាត់ ! »



អែនជ្រូពុំប្រាកដក្នុងចិត្តអំពីទិវានាំឪពុកម្ដាយមកកាន់សាលារៀនឡើយ ។

រចនារូបភាពដោយ ហ្គាយ ហ្វ្រានស៊ីស

ទឹកមុខរបស់អែនដ្រូឡើងក្រហម ។ គាត់គ្មានអ្វីនិយាយច្រើនអំពីឪពុកម្ដាយរបស់គាត់ទេ ។ គាត់ពុំចាំច្រើនពីម្ដាយរបស់គាត់ទេ ។ គាត់បានចាកចេញទៅតាំងពីអែនដ្រូនៅតូចម្ល៉េះ ។ ហើយអែនដ្រូក៏ពុំស្គាល់ឪពុករបស់គាត់ផងដែរ ។

អែនដ្រូបានស្ដាប់ក្មេងដទៃទៀតនិយាយអំពីម្ដាយ និងឪពុករបស់ពួកគេ ។ ម្ដាយរបស់តូនីគឺជាអ្នកពន្លត់អគ្គិភ័យ ហើយឪពុករបស់ជេសីកាធ្វើការនៅសួនសត្វ ។ មនុស្សគ្រប់គ្នាសង្ឃឹមថា ឪពុករបស់នាងនឹងយកសត្វស្វា ឬសត្វស្លូសមកកាន់ថ្នាក់រៀន !

តូនីបានសួរអែនដ្រូ « ចុះឪពុកម្ដាយរបស់ឯងវិញ ? »

អែនដ្រូបានឈ្ងោកមុខមើលចុះក្រោម ។ គាត់បានញាក់ស្មា ។ « ខ្ញុំរស់នៅជាមួយលោកតាលោកយាយរបស់ខ្ញុំ » ។

អែនដ្រូស្រឡាញ់ណាណា និងប៉ាប៉ា ប៉ុន្តែពួកគាត់គ្មានការងារអស្ចារ្យអ្វីឡើយ ។ ណាណាលក់ភួយ និងសម្លៀកបំពាក់ទារក ។ ប៉ាប៉ាបើកឡានធំដឹកអាហារ ។ អែនដ្រូពុំប្រាកដក្នុងចិត្តអំពីទិវានាំឪពុកម្ដាយមកកាន់សាលារៀនឡើយ ។

នាយប់នោះ អែនដ្រូបានអានជំពូកទីមួយនៃព្រះគម្ពីរមរមន ៖ « ខ្ញុំ នីហ្វៃ ដោយបានកើតមកពី ឪពុកម្ដាយល្អ . . . » ( នីហ្វៃទី ១:១ ) ។

អែនដ្រូបានគិតថា « ខ្ញុំមិនរស់នៅជាមួយឪពុកម្ដាយខ្ញុំទេ ។ ខ្ញុំគ្រាន់តែរស់នៅជាមួយណាណា និងប៉ាប៉ា » ។

ភ្លាមនោះ អែមមីបានដើរចូលមកក្នុងបន្ទប់របស់អែនដ្រូឱបភួយទន់ៗដ៏កក់ក្ដៅ ។ នាងបានលើកភួយនោះឡើងឲ្យអែនដ្រូមើលឃើញ ។ « ណាណាធ្វើវា ! »

« មែនហើយ ណាណាធ្វើភួយនេះសម្រាប់បង » ។ អែនដ្រូបានញញឹមបន្តិច ។

គាត់បានគិតអំពីរឿងល្អៗទាំងអស់ដែល ណាណាបានធ្វើសម្រាប់គាត់—ចម្អិនអាហារពេលព្រឹកពីមុនសាលារៀន ជួយធ្វើកិច្ចការមកពីសាលាលេងល្បែងកម្សាន្តជាមួយគាត់ និងអែមមី ។ ណាណាដូចជាម្ដាយម្នាក់ខ្លាំងណាស់ ។

បន្ទាប់មក អែនដ្រូបានគិតអំពីប៉ាប៉ា ។ ប៉ាប៉ាអានរឿងនិទានឲ្យអែនដ្រូស្ដាប់រាល់យប់ ។ គាត់បានជួយកិច្ចការសាលាផងដែរ ។ គាត់ក៏បានបង្រៀនអែនដ្រូឲ្យចេះជិះកង់ផងដែរ ។ ប៉ាប៉ាដូចជាឪពុកម្នាក់ខ្លាំងណាស់ ។

ស្នាមញញឹមរបស់អែនដ្រូមានកាន់តែធំឡើង ។ គាត់ពិតជាមានអំណរគុណចំពោះណាណា និងប៉ាប៉ាណាស់ ។ គាត់នៅតែមានអារម្មណ៍ភ័យក្នុងការយកលោកតាលោកយាយទៅសាលារៀន ។ ប៉ុន្តែវានឹងមិនអីទេ ។ គាត់បានគិតថា « ខ្ញុំអាចមិនមានឪពុកម្ដាយល្អ ប៉ុន្តែខ្ញុំមានលោកតាលោកយាយល្អ ហើយនោះគឺជារឿងពិសេសណាស់ » ។

នៅទិវានាំឪពុកម្ដាយមកកាន់សាលារៀន អែនដ្រូបានអង្គុយជាមួយប៉ាប៉ានៅតុក្រោយនៃថ្នាក់រៀន ហើយស្ដាប់ឪពុកម្ដាយរបស់ក្មេងៗដទៃទៀត ។ ម្ដាយរបស់តូនីបានយកឯកសណ្ឋានអ្នកពន្លត់អគ្គិភ័យមក ។ គាត់បានឲ្យមនុស្សគ្រប់គ្នាសាកពាក់មួកសុវត្ថិភាពរបស់គាត់ ។ ឪពុករបស់ជេសីកាបានយកសត្វអណ្ដើកមួយមកពីសួនសត្វ ។

អ្នកគ្រូឃីមបលបាននិយាយថា « ដល់វេនរបស់កូនហើយ អែនដ្រូ » ។

អែនដ្រូបានដើរទៅមុខសិស្សជាមួយប៉ាប៉ា ។ គាត់បានដកដង្ហើមធំ ហើយនិយាយថា « ប៉ាប៉ារបស់ខ្ញុំគាត់បើកឡានធំ ហើយដឹកអាហារឲ្យគេ ។ គាត់ជួបមនុស្សជាច្រើន ហើយគាត់ខិតខំធ្វើការណាស់ » ។

អែនដ្រូបានងើយមុខឡើង ហើយបានឃើញប៉ាប៉ាញញឹម ។ បន្ទាប់មក ប៉ាប៉ាបាននិយាយអំពីការបើកឡានធំរបស់គាត់ ។ គាត់ក៏បានឲ្យនំទៅមនុស្សគ្រប់គ្នាដែលគាត់បានយកមកពីកន្លែងការងារគាត់ផងដែរ ! ក្មេងៗនៅក្នុងថ្នាក់របស់អែនដ្រូបានសួរសំណួរជាច្រើនដល់ប៉ាប៉ាអំពីការងាររបស់គាត់ ។

អែនដ្រូរីករាយដែលមានប៉ាប៉ានៅជាមួយគាត់ ។ គាត់ និងប៉ាប៉ា និងណាណា ព្រមទាំងអែមមីគឺជាគ្រួសារមួយ — ហើយពួកគេជាគ្រួសារដ៏ល្អមួយ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា.*




ទីបំផុតក្លាយជា
ក្រុមគ្រួសារ
ដ៏និរន្តរ៍

ដោយ ជេន ម៉ាកប្រាយដ៍
ផ្អែកទៅលើដំណើររឿងពិត

*« ទោះជាអ្វីក៏ដោយ ដែលអ្នកនឹងភ្ជាប់នៅលើផែនដី ក៏នឹងត្រូវបានភ្ជាប់នៅលើស្ថានសួគ៌ដែរ » ( ហេលេមិន ១០:៧ ) ។*

ម៉ែបានសួរ តើពាក្យ ‹ គ្រួសារគឺនិរន្តរ៍ › មានន័យដូចម្ដេច ? នាងបានដើរគ្រាប់ល្បែងកម្សាន្តរបស់នាងនៅលើក្ដារ ។ នាង និងមិត្តភក្តិស្និទ្ធស្នាលរបស់នាង សូយ កំពុងលេងល្បែងកម្សាន្តនៅក្នុងបន្ទប់ទទួលភ្ញៀវរបស់សូយ ។ នៅលើជញ្ជាំងមានរូបភាពមួយដែលមានអក្សរថា « គ្រួសារគឺនិរន្តរ៍ » ។ ម៉ែចូលចិត្តពាក្យនោះណាស់ ។

សូយបានពន្យល់ថា « វាមានន័យថា ទោះបីបន្ទាប់ពីយើងស្លាប់ក្ដី ក៏យើងនៅតែអាចក្លាយជាគ្រួសារដដែល » ។ នាងបានដាក់កាតមួយចុះ ហើយដើរគ្រាប់ល្បែងកម្សាន្តរបស់នាង ។

ម៉ែបានសម្លឹងមើលជុំវិញបន្ទប់ ។ វាមើលទៅដូចជាធម្មតា ។ មានសាឡុង តុ ខ្នើយ និងទូរទស្សន៍មួយ ។ ប៉ុន្តែផ្ទះរបស់សូយមានអារម្មណ៍ប្លែកពីផ្ទះផ្ទាល់របស់នាង ។ ម៉ែបានសួរ « តើឯងមានក្រុមគ្រួសារជានិរន្តរ៍ឬ ? »



សូយបានងើយមើលលើចេញពីល្បែងកម្សាន្តនោះដោយញញឹម ។ « ចាស៎ ! ម្ដាយ និងឪពុករបស់ខ្ញុំរៀបការនៅព្រះវិហារបរិសុទ្ធ ។ ដូច្នេះពួកយើងអាចរស់នៅជាមួយគ្នាជានិរន្តរ៍ ។

ម៉ែបានសួរ « តើនោះជាអ្វីដែលធ្វើឲ្យផ្ទះរបស់ឯងមានអារម្មណ៍ប្លែកឬ ? »

សូយមើលទៅដូចជាភាន់ភាំង ។ « ប្លែក ? »

ម៉ែពុំដឹងអំពីរបៀបដើម្បីពន្យល់អំពីអារម្មណ៍ដែលនាងមាននៅក្នុងផ្ទះរបស់សូយឡើយ ។ វាជាអារម្មណ៍រីករាយ និងកក់ក្ដៅ ។ ប៉ុន្តែវាស្ដាប់ទៅដូចជាឆោតណាស់ដែលនិយាយរឿងនោះ ។ នាងបាននិយាយថា « មិនអីទេ តោះយើងបន្តលេងទៀត » ។

នៅយប់នោះ ម៉ែពុំអាចឈប់គិតអំពីគ្រួសារដ៏និរន្តរ៍របស់សូយបានឡើយ ។ នាងចូលចិត្តអារម្មណ៍ដែលនាងមាននៅក្នុងផ្ទះរបស់សូយ ។ គ្រួសាររបស់ម៉ែនឹងប្ដូរទៅរស់នៅទីក្រុងអនតារីយ៉ូ ប្រទេស កាណាដា នៅក្នុងរយៈពេលពីរបីថ្ងៃទៀត ។ គាត់ឆ្ងល់ថា តើផ្ទះថ្មីរបស់នាងនឹងធ្វើឲ្យនាងមានអារម្មណ៍បែបណា ?

ម៉ែបាននិយាយនៅពេលម្ដាយនាងដាក់នាងឲ្យចូលគេង « ម៉ាក់ ផ្ទះរបស់សូយមានអារម្មណ៍រីករាយណាស់ ។ ខ្ញុំចង់ឲ្យផ្ទះថ្មីរបស់យើងធ្វើឲ្យយើងមានអារម្មណ៍ដូច្នេះដែរ » ។ ម៉ែបានគិតអំពីសេចក្ដីស្រឡាញ់ដ៏ខ្លាំងដែលនាងមានចំពោះម៉ាក់ ប៉ា និងប្អូនប្រុសៗរបស់នាង ។ ខ្ញុំចង់ឲ្យក្រុមគ្រួសាររបស់យើងក្លាយជានិរន្តរ៍ផងដែរ » ។

ម៉ាក់បានស្ដាប់ដោយស្ងៀមស្ងាត់ ។ បន្ទាប់មកម៉ាក់បាននិយាយថា « ម៉ាក់ក៏អញ្ចឹងដែរកូន » ។

នៅថ្ងៃបន្ទាប់ ម៉ាក់បានទូរសព្ទទៅផ្ទះរបស់សូយ ។ គាត់បានដឹងថា គ្រួសាររបស់សូយបានទៅសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ម៉ែបានប្រាប់ឪពុកម្ដាយនាងខណៈដែលពួកគាត់កំពុងរៀបចំឥវ៉ាន់ « កូនចង់ទៅព្រះវិហារនោះដែរ » ។ ឥឡូវនេះផ្ទះរបស់ពួកគេស្ទើរតែនៅទទេហើយ ។

ប៉ាបាននិយាយនៅពេលគាត់បានបិតស្កុតប្រអប់មួយ « ម្ដាយរបស់សូយបាននិយាយថា គាត់អាចជួយយើងឲ្យរកឃើញអគារព្រះវិហារនោះបាន » ។

ម៉ែបានញញឹម ហើយមានអារម្មណ៍ភ័យបុកពោះ ។ ប្រហែលជាផ្ទះថ្មីរបស់ពួកគេអាចធ្វើឲ្យពួកគេមានអារម្មណ៍កក់ក្ដៅ និងរីករាយដូចជាផ្ទះរបស់សូយដែរ ។

នៅពេលពួកគេបានចាប់ផ្ដើមផ្ទះថ្មីរបស់ពួកគេ គ្រួសាររបស់ម៉ែបានចាប់ផ្ដើមទៅព្រះវិហារ ។ មនុស្សនៅទីនោះមានការរួសរាយណាស់ ។ មនុស្សគ្រប់គ្នាបានហៅគ្នាទៅវិញទៅមកថា « បងប្អូនប្រុស » និង « បងប្អូនស្រី » ។ ម៉ែបានទៅថ្នាក់អង្គការបឋមសិក្សាជាមួយប្អូនប្រុសៗរបស់គាត់ ។ គាត់ចូលចិត្តច្រៀងចម្រៀង និងអានព្រះគម្ពីរ ។

មិនយូរប៉ុន្មានក្រោយមក មានយុវនារីពីររូបបានមកផ្ទះរបស់ម៉ែ ។ ឈ្មោះរបស់ពួកគេគឺ ស៊ីស្ទើរ ចាស្ទីន និង ស៊ីស្ទើរ រ៉ាមូស ហើយពួកគេគឺជាអ្នកផ្សព្វផ្សាយសាសនា ។ ពួកគេបានប្រាប់ក្រុមគ្រួសាររបស់ម៉ែអំពីព្រះវរបិតាសួគ៌ ព្រះយេស៊ូវ និងព្រះគម្ពីរមរមន ។ ម៉ែចូលចិត្តស្ដាប់ដំណឹងល្អ ។ សូម្បីតែប្អូនប្រុសៗរបស់គាត់ក៏អង្គុយយ៉ាងស្ងៀមស្ងាត់ ហើយស្ដាប់ដែរ !

ម៉ែបានប្រាប់ស៊ីស្ទើរ រ៉ាមូស និង ស៊ីស្ទើរ ចាស្ទីនអំពីផ្ទះរបស់សូយ ។ ស៊ីស្ទើរ រ៉ាមូសបាននិយាយដោយស្នាមញញឹមយ៉ាងធំថា « ខ្ញុំចង់បានក្រុមគ្រួសារដ៏និរន្តរ៍មួយដូចជាគ្រួសាសូយដែរ ។

ព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យយើងទាំងអស់គ្នាមានក្រុមគ្រួសារនិរន្តរ៍ ។ ទ្រង់សព្វព្រះទ័យឲ្យយើងសប្បាយរីករាយ » ។

មិនយូរក្រោយមក គ្រួសាររបស់ម៉ែបានសម្រេចចិត្តទទួលបុណ្យជ្រមុជទឹក ។

សូយ និងគ្រួសាររបស់គាត់បានបើកឡានមកកាន់ទីក្រុងអនតារីយ៉ូចូលរួមក្នុងពិធីបុណ្យជ្រមុជទឹកនោះ ។ មួយឆ្នាំក្រោយមក ពួកគេបានត្រឡប់មកវិញម្ដងទៀត ។ លើកនេះគឺដោយសារ ម៉ែ និងគ្រួសាររបស់គាត់ត្រូវបានផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធ ។

នៅថ្ងៃនៃពិធីផ្សារភ្ជាប់ ម៉ែបានឈរនៅខាងក្រៅព្រះវិហារបរិសុទ្ធ ជាមួយក្រុមគ្រួសាររបស់គាត់ ដោយស្លៀកសម្លៀកបំពាក់ពណ៌-ស ។ ពួកគេទាំងអស់គ្នាបានញញឹមយ៉ាងប៉ប្រិម ។ ម៉ែបានទទួលអារម្មណ៍កក់ក្ដៅ និងសុខសាន្តក្នុងចិត្ត ។ គាត់បាននិយាយយ៉ាងរីករាយថា « ឥឡូវនេះយើងគឺជាក្រុមគ្រួសារដ៏និរន្តរ៍ហើយ ! »

ប៉ាបាននិយាយថា « ត្រឹមត្រូវហើយ ។ យើងគឺជាក្រុមគ្រួសារដ៏និរន្តរ៍ » ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋខូឡូរ៉ាដូ ស.រ.អា. ។*

រចនារូបភាពដោយ ប្រាយអិន ប៊ីច

# ជា មិត្តភក្តិ និង ជាអ្នកផ្សព្វផ្សាយសាសនា

## ជម្រាបសួរ !

ខ្ញុំឈ្មោះ វ៉ែន បៅធីស្តា ហើយខ្ញុំមកពីប្រទេសអាហ្សង់ទីន ។



ខ្ញុំបញ្ចាំងពន្លឺរបស់ខ្ញុំចេញទៅ តាមរយៈការចែកចាយដំណឹងល្អ ។



1

### កល្យាណមិត្ត

កល្យាណមិត្តរបស់ខ្ញុំ ហ្វាយុនដូ និងខ្ញុំបានស្គាល់គ្នាតាំងពីពួកយើងនៅអាយុប្រាំឆ្នាំមកម្ល៉េះ ។ ពួកយើងទាំងពីរនាក់ចូលចិត្តកីឡាបាល់ទាត់ ! ខ្ញុំបានអញ្ជើញគាត់ឲ្យមកសកម្មភាពជាច្រើនរបស់សាសនាចក្រ ។



2

## សំណួរទីមួយរបស់ហ្វាយុនដូ

មានគ្រាមួយ នៅពេលហ្វាយុនដូបរិភោគអាហារពេលល្ងាចជាមួយពួកយើង គាត់បានសួរថា « ហេតុអ្វីគ្រួសាររបស់អ្នកអធិស្ឋានជានិច្ច ? » ខ្ញុំបាននិយាយថា ដោយសារព្រះវរបិតាសួគ៌បានប្រទានពរដល់យើង ហើយនេះជារបៀបដែលពួកយើងថ្លែងអំណរគុណចំពោះទ្រង់ ។ គាត់មានការអស្ចារ្យក្នុងចិត្តណាស់ !



3

## រាត្រីជួបជុំក្រុមគ្រួសារ

ហ្វាយុនដូបានមកចូលរួមកម្មវិធីរាត្រីជួបជុំក្រុមគ្រួសារ ពេលប្អូនប្រុសរបស់ខ្ញុំ បេនយ៉ាមីន ត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលបុណ្យជ្រមុជទឹក ។ ហ្វាយុនដូទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ហើយគាត់បានសួរប្រសិនបើគាត់អាចទទួលបុណ្យជ្រមុជទឹកផងដែរ ! ក្រោយមក ឪពុករបស់ខ្ញុំបាននិយាយទៅកាន់ឪពុកម្ដាយរបស់ហ្វាយុនដូ ។

ពួកអ្នកផ្សព្វផ្សាយសាសនាបានបង្រៀនក្រុមគ្រួសាររបស់ហ្វាយុនដូ ។ បន្ទាប់មក ទាំងហ្វាយុនដូ និងបងស្រីរបស់គាត់ អ័រហ្គើស៊ីន បានទទួលបុណ្យជ្រមុជទឹក ! ឪពុកម្ដាយរបស់គាត់បានមកព្រះវិហារ ប៉ុន្តែពួកគាត់ពុំទាន់ជ្រមុជទឹកនៅឡើយទេ ។



4



## សំណួរទីពីររបស់ហ្វាយុនដូ

ហ្វាយុនដូបានសួរម្ដាយរបស់ខ្ញុំថា តើគាត់នឹងចេះច្រើនអំពីព្រះដូចជាខ្ញុំដែរឬអត់ ។ ម្ដាយរបស់ខ្ញុំបានញញឹម ហើយនិយាយថា ប្រសិនបើគាត់សិក្សាព្រះគម្ពីរ ហើយអធិស្ឋាន នោះគាត់អាចរៀនបានកាន់តែច្រើន !

## តើអ្នកអាចបញ្ចាំងពន្លឺចេញទៅដោយរបៀបណា ?

- សូមអញ្ជើញមិត្តភក្ដិម្នាក់ឲ្យមកសកម្មភាពព្រះវិហារ ឬរាត្រីជួបជុំក្រុមគ្រួសារ ។
- សូមធ្វើជាគំរូល្អអំពីការមានចិត្តសប្បុរស និងសេចក្ដីស្រឡាញ់ ។
- សូមអធិស្ឋានទូលសូមជំនួយ និងការបំផុសគំនិត ។



## សូមផ្ញើរូបផ្ដាយមកយើង !

ព្រះយេស៊ូវសុំឲ្យពួកយើង « បញ្ចាំងពន្លឺរបស់អ្នកឲ្យភ្លឺនៅមុខមនុស្ស » ( ម៉ាថាយ ៥:១៦ ) ។ តើអ្នកបញ្ចាំងពន្លឺរបស់អ្នកចេញទៅដោយរបៀបណា ? សូមកាត់រូបផ្ដាយនេះចេញ ហើយសរសេររឿងរបស់អ្នកលើវា ។ សូមឲ្យឪពុកម្ដាយអ៊ីម៉ែលរូបថតនៃរូបផ្ដាយរបស់អ្នក ជាមួយនឹងការអនុញ្ញាតរបស់ពួកគាត់ទៅកាន់ liahona@ldschurch.org ។

ថតរូបដោយ អាឡេចាន់ដ្រូ ហ្គុធៀរែស្ស ។ រូបថតបុណ្យជ្រមុជទឹកទទួលបានសិទ្ធិអនុញ្ញាតពីក្រុមគ្រួសាររបស់ហ្វាយុនដូ ។





« ខ្ញុំមានសេចក្ដីជំនឿ និងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និងតួនាទីរបស់ទ្រង់ជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះរបស់យើង » ។

**ដោយអែលឌើរ ហ្គែរី អ៊ី ស្ទីវ៉ែនសុន**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*ដកស្រង់មកពី « A Gospel Perspective » ( ការប្រជុំធម្មនិដ្ឋានសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់–ហាវ៉ៃ ថ្ងៃទី ១៩ ខែ កញ្ញា ២០១៧ ) គេហទំព័រ devotional.byuh.edu ។*

រចនារូបភាពដោយ ប៊ែន ស៊ីម៉ុនសិន ផ្អែកលើសួនច្បារនៃព្រះវិហារបរិសុទ្ធ ប៉ារីស បារាំង ។

# ក្លឹបអាន ព្រះគម្ពីរមរមន

## សូមចូលរួម តាមរយៈការអានព្រះគម្ពីរមរមន !

អ្នកអាចអានដោយខ្លួនឯង ជាមួយក្រុមគ្រួសាររបស់អ្នក ឬជាមួយមិត្តភក្តិ ។ បន្ទាប់មក សូមផ្ញើរូបថតមួយដែលអ្នកកំពុងអានព្រះគម្ពីរមរមន ហើយប្រាប់យើងអំពីអ្វីដែលអ្នកបានរៀន ឬខគម្ពីរដែលអ្នកចូលចិត្តមកពីព្រះគម្ពីរមរមន ។ សូមផ្ញើវាតាមរយៈគេហទំព័រ liahona.lds.org ( សូមចុចលើ « Submit an Article » ) ។



**បទគម្ពីរសម្រាប់ខែនេះ ៖**

## ហេលេមិន ៥:១២

« ចូរចងចាំចុះ ចូរចងចាំចុះថា គឺនៅលើសិលានៃព្រះដ៏ប្រោសលោះនៃយើង គឺព្រះគ្រីស្ទជាព្រះរាជបុត្រានៃព្រះ ដែលកូនត្រូវសង់គ្រឹះរបស់កូន » ។



ក្រុមគ្រួសាររបស់ខ្ញុំកំពុងអានព្រះគម្ពីរមរមន ។ ជួនកាលយើងដើរតួសម្ដែងរឿងទាំងនោះ ។ ការធ្វើបែបនេះពិតជាសប្បាយណាស់ ។ ខ្ញុំរៀនពាក្យ និងអ្វីថ្មីៗជាប្រចាំថ្ងៃ ។ ការធ្វើកិច្ចការទាំងនេះជួយខ្ញុំឲ្យបន្តផ្ដោតលើការប្រជុំសាក្រាម៉ង់ និងថ្នាក់អង្គការបឋមសិក្សា ។ វាក៏ជួយខ្ញុំឲ្យបន្តមានភាពស្និទ្ធស្នាលជាមួយគ្រួសាររបស់ខ្ញុំផងដែរ ។

**អិន អាំម៉ារ៉ុន អាយុ ៧ ឆ្នាំ ទីក្រុង ភ្នំពេញ ប្រទេស កម្ពុជា**



ខ្ញុំចូលចិត្តអានព្រះគម្ពីរមរមនចាប់តាំងពីអ្នកផ្សព្វផ្សាយសាសនាបានណែនាំឲ្យយើងស្គាល់គម្ពីរនេះ ។ រឿងព្រះគម្ពីរដែលខ្ញុំចូលចិត្តគឺនៅក្នុងគម្ពីរម៉ូសាយ ពេលស្ដេចបេនយ៉ាមីនបានដឹកនាំប្រជាជនរបស់ទ្រង់ដោយសេចក្ដីជំនឿរបស់ទ្រង់ ។ ខ្ញុំចង់មានចិត្តស្មោះត្រង់ និងគោរពប្រតិបត្តិតាមអ្វីដែលឪពុកម្ដាយរបស់ខ្ញុំស្នើឲ្យខ្ញុំធ្វើ ។

**ចានីស អេស អាយុ ១០ ឆ្នាំ ទីក្រុង អ៊ីឡូយឡូ ប្រទេស ហ្វីលីពីន**

# ទំព័ររបស់យើង




« ការនិមិត្តដំបូង » ដោយ អាឡាណា អិល អាយុ ៧ ឆ្នាំ ទីក្រុង សៅ ប៉ូឡូ ប្រទេសប្រេស៊ីល



ម៉ាកូ ស៊្បី អាយុ ៩ ឆ្នាំ ទីក្រុង លីម៉ា ប្រទេស ប៉េរូ



*ខ្ញុំមានចិត្តសប្បាយរីករាយដើម្បីទទួលបុណ្យជ្រមុជទឹកចូលក្នុងសាសនាចក្រពិតរបស់ព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំដឹងថា ព្រះគម្ពីរមរមនពិត ហើយខ្ញុំចូលចិត្តអានវាជារៀងរាល់ថ្ងៃ ។ វាធ្វើឲ្យខ្ញុំមានការទទួលខុសត្រូវកាន់តែច្រើនក្នុងនាមជាបងប្រុសចំពោះបងប្អូនបង្កើតរបស់ខ្ញុំ ។*

អែនជ្រៀ អិល អាយុ ១០ ឆ្នាំ ទីក្រុង អ៊ីឡូយឡូ ប្រទេស ហ្វីលីពីន




ហារ៉ាដា ខេ អាយុ ៨ ឆ្នាំ ទីក្រុង យ៉ូកូហាម៉ា ប្រទេស ជប៉ុន

# នាងរស់គឺជាមិត្តដ៏មានភក្ដីភាព

ស្ត្រីម្នាក់ឈ្មោះ ន៉ាអូមីបានរស់នៅជាមួយកូនប្រុសពីរនាក់របស់គាត់ និងភរិយារបស់ពួកគេ ។ នៅពេលកូនប្រុសទាំងពីរនាក់របស់គាត់បានស្លាប់ទៅ ន៉ាអូមីបានប្រាប់ភរិយារបស់កូនៗគាត់ថា ពួកគេអាចត្រឡប់ទៅរស់នៅជាមួយគ្រួសារផ្ទាល់របស់ពួកគេវិញបាន ។ ប៉ុន្តែមានភរិយាម្នាក់របស់កូនប្រុសគាត់ឈ្មោះនាងរស់ពិតជាមានភក្ដីភាពណាស់ ។ គាត់បានជ្រើសរើសដើម្បីបន្តនៅ ហើយជួយមើលថែន៉ាអូមី ។ នាងរស់បានទៅប្រមូលគ្រាប់ស្រូវពីវាលស្រែនៅក្បែរនោះ ។ ម្ចាស់ស្រែបានឮពីចរិតល្អរបស់នាងរស់ ។ គាត់បានមានសន្ដានចិត្តល្អនឹងនាង ។ នាងរស់បានសម្រេចចិត្តរៀបការជាមួយគាត់ ។ នាងរស់ និងន៉ាអូមីបន្តធ្វើជាមិត្តភក្ដិល្អនឹងគ្នា ហើយន៉ាអូមីបានជួយមើលថែកូនប្រុសរបស់នាងរស់ ។ ជាច្រើនឆ្នាំក្រោយមកព្រះយេស៊ូវបានប្រសូត្រនៅក្នុងខ្សែស្រឡាយនៃគ្រួសារនេះ ។ នោះមានន័យថា នាងរស់គឺជាជីដូនជីតាម្នាក់របស់ព្រះយេស៊ូវ !

*សូមអានអំពីនាងរស់នៅក្នុង នាងរស់ ១–៤ ។*




*« នាងរស់មានចិត្តល្អ និងគួរឲ្យស្រឡាញ់ » ដោយ ឃីលី យូ អាយុ ៨ ឆ្នាំ រដ្ឋ វើរជីញ៉ា ស.រ.អា.*




**នាងរស់បានជ្រើសធ្វើជាមិត្តភក្ដិដែលមានភក្ដីភាព ហើយខ្ញុំក៏អាចធ្វើដូច្នោះបានផងដែរ !**

- ☐ សូមទន្ទេញ នាងរស់ ១:១៦ ។
- ☐ ការមានភក្ដីភាពមានន័យថា ការជួយជ្រោមជ្រែងដល់នរណាម្នាក់សូម្បីតែនៅពេលវាមានការលំបាកក្ដី ។ សូមសរសេរនៅក្នុងទិនានុប្បវត្តិរបស់អ្នកអំពីគ្រាមួយដែលមនុស្សម្នាក់មានភក្ដីភាពចំពោះអ្នក ។
- ☐ សូមរាប់អានមិត្តភក្ដិថ្មីម្នាក់នាសប្ដាហ៍នេះ ។ សូមរៀនរឿងរីករាយបីយ៉ាងអំពីពួកគេ !
- ☐ ខ្ញុំអាចក្លាយជាកល្យាណមិត្តម្នាក់តាមរយៈ . . .

_______________

_______________

# ហាណា និង សាំយ៉ូអែល

ដោយ គីម វេប រីដ

ហាណាមានអារម្មណ៍សោកស្ដាយដែលគាត់គ្មានកូន ។ គាត់បានអធិស្ឋាននៅក្នុងព្រះវិហារបរិសុទ្ធ ។ គាត់បានសន្យាថា ប្រសិនបើគាត់មានកូនប្រុសម្នាក់ នោះគាត់នឹងចិញ្ចឹមកូនប្រុសនោះឲ្យបម្រើព្រះ ។





ហាណា និងស្វាមីរបស់គាត់ពិតជាបានកូនមែន ! ហាណាបានដាក់ឈ្មោះគាត់ថាសាំយ៉ូអែល ។ គាត់បានដឹងថា ព្រះបានឆ្លើយតបការអធិស្ឋានរបស់គាត់ ។

រចនារូបភាពដោយ អាបរីល ស្តុត



នៅពេលសាំយូអែលធំឡើង ហាណាបានរក្សាការសន្យារបស់គាត់ ។ គាត់បានសូមអេលី ជាសង្ឃនៅព្រះវិហារបរិសុទ្ធឲ្យបង្រៀនសាំយូអែលអំពីរបៀបបម្រើព្រះ ។ អេលីបានជួយមើលថែសាំយូអែល ។

នាយប់មួយ ពេលសាំយូអែលកំពុងតែដេក គាត់បានឮសំឡេងមួយ ។ គាត់បានសួរថា ជាអេលីឬដែលបានហៅគាត់ ។ អេលីបាននិយាយថា ព្រះកំពុងព្យាយាមមានបន្ទូលមកកាន់សាំយូអែល ។ នៅពេលសាំយូអែលបានឮសំឡេងនោះលើកក្រោយមកទៀត គាត់បានស្ដាប់ ។ បន្ទាប់មក ព្រះបានមានបន្ទូលទៅកាន់សាំយូអែល ។ សាំយូអែលបានស្ដាប់ព្រះ ហើយបានធ្វើតាមទ្រង់ ។





ខ្ញុំអាចរៀនអំពីព្រះ ហើយធ្វើតាមបទបញ្ញត្តិរបស់ទ្រង់ ! ■

*ដកស្រង់មកពី សាំយូអែល ទី១ ១–៣ ។*

# ខ្ញុំអាចចែកចាយជាមួយមនុស្សដទៃ



គំនូរព្រាងដោយ អាប៊្រីល ស្តុត



ដោយប្រធាន អែសរ៉ា ថាហ្វ បែនសិន ( ១៨៩៩–១៩៩៤ )

# ព្រះគម្ពីរមរមននាំមកនូវភាពរីកចម្រើនយ៉ាងមហិមា

*មានអំណាចមួយនៅក្នុងព្រះគម្ពីរដែលនឹងចាប់ផ្ដើមហូរចូលមកក្នុងជីវិតរបស់អ្នក ពេលអ្នកចាប់ផ្ដើមសិក្សាដោយហ្មត់ចត់ ។*



តើពុំមានអ្វីដែលនៅក្នុងដក់ដួងចិត្តរបស់យើង ដើម្បីទាញយើងឲ្យខិតជិតព្រះ ដើម្បីឲ្យប្រែក្លាយកាន់តែដូចទ្រង់នៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ដើម្បីទទួលបាននូវអារម្មណ៍ថា មានវត្តមានរបស់ទ្រង់នៅមួយនឹងយើងជាប់ជានិច្ចទេឬ ? បើសិនជាគ្មានទេ នោះព្រះគម្ពីរមរមននឹងជួយយើងឲ្យចូលកាន់តែជិតព្រះបានច្រើនជាងគម្ពីរដទៃផ្សេងទៀតទាំងអស់ ។

ព្រះគម្ពីរមរមនពុំគ្រាន់តែបង្រៀនយើងអំពីសេចក្ដីពិតនោះទេ តែវាជាសេចក្ដីពិតនោះហើយ ។ ព្រះគម្ពីរមរមនពុំគ្រាន់តែថ្លែងទីបន្ទាល់អំពីព្រះគ្រីស្ទប៉ុណ្ណោះនោះទេ តែវាជាទីបន្ទាល់ផងដែរ ។ ប៉ុន្តែវាមានអ្វីៗជាច្រើនទៀត ។ មានអំណាចមួយនៅក្នុងព្រះគម្ពីរដែលនឹងចាប់ផ្ដើមហូរចូលមកក្នុងជីវិតរបស់អ្នក ពេលអ្នកចាប់ផ្ដើមសិក្សាដោយហ្មត់ចត់អំពីព្រះគម្ពីរនេះ ។ អ្នកនឹងរកឃើញអំណាចកាន់តែមហិមា ដើម្បីទប់ទល់នឹងការល្បួង ។ អ្នកនឹងរកឃើញអំណាច ដើម្បីចៀសផុតពីការបោកបញ្ឆោត ។ អ្នកនឹងរកឃើញអំណាចដើម្បីឈរនៅលើផ្លូវតូច និងចង្អៀត ។ ខគម្ពីរហៅថា « ព្រះបន្ទូលទាំងឡាយខាងជីវិត » ( គ. និង ស. ៨៤:៨៥ ) ហើយគ្មានព្រះគម្ពីរណាទៀតដែលពិតជាងព្រះគម្ពីរមរមនឡើយ ។ នៅពេលអ្នកចាប់ផ្ដើមស្រេកឃ្លាននូវព្រះបន្ទូលទាំងនោះ អ្នកនឹងឃើញថា ជីវិតនឹងកាន់តែមានភាពរីកចម្រើនយ៉ាងមហិមា ។ . . .

ការសន្យាទាំងនេះ — បានបង្កើនសេចក្ដីស្រឡាញ់ និងភាពចុះសម្រុងគ្នានៅក្នុងផ្ទះ ការគោរពគ្នាដ៏អស្ចារ្យរវាងឪពុកម្ដាយ និងកូនៗ ជួយបង្កើនជីវភាពខាងវិញ្ញាណ និងសេចក្ដីសុចរិត — គឺមិនមែនជាការសន្យាដែលគ្មានប្រយោជន៍ឡើយ ប៉ុន្តែពិតដូចអ្វីដែលព្យាការីយ៉ូសែប ស្ម៊ីធបានបញ្ជាក់នៅពេលលោកមានប្រសាសន៍ថា ព្រះគម្ពីរមរមននឹងជួយយើងឲ្យខិតកាន់តែជិតព្រះ ។ . . .

ដប់ឆ្នាំជាងបានកន្លងផុតទៅហើយ ខ្ញុំបានថ្លែងដូចខាងក្រោមអំពីព្រះគម្ពីរមរមន ៖

« តើលទ្ធផលដ៏អស់កល្បជានិច្ចស្ថិតនៅលើការអនុវត្តរបស់អ្នកតាមព្រះគម្ពីរនេះដែរឬទេ ? ពិតមែនហើយ មិនថាចំពោះពរជ័យរបស់យើង ឬការដាក់ទោសរបស់យើងនោះទេ ។

ពួកបរិសុទ្ធថ្ងៃចុងក្រោយគ្រប់រូបគួរតែខិតខំធ្វើការសិក្សាព្រះគម្ពីរមរមនពេញមួយជីវិត ។ បើពុំដូច្នោះទេ គាត់នឹងដាក់ព្រលឹងគាត់ទៅក្នុងគ្រោះថ្នាក់ ហើយធ្វេសប្រហែសនឹងការណ៍ដែលអាចផ្ដល់ឲ្យមានភាពត្រូវគ្នាខាងវិញ្ញាណ និងបញ្ញារួមគ្នាមកក្នុងជីវិតគាត់ទាំងមូល ។ មានភាពខុសគ្នាមួយរវាងអ្នកប្រែចិត្តជឿដែលសាងសង់លើថ្មនៃព្រះគ្រីស្ទតាមរយៈព្រះគម្ពីរមរមន ហើយកាន់ខ្ជាប់ដំបងដែកនោះ និងអ្នកដែលមិនធ្វើតាមនេះ » ។

. . . សូមយើងកុំនៅក្រោមការដាក់ទោស . . . ដោយការមិនសូវយកចិត្តទុកដាក់នឹងអំណោយទានដ៏អស្ចារ្យ និងមហិមានេះទុកជាគ្មានផលប្រយោជន៍នោះឡើយ ។ ផ្ទុយទៅវិញ ចូរយើងយកឈ្នះលើការសន្យាទាំងឡាយ ដែលភ្ជាប់ជាមួយនឹងទ្រព្យសម្បត្តិដែលបានកប់ទុកក្នុងចិត្តរបស់យើង ។ ■

*ដកស្រង់មកពី « The Book of Mormon — Keystone of Our Religion » Ensign ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ៤–៧ ។*



**ការធ្វើដំណើរទៅទិសខាងលិច**
**ដោយ ដេវីឌ មីខល**

*ចាប់ពីឆ្នាំ ១៨៥៦ ហូតដល់ឆ្នាំ ១៨៦០ ក្រុមរទេះអូសចំនួន ១០ ក្រុម ដែលមានពួកបរិសុទ្ធថ្ងៃចុងក្រោយដែលធ្វើអន្តោប្រវេសន៍ចំនួន ៣០០០ នាក់ពីប្រទេស អង់គ្លេស, វ៉ែល, ស្កត់ឡែន, និងស្កេនឌីណាវៀរ បានដើរអស់ចម្ងាយ ២០៩០ គីឡូម៉ែត្រដើម្បីចូលរួមនឹងពួកបរិសុទ្ធផ្សេងទៀតនៅក្នុងទីក្រុងស៊ីយ៉ូន ។ អ្នកត្រួសត្រាយទាំងនេះបានអូសទាញរបស់របរគ្រប់យ៉ាងដែលពួកគេមានឆ្លងកាត់វាលទំនាបទ្វីបអាមេរិក ដោយប្រើរទេះអូសទំហំ ( ១ x ១.៥ ម៉ែត្រ ) ។*




យុវមជ្ឈិមវ័យ

**មានអារម្មណ៍ថាដាច់ទំនាក់ទំនងឬ ?**

*យើងរស់នៅក្នុងគ្រាដែលមានការបង្វែរអារម្មណ៍ និងគ្មានការរង់ចាំឡើយ ។ ប៉ុន្តែដើម្បីមានទំនាក់ទំនងពិតប្រាកដជាមួយព្រះ នោះយើងត្រូវបន្ថយល្បឿន ហើយបង្អង់សិន ។*

៤៨

យុវវ័យ

ស្មុគស្មាញជាមួយនឹងសំណួរពិបាកឬ ? នេះគឺជាជំនួយ ។

៥០

ការប្រជុំសាក្រាម៉ង់

យោបល់គន្លឹះ ៧ ចំណុច សម្រាប់ការឡើងនិយាយ

៥៦

កុមារ

សូមចូលរួមក្លឹបអានព្រះគម្ពីរមរមនរបស់យើង !

៧៣



CAMBODIAN

4 02147 98258 2


សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ